# ទស្សនាព្រះម៉ែមហានគរទៀត



ឯកសារសាវតាព្រះម៉ែមហានគរ

សាវជ្រាវ និងរៀបរៀងដោយ

ខ្ញុំព្រះករុណាខ្ញុំបាទ

**គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ

រូបព្រះមាតានាគ

រួចពីទោស

ភាគ៣

# អារម្ភបទ

ក្រោយពីខ្ញុំព្រះករុណាខ្ញុំបាទបានចងក្រង អត្ថបទស្រាវជ្រាវអាថ៌កំបាំងបណ្ដាំមាតាមហានគរក្មែរ ភាគមួយ និងភាគពីររួចហើយ ញាតិទាំងឡាយដែលគាត់បានមកជួបជាមួយខ្ញុំ គាត់សំណូមពរឲ្យខ្ញុំសរសេរពន្យល់ពីអត្ថន័យនៅក្នុងរូបចម្លាក់នៅតាមប្រាសាទនានា ដែលខ្ញុំព្រះករុណាខ្ញុំបាទមានជាបន្ថែមទៀត។ ដោយពួកគាត់ភ័យខ្លាចអត់ពីខ្ញុំទៅពុំមានអ្នកណាចេះមើល បកស្រាយអត្ថន័យនៃភាសារូបចម្លាក់ទាំងនោះឲ្យមកជារឿងរបស់ក្មែរបាន ព្រោះបរទេសអ្នកបកប្រែភាសាចម្លាក់នៅលើថ្មប្រាសាទពីសម័យមុន គេបានពន្យល់ថាជាសាច់រឿងនៅក្នុងសាសនាព្រហ្មញ្ញ និងពុទ្ធសាសនាទាំងពីរនិកាយទៅហើយ។

ដោយការសំណូមពររបស់ញាតិរួមទាំងខ្ញុំព្រះករុណាខ្ញុំបាទ ពិចារណាទៅលើស្នាដៃសង្ខេបភាគមួយ និងភាគពីរ ដែលបានចងក្រងហើយ ខ្ញុំគិតថាស្នាដៃទាំងពីរភាគនេះ ពុំអាចធ្វើឲ្យកូនខ្មែរនាគប្រុសស្រីងាយនឹងយល់ដឹងបានឡើយ ព្រោះរឿងនេះបានលាក់បំបាំងរាប់ពាន់ឆ្នាំហើយ ដូច្នេះខ្ញុំព្រះករុណាខ្ញុំបាទត្រូវចងក្រងភាគ៣នេះជាបន្តទៀត ដោយយករូបភាពទាំងអស់ដែលប្រមូលបាន យកមកបកស្រាយពន្យល់ពីអាថ៌កំបាំងគំនិតក្នុងភាសារូបឲ្យមកជារឿងរបស់ក្មែរ ដែលមាតាមហានគរលោកបានពន្យល់រួចចារឹករឿងក្នុងចិត្ត ទុកក្នុងថ្មពីហេតុភេទក្នុងនគរកាលពីអតីត បច្ចុប្បន្ន និងតទៅអនាគត តើនគរក្មែរនេះនឹងវិវឌ្ឍន៍ប្រែប្រួលទៅជាយ៉ាងណា?

ខ្ញុំព្រះករុណាខ្ញុំបាទមានក្ដីសង្ឃឹមទុកជាមុនថា ឯកសារសាវតាស្រាវជ្រាវក្នុងភាគទី៣នេះ ទុកដូចជាដួងកែវប្រទីបមួយសម្រាប់កូននាគទ្រោលបំភ្លឺមើលឲ្យកាន់តែច្បាស់ ពីបណ្ដាំព្រះម៉ែមហានគរ ឬសាសនព្រះមាតានាគ។

គេហទំព័រ: http://kietchanthon.blogspot.com

http://kietchanthon.info

អ៊ីម៉ែល: kietchanthon@gmail.com

info@kietchanthon.info

ឯកសារនេះស្រាវជ្រាវ និងចងក្រងដោយ

ខ្ញុំព្រះករុណាខ្ញុំបាទ **គៀត ចាន់ថុន**

អតីតសិស្សសាលាវិចិត្រសិល្បៈ

# I.រូបភាពចម្លាក់និយាយពីការជាប់ទោសដំបូង របស់ព្រះមាតាមហានគរ (ព្រះមាតានាគ)

## ១/.រូបភាពចម្លាក់ទី១(នៅសារមន្ទីរជាតិភ្នំពេញ)




រូបភាពចម្លាក់នេះ ជាផ្ដែរនៅលើទ្វារប្រាសាទប៉ៃនជុន តើពាក្យផ្ដែរមានន័យដូចម្ដេច? ផ្ដែរ ក្លាយមកពីពាក្យគន្លាស់កាត់ថា ផ្ដែរមើលកេមុាំ⇔ផ្ដាំមើលកេរម៉ែ ព្រោះពាក្យផ្ដែរមាន «រ» ដែលម៉ែ គាត់ផ្ដាំឲ្យមើលរឿងរបស់គាត់នៅលើមាត់ទ្វារ (ផ្ដែរ) គ្រប់ៗទ្វារប្រាសាទ និងក្បាំងក្លែង។ តើរូបភាព នេះ ព្រះម៉ែចង់និយាយប្រាប់ពីរឿងអ្វី? បើយើងមើលដោយពិនិត្យគិតពិចារណា នោះនឹងឃើញសាច់ រឿងមួយដែលគួរឲ្យសង្វេគពន់ពេក ព្រោះរូបរឿងបានរៀបរាប់នូវទុក្ខវេទនាក្នុងទីឃុំឃាំងរបស់ស្ត្រី ម្នាក់ អស់រយកាលរាប់ពាន់ឆ្នាំ ដោយហេតុតាំងខ្លួនជា**មេ** និង**ម៉ែ (ស្គរតាំងម៉ែ)**។

រូបនេះបានបង្ហាញនូវរូបកណ្ដាលមានក្បាលនាគមួយដែលមានក្បាលប្រាំមួយ ឯក្បាលទីប្រាំ ពីរគឺក្បាលរបស់ស្ត្រីនោះ គាត់នោះហើយជាព្រះនាងនាគនោះឯង។ ព្រោះគ្រប់ក្បាលនាគខ្មែរ ដូនតា របស់យើង តែងឆ្លាក់សេសពុំមែនគូឡើយ **ឧ.** នាគមានក្បាល មួយ បី ប្រាំ ប្រាំពីរ ប្រាំបួន...។ល។

ចំណែកព្រះម៉ែដែលនៅក្នុងក្បាលនាគនោះ បានបង្ហាញពីភាពរស់រវើករបស់គាត់ ហាក់បី ដូចជាមនុស្សមានជីវិត ហើយគាត់ចង់ប្រាប់យើងថានាគគឺតំណាងគាត់។ គឺនាគដែលខ្ញុំបានពន្យល់ ក្នុងអាថ៌កំបាំងបណ្ដាំព្រះម៉ែមហានគរខ្មែរក្នុងភាគទីមួយ រួចហើយអំពីពាក្យថា "នាងនាគ"។ តែគួរ ឲ្យអនិច្ចាគាត់ណាស់ នាគគាត់គឺមានត្រឹមតែក្បាលប៉ុណ្ណោះ ពីត្រឹម "ក" ទៅក្រោយគឺត្រូវសត្វម្ករលេប

តែតាមពិតនាគនៅមុខផ្លូវចូលអង្គរតូចគឺយក្សចាប់ឬលេប ដូច្នេះរូបដែលយើងឃើញពីមុនហៅថាសត្វម្ករនោះ ដល់ពេលខ្ញុំស្រាវជ្រាវទៅទើបដឹងថាជាយក្ស ដែលជាអ្នកដាក់ទណ្ឌកម្មដល់គាត់។ ហេតុដូចនេះហើយការ**ឆ្ងល់របស់ខ្ញុំកាលពីជាងម្ភៃឆ្នាំមុន** ខ្ញុំបានរកឃើញចម្លើយមួយដ៏សមស្របថា គ្រប់រូបចម្លាក់រឿងតាមប្រាសាទនានា ភាគច្រើនគាត់បានឆ្លាក់ពីយក្សចាប់នាគ ហើយនាគនោះគឺតំណាងឲ្យព្រះម៉ែមហានគរ ដូចមានក្នុងរឿងកូរសមុទ្រទឹកដោះជាភស្តុតាងស្រាប់។ គាត់ត្រូវយក្សចាប់ឃុំឃាំងប៉ុណ្ណឹងហើយ តែគាត់នៅតែអាចបែងភាគលួចចេញពីក្នុងគុក មកជួបជាមួយកូន ដែលជាអ្នកទទួលមរតកផ្ទាល់ពីគាត់ គឺអ្នកដឹកនាំនគរសម័យមុន (ស្ដេច) ដែលខ្ញុំបានរៀបរាប់ក្នុងភាគមួយពីឯកសារអ្នកការទូតចិន ជីវតាក្វាន់ ដោយគាត់បានមកស្រុកខ្មែរសម័យនោះ។ គាត់បានឮអ្នកស្រុកនិយាយតៗគ្នាពីបិសាចពស់ដែលតែងតែលួចចេញមកជួបជាមួយស្ដេចនោះ "ពេលបានជួបបិសាចពស់នោះនគររុងរឿង ស្ដេចមានអាយុ ពេលដែលមិនបានជួបបិសាចពស់ នគរកើតកលយុគ ស្ដេចអស់អាយុ" អាថ៌កំបាំងនេះខ្ញុំបានពន្យល់ក្នុងឯកសារភាគមួយរួចហើយ ។ ដោយគាត់ពូកែលួចចេញពីគុកមកជួបកូននោះ ទើបយក្សថែមសោមួយជាន់ទៀតគឺ **"គ្រុឌ"** (សព្វថ្ងៃនិមិត្តសញ្ញាទង់ស្ដេចសៀម) នៅក្នុងរូបភាពចម្លាក់បានបង្ហាញពី គ្រុឌពីរនៅពីខាងលើគ្រៀក ក្បាលនាគជាប់មិនឲ្យចេញរួច ក៏ប៉ុន្តែគាត់នៅតែអាចបែងភាគចេញមកបានទៀត មើលរូបភាពនាគនៅខ្លោងទ្វារចូល ប្រាសាទអង្គរធំ បន្ទាយក្ដី បន្ទាយឆ្មារ បាណន់ ...។ល។

## ២/.រូបភាពចម្លាក់ទី២រូបក្បាលនាគនៅសម័យបាយ័ន(ប្រាសាទបាយ័ន)



បើយើងមើលរូបភាពក្បាលនាគ សម័យបាយ័ន យើងនឹងឃើញការវិវឌ្ឍន៍នៃទោស របស់មាតាមហានគរកាន់តែកើនច្រើនឡើង និមិត្តរូបខ្លួនគាត់ត្រូវយក្សលេបត្រឹមក ចំណែកឯក្បាលខាងមុខ និងខាងក្រោយ ត្រូវគ្រុឌចាប់ក្រុងក្បាលខាងលើជាប់។ ប៉ុន្តែគាត់នូវតែអាចលួចចេញពីគុកបានទៀត ព្រោះនៅចន្លោះជើងគ្រុឌខាងក្រោមពីក្រោយ មានឆ្លាក់ក្បាលនាគបីលួចចេញពីក្រោមជើងគ្រុឌ ដើម្បីចេញមកជួបកូន (មើលឯកសារភាគ១)។ ដោយមិនអាចឃាត់ឃាំងឫទ្ធិរបស់

មាតាមហានគរបាន យក្សបានប្រើសោទីបីទៀត (មើលរូបទី១) គឺសន្ធប់បិទពីខាងលើក្បាលនាគ ដោយប្រើផ្នកមកចុកបង្កើយរបស់គាត់ ទើបសម័យខាងក្រោយ លោកពុំអាចលួចចេញមកចង្អុលបង្ហាញផ្លូវ ដល់អ្នកដឹកនាំប្រទេសសម័យក្រោយៗបានទៀតឡើយ។ នេះជាហេតុដែលធ្វើឲ្យអរិយធម៌ថ្មបានចាប់ផ្ដើមរលំស្រុតបន្តិចម្ដងៗ រិះរៃតែនឹងផុតពូជអ្នកស្នងនូវកេរមរតកម៉ែ។ ផ្នកបិទចុងក្រោយនេះ ខ្ញុំបានពន្យល់ប្រាប់នៅក្នុងមង្គលទីបីរួចទៅហើយ ពីរឿងបរទេសតាមបិទសន្ធប់រូងនាគ ហើយមាត់រូងក្រោយគេគឺនៅភ្នំអដ្ឋរស្សនោះឯង។ ទទួលទោសប៉ុណ្ណឹងហើយ យក្សនៅតែមិនអស់ចិត្តទៀត ពួកគេថែមទាំងប្រើមនោគមវិជ្ជា មកសណ្ដំជនជាតិនេះឲ្យដេកលក់ លែងនឹកគិតស្រាវជ្រាវរាវរកអាថ៌កំបាំងរបស់ខ្លួន ព្រោះនៅខាងលើថ្មផ្នកចុកបង្កើយនាគ (រូបទី១) នោះគាត់បានឆ្លាក់រូបសត្វករវិក″ មួយជួរជាសោចាក់ជាន់ទីបួន សម្រាប់ច្រៀងបំភ័ន្តស្មារតីកូននាគឲ្យវង្វេងភ្លេច សត្វករវិកមួយតំណាងប្រទេសមួយ ចុះសត្វករវិកមួយជួរតំណាងឲ្យប៉ុន្មានប្រទេស? តើអាថ៌កំបាំងសម្លេងសត្វករវិកនេះមានឫទ្ធិយ៉ាងណាទៅ?

មហិទ្ធិឫទ្ធិសត្វករវិកនេះ មាននិយាយពន្យល់នៅក្នុងគម្ពីរមហាវង្សពង្សាវតារលង្កាទ្វីប គឺរឿងព្រះបាទធម្មាសោក ឬអសោករាជ្យ ដែលជាស្ដេចមានអំណាចផ្សាយទៅលើអាកាស មួយយោជន៍ និងទៅក្រោមមួយយោជន៍ អានិសង្សនេះកើតឡើងដោយគាត់បានបំពេញនូវទានទឹកឃ្មុំ កាលពីជាតិមុនជាមួយនឹងព្រះបច្ចេកពុទ្ធមួយអង្គ ដែលគាត់ក្នុងជាតិនោះជាឈ្មួញលក់ទឹកឃ្មុំ។ អ្នកដែលបានជួយចង្អុលបង្ហាញផ្ទះអ្នកលក់ទឹកឃ្មុំ គឺនាងកុម្ភៈទាសី ជាស្រីកណ្ដៀតក្អមដងទឹក ដោយនាងបានធ្វើទានសំពត់រុំដំបៅជាមួយនឹងព្រះបច្ចេកពុទ្ធអង្គនោះ ដែលមកបិណ្ឌបាតទឹកឃ្មុំដោយនាងបានជួយចង្អុលផ្លូវប្រាប់ ទីបំផុតនាងកុម្ភៈទាសីបានមកជាមហេសីព្រះបាទធម្មាសោកនេះ មានឈ្មោះថា ″នាងអសន្ធិមិត្តា″។ ព្រះនាងអសន្ធិមិត្តានេះហើយបានសួរទៅព្រះភិក្ខុសង្ឃ ដែលជាព្រះអរហន្តថា តើសម្លេងព្រះសម្មាសម្ពុទ្ធ ពីរោះយ៉ាងណាទៅ? ហើយសម័យនេះមានអ្វី មកប្រៀបធៀបឲ្យប្រហាក់ប្រហែលនឹងសម្លេងព្រះអង្គបាន ព្រះភិក្ខុសង្ឃបានមានថេរៈដីកាថា មានសត្វករវិក មានសម្លេងប្រហាក់ប្រហែល និងសម្លេងព្រះសម្មាសម្ពុទ្ធ។ ដោយហេតុចង់ស្ដាប់សម្លេងសត្វនោះ ព្រះនាងអសន្ធិមិត្តា បានអង្វរស្វាមីជួយរកសត្វនោះមកឲ្យខ្លួន ព្រះបាទធម្មាសោកបានប្រើសេនាយក្ស ដែលនៅក្រោមអំណាចរបស់ព្រះអង្គ ឲ្យទៅចាប់សត្វនោះមកថ្វាយ។ ពេលបានសត្វនោះមកហើយវាពុំព្រមរងាវសោះព្រោះគ្មានគូ ទើបគេយកកញ្ចក់ទៅដាក់ឲ្យឃើញរូបវាម្ខាងទៀត ទើបវារងាវ។ ពេលដែលសត្វករវិករងាវ

ព្រះឃោសាចារ្យបានពន្យល់ថា សត្វកំពុងហើរលើមេឃត្រូវឈប់សំកាំងខ្លួន ដើម្បីស្តាប់នូវសូរសព្ទដ៏ពីរោះរបស់សត្វនេះ សត្វត្រីនៅក្នុងទឹកដែលងើបមកដកដង្ហើម ត្រូវសំកាំងនៅលើទឹក ចាំស្តាប់សម្លេងសត្វនោះសិន រីឯសត្វម្រឹគដែលខ្លាកំពុងដេញក៏ឈប់ស្ងៀម ចាំស្តាប់សម្លេងសត្វនោះដោយពុំគិតពីមរណៈភ័យ រីឯសត្វខ្លាវិញដែលកំពុងដេញម្រឹគនោះ ក៏ឈប់ស្ងៀមចោលចំណីចាំស្តាប់សត្វនោះរងាវឲ្យចប់សិន។ អនុភាពនៃសម្លេងពីរោះរបស់សត្វករវិកក្នុងពេលនោះ បានធ្វើឲ្យព្រះនាងអសន្ធិមិត្តាបាននូវអមតធម៌ (សោតាបត្តិផល) ដោយព្រះនាងបានពិចារណាតាមហេតុបច្ច័យនៃធម៌ថា សភាវធម៌ទាំងឡាយកើតមាន ព្រោះមានហេតុ និងបច្ច័យ ពុំមានបុគ្គលណាមួយ អាចធ្វើឲ្យកើតឡើងដោយខ្វះហេតុនោះឡើយ ដូចជាសម្លេងពីរោះ របស់សត្វករវិកនេះជាដើម។

ដោយខ្ញុំបានដកយករឿងសម្លេងសត្វករវិក មកអត្ថាធិប្បាយពន្យល់ដោយសង្ខេបនេះ ព្រោះចង់យកមកឆ្លុះបញ្ចាំង រូបភាពក្នុងចម្លាក់របស់យើងក្នុងរូបទីមួយ ដែលមាតាមហានគរលោកបានឲ្យកូននាគសម័យនោះ ឆ្លាក់រឿងនេះទុកសម្រាប់កូននាគសម័យក្រោយមើល ដោយត្រិះរិះគិតពិចារណាថា បើសត្វករវិកច្រើនម្លឹងៗ តើធ្វើដូចម្តេចយើងអាចស្គាល់សាវតាពិតរបស់ខ្លួនបាន? ដូចនេះលោកមានសង្ឃឹមតិចណាស់ ចំពោះកូនខ្មែរសម័យខាងក្រោយ ដែលព្រមទទួលស្គាល់រឿងពិតនៅលើថ្មថាជារឿងរបស់ព្រះម៉ែមហានគរ។ ព្រោះសត្វករវិកចាស់ហើរចេញទៅ សត្វករវិកថ្មីហើរចូលមក (មើលរូបទី១) សត្វករវិកនេះ តំណាងឲ្យការផ្សព្វផ្សាយមនោគមវិជ្ជាបរទេស ដែលធ្លាប់ធ្វើអាណានិគមសាបព្រោះបំភ័ន្តបញ្ញាស្មារតីកូនខ្មែរ ឲ្យលង់លិចរាប់ជំនាន់មកហើយ ដោយខ្ញុំបានពន្យល់ពីអត្ថន័យបទសារិកាកែវអើយក្នុងភាគ១រួចហើយ ។

## ៣/.រូបភាពទី៣ចម្លាក់ផ្តែរ(ប្រាសាទបន្ទាយស្រី)

ផ្តែរនេះបានបង្ហាញពីយក្ស ចាប់ព្រះម៉ែមហានគរយកមកដាក់ទោស គឺក្រុងរាពណ៍ចាប់នាងសេតា ហើយក្នុងរូបនេះមានក្បាលគ្រុឌកំពុងចាប់ខាំក្បាច់ តំណាងឲ្យខ្លួននាគទាំងសងខាងកុំឲ្យសត្វនាគនេះរើខ្លួនរួច នៅក្នុងទីឃុំដ៏កំបាំងនេះ អ្នកដឹងរឿងគឺមានតួរអង្គតែបីប៉ុណ្ណោះ ទីមួយយក្ស ទីពីរគ្រុឌ ហើយទីបីគឺព្រះម៉ែនាគ ដែលជាមាតាមហានគរនោះឯង គឺពុំមានអ្នកដ៏ទៃណាដឹងរឿងកំបាំងទាំងនេះឡើយ។



ចំណែកឈ្មោះរបស់ព្រះម៉ែមហានគរនោះ គាត់មានឈ្មោះជាច្រើនដូចជា លីវយី(ចិន) សោមា (ឥណ្ឌា) ព្រះនាងនាគ(រឿងព្រេងប្រចាំនគរ) ព្រះនាងសេតា(ក្នុងរឿងរាមកេរ្តិ៍) ព្រះនាងក្រពុំឈូក(រឿងទាក់ទងនឹងទង់ក្រពើ) ព្រះម៉ែសក់ក្រអូប(រឿងព្រេងទាក់ទងបទភ្លេងការ) ព្រះនាងរំសាយសក់(រឿងទាក់ទងភ្នំក្រពើ ទ្រុងមាន់ សំពៅ...) ព្រះនាងវិមានច័ន្ទ(រឿងទាក់ទងរូបមាតានៅតែក្បាល) ទិព្វសេតាច័ន្ទ(រឿងទាក់ទងពៀរវេរា ហើយនឹងដើមកំណើតអង្គរតូច) ព្រះនាងហ៊ីងព្រះធរណី ឬគង្ហីង(ទាក់ទងនឹងអ្នកបង្កើតទឹកដី) ព្រះនាងអាក់អរ(ទាក់ទងប្រាសាទភ្នំដា និងអង្គរបុរី ព្រោះ**អរត្រូវអាក់**) បិសាចពស់(ឯកសារអ្នកកត់ត្រាជីវតាក្វាន់)។ល។ ប៉ុន្តែឈ្មោះទាំងអស់ដែលអាចយកជាត្រីវិស័យក្នុងការស្រាវជ្រាវបាន គឺមានតែរឿងព្រះថោងព្រះនាងនាគតែប៉ុណ្ណោះព្រោះរឿងនេះ បានបើកបង្ហាញពីការបង្កើតពូជខ្មែរ(**កេរ+មេ**) និងខ្មែរ(**កេរ+ម៉ែ**) ដែលខ្ញុំបានពន្យល់ក្នុងភាគមួយរួចមកហើយ ឯរឿងដទៃទៀត គ្រាន់តែជាគ្រឿងផ្សំឲ្យរូបរាងរឿងរបស់គាត់កាន់តែច្បាស់ ក្នុងការស្វែងរកអាថ៌កំបាំងរបស់គាត់តែប៉ុណ្ណោះ។ ហេតុនេះបានជាសម័យខាងក្រោយអង្គរ កូននាគប្រុសស្រីពុំអាចយល់ពីសាវតាពិតរបស់ខ្លួនបាន ព្រោះអនុភាពសត្វករវិកដែលពន្យល់រួចហើយក្នុងរូបភាពទីមួយនោះ បានច្រៀងបំភ្លៃការពិតទៅជាមិនពិត នេះម្យ៉ាងៗទៀតព្រះម៉ែមហានគរលោកលែងលួចចេញពីទីឃុំឃាំងមកខាងក្រៅបានទៀត ព្រោះសោឃុំខ្លួនគាត់កាន់តែច្រើនជាន់ ហើយជាពិសេសសត្វករវិកនោះ បាន

ស្រែកច្រៀងបំភ័ន្តការពិតរបស់គាត់ ព្រោះតួអង្គតំណាងសត្វទាំងនោះភាគច្រើន សុទ្ធតែជាប្រទេសដែលធ្លាប់ចំណុះឲ្យគាត់ពីអតីតកាល។

## ៤/.រូបភាពទី៤ផ្ដែរប្រាសាទរលស់ (សៀមរាប)




ក្នុងរូបរឿងរបស់ផ្ដែរនេះ ព្រឹទ្ធដូនតាបានឆ្លាក់ក្បាលយក្សដ៏ធំមួយ កំពុងឱបក្បាលនាគពីរសង្ខាង និងមួយទៀតនៅក្នុងរង្វង់អណ្ដាតខាងក្រោមមុខយក្ស ហើយនៅក្រោមខ្លួននាគដែលយក្សចាប់ទាំងសង្ខាង មានរូបស្ត្រីអង្គុយពែនភ្នែន ស្លៀកពាក់ជាស្ដេច។ រូបនេះគាត់ចង់ប្រាប់យើងថា រូបគាត់នៅខាងក្រោមខ្លួននាគដែលត្រូវយក្សចាប់នោះ គឺតំណាងឲ្យ ព្រះនាងនាគ ឬ ព្រះម៉ែនាគ (មើលការពន្យល់ក្នុងភាគ១ ភាគ២) ត្រូវលាក់បំបាំងដោយអំណាចបិទបាំងរបស់យក្ស។

សរុបសេចក្ដីមក រូបនេះបានបើកបង្ហាញពីរូបពិតរបស់យក្សក្នុងរូបទីមួយ ដែលជារូបពីរចំហៀង ឲ្យមើលឃើញចំពីមុខនូវសកម្មភាពរបស់យក្ស ក្នុងការចាប់ក្បាលនាគទាំងបីយកទៅឃុំ ដែលនាគនោះជានិមិត្តរូបតំណាងមាតាមហានគរ ដែលនៅខាងក្រោមដៃយក្ស គឺរូបស្ត្រីតូចៗទាំងពីរនោះ។

## ៥/.រូបភាពទី៥នៅក្នុងក្បាំងភ្លែង (ប្រាសាទសំបូរព្រៃគុកខេត្តកំពង់ធំ)



ប្រាសាទនេះទោះបីកសាងឡើងពីឥដ្ឋ ដែលមានចំណាស់ទ្រុឌទ្រោមណាស់ទៅហើយ ក៏នៅបន្សល់ទុករូបភាពចម្លាក់ក្បាលស្ត្រីម្នាក់ត្រឹម**ក** នៅក្នុងរង្វង់គ្របពីខាងលើ ដែលស្ថិតក្នុងទីខ្ពស់ហាក់បីដូចជាប្រាប់យើងទាំងអស់គ្នាជាកូនខ្មែរថា ទោះបីព្រះម៉ែជាអ្នកទោសគេលេបដល់កក៏ដោយ ម៉ែនៅតែតាមជួយមើលថែរក្សាកូនម៉ែទាំងអស់គ្នាដដែល។ ព្រោះព្រះម៉ែមិនអាចឲ្យកេរតំណែល ដែលខំប្រឹង**ក**កើតទឹកដីនេះ ឲ្យរលាយសាបសូន្យចេញពីក្នុងលោកនេះបានឡើយ ម្យ៉ាងទៀតដែលម៉ែខំបំពេញពលិកម្មសុខចិត្តរងទុក្ខទទួលទោសរាប់ពាន់ឆ្នាំ ក៏ព្រោះតែមាតុភូមិ ដែលជាមរកតទុកសំរាប់កូនម៉ែ។

## ៦/.រូបភាពទី៦ក្បាលព្រះម៉ែពាក់មកុដរាជកប់ត្រឹម**ក**រួចទូលយោនី(ប្រាសាទនាគព័ន្ធ)



រូបភាពចម្លាក់នេះ ខ្ញុំបានពន្យល់រួចម្តងមកហើយ នៅក្នុងភាគមួយនិងភាគទីពីរ ដែលខ្ញុំត្រូវយកបកស្រាយនេះ ចង់ពន្យល់ថាព្រះម៉ែបានពង្រាយរឿងទុក្ខវេទនារបស់គាត់ គ្រប់ជញ្ជាំងថ្ម ដែលអាចរក្សារទុកនៅរឿងបានយូរ។ រូបនេះបង្ហាញពីស្ត្រីម្នាក់ពាក់មកុដជាស្តេចគ្រងរាជ រួចទូលយោនីខ្លួនឯងមាត់ស្រែកហៅកូននាគប្រុសស្រី ឲ្យជួយគាត់ផង។ ឯកសារថ្មនេះ បរទេសគេពន្យល់ថាទឹកដែលហូរចេញពីមាត់រូបស្ត្រីនេះ និងរូបក្បាលសត្វទាំងបីទៀត ដំរី សេះ និងរាជសី គឺជាឱសថសម្រាប់ព្យាបាលរោគទាំងបួន ដែលមាននៅក្នុងខ្លួនមនុស្ស។ ចំណែកការឈ្វេងយល់របស់ខ្ញុំវិញ ខ្ញុំបានពន្យល់រួចហើយតាំងពីរូបទី១ រហូតដល់រូបទី៦នេះ គឺមានន័យដូចគ្នា ប៉ុន្តែរូបនេះប្លែកត្រង់ទូលយោនីខ្លួនឯង និងមាត់ហាបញ្ចេញទឹក តើទូលយោនីខ្លួនឯងមានន័យដូចម្តេច? ហើយមាត់ហាស្រែកចេញទឹកមានន័យដូចម្តេច? ភាសាគំនិតរូបនេះ ត្រូវបានពន្យល់ប្រាប់យើងថា ម្តាយគ្រប់រូបគាត់តែងតែប្រសូត្របុត្រប្រុសស្រីតាមទ្វារយោនីនេះ ហេតុតែប្រសូត្របុត្រ គាត់ត្រូវហួងហែងថែរក្សាបុត្រ ហេតុតែប្រកាន់មាំថា ជាបុត្ររបស់គាត់ៗសុខចិត្តដាច់**សីល៥** (សិក្ខាបទ៥) ដើម្បីចិញ្ចឹមបុត្រ អំពើដែលពុំមានសីលបានធ្វើឲ្យគាត់ត្រូវទូលយោនីខ្លួនឯង ព្រោះបើគាត់ពុំមានទ្វារយោនីនេះ តើគាត់ត្រូវបង្កើតបុត្រតាមណា? ហេតុនេះគាត់ចង់បង្ហាញប្រាប់កូននាគប្រុសស្រី ដែលកំពុងទទួលកេរមរតកគាត់ឲ្យបានយល់ថា ហេតុតែដើម្បីប្រទេស នគរ មាតុភូមិនេះ គាត់បានធ្វើបាបកម្មយ៉ាងច្រើនដើម្បីកូនខ្មែរ ទីបំផុតអំណាចជាស្តេចពីអតីតកាល បានត្រឹមតែទូលយោនីខ្លួនឯង រួចកប់ខ្លួនដល់ត្រឹម**ក**តែប៉ុណ្ណោះ។ ចុះទឹកដែលហូរចេញពីមាត់ដែលហាស្រែកនោះ មានន័យដូចម្តេច? គឺមានន័យថា ពេលដែលគាត់ធ្លាក់ទៅរងទុក្ខក្នុងអបាយភូមិហើយ ទើបស្តាយក្រោយ ដូច្នេះមានតែស្រែកហៅកូននាគប្រុសស្រីឲ្យជួយគាត់តែប៉ុណ្ណោះ ដែលសម្លេងស្រែក កើតចេញពីទឹកចិត្តឈឺចាប់ក្នុងអបាយភូមិ ព្រោះហេតុតែកូន (ទំនួញ

ប្រែតខែភ្នំ) ដូច្នេះទឹកគឺតំណាងឲ្យទឹកចិត្តម្ដាយរាល់រូប។ រូបនេះមិនត្រឹមតែកប់ត្រឹមកហើយទូលយោនីខ្លួនឯងប៉ុណ្ណោះទេ គឺជាប់ឃុំក្នុងគុហារមួយ គ្របពីលើថែមទៀត ដូចអត្ថន័យរូបទី៥ ដែលនៅប្រាសាទសំបូរព្រៃគុកដែរ។

## ៧/.រូបភាពទី៧នាគក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)



រូបចម្លាក់នេះក៏បានបង្ហាញពីយក្សមួយ កំពុងលេបនាគទៅដល់ក ទោះបីជានាគនេះឡើងទៅដល់កំពូលលើហើយ (ប្រាំងក្លែង ឬក្បាំងក្លែង) ក៏នៅតែជាប់ទោសដដែល។ ហេតុអ្វីបានជាដូច្នោះ? ប្រាសាទភាគច្រើនគឺ កើតក្រោយពេលដែលពួកគាត់ជាប់ទោសរួចទៅហើយ (ម្ដាយឪពុក) ដូច្នោះទោះបីជាអរិយធម៌ថ្មក្នុងសម័យអង្គរ ឡើងទៅដល់កំពូលយ៉ាងណាក៏ដោយ គឺគ្រាន់តែជាគំនិតរបស់ព្រះម៉ែមហានគរតែប៉ុណ្ណោះ (បិសាចពស់) ដែលលោកបានលួចចេញពីទីឃុំឃាំង មកជួយរុញគំនិតកូននាគសម័យនោះ ឲ្យទៅដល់កំពូលអរិយធម៌។ ព្រោះរូបមន្តដឹកនាំនគរសម័យនោះ គឺរូបមន្តនាគចេញពីរូង ហេតុនេះទើបធ្វើឲ្យកូននាគសម័យនេះ អាចឡើងទៅដល់កំពូលអច្ឆរិយៈបាន ក៏ព្រោះតែ អច្ឆរា = អប្សរា ដែលជាមេគំនិត បង្កើតភាពអច្ឆរិយៈ (ខ្មែរ) ។

អប្សរាឬអច្ឆរា (បា.សំ) ស្ត្រីមានសម្បុរថ្លាស្រស់ផូរផង់ ឬស្ត្រីមានមុខស្រស់បំព្រង ស្ត្រីសួគ៌ ស្រីអប្សរ ស្រីទេពអប្សរ នាងអប្សរ....អច្ឆរា (វចនានុក្រមសម្ដេចជួនណាត)។

ភាសាចារឹកនៅនគររាជបានសរសេរថា បើសិនណាជាមានជាតិក្រោយទៀត សូមឲ្យខ្ញុំបានកើតជាខ្មែរ តើដើម្បីប្រយោជន៍អ្វី? ដែលពួកគេចង់មកកើតជាខ្មែរ គឺដើម្បីបំពេញកិច្ចជាកូនកតញ្ញូនិងកតវេទីជូនចំពោះមាតាបិតាមហានគរនោះឯង ដោយពួកគាត់បានលះបង់មួយជីវិត ហើយសុខចិត្តធ្លាក់ទៅសោយទុក្ខនៅក្នុងអបាយភូមិ ព្រោះហេតុតែដើម្បីកូនខ្មែរប្រុសស្រី ហើយពួកគាត់តែង

នឹកសង្ឃឹមថា នឹងមានកូននាគណាម្នាក់មកជួយគាត់ជាមិនខាន នូវពេលកំណត់ទោសរបស់គាត់ត្រូវបញ្ចប់។ ហើយរូបរឿងទាំងនេះគាត់បានឲ្យកូនខ្មែរសម័យអង្គរឆ្លាក់ទុកនៅគ្រប់ប្រាសាទ និងនៅលើថ្មបាតស្ទឹងភ្នំគូលែន ក្បាលស្ពាន ព្រៃទេវតា និងនៅទីស្ថានដទៃៗផ្សេងៗទៀត ដែលរូបខ្ញុំបាទមិនទាន់បានដឹងនឹងទៅដល់។

## ៨/.រូបភាពទីប្រាំ៨គ្រុឌប្រាំងក្លែង(ប្រាសាទបន្ទាយស្រី)



រូបភាពនេះ ក៏មិនខុសពីរូបភាពមុនៗដែរ គឺបានបង្ហាញពីយក្ស ខាំលេបនាគ បន្ទាប់មកគឺគ្រុឌ(សៀម) ដែលនៅក្នុងមាត់គ្រុឌ គឺខ្លួននាគ ហើយនៅខាងក្រោមជើងគ្រុឌ គឺមានក្បាលនាគមួយគូ។ ហើយត្រចៀករបស់សត្វគ្រុឌ មានពាក់ក្រវិលមូលមួយគូ ដែលក្រវិលនេះ មាននៅត្រចៀកយក្សរូបទីបី គឺគាត់ចង់បង្ហាញប្រាប់យើងថា ក្រវិលមូលនេះ គឺតំណាងឲ្យបក្សពួកយក្ស ហើយដៃរបស់គ្រុឌបានបែងភាគជាបួន ដើម្បីចាប់មាតាបិតាកុំឲ្យរើខ្លួនរួច ទោះបីជាត្រូវឡើងទៅដល់ខាងលើហើយ ក៏នៅជាប់ទោសដដែល ហើយក្បាលគ្រុឌពាក់មកុដរាជ គឺតំណាងឲ្យស្តេចនគរមួយ។ រូបភាពទាំងនេះ នៅក្នុងគម្ពីរព្រហ្មញ្ញ ពុំបាននិយាយរៀបរាប់ពីរឿងនាគជាប់ទោសឡើយ ហេតុតែយើងប្រគល់សិទ្ធឲ្យបរទេសស្រាវជ្រាវនឹងយកគំនិតគេមកសិក្សា ទីបំផុតយើងមើលរឿងរបស់ខ្លួន ទៅជារឿងរបស់សាសនាទៅវិញ។

## ៩/.រូបភាពទី៩ រូបបាំងក្លែង(មិនស្គាល់ប្រភព)



បើយើងពិនិត្យរូបចម្លាក់នេះ គាត់បានបង្ហាញប្រាប់យើងថាបាំងក្លែងគឺមានន័យថា "បាំង" កុំឲ្យមើលឃើញ "ក្លែង" ឲ្យខុសពីសភាពដើម មួយទៀតគាត់បានប្រាប់យើងថា រឿងក្នុងបាំងក្លែង គឺជារឿងរបស់នាគ ព្រោះតួបាំងក្លែង គឺជានាគមួយគូកំពុងជាប់ទោស ត្រូវយក្សលេប។ ហើយរឿងដែលមានក្នុងបាំងក្លែងគឺជារឿងរបស់គាត់ ព្រោះហេតុអ្វី? ព្រោះរូបនៅក្នុងខ្លួននាគមួយគូត្រូវឃុំក្រុងនោះ បានឆ្លាក់រៀបរាប់នូវគ្រប់សកម្មភាពផ្សេងៗទៅតាមពេលវេលា វិវឌ្ឍន៍របស់នគរនាគនេះ (មាតុភូមិ) ហើយបាំងក្លែងគឺមាននៅលើទ្វារ គ្រប់ប្រាសាទបុរាណទាំងអស់ ដែលមានក្នុងនគរបច្ចុប្បន្ន ហើយនឹងនៅក្នុងប្រាសាទ ដែលបរទេសដណ្ដើមយកទៅ កាលពីអតីតជារបស់ព្រះម៉ែ។ ដូច្នេះបរទេសអ្នកសិក្សាស្រាវជ្រាវភាសារូប (ភាសាគំនិត) គេយល់ថា ព្រះម៉ែមហានគរលោកមានប្រាជ្ញាណាស់ បានលាក់រឿងក្នុងបេះដូងខ្លួន ទុកនៅក្នុងថ្មទាំងអស់ ទើបគេប្រើប្រាស់ប្រាក់ដើម្បីជួលកូននាគ ដែលល្ងង់ឲ្យដាប់បំផ្លាញ ឯកសារថ្មទាំងនេះ។ ឯកសារទាំងនេះបើកុំតែត្រូវដាប់បំផ្លាញ រាប់រយឆ្នាំទៅមុខទៀត គឺពុំទាន់ខូចទៅណាឡើយ ឲ្យតែយើងចេះថែទាំរក្សា យើងមើលសក្យមុនីចេតិយ នៅពុទ្ធគយាដែលជាស្នាព្រះហស្ថ របស់ព្រះបាទធម្មាសោកមកទល់នឹងសព្វថ្ងៃ មានអាយុ ជាង២ពាន់ឆ្នាំទៅហើយ តែត្រូវបានឈរត្រដែត បង្ហាញពិភពមនុស្ស ទេវតាឲ្យមកធ្វើនមស្ការគោរពបូជាគ្រប់ៗគ្នា ព្រោះហេតុអ្វី? ចម្លើយមិត្តអ្នកអានឆ្លើយដោយខ្លួនឯងចុះ។

នៅក្នុងរូបបាំងក្លែងទី៩នេះ គាត់បានបង្ហាញពីស្ត្រីពនាក់ ដែលស្ត្រីម្នាក់មានក្បាលនាគបែកជាបី អង្គុយបត់ជើង លើកដៃសំពះនៅជាន់ខាងក្រោម។ ហើយជាន់ខាងលើបន្ទាប់ ក៏មានស្ត្រីមានក្បាល

នាគបែកជាបីម្នាក់ នៅម្ខាងទៀតមានរូបបុរស និងរូបមនុស្សដូចនៅពីខាងក្រោយខ្នង ចំណែកកណ្ដាលមានបល្ល័ង្កទទេមួយដែលប្រកនាគ។ តើរូបនេះគាត់ចង់និយាយពីអ្វី? ស្ត្រីទាំង៧នាក់មានក្បាលជានាគក្បាលបី នោះគឺតំណាងឲ្យទេពធីតា ដែលមកហែក្បាលកបិលមហាព្រហ្ម រាល់ៗឆ្នាំនេះឯង ព្រោះប្រាំពីរស្មើមួយសប្ដាហ៍ ហេតុអ្វីបានជាគាត់ឆ្លាក់នាងទាំង៧ ជានាគក្បាល៣រួចលើកដៃសំពះ? បានជាគាត់ឆ្លាក់នាងនាគទាំងនោះ មានក្បាល៣ ព្រោះបុរសស្ត្រីជាកូនម៉ែទាំងអស់កើតក្នុងនគរនាគ ដំបូងឡើយកូននាគមានក្បាលតែមួយទេ ចាប់ផ្ដើមមានភរិយាស្វាមី នាគបំបែកក្បាលជាពីរ មានកូនបំបែកក្បាលបី រហូតដល់មានចៅប្រុសស្រី មុខរបរ ទ្រព្យសម្បត្តិ នាគត្រូវបំបែកក្បាលកាន់តែច្រើន ទីបំផុតនាគម៉ែនាគឪត្រូវជាប់នូវក្នុងក្បាលដ៏ច្រើន ដែលពុំអាចរើខ្លួនរួចឡើយ ហើយនាគពិតប្រាកដ គឺមានក្បាលតែមួយទេ។ ចំណែកឯដៃលើកសំពះគឺ បួងសួងសុំឲ្យម៉ែឆាប់រួចផុតពីបាបកម្ម តែកម្មនេះពុំមែនរួចបានដោយការបួងសួងឡើយ លុះត្រាតែមានកូននាគណាម្នាក់ ស្ម័គ្រចូលទៅក្នុងទ្រូងព្រះម៉ែដើម្បីបើកគាត់ឲ្យរួច។ អាថ៌កំបាំងនេះមាននៅក្នុងពាក្យកូនសោ និងមេសោ មេសោរអាចរបើកបាន លុះត្រាតែកូនចូលទៅបើកនៅក្នុងទ្រូងម៉ែ ដូច្នេះទើបអ្នកនគរហៅថា មេសោ និងកូនសោ ពុំមែនហៅបាសោឡើយ នេះជាប្រស្នាបណ្ដាំព្រះម៉ែមហានគរ។ ថ្នាក់ទី២ក៏មិនខុសពីអត្ថន័យថ្នាក់ទី១ឡើយ គ្រាន់តែអ្នកនៅជាន់ទី២ខាងលើ នៅក្បែរនឹងបល្ល័ង្កទទេតែប៉ុណ្ណោះ ហើយប្រស្នាកំបាំងបល្ល័ង្កទទេនេះខ្ញុំបានពន្យល់ក្នុងភាគមួយ និងភាគពីររួចហើយ (បាយ័ន់កោរ)។

## ១០/.រូបភាពទី១០រូបនៅលើសសរ (ផ្លូវចូលប្រាសាទបន្ទាយសម្រែ)



នៅក្នុងរូបភាពនេះ បង្ហាញពីអច្ឆរា ដែលមានពាក់ក្បាំងមកុដកំពូលបី ត្រូវឃុំខ្លួនដោយនាគបួន ហើយមានរាង ដូចជាបេះដូងផ្កាប់ អត្ថន័យគឺដូចជាសត្វត្រកួត ត្រូវយកកន្ទុយមកចងកខ្លួនឯង យ៉ាងដូច្នោះ តើដោយសារហេតុអ្វី? ព្រះម៉ែនាគ ហេតុតែចង់ឲ្យកូននាគសម័យក្រោយៗ រស់នៅដោយមោទនភាព ក្នុងកេរមរតករបស់ខ្លួន គាត់បានតាំងខ្លួនជាមេជាម៉ែ ទីបំផុតបានត្រឹមតែជាប់ ក្នុងចំណងប្រាំប្រការ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដោយការប្រកាន់មាំថា ជាភរិយា ស្វាមី កូនខ្មែរប្រុសស្រីទូទាំងនគរ ដែលជាពូជពង្សរបស់គាត់។ ទីបំផុតបានត្រឹមតែជាប់ផុង ក្នុងអបាយភូមិ ដែលជាទីទុក្ខ ព្រោះហេតុតែសេចក្ដីប្រកាន់ថា ជាសត្វ ជាបុគ្គល ជាតួខ្លួន តាមពិតគឺជាបុគ្គលប្បញ្ញត្តិសោះ។

## ១១/.រូបភាពទី១១ (នៅប្រាសាទបន្ទាយស្រី)

ក្នុងរូបភាពនេះ បានបង្ហាញពីស្ត្រីម្នាក់ពាក់មកុដរាជ្យ បាំងខ្លួននៅក្នុងព្រៃក្បាច់ ដែលបង្ហាញចេញនៅដោះលៀនចេញមកក្រៅតាមចន្លោះក្បាច់ ដើម្បីឲ្យយើងស្គាល់ថាជាស្ត្រី។ ចំណែកឯដៃទាំងពីរលើកលាបង្ហាញពីបាតដៃ គឺគាត់ចង់ពន្យល់ប្រាប់យើងថា ឈប់នាំគ្នាមើលរឿងខ្នងដៃដូចពីមុនទៀត បើមើលខ្នងដៃគឺពុំស្គាល់គាត់ឡើយ ព្រោះមរតកម៉ែទាំងអស់ កើតចេញពីបាតដៃទាំងគូរបស់ម៉ែនេះ។



ដូចជាក្នុងទំនាយដែលចាស់ៗនិយាយតៗគ្នាថា **រកា**សាដាន **ចផ្កាប់**ចាន **ក្ញុរ**ឆ្កេលូ ពាក្យទំនាយនេះ ពីមុនខ្ញុំពុំបានយល់ន័យឡើយ ពេលដែលខ្ញុំស្រាវជ្រាវអាថ៌កំបាំងព្រះម៉ែមហានគរ ទើបខ្ញុំយល់ ប្រស្នាទំនាយនេះ ដែលមានជម្រៅពុំនឹកស្មានដល់។ ពាក្យរកាសាដានគឺមានន័យថា សាដានស្នាមចាស់របស់គាត់ តែមកដល់ឆ្នាំរកាត្រូវសាដាន បែរជាសាពុំរួច ព្រោះរកាត្រូវកោង (រកាកោង មើលការពន្យល់ភាគមុន)។ ពាក្យ**ច**ផ្កាប់ចានមានន័យថា ចានយើងអាចដឹងប្រភពនាំចូលរបស់វាបាន លុះត្រាតែផ្កាប់ ព្រោះហេតុអ្វី? គ្រប់ចានតូចធំ តែងតែមានសញ្ញាសម្គាល់ប្រទេសដែលផលិតនៅបាតចានយើងអាចស្គាល់ប្រភពរបស់វា លុះត្រាតែមើលបាត ដូចជាក្នុងប្រស្នារូបនេះ មិនខុសពីមើលបាតចានឡើយ គឺមើលបាតដៃ។ នៅក្នុងសម័យពុទ្ធកាល ព្រះអង្គតែងសម្ដែងធម៌ប្រោសបរិស័ទ ហើយបរិស័ទទាំងនោះ ពេលស្ដាប់ធម៌រួចយល់ពីអត្ថន័យធម៌តែងតែភ្លាតមាត់ឧទានថា អស្ចារ្យណាស់ព្រះអង្គ ធម៌ព្រះអង្គសម្ដែងដូចជាគេត្រឡប់ររបស់ផ្កាប់ឲ្យផ្ងារឡើង ដូចជាគេដុតប្រទីបបំភ្លឺក្នុងទីងងឹត...។ល។ យ៉ាងណាមិញ រូបភាពនេះ គាត់ក៏ចង់បង្ហាញកូននាគប្រុសស្រី ឲ្យយល់ពីរឿងពិតរបស់គាត់ ដែលបានបិទបាំងក្នុងព្រៃគី អតីតកាលដ៏យូរលង់ណាស់មកហើយ ឲ្យមកឃើញរឿងពិតរបស់គាត់ដូចជាគេផ្ងារបាតដៃដែលធ្លាប់តែផ្កាប់ឲ្យផ្ងារឡើងយ៉ាងដូច្នោះ។

សរុបសេចក្ដីមក ប្រស្នាក្នុងរូបនេះ គាត់ចង់ឲ្យយើងមើលរឿងរ៉ាវរបស់គាត់ នៅលើបាតដៃទាំងគូ ដែលខំប្រឹងលាចេញពីព្រៃក្បាច់ ឲ្យបានឃើញក្រយៅពិតនៅក្នុងបាតដៃទាំងពីររបស់គាត់ ហើយឈប់នាំគ្នាមើលខ្នងដៃតទៅទៀត។

## ១២/.រូបភាពទី១២រូបផ្ដែរ (មិនស្គាល់ប្រភព)



ក្នុងរូបភាពផ្ដែរនេះ អត្ថន័យរបស់រូបក៏មិនសូវខុសពីរូបផ្ដែរមុនឡើយ គ្រាន់តែក្នុងផ្ដែរនេះមានបន្ថែមរូបឥសី អង្គុយក្នុងទ្រនុងខ្នងនាគ ដែលយើងពុំធ្លាប់បានឃើញពីមុន។ ក្នុងរូបនេះមានគ្រុឌកំពុងចាប់នាគពីរ ដែលនាគទាំងពីរពុំមានខ្លួនពិតឡើយ គឺជាខ្លួនរបស់យក្ស (មុរ) ព្រោះតួខ្លួនពិតរបស់គាត់បានបាត់រូបរាងទៅហើយ សូម្បីតែទ្រនុងនាគខាងលើក៏ជាខ្លួនរបស់យក្សដែរ។ នៅខាងក្រោមក្បាលនាគទាំងសងខាង មានទំផ្កាឈូក និងមានសត្វតោម្នាងមួយ កំពុងជ្រោងលើកក្បាលនាគឡើង តើទំផ្កាឈូកមានន័យដូចម្ដេច? ទំផ្កាឈូកដែលទ្រនាគ គឺតំណាងឲ្យនាគទាំងពីរជាអ្នកគោរពព្រះពុទ្ធសាសនា ព្រោះផ្កាឈូក តំណាងឲ្យព្រះពុទ្ធសាសនា។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងថា សត្វដែលកំពុងស្ថិតក្នុងភពបី គឺកាមភព រូបភព និងអរូបភព ប្រៀបប្រដូចនឹងផ្កាឈូកដែលដុះក្នុងជលស្ថានទាំងបួនពួក។ ផ្កាឈូកទីមួយ ប្រៀបដូចបុគ្គលដែលទើបដុះចេញពីភក់ ផ្កាឈូកទីពីរ ប្រៀបដូចបុគ្គលដែលដុះចេញពីភក់ ហើយដែលនៅក្នុងទឹក ផ្កាឈូកទីបីប្រៀបដូចបុគ្គលដែលដុះផុតពីទឹក ផ្កាឈូកទីបួន ប្រៀបដូចបុគ្គលដែលដុះផុតពីទឹកហើយរងចាំងព្រះសែងសូរិយា ចាំងមកប្រុងនឹងរីក។ ដូច្នេះទើបព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គដែលបានត្រាស់ដឹង ដូចជាអម្បាលខ្សាច់ក្នុងមហាសាគរ តែងមានពុទ្ធកិច្ចប្រាំយ៉ាង ព្រឹកព្រះអង្គនិមន្តបិណ្ឌបាត ថ្ងៃរសៀលទ្រង់សម្ដែងធម៌ប្រោសពុទ្ធបរិស័ទ ពេលប់ទ្រង់ផ្ដល់ឱវាទចំពោះពួកភិក្ខុសង្ឃ អាធ្រាតទ្រង់ដោះស្រាយប្រស្នាពួកទេវតា ជិតភ្លឺទ្រង់ពិចារណាមើល

និស្ស័យសត្វ ដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង។ ហេតុនេះហើយទើប ព្រះម៉ែមហានគរលោក បានយករចនាប័ទ្ម = ត្របកផ្កាឈូកនេះ មកប្រតិស្ឋានទុកគ្រប់ប្រាសាទ ដើម្បីទុកជាប្រស្នាឲ្យកូននាគ សម័យក្រោយមើលរួចត្រិះរិះគិតពិចារណា នេះជារអាថ៌កំបាំងរបស់ព្រះម៉ែមហានគររចនាប័ទ្ម = (សំ) ក្បាច់ត្របកឈូក (វចនានុក្រមសម្ដេចព្រះសង្ឃរាជ **ជួន ណាត**)។ ចំណែកឯសត្វតោពីរ តំណាងឲ្យទីក្រុងមួយដែលនឹងកើតឡើងទៅអនាគត គឺទីក្រុងដែលមានរូបសំណាកតោពីនោះឯង ប៉ុន្តែក្នុងរូបភាពនេះ ពុំទាន់មានកូនខ្មែរណាមួយអាចមកជាន់លើក្បាលយក្ស និងជាន់លើគ្រុឌបាន ទើបតោទាំងពីរ ពុំអាចមានកម្លាំងលើករឿងព្រះម៉ែនាគរួចឡើយ ព្រោះនាគទាំងពីរជាប់ឃុំនៅក្នុងអំណាចយក្ស គ្រុឌ គម្របថ្ម និងសត្វករវិក ដែលខ្ញុំបានពន្យល់ក្នុងរូបភាពទីមួយរួចហើយ។ នៅខាងលើទ្រនុងនាគ មានរូបឥសីមួយគូ កំពុងអង្គុយពែនភ្នែនលើផ្កាឈូក ដៃលើកសំពះ ចំណែកឯនៅកឥសី មានពាក់ខ្សែអង្កាំសម្រាប់ធ្វើសមាធិ តើឥសីទាំងពីរតំណាងឲ្យអ្វី? ឥសីទីមួយគឺតំណាងឲ្យឥសីកម្ពុ ព្រះថោងកៅណ្ឌិន ហ៊ុនទៀន....។ល។ ដែលគាត់ជាស្វាមីរបស់ព្រះនាងនាគពីអតីត ហើយគាត់ជាប់ទោសដូចព្រះម៉ែមហានគរដែរ គ្រាន់តែគាត់នៅក្រៅឃុំតែប៉ុណ្ណោះ ដូច្នេះហើយទើបគេឆ្លាក់រូបគាត់អង្គុយនៅលើទ្រនុងនាគ បានន័យថា គាត់នៅក្រៅឃុំ (ព្យួរទោស)។ ចំណែកឥសីទីពីរ គឺតំណាងឲ្យពូជឥសីខាងក្រោយគឺ "កូន" ព្រោះសម័យក្រោយ គឺកូនខ្មែរគ្រប់ជំនាន់ដែលបានទទួលមរតកឥសីពីអតីតកាល គឺតំណាងឲ្យឥសីកម្ពុ ព្រោះអ្នកដឹកនាំនគរសម័យក្រោយៗ គឺជាបុរសបន្តគ្នា គេពុំបានដឹងពីរឿងព្រះមេ និងព្រះម៉ែពីអតីតកាលទៀតឡើយ។ រូបនាគដែលជាប់ទោសមានក្បាលបីនោះ មួយតំណាងម្ដាយ ពីរតំណាងឪពុក បីតំណាងឲ្យកូន ហេតុអ្វីបានជាឥសីទាំងពីរអាចនៅក្រៅឃុំបាន? ព្រោះស្ត្រីដែលជាភរិយាឬម៉ែ ហេតុតែនគរខ្លួន កូនខ្លួន ក្នុងនាមជាម៉ែ (ស្អុរតាំងម៉ែ) គាត់សុខចិត្តយកអម្រែកទោសពីរថែមទៀត របស់ស្វាមី និងកូន មកទទួលរែកតែម្នាក់ឯង។ ដោយគាត់យល់ថា បើជាប់ទោសទាំងអស់គ្នា គឺគ្មានអ្នកណាទៅខាងក្រៅឃុំសរជាតិ ដើម្បីជួយគ្នាឡើយ ដូច្នេះហើយទើបគាត់ ទទួលអម្រែកទាំងពីរថែមទៀត រួមទាំងទោសរបស់គាត់មួយផង ទើបរួមជាបី (មើលសោបីជាន់រូបទីមួយ)។ នៅលានព្រះគម្លង់ស្ដេចគម្លង់ (ព្រះថោង) គេឆ្លាក់រូបគាត់នៅខាងលើ ប៉ុន្តែនៅទិសទាំងបួន មានអ្នកឈរយាមគាត់គ្រប់ទិស តែសព្វថ្ងៃរូបទាំងបួនទិសនោះ នូវសល់តែជើងទំរតែប៉ុណ្ណោះ ឯរូបខាងលើមិនដឹងទៅដល់ទីណាឡើយ នេះបានបង្ហាញឲ្យយើងដឹងថា គាត់នូវព្យួរទោសនៅឡើយ។ បញ្ញាសជាតករបស់ខ្មែរ ក៏បានពន្យល់ពីការសរជាតិរបស់ពោធិសត្វ ដើម្បីបំពេញបារមី ហេតុអ្វីបានជារឿងនៅក្នុងបញ្ញាសជាតកខុសពីរឿងក្នុងជាតកគម្ពីរព្រះត្រៃបិតក ព្រោះរឿងក្នុងបញ្ញាសជាតក និងជាតកនានា ជា

រឿងសរជាតិរបស់អ្នកទាំងពីរ ដែលខ្ញុំបានពន្យល់ហើយខាងលើ ហើយអ្នកប្រាជ្ញជំនាន់នោះ គាត់បាន លាក់រឿងគាត់ក្នុងស្រោមព្រះពុទ្ធសាសនា។ ឥសីទាំងពីរនេះទៀតសោត វិលងអត្តភាពពីមួយកំណើត ទៅមួយកំណើត គឺស្ត្រីជាព្រះម៉ែនេះហើយ (បិសាចពស់) ដែលបានមកភ្ជាប់រឿងឲ្យនឹងតជាប់គ្នាឡើង ទម្រាំដល់ពេលដែលត្រូវកំណាត់រួចពីទោស។ ក្នុងភាគមួយ និងភាគពីរមុន ខ្ញុំពុំបានបង្ហាញ ពីស្វាមី ឬ ឪពុករួមទាំងកូននេះឡើយ ព្រោះពួកគាត់កំពុងនៅព្យួរទោសខាងលើស្រាប់ ដូចនេះខ្ញុំបានពន្យល់បក ស្រាយតែរឿងរបស់មាតាមហានគរតែប៉ុណ្ណោះ ដែលសុខចិត្តយកទម្ងន់ទោសអ្នកទាំងពីរ មកទទួល តែឯង **នេះជាហេតុដែលខ្ញុំពុំបានពន្យល់ក្នុងភាគមុនៗ។**

សរុបសេចក្ដីមក ភាសារូបក្នុងផ្ទៃរនេះក៏មិនខុសពីន័យផ្ទៃរមុនៗឡើយ គ្រាន់តែគាត់បាន បន្ថែមឥសីពីររូប ដែលខ្ញុំត្រូវបកស្រាយពន្យល់ដោយសង្ខេបនៅក្នុងរូបភាពនេះ គ្រាន់ទុកជាទុន សម្រាប់កូននាគប្រុសស្រីពិចារណាឈ្វេងយល់ មកជារឿងរបស់ព្រះម៉ែ ឈប់យល់ច្រឡំថាជារឿង នៅក្នុងសាសនាទៀត។

## ១៣/.រូបភាពទី១៣រូបនាគក្បាល៥លើ៧ជាប់ទោសត្រឹមក (លានព្រះគំលង់)



រូបភាពក្បាលនាគពីរជាន់នេះ តំណាងឲ្យនាគជាប់ទោស ក្នុងទីឃុំលានព្រះ គម្លង់ ព្រោះនាគដែលស្ថិតក្នុងទីនេះ មានតែ ក្បាលខ្លួនត្រូវកប់ទៅក្នុងដី ឬភក់ ដែលដី និង ភក់នេះ សព្វថ្ងៃបានរឹងក្លាយទៅជាថ្ម (ថ្មភក់ ឬភក់ថ្ម)។ ក្នុងសកម្មភាពរូបភាពនេះ មាន ក្បាលនាគពីរជាន់ ក្បាលខាងក្រោមមាន៧ ក្បាលខាងលើមាន៥។ កន្លែងខ្លះក្បាលខាង ក្រោម៩ និងក្បាលខាងលើ៥ ហើយនាគទាំង នោះ គឺបិទមាត់សង្រួមរួចងើយទៅលើ ស្រែក ហៅកូនឲ្យជួយ ព្រោះទីលាននេះគឺជាគុក វា ខុសពីនាគនៅកំពុងក្ដី ដែលនាគក្បាល៩ នៅ

ពីលើនាគក្បាល៥វិញ តើអត្ថន័យនាគក្បាល៥លើ៧នេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី? ខ្ញុំបានបកស្រាយពន្យល់ដោយត្រួសៗរួចមកហើយក្នុងអាថ៌កំបាំងបណ្តាំព្រះម៉ែមហានគរភាគ១ ភាគ២ រហូតមកដល់ភាគ៣នេះ គឺនិយាយតែពីអាថ៌កំបាំងរបស់សត្វនាគ ជានិមិត្តរូបតំណាងឲ្យមាតានាគដែលគាត់ត្រូវជាប់ទោស ព្រោះហេតុតែសេចក្តីប្រកាន់មាំក្នុងបញ្ចខន្ធ (ខន្ធ៥) **គឺរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ**។ ដោយសន្មត់ថាជាខ្លួន ថាជាស្វាមី បុត្រា បុត្រី កូនក្មេរប្រុសស្រី ថាជាញាតិ ហេតុនេះទើបក្បាលទាំង៥ (តំណាងបញ្ចខន្ធ) មានកម្លាំងអាចត្រួតសង្កត់នៅលើក្បាល៧បាន ដោយក្បាល៧នេះតំណាងឲ្យមួយសប្តាហ៍។ ដូច្នេះពីមួយសប្តាហ៍ទៅមួយសប្តាហ៍ ត្រូវបញ្ចខន្ធសង្កត់ជាប់ ពុំអាចរើខ្លួនរួចឡើយ ហើយខន្ធនោះ ត្រូវជាប់ក្នុងឃុំ (អបាយភូមិ) នោះដែរ ព្រោះបុថុជ្ជនគ្រប់រូបដែលគ្មានសីលកម្រនឹងរួចពីអបាយភូមិបានណាស់។ នៅពីខាងលើក្បាលនាគ សង្ខាងក្បាលនាគ មានពលសេនាយក្សជាច្រើន នៅយាមការពារទាំងខាងក្រោមពីចំហៀងទាំងសង្ខាង ទាំងខាងលើ មិនឲ្យព្រះម៉ែនាគ (បិសាចពស់) រើខ្លួនចេញពីភក់ថ្មនេះរួចឡើយ (នេះជាអាថ៌កំបាំងភាសារូបក្នុងលានព្រះគម្លង់ទី១)។

## ១៤/.រូបភាពទី១៤រូបនាគក្បាល៥លើ៩(លានព្រះគម្លង់)



ក្នុងរូបភាពនេះ នាគមានក្បាល៥ នៅពីលើនាគក្បាល៩ ហើយក្បាលនាគទាំង១៤សុទ្ធតែសង្រួមងើយក្បាលទៅលើដូចគ្នា ព្រោះដូនតាខ្មែរគាត់កម្រឆ្លាក់នាគសង្រួមណាស់ នាគសង្រួមមានតែនាគពីរបែបប៉ុណ្ណោះ ទីមួយគឺនាគមានសីល ទីពីរគឺនាគដែលជាប់ឃុំឃាំង។ ក្បាលនាគដែលស្ថិតក្នុងទីលាននេះទាំងអស់ ងើយក្បាលទៅលើ ហើយរំពឹងគិតថា ពេលណាហ្ន៎ ទើបកូននាគគេមើលឃើញរួចដឹងរឿងខ្លួន បើជញ្ជាំងក្នុងទីឃុំនេះខ្ពស់ម្ល៉េះៗ តើអាត្មាអញស្រែកហៅកូនធ្វើម្ដេចឮ ទោះបីជាជញ្ជាំងឃុំនៅជាប់នឹងផ្លូវថ្នល់ក៏ដោយ ពួកគេក៏ពុំអាចមើលឃើញដែរ មានតែនៅស្ងៀមទ្រាំបង្ហូរទឹកភ្នែករងចាំ លុះដល់បាបកម្មឲ្យផលអស់ (ទំនួញប្រេត)។ ចំណែកឆ្មាំដែលយាមគាត់គឺមានបួនជាន់ ខាងក្រោម កណ្ដាល និងលើ បើយើងមើលសកម្មភាពអ្នកយាមទាំងនោះព្រះម៉ែមហានគរលោកពុំអាចលួចចេញមកខាងក្រៅបានទៀតឡើយ ព្រោះភាសារូបក្នុងទីនេះ បានប្រាប់យើងជាកូននាគសម័យខាងក្រោយថា បិសាចពស់ដែលចិនជីវតាក្វាន់និយាយនោះ មិនអាចចេញមកជួយចង្អុលផ្លូវប្រាប់ក្នុងការដឹកនាំនគរបានទៀតទេ តើគាត់ចេញមកម្ដេចរួច បើគាត់នៅសល់តែក្បាល ហើយអ្នកចាំយាមគាត់ច្រើនម្ល៉េះៗនោះ? ចម្លើយសូមកូននាគប្រុសស្រីមើលរឿងក្នុងរូបទីលាននេះ និងរូបទាំង១៧ដែលខ្ញុំបានពន្យល់រួចហើយនោះផង យើងនឹងយល់ច្បាស់ពីអាថ៌កំបាំងទោសរបស់គាត់ជាពុំខាន។

## ១៥/.រូបភាពទី១៥រូបនាគក្បាល៩ពីលើក្បាល៥ (ស្ពានកំពុងក្ដី)

អត្ថន័យរូបនេះ ខ្ញុំបានពន្យល់ក្នុងភាគមុន ខ្លះៗហើយ ខ្លាចក្រែងពុំសូវច្បាស់ ដូច្នេះខ្ញុំត្រូវបកស្រាយពន្យល់ បន្ថែមទៀត ដើម្បីឲ្យកាន់តែងាយយល់ ចំពោះភាសាគំនិត ដែលបានបង្កប់នៅក្នុងរូបនេះ។ ហេតុអ្វីបានជានាគ កំពុងក្ដីនេះ នាគក្បាល៩នៅពីលើ៥ទៅវិញ ខុសពីនាគក្នុងលានព្រះគម្លង់ អាថ៌កំបាំងប្រស្នារូបនេះ គាត់ចង់ប្រាប់យើងថា ស្ពានកំពុងក្ដីនេះ ស្ថិតនៅលើស្ទឹងជីក្រែង ខ្ញុំបានពន្យល់រួចហើយ ក្នុងភាគមុន ចំណែករូបនាគ លើស្ពាននេះ គ្មានកន្ទុយទេ គឺក្បាលនាគរួមខ្លួន តែមួយ (នាគព័ន្ធ)



សងខាង ហើយនៅក្រោម ក្បាលនាគពីរជាន់ ទាំងក្បាល១៤នេះ មាននៅសល់ស្នាមរូបស្ត្រីម្នាក់ ឈរទ្រពីខាងក្រោម តំណាងឲ្យនាគខាងលើ គឺ ព្រះម៉ែនាគ (មាតាមហានគរ)។ នាគក្បាល៩នេះ នៅលើទម្រផ្កាឈូក ដែលខ្ញុំបានពន្យល់រួចហើយ ពីន័យផ្កាឈូក តើក្បាល៩តំណាងអ្វី? ក្បាល៩ គឺតំណាងឲ្យលោកុត្តរធម៌ គឺមគ្គបួន ផលបួន និងនិព្វានមួយ ដែលធ្វើឲ្យផ្កាឈូក គឺបញ្ញានេះ អាចរីករួច ព្រោះអំណាចនៃគុណធម៌របស់ពួកគាត់ ទីបំផុតផ្កាឈូក ដែលជាទម្រដ៏ធំនេះ និងអាចរីករួចនៅចុងបញ្ចប់ ក្នុងរឿងអាថ៌កំបាំងនេះ។ ចំណែកឯក្បាល៥ តំណាងឲ្យបញ្ចក្ខន្ធ ដែលខន្ធនេះពុំអាចឡើងទៅសង្កត់លើ៩ បានទៀតឡើយ នៅពេលណាដែលវិបស្សនាកម្មដ្ឋាន កើតផុលផុសឡើង។ នេះជាប្រស្នាដែលក្បាលនាគកំពុងក្តី និងក្បាលនាគលានព្រះគម្លង់ ស្ថិតក្នុងទិសបញ្ច្រាសគ្នានោះ បញ្ញាក្នុងទីទុក្ខពុំអាចមាន វិបស្សនាកើតឡើងឡើយ នេះជាក្រិតក្រមធម្មជាតិ។ នាគកំពុងក្តី គឺចេញផុតពីទីឃុំហើយ លូនវាបន្តិចម្តងៗចេញពីក្តី ដែលមានដីក្រែងនៅខាងក្រោមនោះ (ស្ទឹងដីក្រែង) ជួយជ្រោងព្រះម៉ែនាគឲ្យឡើងមកខាងលើ រហូតបានរួចផុតពីអំណាចឃុំរបស់យក្ស (ពន្យល់រួចហើយក្នុងភាគមុន)។

## ១៦/.រូបភាពទី១៦រូបគ្រុឌចាប់ជាន់នាគ (នៅជញ្ជាំងខាងក្រៅលានជល់ដំរី)



ក្នុងសកម្មភាពរូបនេះ បានបង្ហាញពីគ្រុឌមួយ ដែលមានមាឌធំ កំពុងតែឈរច្រៀងដៃចាប់កន្ទុយនាគសង្ខាង រីឯជើងខាងក្រោម ជាន់ត្រង់កខ្លួននាគបី ក្បាលមួយនៅកណ្តាលក្បាលពីសង្ខាង ហាក់បីដូចជាខ្លាចនាគទាំងបីរើបម្រះរួចពីអំណាចខ្លួន។ ចំណែកនៅលើក្បាលនាគសង្ខាង ពីខាងក្រោយ មានក្បាលយក្សកំពុងខាំក្បាច់និមិត្តរូបខ្លួននាគ បើយើងមិនដឹង មើលទៅដូចជាក្បាច់សម្រាប់លម្អ តាមពិតនិមិត្តរូបយក្សដែលជាម្ចាស់ពៀរ ដែលកំពុងញញួញធ្មេញខាំក្បាច់ដែលគ្របក្បាលនាគ។ សរុបសេចក្តីមកអត្ថន័យក្នុងរូបទី១៦ ក៏មិនខុសពីរូបមុនៗដែលខ្ញុំបានពន្យល់រួចហើយ ព្រោះពួកគាត់ឆ្លាក់រូបភាពដដែលៗនេះ គាត់ភ័យខ្លាចកូននាគសម័យខាងក្រោយពុំចាប់អារម្មណ៍មើល រួចឆ្ងល់ហើយពិចារណាស្វែងយល់លើសិលាចារឹករូបរឿងសាវតាទាំងនោះ។

## ១៧/.រូបភាពទី១៧គ្រុឌនៅកែងខ្លោងទ្វារ (នៅជញ្ជាំងខាងក្រៅប្រាសាទបន្ទាយក្ដី)



រូបគ្រុឌខ្លោងទ្វារនេះ អត្ថន័យរបស់វាក៏មិនខុសពីរូបមុនដែរ គ្រាន់តែរូបភាពក្បាលនាគនៅក្រោមជើងគ្រុឌយើងអាចមើលឃើញច្បាស់ជាង ហើយរូបខ្លោងទ្វារនេះបានបង្ហាញពីអ្នកកាន់កន្ទុយនាគ គឺស្ត្រីម្នាក់នៅចន្លោះក្បាលព្រហ្មខាងលើ តែខ្លោងទ្វារនេះ រូបនៅខាងលើមើលពុំសូវឃើញឡើយ ខ្ញុំនឹងយករូបភាព ខ្លោងទ្វារប្រាសាទតាព្រហ្មមកពន្យល់វិញ ព្រោះនៅមានរូបភាពច្បាស់ជាងគ្រាន់នឹងមើលឃើញអាចពន្យល់បកស្រាយបាន។

## ១៨/.រូបភាពទី១៨រូបខ្លោងទ្វារប្រាសាទ (តាព្រហ្មមើលពីចំហៀង)



រូបខ្លោងទ្វារប្រាសាទតាព្រហ្មនេះ គ្រុឌនៅខាងជ្រុងទ្វារ កំពុងជាន់ខ្លួននាគទាំងបី នៅខាងក្រោមជើងនោះ គឺនៅសល់តែដៃគ្រុឌតែប៉ុណ្ណោះ រីឯខ្លួនគ្រុឌបានបំផ្លាញស្លាកស្នាម អស់ហើយ តែក៏យើងអាចនៅមើលយល់បានដែរ ដោយយើងយករូបនេះ ទៅប្រៀបធៀប និងខ្លោងទ្វារបន្ទាយក្ដី ឬបន្ទាយឆ្មារ និងប្រាសាទដ៏ទៃៗទៀត ដែលនៅសល់អាចមើលយល់បាន។

តើក្បាលនាគ ដែលគ្រុឌកំពុងជាន់នោះកន្ទុយទីពានៅឯណា? បើយើងក្រឡេកមើលទៅលើ ចន្លោះត្រចៀកព្រហ្មទាំងសង្ខាងនៃរូបនេះ យើងនឹង

ឃើញរូបស្ត្រីម្នាក់ឈរ ដែលក្បាលមានពាក់ក្បាំងដូចអប្សរា ដៃទាំងពីរកាន់កន្ទុយនាគ យើងមើលឃើញតែទ្រនុងខ្នងនាគ ទម្លាក់ខ្លួនចុះមកក្រោម រីឯក្បាលនាគ គឺនៅក្រោមជើងគ្រុឌខាងក្រោម។ អត្ថន័យទាំងនេះ ខ្ញុំបានពន្យល់តាំងពីរូបភាពទីមួយមកម្ល៉េះ គឺព្រះម៉ែមហានគរលោកទៅដល់កំពូលព្រហ្មទៅហើយ ទីបំផុតគាត់ទម្លាក់ក្បាលចុះមកក្រោម ព្រោះហេតុតែធ្វើជាព្រហ្មឲ្យកូនប្រុសស្រី (វិហារធម៌) សុខចិត្តឲ្យគ្រុឌជាន់ខ្លួនកប់ក្នុងភក់ តាំងពីភក់នៅទន់ រហូតដល់ភក់រឹងក្លាយជាថ្ម (ថ្មភក់)។

ហេតុនេះហើយបានជាសម័យក្រោយស្ថាបត្យកម្ម សំណង់ប្រាសាទ ព្រះវិហារ រាជវាំង....តែងតែធ្វើបន្តគ្នានូវក្បាលនាគអមក្បាំងក្លែង ហោជាង ដំបូល ធ្វើនាគសំយ៉ុងក្បាលចុះមកក្រោម ដោយពុំបានដឹងថា ហេតុអ្វីនាគទៅដល់កំពូលលើទៅហើយ បែរជាលូនវាចុះមកក្រោមវិញ នេះជាប្រស្នាព្រះម៉ែមហានគរ ដែលបានទុកកេរឲ្យយើងជាអ្នកស្រាយនៅប្រស្នារាប់ពាន់ឆ្នាំនេះ។

ចំណែកនៅ**ភ**ព្រហ្មខាងក្រោម ខ្ញុំបានពន្យល់ន័យខ្លះហើយ ក្នុងភាគមុន ពេលនេះខ្ញុំគ្រាន់លើកយកចំណុចខ្វះខាតខ្លះ មកពន្យល់បន្ថែមតែប៉ុណ្ណោះ នៅកព្រហ្មមានស្ត្រីអង្គុយ១២នាក់ តំណាងឲ្យមាតាទាំង១២ បន្ទាប់មកមានដំបូលរាងចង្អូរដូចប្រ៊ីប្រូ តែតាមពិតពុំមែនប្រ៊ីប្រូដូចសព្វថ្ងៃឡើយ គឺជាតួខ្លួននាគដែលបានពាក់ជាន់ៗគ្នាក្លាយជាដំបូលបញ្ឆោតមួយ តែសម័យក្រោយដំបូលនេះ បានក្លាយជាគ្រឿងស្រកានាគ (ពន្យល់រួចហើយក្នុងភាគមុន)។ ស្ត្រីទាំង១២ មានភារកិច្ច ថែរក្សាព្រហ្ម គឺមាតុភូមិនេះ ប៉ុន្តែមាតាទាំង១២មានតែ៧នាក់ទេ ដែលថែព្រហ្មម៉ែឪរាល់ឆ្នាំ ហើយ៧នាក់នេះប្រចាំគ្នាទៀត ដល់វេនអ្នកណា អ្នកហ្នឹងទៅហែទៅ ចំណែកអ្នកឯទៀតរវល់ចិញ្ចឹមក្រុមគ្រួសាររបស់ខ្លួន ព្រោះបេះដូងពួកគាត់ខៃថ្ងៃស៊ីអស់ហើយ (អាចិកំបាំងដូងខៃស៊ី) តើមាតាបិតាមហានគរសង្ឃឹមអ្វី បើបេះដូងកូនគាត់ ខៃស៊ីអស់ទៅហើយនោះ? នេះជាប្រស្នាថ្មបានរៀបរាប់ប្រាប់ពីទុក្ខសោកវេទនា នឹងភាពអស់សង្ឃឹមរបស់គាត់ មកលើកូននាគប្រុសស្រីជំនាន់ខាងក្រោយ ដែលគាត់ពុំអាចចេញពីទីឃុំឃាំងរួច មានតែដេករងចាំបាបកម្មចាស់ឲ្យផលអស់តែប៉ុណ្ណោះ។

សរុបសេចក្ដីមក អត្ថន័យរបស់រូបខ្លោងទ្វារប្រាសាទទាំងពីរនេះ គឺគំនិតរបស់ពួកគាត់ បានយកមកបង្កប់ទុកក្នុងថ្ម ដូចខ្ញុំបានពន្យល់ដោយសង្ខេបនេះ ពុំមែននិយាយពីរឿងព្រហ្មញ្ញសាសនានៅឥណ្ឌាឡើយ ព្រោះឥណ្ឌាពុំមានប្រាសាទមុខព្រហ្មទេ មុខព្រហ្មទាំងអស់ ដែលមាននៅលើទឹកដីខ្មែរពីអតីតកាល និងសល់គង់វង្សមកដល់បច្ចុប្បន្ន គឺតំណាងឲ្យព្រហ្មម៉ែព្រហ្មឪ និងព្រហ្មកូនដែលត្រូវមកជួយម៉ែឪ ឲ្យរួចផុតពីបាបកម្មចាស់តែប៉ុណ្ណោះ។

# ១៩/.រូបភាពទី១៩រូបយក្សជាន់ព្រះម៉ៃ (មិនស្គាល់ប្រភព)



រូបភាពនេះ គាត់ឆ្លាក់រង្វង់ក្បាច់មួយវង់ ព័ទ្ធជុំវិញយក្សឈរលើកជើងឆ្វេង ដែលមានទំរ ជាផ្កាឈូក ដែលនៅខាងក្រោមជើងយក្សម្ខាងនោះ មានស្ត្រីបួននាក់ កំពុងលើកដៃសំពះដាក់បន្ទូលលើក្បាល ហាក់ដូចជាបួងសួងឲ្យអ្នកណាមួយមកជួយខ្លួន។ តើស្ត្រីទាំងបួននៅក្រោមជើងយក្សតំណាងអ្វី? ស្ត្រីទាំងបួននាក់ តំណាងឲ្យព្រះម៉ៃមហានគរ ដែលគាត់ជាប់ក្នុងឃុំ សោទាំងបួនជាន់ (មើលការពន្យល់ ក្នុងរូបភាពទីមួយ) ឯគាត់លើកដៃបន្ទូលទៅលើ គឺគាត់អង្វរកូននាគប្រុសស្រី ឲ្យជួយគាត់ផង ព្រោះគាត់ទ្រទ្រង់ទម្ងន់ទុក្ខធ្ងន់ណាស់ (យក្សជាន់) ចំណែកផ្កាឈូក ដែលគាត់ដេកពីលើ តំណាងឲ្យការបំពេញបារមី របស់គាត់ ប្រាថ្នាឲ្យបានជាពុទ្ធមាតា ទៅអនាគតជាតិ។ ឯក្បាលស្ត្រីព្យួរក្រោមជើងយក្ស ដែលលើកបត់នោះ គឺតំណាងឲ្យមាតាទាំងប្រាំពីរ (ទេពធីតាទាំងប្រាំពីរ) ដែលមកហែក្បាលកបិលមហាព្រហ្មរាល់ៗឆ្នាំ តាមពិតមាតាទាំងអស់មានដល់ដប់ពីរនាក់ឯនុះ ហើយក្បាលទាំងនោះមានច្រវាក់ទាក់បន្តគ្នា មើលទៅហាក់បីដូចជាខ្សែលម្អ តាមពិតពួកគាត់ជាប់ទោសយក្ស ដូចព្រះម៉ៃមហានគរដែរ។ ដៃយក្សទាំងអស់មានដប់ប្រាំមួយ គឺម្ខាងមានប្រាំបីៗ តែប្រាំបីនេះមាននៅសល់ម្ខាងប្រាំពីរទេ ឯដៃពីរទៀតកំពុងតែឱបកូនស្រីកង្រី ដូច្នេះដៃដែលបែងសងខាងមានប្រាំពីរដៃ។ តើដៃប្រាំពីរតំណាងអ្វី? ដៃប្រាំបីតំណាងអ្វី? ដៃប្រាំពីរគឺតំណាងឲ្យមួយសប្តាហ៍រាល់ខែ និងឆ្នាំ ចំណែកដៃប្រាំបីតំណាងឲ្យទិសតូចបួន ទិសធំបួន គឺទិសទាំងប្រាំបី មានន័យថាគ្រប់ៗទិសតូចធំទាំងប្រាំបី រាល់សប្តាហ៍ (ប្រាំពីរថ្ងៃ) ថ្ងៃណាក៏ព្រះម៉ៃ

មហានគររួមទាំងម៉ែទាំងដប់ពីររបស់គាត់និងកូន ត្រូវនៅក្នុងការឃុំគ្រងរបស់យក្ស។ នៅលើដៃស្តាំទាំងប្រាំពីរមានក្មេងម្នាក់ទើបតែងើបរួចពីក្នុងពួច ឬក្រឡុកំពុងដេកពោបចង់ងើបក្រោកអង្គុយដែរ តែពុំអាចងើបរួច ដូច្នេះបានត្រឹមតែដេកពោបនៅលើមាត់ពួចតែប៉ុណ្ណោះ។ ចំណែកឯដៃឆ្វេងទាំងប្រាំពីរវិញ ទើបក្មេងតូចនោះ អាចងើបអង្គុយលើមាត់ពួច ឬក្រឡុបាន ដល់ដៃទីប្រាំពីរ គឺមានដៃរបស់កង្រីជាស្ត្រីកូនយក្សបានចាប់ក្មេងនោះ ក្នុងដៃលើកយកទៅដាក់លើក្បាល នាងសន្ធមារដែលជាមាតា។ ដូច្នេះហើយទើបសាច់រឿងព្រេងនាងទាំងដប់ពីរ ឬពុទ្ធិសែននាងកង្រីបានបញ្ជាក់ប្រាប់ថាពុទ្ធិសែនបានរៀបការជាមួយនឹងនាងកង្រីហើយបានយកកែវភ្នែកម្តាយទាំងដប់មួយៗចំហៀង រួមទាំងថ្នាំទិព្វផងទៅដាក់បញ្ចូលឲ្យម្តាយវិញ ទើបម្តាយធំទាំងដប់មួយ រួមទាំងម្តាយបង្កើតខ្លួនផងមានកែវភ្នែកភ្លឺឡើងវិញ។ ដែលអាចមានកែវភ្នែកមើលឃើញ គឺបញ្ហានេះក៏ព្រោះតែមានការជួយឧបត្ថម្ភជ្រោមជ្រែង ពីសំណាក់នាងកង្រីជាកូនយក្សតែប៉ុណ្ណោះ ដូចក្នុងរូបភាពនេះបានបង្ហាញប្រាប់យើងស្រាប់ បើពុំដូច្នោះទេកូននាគនេះ ពុំអាចដឹងរឿងហើយឡើងទៅជាន់លើក្បាលយក្ស ឲ្យព្រមលែងម្តាយនៅខាងក្រោមបានឡើយ កង្រីជាកូនសោមួយ អាចបើកបំភ្លឺអាថ៌កំបាំងរបស់មាតាទាំងដប់ពីរបានពេលកែវភ្នែកមាតាទាំងដប់ពីរភ្លឺ នឹងដឹងរឿងរបស់ព្រះម៉ែមហានគរជាមិនខាន ព្រោះពួកគាត់ទាំងដប់ពីរជាកូនរបស់ព្រះម៉ែមហានគរ។ កូនណាបានរៀបការជាមួយកង្រី ទើបអាចមានដំណឹងយល់ដឹងពីកន្លែងលាក់កែវភ្នែករបស់ម៉ែទាំងដប់ពីរបាន ពេលណាដឹងរឿងម៉ែទាំងដប់ពីរ គេនឹងដឹងរឿងម្តាយឪពុកនាងទាំងដប់ពីរ ដែលបានយកកូនទៅបំបរបង់ចោលក្នុងព្រៃជាពុំខាន ព្រោះវាជាប្រាស្នាអាថ៌កំបាំងដែលបានលាក់កប់ទុករាប់ពាន់ឆ្នាំហើយ។ ឯគ្រុឌនៅលើក្បាលយក្សនោះ គឺតំណាងឲ្យសោជាន់ទីពីរដែលខ្ញុំបានពន្យល់ពីរូបភាពមុនៗរួចមកហើយ ឯរង្វង់ព័ទ្ធពីលើគឺជាផ្អកឬអង្រុត (បក្សីចាំក្រុង) ដែលបិទបាំងលាក់រឿងរបស់គាត់មិនឲ្យកូននាគសម័យក្រោយយល់ដឹងបាន។

សរុបសេចក្តីមកការបកស្រាយពន្យល់ដោយសង្ខេបនេះ គឺបង្ហាញពីអត្ថន័យខ្លឹមសារពិត ដែលបានបង្កប់លាក់ទុកក្នុងរូបភាពចម្លាក់នេះ ពុំមែនជាព្រះសីរៈ ឬឥសូររាំជាន់កូនក្មេងដូចឯកសារបរទេសដែលបានបកពីអតីតកាលនោះទេ ព្រោះបរទេសពុំមែនជាខ្មែរ បេះដូងរបស់ពួកគេពុំមែនជាបេះដូងនាគឡើយ គឺមានតែយើងជាកូនខ្មែរនេះទេដែលមានបេះដូងនាគ ព្រោះយើងជាពូជពង្សព្រះនាងនាគ។

## ២០/.រូបភាពទី២០យក្សឈរជាន់ព្រះម៉ែមហានគរ(នៅសារមន្ទីរជាតិភ្នំពេញ)



រូបភាពចម្លាក់នេះ បង្ហាញពីយក្ស ក្បាល១០រួចដៃបែងភាគម្ខាង៨ ហើយនៅលើដៃទាំង១៦មានក្មេងតូចអង្គុយគ្រប់ រូបនេះនិងរូបនៅប្រាសាទបន្ទាយឆ្មារ ជញ្ជាំងខាងក្រោយ គឺមានន័យដូចគ្នា។ នៅខាងក្រោមជើងយក្ស មានស្ត្រីម្នាក់ពាក់ក្បាំងមកុដ ត្រូវយក្សជាន់ដល់**ក** ឯខាងក្រោមស្ត្រីគឺទំរង់ផ្កាឈូកដ៏ធំមួយ ហើយស្ត្រីពាក់ក្បាំងត្រូវក្រុងរាពណ៍ជាន់នោះ បានបែងភាគជាបួនជាន់ ដូចមុនដែរ គ្រាន់តែរូបនេះជាន់ៗជាប់គ្នា តើយក្សតំណាងអ្វី? ស្ត្រីនៅក្រោមជើងយក្សតំណាងអ្វី? ផ្កាឈូកតំណាងអ្វី?

**ក**/.យក្សតំណាងឲ្យម្ចាស់ពៀរ គឺឆ្នាំគុក អ្នកចាប់ព្រះម៉ែមហានគរ យកទៅឃុំ

**ខ**/.ដៃបែងភាគ៨ តំណាងឲ្យទិសតូច៤ធំ៤ ដែលនៅក្នុងទិសណាមួយ ក៏ស្ថិតនៅក្រោមអំណាចយក្សគ្រប់គ្រង។

**គ**/.ក្មេងដែលនៅលើដៃយក្ស តំណាងឲ្យកូនខ្មែរ (កូននាគ) ដែលសុខចិត្ត បំពេញគុណធម៌ គឺកតញ្ញូ កតវេទី ដើម្បីឡើងតតាំងជាមួយយក្សឲ្យព្រមចុះចាញ់ ដើម្បីដោះលែងព្រះម៉ែដែល ត្រូវយក្សជាន់រាប់ពាន់ឆ្នាំនោះ។

**ឃ**/.ស្ត្រីដែលនៅខាងក្រោមជើងយក្ស តំណាងឲ្យព្រះម៉ែមហានគរ ដែលបានប្រព្រឹត្តខុស ក្នុងឋានក្រុងរាពណ៍ (ព្រះបាទទសកណ្ឋ ឬទសមុខ)នេះ ត្រូវបានយក្សចាប់ជាន់ ពីត្រឹមកទៅដល់ខាងក្រោម (និមិត្តរូបនាគខ្មែរមានតែក្បាល) ហើយគាត់បានបែងភាគ៤ជាន់ ដើម្បីលួចឡើងមកជួបកូននាគ សម័យមុនជួយចង្អុលផ្លូវដឹកនាំនគរ ឲ្យបានរុងរឿង (បិសាចពស់) អាចទៅដល់កំពូលនៃអារ្យធ

មិ។ តែក្រោយមក គាត់ពុំអាចចេញ ពីឃុំរួចទៀតឡើយ ព្រោះយក្សបាន ថែមសោចាក់គាត់កាន់តែច្រើន ធ្វើឲ្យកូននាគសម័យក្រោយ លែងដឹងពីអាថ៌កំបាំងមេនាគ ព្រមទាំងសត្វករវិកដ៍ច្រើន បំពេបំភ័ន្តស្មារតី ថែមពីលើទៀត ធ្វើឲ្យកូនខ្មែរ ឬកូននាគបានដើរបញ្ច្រាសសាសនព្រះម៉ែមហានគរ ដែល ជាមេនាគទីពីរ និងបញ្ច្រាសឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ដែលជាមេនាគទីបី (ពន្យល់ក្នុងមង្គលទី៣ ភាគមុន) នៅក្នុងទំនាយថ្ងៃសុក្រ ថ្ងៃសៅរ៍ ដូនតាយើងបានទុកប្រស្នាកំបាំងក្នុងវគ្គមួយថា៖

ឱះឱអាសូររាជសីហ៍សត្វ សព្វថ្ងៃជ្រកបាត់ក្នុងហេមពាន្ត
មិនឃើញអ្នកចេញមកទូន្មាន ឬរអាក់អន់អៀនដំណើរអ្វី?
ឬមួយឃើញបឹងរឹងហែងហួត ពិរុណរាំងស្ងួតវិនាសត្រី
ឬឃើញស្មាពីរលើឃ្លាងបី ទើបបានអ្នកថ្លៃមិនចេញមក
បាត់សូន្យយ៉ាងហ្នឹងដឹងយ៉ាងណា ឬចាំអាចារ្យទៅតាមរក
ឬមួយគ្មានម្លប់នឹងឈប់ជ្រក ទើបកែវពន្លកមិនមកអាយ។
ម្តេចអ្នកមិនអាសូរសព្វសត្វ រង់ចាំពេកក្តាត់លំបាកកាយ
សព្វថ្ងៃគ្មានសោះហៅសប្បាយ ព្រួយណាស់ហើយណាយឥតឧបមា។
ហែជនទាំងឡាយចូរស្តែងស្តាប់ អស់អាថ៌សារសព្វគ្រប់ប្រការ
ពីលោកអ្នកប្រាជ្ញចែងចរចា ចោទចងប្រស្នាដោយប្រាជ្ញប្រាណ។
ព្រោះដោយបានដឹងដំណឹងច្បាស់ ប្រាកដជាក់ណាស់ទើបនិទាន
ឲ្យអស់អ្នកផងទើបបានហ៊ាន អ្នកអើយគ្រប់ប្រាណស្តាប់ប្រស្នា។
នេះឯងឲ្យដឹងបានច្បាស់ជាក់ បើដឹងហើយអ្នកកុំចរចា
រង់ចាំមើលទៅតាមសាសនា ធម្មតាសាសនាខ្មែរមិនសូន្យ។
វិស័យស្រមោលមិនចោលប្រាណ ស្រីង្គារក្នុងឋានមិនបង់ខ្លួន

រីឯដង្កៅមិនចោលក្បួន មាតានិងកូនមិនដែលបង់។
អ្នកអើយពុំហើយគួររំពឹង ទប់ចិត្តឲ្យនឹងទាត់ទៀងត្រង់
ណាៗអ្នកកុំចោលព្រះសង្ឃ ខ្ញីឃ្មុតតម្រង់កុំតាមគេ។
ត្បិតរាជ្យឥឡូវខុសសណ្ដាប់ ក្រពើលង់ស្លាប់ក្នុងទន្លេ
មច្ឆាខ្លាចបឹងអ្នកដឹងទេ កូនខ្លាខ្លាចមេភេខ្លាចត្រី។
អន្ទង់ខ្លាចភក់កុកព្រីបឹង ស្វាក្រេះក្រញឹងចេះស្រដី
ឈើធំមួយដើមបង្អោងបី ទិវាប្រុសស្រី**ស្រឡាញ់ប្រេត**។
សំបកឃ្លោកលិចក្នុងទឹកស្រែ អំបែងបែកប្រែជាអណ្ដែត
នេះហើយហៅកើតកោលាភេទ ផ្គរលាន់ខែចេត្រភ្លៀងលិចស្រុក។
លិចស្រែចំការច្បារដំណាំ លិចព្រៃទាំងប្រាំត្រពាំងថ្លុក
ទើបត្រីទាំងឡាយសប្បាយសុខ ស្បៀយទុក្ខរីកមុខដោយសារភ្លៀង។
ភ្លើងភ្លឺបំផ្លុងកណ្ដាលព្រៃ រោលរាលដល់ន័យស្រីមានរាង
សំពត់ពេញដីស្រីមិនលាង ព្រោះឃើញទឹកភ្លៀងពីលើភ្នំ។
សេចក្ដីចំណោទអស់នេះណា ថែងតាមប្រាជ្ញាគិតផ្សែផ្សំ
លើកតាមហេតុភេទបុរីរម្យ កើតខុសក្រិតក្រមទំនៀមខ្មែរ។
ជំពូកមួយទៀតខ្ញុំគិតថា ចង់ដឹងប្រាជ្ញាអ្នកស្រុកស្រែ
ក្រែងមានលោកណាប្រាជ្ញពូកែ អាចកត់បកប្រែស្រាយដឹងទៅ។

អាថ៌កំបាំងកំណាព្យប្រស្នានេះ មកទល់នឹងសព្វថ្ងៃ មិនទាន់ឃើញអ្នកប្រាជ្ញណាមួយ អាចស្រាយបំភ្លឺពន្យល់បាននៅឡើយ ត្បិតយើងមើលឃើញរាក់ ក៏ប៉ុន្តែមានន័យជ្រៅ ព្រោះវាសុទ្ធតែកើត

ចេញពីគតិបណ្ឌិតកូននាគសម័យមុន ដែលលោកមានចក្ខុវិស័យ អាចយល់ដល់សន្ដានចិត្តមនុស្ស សម័យក្រោយ នៅការវិវឌ្ឍន៍ផ្នត់គំនិតចរិយាមារយាទ គុណធម៌ និងផ្លូវចិត្តខាងក្នុង។

**ង**/.ផ្កាឈូកតំណាងឲ្យបញ្ញាក្នុងព្រះពុទ្ធសាសនា តទៅអនាគតខាងមុខរបស់គាត់ (ពន្យល់រួចហើយ)។ សរុបសេចក្តីមកអត្ថន័យភាសាគំនិតក្នុងរូបនេះ ក៏មិនខុសពីអត្ថន័យក្នុងរូបមុនដែរ គ្រាន់តែពួកគាត់បានឆ្លាក់រូបមុនព្រះម៉ែមហានគរ ត្រួតៗគ្នាបួននាក់ ឯក្នុងរូបនេះ គាត់បែងភាគក្នុងរូបមួយទៅជាបួន ព្រោះគាត់ខ្លាចយើងមើលរូបនេះពុំយល់ គាត់ឲ្យទៅមើលក្នុងរូបមុនដោយវាងាយស្រួលមើលជាង។

## ២១/.រូបភាពទី២១រូបក្មេងស្រី(ជនជាតិមន)



រូបភាពនេះ បង្ហាញពីក្មេងស្រីជនជាតិភាគតិចមន ដែលមានពាក់កងដក "ក" ឲ្យវែង ហេតុអ្វីក៏ខ្ញុំត្រូវយករូបនេះមកពន្យល់? តើវាមានទាក់ទងអ្វី ទៅ នឹងអាថ៌កំបាំងមាតាមហានគរ? ពាក្យថាជនជាតិមន ឬខ្មែរមន គឺជាអំបូរជនជាតិមួយរួមគ្នាពីអតីតកាល តើពាក្យមនមានន័យដូចម្ដេច? មន = មនៈ ឬមនសិការ ⇨ ការធ្វើទុកក្នុងចិត្ត ការកំណត់ទុកក្នុងចិត្ត ដំណើរយកចិត្តទុកដាក់ (វចនានុក្រមសម្ដេចព្រះសង្ឃរាជ**ជួន ណាត**)។

ក្នុងរូបភាពទី៥ និងទី៦ ដែលខ្ញុំបានពន្យល់រួចហើយ ពីមាតាបានត្រូវយក្សដាក់ទណ្ឌកម្ម កប់ត្រឹមក ឬយក្សលេបទៅដល់ "ក" ដូច្នេះស្ត្រីមន ដែលជាកូនគាត់ពីអតីតដែរនោះ ត្រូវទទួលរងនូវបាបនេះ ដូចរូបគាត់ដែរ ដើម្បីបំពេញកិច្ច ជាកូនកត្តញ្ញូកតវេទី ស្ត្រីមនត្រូវពាក់កងដកកឲ្យវែង ដើម្បីតំណាងឲ្យមាតាអាចដក "ក"

បានវែង មើលមកមាតុភូមិខ្លួនឃើញ។ ជាតិជាស្ត្រីរាល់រូប មិនថាជាតិណាៗឡើយ តែងស្រឡាញ់រូបសម្រស់របស់ខ្លួន តែអនិច្ចាអ្វី តែជនជាតិនេះ ត្រូវពាំនៀរកម្មពីអតីត ត្រូវពាក់កងដកកឲ្យវែងដូចជាកកុកយ៉ាងនេះ? នេះជាហេតុប្រស្នាអាថ៌កំបាំងមួយរបស់ស្ត្រីជនជាតិភាគតិចនេះ ដែលបានបំពេញពលិកម្មបន្តគ្នា រាប់ជំនាន់មកហើយ ទោះបីមកទល់សព្វថ្ងៃ ក៏ត្រូវតែពាក់កងដកក ដើម្បីបំពេញកិច្ចជាកូនកតញ្ញូកតវេទី ហើយអត្ថន័យជាតិមននេះ មកពីពាក្យមនសិការនេះឯង។ ចំណែកឯយើងវិញក៏មានពាក្យមននេះដែរ គឺអ្វី? ឈ្មោះតំណាងឲ្យរុក្ខជាតិមួយបែបគឺ ដើមមន តើដើមមនសម្រាប់ធ្វើអ្វី? ស្លឹកមនគេសម្រាប់យកមកឲ្យដង្កូវនាងស៊ី ដង្កូវនាងបង្កើតសំបុកៗគេស្រាវយកមកធ្វើសសៃរសូត្រ សូត្រគេត្បាញគោមហូល តំណាងឲ្យស្រកានាគ (ពស់) ហូលស្ត្រីខ្មែរស្លៀកដណ្តប់ទូទាំងប្រទេស ដូចនេះមាតានាគនៅព័ទ្ធថែរក្សា មាតុភូមិរបស់គាត់រាល់ថ្ងៃ តើស្ត្រីស្លៀកពាក់ហូល មានដឹងអាថ៌កំបាំងនេះទេ? រីឯដង្កូវនាងខំធ្វើសំបុក ដើម្បីឲ្យគេហូតយកសសៃសូត្រនោះ បានត្រឹមតែធ្វើពលិកម្ម គឺត្រូវដេកស្ងោរក្នុងទឹកក្តៅតែប៉ុណ្ណោះ នេះគឺជាបាបកម្មរបស់គាត់ (និមិត្តរូបមាតានាគ)។ នេះជាប្រស្នាពាក្យ ដង្កូវនាង (នាងនាគ) ពាក្យថាមន (ដើមមន) និងពាក្យសម្គាល់ជនជាតិមន (មនសិការ) ដែលជាអំបូររួមជាតិគ្នាពីអតីត ព្រោះពាក្យមននៅក្នុងប្រវត្តិសាស្ត្រខ្មែរ អ្នកប្រាជ្ញជំនាន់មុនបានពន្យល់ផ្សេង តែខ្ញុំពុំយល់ដូចពួកគាត់ឡើយ ព្រោះទំនៀមទម្លាប់របស់ជនជាតិនេះ ពាក់កងដកក វាទាក់ទង និងអាថ៌កំបាំងព្រះមាតាមហានគរ ដែលខ្ញុំបានបកស្រាយពន្យល់ដោយសង្ខេបខាងលើ ព្រោះពួកគេសុខចិត្ត លះបង់សោភ័ណភាពរបស់ខ្លួនមួយជីវិត ដើម្បីកេរដំណែលដូនតា គឺបំពេញកតញ្ញូកតវេទី។

## ២២/.រូបភាពទី២២រូបព្រហ្មត្រូវគ្រុឌចងត្បៀង(នៅប្រាសាទបាយ័ន)



មុខព្រហ្មនេះ ខ្ញុំបានពន្យល់ក្នុងភាគមុនរួចហើយ ដែលខ្ញុំយកមកពន្យល់ក្នុងភាគទីបី គ្រាន់តែចង់ឲ្យមិត្តអ្នកអាន ដែលជាកូននាគប្រៀបធៀបរូប ដោយខ្ញុំបានពន្យល់រួចហើយ។ យើងដឹងហើយថា ព្រហ្មជាសត្វបដិសន្ធិនៅក្នុងរូបព្រហ្ម ដោយអំណាចរូបាវចរឈាន (បឋមឈាន....ចតុត្ថជ្ឈាន) ហើយព្រហ្មនេះទៀតសោត គឺគ្មានភេទទេ (មិនមែនប្រុសមិនមែនស្រី) សោយអាហារ គឺបីតិ (ក្នុងគម្ពីរពុទ្ធសាសនា) តែយើងឆ្ងល់ហើយសួរខ្លួនឯងថា ហេតុអ្វីព្រហ្មខ្មែរមានតែក្បាល ហើយនៅលើក្បាលព្រហ្មនោះ មានសត្វគ្រុឌ ដែលជាសត្វតិរិច្ឆាន ឈរជើងត្របែង (ត្បៀង) ស្រាក់ដៃគ្នានៅជុំវិញសង្កត់ពីលើព្រហ្មទៅវិញ? នេះជាប្រស្នាកំបាំងបង្កប់ក្នុងរូប ដែលខ្ញុំបានពន្យល់រួចហើយ នៅរូបភាពទី១៧ ១៨ និយាយពីខ្លោងទ្វារប្រាសាទបន្ទាយក្ដី និងប្រាសាទតាព្រហ្ម។ ដូចនេះមាតាមហានគរ លោកចង់ពន្យល់បង្ហាញប្រាប់យើង ជាកូននាគប្រុសស្រី ឲ្យបានយល់ថា ទោះបីជាមាតាបិតាមហានគរលោកចម្រើនសមាធិភាវនាបាននូវផលសមាបត្តិ ជាលោកិយយ៉ាងណាក្ដី ក៏ចិត្តរបស់ពួកគាត់នៅជាបុថុជ្ជន (មិនមែនព្រះអរិយ)។ ព្រោះលោភមូលចិត្ត៨ដួង គឺនៅពេញដដែល ធ្វើឲ្យពួកគាត់ត្រូវសំយ៉ុងចិត្តចុះទៅរកអកុសល ជាដាច់ខាត នេះជាហេតុធ្វើឲ្យពួកគាត់ជាប់ក្នុងទោស ព្រោះការប្រកាន់មាំ ថាខ្លួនជាព្រះមេ ជាព្រះម៉ែ ជាប្រមុខ ជាម្ចាស់នគរ (ប្រកាន់មាំក្នុងឧបាទានក្ខន្ធ៥)។

# ២៣/.រូបភាពទី២៣រូបព្រហ្ម(នៅបាយ័ន)



មុខព្រហ្មនេះ ក៏ស្ថិតក្នុងប្រាសាទបាយ័នដែរ នៅជ្រុងប្រសព្វត្រចៀកព្រហ្ម មានរូបឥសីពាក់កណ្ដាលខ្លួនមួយ គឺតំណាងឲ្យបិតាមហានគរ ដែលខ្ញុំបានពន្យល់ក្នុងរូបទី១២ រួចហើយ។ ចំណែក នៅជាប់ត្រចៀកព្រហ្ម មានរាង ជាក្បាច់កន្ទុយហង្ស គឺតំណាងឲ្យ ទ្រនុងខ្នងនាគ ដែលខ្ញុំបាន បកស្រាយពន្យល់រួចហើយ ក្នុងរូបទី១២ រីឯនៅកព្រហ្មមានក្រយៅរង្វង់ បន្តគ្នាគ្រប់ៗកព្រហ្មនោះ គឺតំណាងឲ្យទោសរបស់ពួកគាត់ត្រូវយក្សលេបមកដល់ត្រឹមក (ពន្យល់ហើយក្នុងរូបទីមួយ)។ ហេតុដូចនេះ មាតាបិតា និងកូនគាត់ គ្រប់ជំនាន់មកខាងក្រោយ ត្រូវទទួលទោសពីយក្សមិនឲ្យងូតទឹក ជាងពីពាន់ឆ្នាំហើយ គាត់ខ្លាចក្រែងយើងមើលអាថ៌កំបាំងនេះពុំយល់ ទើបគាត់បានឲ្យកូននាគទី៧ (ជ័យវរ្ម័នទី៧) កសាងលានព្រះគម្ពង់ទុក ព្រោះរឿងរ៉ាវចុងក្រោយក្នុងទីលាននេះ គេបានឆ្លាក់មនុស្សប្រុសស្រី អេះរមាស់ ដែលមិនបានងូតទឹករាប់ពាន់ឆ្នាំកន្លងមកនោះ ស្នាមអេះបានមុតចូលជ្រៅៗ ទៅក្នុងដងខ្លួនមនុស្សក្នុងចម្លាក់ថ្ម ដូចជាស្នាមក្រចកអេះយ៉ាងដូច្នោះ។ នៅគ្រប់ថ្ងាសព្រហ្ម គឺមានភ្នែកមួយចំកណ្ដាល គាត់ចង់ប្រាប់កូននាគជំនាន់ក្រោយថា ត្រូវមើលរឿងគាត់ក្នុងថ្ងាស មានន័យថា ចេះត្រិះរិះគិតពិចារណា (កុំមើលតែនឹងភ្នែក គឺត្រូវមើលនឹងថ្ងាស) ទើបដឹងរឿងរបស់ពួកគាត់។

សរុបសេចក្ដីមកហេតុផលភាសារូប ដែលខ្ញុំបានបកស្រាយពន្យល់ដោយសង្ខេបនេះ ដូចជាការពន្យល់រៀបរាប់ខាងលើ ព្រោះជារឿងរបស់ព្រហ្មម៉ែព្រហ្មឪ គាត់ពុំបាននិយាយរឿងព្រហ្មញ្ញសាសនាឡើយ គឺពួកគាត់និយាយតែពីរឿងក្នុងចិត្តព្រហ្ម។

## ២៤/.រូបភាពទី២៤រូបមុខព្រហ្ម (ប្រាសាទបន្ទាយឆ្មារ)



ប្រាសាទនេះ ស្ដេចជ័យវរ្ម័នទី៧ លោកកសាងឡើង ដើម្បីឧទ្ទិសឲ្យកូនរបស់គាត់ ពាក្យថាកសាងឡើង ដើម្បីឧទ្ទិសឲ្យកូនរបស់ គឺមានន័យថា កូនខ្មែរគ្រប់ជំនាន់គ្រប់កាល គ្រប់សម័យខាងក្រោយ បើចង់ដឹងរឿងពិតរបស់ខ្លួន ត្រូវទៅមើលភាសារូប ក្នុងប្រាសាទនេះ នោះនឹងអាចដឹងអាថ៌កំបាំងខ្លួន ជាកូនពុំខានឡើយ។ រូបភាពមុខព្រហ្មនេះ គឺជាសំណល់ ដែលសល់ពីការបំផ្លាញ របស់ពួកជនទុច្ចរិត ព្រោះតែប្រាក់ គាត់សុខចិត្តខ្ទេះបេះដូង យកទៅលក់ឲ្យជនបរទេស ទីបំផុតប្រាសាទដ៏ធំស្កឹមស្កៃមួយ ត្រូវបានបំផ្លាញស្ទើររាបដល់ដី បើកុំតែប្រាសាទនេះ រលំបាក់បែក ម្ល េះសមទេសចរណ៍ ត្រូវយកប្រាក់ទៅចាយក្នុងទីនោះដ៏ច្រើន ដើម្បីទស្សនា និងធ្វើការសិក្សាស្វែងយល់។ មុខព្រហ្មនេះ ក៏មានមនុស្សអង្គុយនៅពីលើក្បាល វាខុសពីព្រហ្មនៅបាយ័ន ព្រោះព្រហ្មបាយ័ន សត្តិរច្ឆានឈរតៀងពីលើ (គ្រុឌនិមិត្តសញ្ញាសៀម) ចំណែកឯមុខព្រហ្មបន្ទាយឆ្មារវិញ (បន្ទាយតូច) គឺជាមនុស្សស្រីអង្គុយលើកដៃសំពះ ជុំវិញក្បាលព្រហ្ម មិនដឹងមានចំនួនប៉ុន្មាន ព្រោះបាក់បែកអស់។ នៅចន្លោះត្រចៀកព្រហ្ម ក៏មានរូបមនុស្សអង្គុយគ្រប់ជ្រុងទាំងបួនដែរ ប៉ុន្តែបានបាក់បែកអស់ ដោយរូបភាពនេះ បានបាត់បង់ភាពដើមអស់ទៅហើយ ខ្ញុំអ្នកស្រាវជ្រាវភាសាគំនិតបង្កប់ក្នុងរូប ពុំអាចបកស្រាយពន្យល់ពីអាថ៌កំបាំង របស់ពួកគាត់ក្នុងរូបថ្មទាំងនេះបានឡើយ ព្រោះភាសារូបស្ថិតក្នុងសកម្មភាពក្នុងថ្ម ពុំមែនយើងចេះតែបកស្រាយឲ្យខុសពីរឿងរ៉ាវក្នុងថ្មបានឡើយ។ ហេតុនេះ ទើបគាត់

កសាងប្រាសាទថ្មទុករាប់ពាន់ ដើម្បីឲ្យកូននាគសម័យខាងក្រោយ មើលរួចត្រិះរិះពិចារណា ពីរឿងក្នុងប្រាសាទមួយ ទៅឆ្លុះបញ្ចាំងរឿងក្នុងប្រាសាទមួយទៀត ពីជំនាន់មួយ នឹងទៅជំនាន់មួយ។ ហើយពួកគាត់បានដឹងជាមុនថា នៅសម័យខាងក្រោយ ពួកបរទេសខាងក្រៅ រួមទាំងកូននាគដែលពុំយល់ច្បាស់ជាបំផ្លាញរឿងខាងក្នុងប្រាសាទ ជាពុំខាន ពេលដែលគាត់នៅអាចលួចចេញពីគុកមកខាងក្រៅបាន គាត់បានប្រាប់កូននាគសម័យនោះ ឲ្យកសាងប្រាសាទ ឆ្លាក់រឿងរ៉ាវរបស់គាត់ទុកឲ្យបានច្រើនពាន់ប្រាសាទ ព្រោះបើគេបំផ្លាញមួយក៏នៅសល់មួយដែរ យ៉ាងហោចណាស់ ក៏អាចសល់រូបភាពខ្លះ ពេលដែលគាត់ដល់កាលវេលាបញ្ចប់នូវបាបកម្ម (ដល់កំណត់នៃទោស) ក៏គង់មានកូននាគណាមួយគេមើលយល់អាថ៌កំបាំងក្នុងថ្មទាំងនេះ ហើយគេអាចជួយពួកគាត់ឲ្យរួចពីទោសបាន។

## ២៥/.រូបភាពទី២៥រូបយក្សបែងភាគមើលពីចំហៀងនិងចំពីមុខ(នៅប្រាសាទបន្ទាយឆ្មារ)



រូបភាពនៅលើជញ្ជាំងប្រាសាទនេះ គឺមានក្មេងតូចម្នាក់ កំពុងអង្គុយលើបាតដៃយក្ស ក្មេងតូចនេះហើយ ដែលតំណាងឲ្យឈ្មោះប្រាសាទបន្ទាយឆ្មារ ព្រោះពាក្យឆ្មារ = តូច ហេតុអ្វីបានជាក្មេងតូចនេះ អាចអង្គុយលើដៃយក្សបាន? ព្រោះក្មេងតូចនេះហើយ ដែលជាកូននាគ ត្រូវមកបំពេញនៅគុណធម៌រួចឡើងតាមដៃយក្សទាំង**១៦** ដែលចង្អុលទៅខាងលើ គាត់ត្រូវព្យាយាមឡើងទៅដាន់លើក្បាលយក្ស ដើម្បីឲ្យយក្សព្រមចុះចាញ់ រួចដោះលែងមាតាបិតាមហានគរ (ប្រស្នាកំបាំងក្នុងរូបនេះ ខ្ញុំបានពន្យល់រួចហើយក្នុងរូបទី១៩ និងទី២០) ចេញពីអំណាចឃុំរបស់ខ្លួន។ ហើយនៅជុំវិញសង្វាងយក្ស

មានមនុស្សប្រុសស្រីលើកដៃហាក់បីដូចជាសំពះ **៦**នាក់ និងម្នាក់ទៀតលើកដៃទ្រវត្តម្យ៉ាង តើតំណាងឲ្យអ្វី? ដែលមនុស្សទាំង៦នាក់ លើកបាតដៃទាំងពីរផ្ងារឡើង គឺគាត់ចង់ឲ្យយើងមើលរឿងក្នុងបាតដៃ (មើលការពន្យល់ក្នុងរូបភាពទី១១) ហើយចំណែកឯមនុស្សម្នាក់ទៀតលើកដៃទ្រវត្តនោះ គឺតំណាងឲ្យការអង្វរចំពោះក្មេងតូចខាងលើ ជួយយកកែវភ្នែកមកឲ្យពួកខ្លួនវិញ ព្រោះពួកគាត់ទាំង៧នាក់នេះ តំណាងឲ្យទេពធីតា ដែលមកហែក្បាលម៉ែឪ (ព្រហ្ម) រាល់ៗឆ្នាំនោះ។ ចំណែកដៃម្ខាងទៀតរបស់យក្សកាន់ផ្កា ឬពួច (មើលរូបចំពីមុខ) អត្ថន័យក៏ខ្ញុំបានពន្យល់រួចហើយក្នុងរូបទី១៩ និង២០ ឯរូបទាំង៧នៅខាងឆ្វេងដៃយក្សនេះ អត្ថន័យរូបក៏មិខុសពីរូបនៅខាងស្តាំដៃយក្សដែរ គ្រាន់តែរូបខាងឆ្វេងអ្នកលើកដៃសំពះដាន់ខាងក្រោម ខុសពីខាងស្តាំ គឺរូបខាងស្តាំលើកដៃទ្ររបស់ម្យ៉ាង។ នៅពីក្រោមជើងយក្សមានប្រអប់ក្បាក់មួយ ដែលប្រអប់នេះ ជានិមិត្តរូបទុកនូវកែវភ្នែក មាតាទាំង**១២** ហើយប្រអប់នេះអាចយកបាន ទាល់តែយក្សនោះរលំ ឬព្រមចុះចាញ់។ នៅម្ខាងទៀតខ្លោងទ្វារ ក៏មានរូបយក្សឈរបែងភាគដៃដូចគ្នា ប៉ុន្តែខុសត្រង់នៅសង្ខាងយក្ស មានរូបម៉ែ និងឪ កំពុងជាប់ក្នុងរង្វង់សីមារបស់យ



ក្ស ហើយរង្វង់សីមាដែលឃុំម៉ែ ឪនោះ កំពុងអណ្តែតឡើងទៅលើម្តងបន្តិចៗ ដោយអំណាចបារមីរបស់ក្មេងតូច ដែលនៅលើបាតដៃយក្សនោះ គាត់បានបំពេញនូវគុណធម៌រកម៉ែឪ ទៅដាក់លើ

កំពូលព្រះវិហារវិញ (មើលការពន្យល់ក្នុងភាគ២ភ្នំដងរែកក្នុងប្រាសាទព្រះវិហារ) ព្រោះក្មេងតូចនោះទីបំផុតនៃរឿងគាត់អាចតតាំងច្បាំងនឹងយក្ស រហូតដល់ឈ្នះ រួចជាន់យក្សឲ្យក្អែនៅរឿងទាំងអស់ដែលយក្សបានលេប (អាចិកំបាំងពាក្យកូនរាហ៍កន្លង) នោះ ឲ្យចេញមកខាងក្រៅវិញ។

សរុបសេចក្តីមក រូបភាពនៅកំពែងប្រាសាទបន្ទាយឆ្មារ គឺបានបង្ហាញពីឈ្មោះរបស់ប្រាសាទនេះតែម្តង រឿងក្នុងបន្ទាយដែលនៅសេសសល់នេះ បានរៀបរាប់ពីសកម្មភាព របស់ក្មេងតូចម្នាក់ដែលហ៊ានតតាំងនឹងយក្សជាម្ចាស់ពៀរ ដែលចាប់ព្រះមាតាបិតាយកឃុំពីអតីតកាលនោះ ឲ្យលោកមានសេរីភាពឡើងវិញ ដោយអំណាចគុណធម៌ គឺកតញ្ញូកតវេទី។

## ២៦/.រូបភាពទី២៦រូបយក្សដួលរលំជញ្ជាំងកំពែងខាងក្រៅ (ប្រាសាទបន្ទាយឆ្មារ)



រូបភាពនៅលើជញ្ជាំងកំពែង ខាងក្រៅប្រាសាទបន្ទាយឆ្មារ ជាបន្តនេះបានបង្ហាញពីសកម្មភាពមនុស្សប្រុសម្នាក់ជិះរទេះ ដៃម្ខាងកាន់ប្រអប់គ្រាប់ភ្នែកម្តាយទាំង១២ ហើយបន្តមកទៀត គឺគាត់ទៅតតាំងច្បាំងនឹងយក្សធាក់យក្សឲ្យដួល ផ្ងារទៅក្រោយ នៅទីបំផុតយក្សនោះ ត្រូវរលំដេកដួលនៅលើ

ដី។ នៅពេលដែលយក្សដេកពោបនៅលើដី យក្សបានក្អែចេញនូវព្រះគោព្រះកែវព្រមទាំងក្បួនគម្ពីរទាំងឡាយនៅលើរទេះ ដែលខ្លួនបានលេបពីអតីតកាលនោះឲ្យចេញមកក្រៅម្តងមួយៗ ទីបំផុតកូននាគប្រុសស្រីតទៅថ្ងៃអនាគត លែងត្រូវរាហ៍កន្លងឬបិទបាំងពន្លឺរស្មីបញ្ញាទៀតហើយ គឺបានន័យថា ឈប់នៅក្នុងអំណាចឃុំខាងក្នុងពោះយក្ស (កូនរាហ៍កន្លង)។

សរុបសេចក្តីមក រូបភាពនៅកំពែងជញ្ជាំងប្រាសាទបន្ទាយឆ្មារ ដែលនៅសេសសល់នេះ បានបើកបង្ហាញ ពីអនាគតកាលរបស់កូននាគប្រុសស្រី កំពុងរស់នៅក្នុងមាតុភូមិនេះ ឲ្យបានដឹងពីសាវតាពិតរបស់ខ្លួន ដែលដួងកែវមាតាបានប្រតិស្ថានទុកក្នុងថ្ម (សិលាចារឹក) ដែលពីមុនយើងតែងនាំគ្នាយល់ថា វាជារឿងរបស់សាសនា "**កុំជឿអ្វីដែលថាតគ្នា កុំជឿអ្វីដែលពុំទាន់បានពិចារណា មុននឹងជឿទៅលើអ្វីមួយ ត្រូវត្រះរិះពិចារណារាវរកហេតុផលសិនសឹមជឿ ព្រោះយើងជាបុត្រដែលកេតចេញពីមាត់របស់ព្រះសម្មាសម្ពុទ្ធជាមេនាគទីបី (ពន្យល់ហើយក្នុងភាគពីរ)**" ។

## ២៧/.រូបភាពទី២៧រូបក្នុងក្បាំងក្លែង(ប្រាសាទបន្ទាយសំរែ)



នៅក្នុងរូបភាពនេះបានបង្ហាញពីមនុស្សចំនួនបួនថ្នាក់ ហើយនៅក្នុងជាន់ថ្នាក់និមួយៗ មានសកម្មភាពរូបផ្សេងៗគ្នា ជាន់ក្រោមមានមនុស្សមួយជួរកំពុងតែលើកដៃសំពះ ជាន់ទីពីរមានក្រុមឥសីជាន់ទីបីមានមនុស្សជាប់ក្នុងរង្វង់សីមា ជាន់ទីបួនមានរូបស្ត្រីលើកដៃសំពះមានរូបពាក់កណ្ដាលខ្លួននិងស្ត្រីទេពអប្សរកំពុងហោះ តើរូបក្នុងជាន់និមួយៗគាត់ចង់និយាយប្រាប់យើងពីរឿងហេតុអ្វី?

**ក**/.ជាន់ទីមួយ រូបស្ត្រីពាក់មកុដ នឹងលម្អដោយគ្រឿងអលង្ការផ្សេងៗ អង្គុយដង្ហែគ្នាកំពុងលើកដៃសំពះនោះ គឺតំណាងឲ្យមាតាទាំងដប់ពីរ ហើយដៃលកន្លងមកត្រូវម្ដាយនាងកង្រីឈ្មោះ សន្ធមារ (យក្ស) ខ្វេះយកកែវភ្នែកអស់ចំនួនដប់មួយកន្លះ (មើលរឿងព្រេង)។ ដូច្នេះធ្វើឲ្យពួកគាត់ ងងឹតមើលអ្វីមិនយល់រហូតទល់នឹងសព្វថ្ងៃនេះ ហើយក្នុងចំណោមកែវភ្នែកទាំងដប់មួយកន្លះ ដែលត្រូវយក្សសន្ធមារខ្វេះយកទៅនោះ សព្វថ្ងៃនៅសល់តែកែវភ្នែកមួយចំហៀងតែប៉ុណ្ណោះ ទើបក្នុងសកម្មភាពរូបនេះបានបង្ហាញថា ពួកគាត់កំពុងសំពះអង្វរឲ្យអ្នកណាមួយមកជួយយកកែវភ្នែកឲ្យពួកគាត់វិញព្រោះហេតុតែគ្មានកែវភ្នែក សូម្បីតែកូនខ្លួនឯងក៏ហែកចែកគ្នាបរិភោគដែរ (មើលការពន្យល់ក្នុងភាគពីរ ពីប្រាសាទនាងដប់ពីរ)។

**ខ**/. ជាន់ទីពីរ មានរូបឥសីប្រាំនាក់ កំពុងអង្គុយបត់ជើង ហើយនៅខាងក្រោយឥសីខាងស្ដាំមានមនុស្សឱនលើកដៃសំពះ និងមានសត្វរមាំង ឬក្ដាន់មួយកំពុងតែដេកពោបងាកក្បាលទៅក្រោយ ឯខាងឆ្វេងដៃឥសីខាងក្រោយក៏មានមនុស្សអង្គុយសំពះដែរ ហើយរូបដែលនៅក្រោយមនុស្សសំពះនោះយើងមើលពុំយល់ថាជារូបអ្វីឡើយ តើរូបទាំងអស់នេះ ព្រឹទ្ធដូនតាគាត់ចង់និយាយពីអ្វី?

ឥសីទាំងប្រាំនោះ គឺតំណាងឲ្យពូជឥសីកម្ពុ (ព្រះថោង ហ៊ុនទៀន កៅណ្ឌិន...) ដែលជាអ្នកបួសខាងក្រៅព្រះពុទ្ធសាសនា ដែលបានសម្រេចឈានសមាបត្តិតែជាមច្ឆាទិដ្ឋិ ព្រោះពុំមានមគ្គដែលប្រកបដោយអង្គប្រាំបីជាគោលគឺ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ។ ហើយពួកអ្នកបួសជាឥសីក្រៅពុទ្ធសាសនានេះមានស្ទើរគ្រប់ប្រទេស ខ្មែរ ចិន វៀតណាម សៀម...។ល។ និយាយរួមឲ្យតែពួកគ្រូចេះទស្សន៍ទាយជឿលើឫក្ស មង្គលភ្ជាក់ផ្អើល ដោយអាងលើក្បួនតម្រានោះ ព្រមទាំងមានទុកពុកមាត់ពុកចង្ការវែងៗ ពួកគេនោះគឺជាឥសីហើយពួកឥសីទាំងនោះ មានឫទ្ធិអភិញ្ញាទៅតាមកម្លាំងផលសមាបត្តិដែលខ្លួនចម្រើនបាន។ ចំណែកឯឥសីក្នុងរូបនេះបានបង្ហាញពីលក្ខណសម្បត្តិខុសៗគ្នាទៅតាមកំរិតនៃគុណធម៌របស់ពួកគាត់ដែលជាកូននាគ កំពុងអង្គុយរង់ចាំមាតាបិតាមហានគរ លោករួចពីបាបកម្មចាស់ ឯមនុស្ស

ដៃលអង្គុយលើកដៃសំពះ នៅខាងក្រោយឥសីទាំងសងខាងនោះ គឺពួកគាត់អង្វរលន់តួចំពោះឥសីទាំងនេះ ឲ្យជួយព្រះមាតាបិតាមហានគរ បានចេញរួចពីទុក្ខទោស ដៃលសល់ពីអតីតកាល។

**គ/.** រូបជាន់ទីបីនេះ អត្ថន័យរូបក៏មិនខុសពីរូបទី២៥ដៃលមាននៅលើជញ្ជាំងកំពែងប្រាសាទបន្ទាយឆ្មារ (ពន្យល់រួចហើយ) ព្រោះរូបនេះគេឆ្លាក់ពួកគាត់កំពុងជាប់ឃុំក្នុងរង្វង់សីមា ដៃលមានដៃកាន់ផ្កាឈូក ផ្កាឈូកតំណាងឲ្យនិមិត្តរូបបញ្ញាក្នុងពុទ្ធសាសនា (ពន្យល់ហើយ)។ ទោះបីជាពួកគាត់ឡើងដល់កំពូលក្បាំងខាងលើក៏ដោយ ក៏ពួកគាត់នៅតែជាប់ទោសដដៃល ព្រោះក្បាំងនាគដៃលនៅគ្របពួកគាត់ពីលើនាគទាំងពីរនោះគឺយក្សនៅលេបត្រឹមកដដៃល។

**ឃ/.** រូបជាន់ទីបួននេះ ស្ត្រីពីរនាក់ដៃលមានតែពាក់កណ្តាលខ្លួនកំពុងលើកដៃប្រណម បួងសួងសូមឲ្យមាតាបិតាបានរួចពីទុក្ខទោស (ឲ្យយក្សព្រមដោះលែង) រីឯស្ត្រីកំពុងហោះហើរនោះវិញ គឺជាទេវតាឬអច្ឆរាដៃលសកម្មភាពរូបហាក់ដូចជាលើកយកដុំអ្វីមួយដៃលកំពុង សង្កត់ពីលើសីមានោះចេញ ខ្ញុំពុំអាចមើលយល់បានឡើយ ព្រោះដុំទាំងនោះត្រូវបានបំផ្លាញ បាត់រូបភាពដើមអស់ហើយ។

សរុបសេចក្តីមក រូបភាពដៃលខ្ញុំបានបកស្រាយក្នុងក្បាំងក្លែងនេះអត្ថន័យក្នុងរូបក៏មិនខុសពីរូបមុនៗដៃលបានបកស្រាយរួចហើយនោះទេ ដៃលខ្ញុំលើកយកមកពន្យល់ ព្រោះចង់ឲ្យកូននាគចេះមើលប្រវត្តិរឿងនៅក្នុងថ្ម ទោះបីជាស្ថិតក្នុងសម័យកាលកសាងខុសគ្នា ក៏ប៉ុន្តែអត្ថន័យគំនិតបង្កប់ក្នុងរូប (ថ្ម) គឺនៅតែដដៃលៗទាំងរូបក្នុងប្រាសាទ ដៃលមាននៅក្នុងដៃនដីខ្មែរសព្វថ្ងៃ និងដៃនដីពីអតីតកាលដៃលគេបានដណ្តើមយកទៅ សាច់រឿងគឺនិយាយពីពួកគាត់ជាប់ក្នុងទោស ពួកគាត់កំពុងរួចពីទោសនឹងនិយាយពីពួកគាត់មានសេរីភាពក្លាយជា **អ្នកជា** ដូចដើម (នេះគឺជារឿងបេះដូងរបស់មេនាគចារឹកបង្កប់ទុកក្នុងភាសាថ្ម)។

# ២៨/. *រូបភាពទី២៨ រូបនៅក្នុងក្បាំងក្លែង* (*ប្រាសាទបន្ទាយស្រី*)



*នៅក្នុងសកម្មភាពដ៏រស់រវើកនៃផ្ទាំងចម្លាក់នេះ បានបើកបង្ហាញពីរឿងរបស់មាតាមហានគរ និងពួក ស្ត្រីដែលជាអ្នកទទួលមរតកព្រះមេជំនាន់ក្រោយ ដោយរូបភាពបានចែកចេញជាពីរជាន់ ហើយបែងជាបន្ទប់ៗ តើរូបទាំងនេះមានបង្កប់អត្ថន័យអ្វីខ្លះ?*

*១/. ជាន់ទីមួយខាងក្រោម បង្ហាញពីស្ត្រីទាំងឡាយបានទទួលរងនូវអំពើហឹង្សាដែលបុរសវាយធ្វើបាប ពេលដែលមនោគមវិជ្ជាថ្មីបានលុកលុយចូលទឹកដីព្រះមេ (កុងសង្កត់ម៉ា ឬកុងម៉ា) ក្រៅពីនគរនេះពុំសល់ទំនៀមទម្លាប់លើកស្ត្រីជាធំឡើយ (មេ)។ មានតែនគរនេះមួយគត់ដែលយើងហៅថា* ***មាតុភូមិ*** *គឺជាភូមិ ឬប្រទេសរបស់ព្រះមាតា ឬព្រះម៉ែ (មើលការពន្យល់ក្នុងភាគមួយនិងពីរ) ហើយសព្វថ្ងៃនេះប្រទេសមេ ឬ ម៉ែ (ក្មេរ, ខ្មែរ) នៅសល់តែឈ្មោះប៉ុណ្ណោះ។*

*សកម្មភាពស្ត្រីទាំងអស់ដែលមានក្នុងរូបត្រូវគេរុញបញ្ចូលទៅក្នុងបន្ទប់ គឺមានន័យថាស្ត្រីត្រូវនៅក្នុងផ្ទះគ្រប់គ្រងផ្ទះសម្បែងមិនអាចចេញទៅខាងក្រៅធ្វើជា* ***មេ*** *ទៀតបានឡើយ ដូច្នេះពាក្យ* ***មេ*** *ពីមុននៅសល់ត្រឹមតែឈ្មោះប៉ុណ្ណោះ ដោយហេតុព្រះមេដែលជាប្រមុខពីអតីតនោះត្រូវជាប់ឃុំ និងលុបដានស្នាមអស់ទៅហើយ (មើលក្នុងមង្គលបីភាគពីរ ឬមើលការពន្យល់រូបទីមួយនេះ)។*

២/.ជាន់ទីពីរត្រង់រូបខ្លោងទ្វារកណ្ដាល បានបង្ហាញពីបុរសម្នាក់ពាក់ក្រវិលដូចរូបស្ត្រីគ្រប់លក្ខណ៍ដែលគាត់ជាអ្នកទទួលមរតកម៉ែ ព្រោះក្រវិលដែលគាត់បានពាក់គឺក្រវិលម៉ែ ដៃគាត់ម្ខាងកាន់ដំបងលើកឡើងបំរុងនឹងវាយ ដៃម្ខាងទៀតបួងសក់ស្ត្រីដែលដួលនោះ ឯជើងម្ខាងបុរសនោះជាន់ធាក់ បានបង្ហាញឲ្យដឹងថាកូននាគសម័យខាងក្រោយអរិយធម៌ថ្ម លែងគោរពនិងទទួលស្គាល់មហិទ្ធិឫទ្ធិមាតាមហានគរទៀតហើយ (បិសាចពស់)។ ដោយសកម្មភាពរូបនេះបានបង្ហាញពីការធ្វើទារុណកម្មផង ជេរប្រមាថផង ដោយខ្លួនជាអ្នករស់ក្នុងភូមិម៉ែទទួលកេរពីម៉ែ ពុំបានតបស្នងនូវសេចក្ដីល្អដែលអ្នកមុនបានធ្វើចំពោះខ្លួន (ក្រធ្វើដឹង ក្រ+ពើ ពន្យល់រួចហើយក្នុងភាគមួយ)។ រូបខ្លោងទ្វារបន្ទប់នេះគឺធំជាងខ្លោងងសងខាង ដូចនេះរូបស្ត្រីកណ្ដាលគឺតំណាងឲ្យស្ត្រីដែលជាប្រមុខនៃពូជកេរមេ និងពូជកេរម៉ែ ហើយនៅខាងក្រោយរូបគាត់មានរូបស្ត្រីតូចៗ នោះតំណាងឲ្យភាពបាត់បង់សិទ្ធិរបស់ព្រះមេជំនាន់ក្រោយៗ ព្រោះមានបន្ទះរាងដូចជាខ្សែ បានបិទឃាំងស្ត្រីនៅខាងក្រោយ។ចំណែកស្ត្រីដែលនៅក្នុងបន្ទប់សងខាង ជាន់ទីពីរក៏ត្រូវបានគេញាត់ទៅខាងក្នុងបន្ទប់ដូចរូបបន្ទប់កណ្ដាលដែរ គឺឈប់មានសិទ្ធិ ឬអំណាចដូចពីមុនព្រោះស្នាមជានរបស់ព្រះមាតា ត្រូវគេលុបជានសាជាននិងលក់ជានអស់ហើយ (មើលការពន្យល់ក្នុងមង្គលទាំងបី ភាគពីរ)។

សរុបសេចក្ដីមក សកម្មភាពរូបទាំងអស់ដែលមាននៅក្នុងក្បាំងក្លែង (បំប្លែង) នេះបានបង្ហាញពីការបាត់បង់ឥទ្ធិពលព្រះនាងនាគ ឬព្រះមាតានាគនៅលើមាតុភូមិរបស់ខ្លួន ដែលពីមុនខ្លួនជាប្រមុខ ឥឡូវត្រូវមនោគមវិជ្ជាថ្មីខាងក្រោយចូលមកលុកលុយបំផ្លាញពេលដែលមាតាលោកសុខចិត្តទៅទទួលទោសព្រោះហេតុតែកូននាគប្រុសស្រី។

## ២៩/. រូបភាពទី២៩ រូបនៅជញ្ជាំង(ប្រាសាទបាយ័ន្ត)



រូបភាពក្នុងចម្លាក់នេះ បានបង្ហាញពីបុរសម្នាក់ពាក់មកុដជាស្ដេចទ្រង់គ្រឿងអលង្ការកំពុងចាប់ពស់ ឬនាគ ដៃស្ដាំចាប់កាន់កន្ទុយនាគ ដៃឆ្វេងចាប់កាន់ខ្លួននាគ ជើងឆ្វេងជាន់កនាគ ដែលនាគនោះកំពុងលូននាំមុខចូលទៅក្នុងបន្ទប់ប្រាសាទដ៏ស្កឹមស្កៃមួយ តើអត្ថន័យរូបចម្លាក់នេះគាត់ចង់និយាយប្រាប់យើងពីអ្វី? ហើយបុរសនោះជានរណា? នាគឬពស់នោះជានរណា? ហើយទេវតានៅលើស្វេតច្ឆត្រតំណាងឲ្យអ្វី?

**ក**/.បុរសតំណាងឲ្យអ្នកទទួលមរតកព្រះម៉ែតំណាខាងក្រោយ គឺអ្នកដឹកនាំនគរព្រោះត្រចៀករបស់គាត់មានពាក់ក្រវិលដូចជាម៉ែដែរដែលគាត់បានទទួលខ្មែរ (កេរម៉ែ)។

**ខ**/.នាគ ឬពស់តំណាងឲ្យប្រមុខរបស់ស្ត្រីក្នុងនគរនេះពីអតីតកាល គឺព្រះនាងនាគ ក្នុងពិធីមង្គលការស្ត្រីធ្វើជាមេគេដឹកនាំគេ នាំមុខគេបានតែមួយភ្លែតតែប៉ុណ្ណោះ គ្រាន់តែចូលផុតមាត់ទ្វារបន្ទប់ភ្លាមត្រូវបុរសជាន់កបាត់ទៅហើយ ដូចមានអត្ថន័យក្នុងរូបភាពចម្លាក់នេះជាភស្តុតាងបង្ហាញស្រាប់។ ដោយនាគនាំគេចូលទៅក្នុងពិភពនាគ (ព្រះថោងតោងស្បៃព្រះនាងនាគ) គ្រាន់តែក្បាលលូនចូលក្នុងមាត់ទ្វារប្រាសាទភ្លាម ត្រូវព្រះថោងជាន់កជាប់ទៅហើយ មើលការពន្យល់ក្នុងអត្ថន័យរូបទី២៨។ បន្ទប់ដែលមានកំពូលប្រាសាទពីខាងលើទ្វារ គឺបង្ហាញពីភាពរុងរឿងរបស់ពូជព្រះនាង

នាគពីអតីតកាល តែភាពរុងរឿងទាំងនេះ ពុំបានស្ថិតក្នុងសន្ដានកូននាគ សម័យខាងក្រោយឡើយ ដោយសារហេតុត្រូវគេលុបដាន សាដាន និងលក់ដាន មើលបទភ្លេងការពេលព្រះនាងនាគ ដឹកព្រះថោងចូលក្នុងបន្ទប់ អាចារ្យឲ្យអ្នកភ្លេងលេងបទទាំងនេះ (មានក្នុងមង្គលបី)។

**គ**/.ទេវតាដែលនៅលើស្វេតច្ឆត្រគឺតំណាងឲ្យនិមិត្តរូបសម្គាល់ឲ្យគណបក្សនយោបាយមួយ (គណបក្សប្រជាជន) ព្រោះគាត់បានដឹងថាក្នុងសម័យកាលខាងក្រោយនឹងមានរូបនិមិត្តសញ្ញានេះ គាត់ចង់ប្រាប់យើងជាកូននាគថា រឿងអាថ៌កំបាំងរបស់គាត់អាចដឹង អាចផ្សព្វផ្សាយមកខាងលើបានលុះត្រាតែមានរូបទេវតានៅខាងលើ (ពេលមាតាពុំអាចចេញពីឃុំរួច) ទើបកូននាគសម័យខាងក្រោយអង្គុរ អាចដឹងពីទុក្ខសោកវេទនារបស់គាត់ក្នុងសមុទ្រទឹកដោះបាន។ ព្រោះពេលកើតឡើងនូវនិមិត្តសញ្ញាទេវតា តំណាងឲ្យ**គណបក្សប្រជាជន**នេះ ពេលនោះរូបកូរសមុទ្រទឹកដោះក៏កើត ឡើងព្រមគ្នា នេះជាសញ្ញាប្រាប់ពេលវេលាឲ្យកូននាគបានដឹងថា **សាសនព្រះម៉ែ** ជិតដល់ពេលរស់ និងអណ្ដែតមកស្ថិតក្នុងក្រសែដួងចិត្តរបស់កូននាគប្រុសស្រីឡើងវិញហើយ។ ដូចមានសម្អាងក្នុងចម្លាក់នេះជាដើម ពីមុនបរទេសបានពន្យល់ក្នុងគម្ពីរភាសារូបរបស់គេ ថាជារឿងរបស់សាសនាដោយគេបានលាក់បំពួនកុំឲ្យកូននាគយល់ដឹងពីភាសារូបពិត តែខ្ញុំពុំយល់ដូចជនបរទេសថា ឬសសេរឡើយ ខ្ញុំជាកូននាគដាច់ខាត់ត្រូវតែដឹងរឿងក្នុងបេះដូងរបស់ម៉ែនាគ និងនៅក្នុងក្បាំងនាគ ឬក្បាល របស់គាត់ ព្រោះខ្ញុំពុំជឿថាម៉ែឪរាល់រូបដែលខំរកស៊ីមួយជីវិត ដើម្បីប្រមូលទ្រព្យសម្បត្តិយកមកទុកឲ្យកូនហើយបែរជាទុកឲ្យអ្នកដទៃនោះ គឺវាពុំមែនជាហេតុត្រឹមត្រូវឡើយ។

សរុបសេចក្ដីមក រូបភាពនេះគាត់ចង់បើកបង្ហាញពីការបាត់បង់សិទ្ធិអំណាចរបស់ខ្លួនពីអតីតកាល ហើយរឿងរបស់គាត់ទាំងនោះលុះត្រាតែដល់បាបកម្មចាស់ឲ្យផលអស់ទើបអាចមានកូននាគណាមួយមកជួយស្រង់ ជួយលើកជួយរើកសាសនប្រស្នាគាត់មកផ្សព្វផ្សាយ ដើម្បីតវង្សត្រកូលនាគឲ្យរស់រវើកឡើងវិញក្នុងសន្ដានចិត្តកូនខ្មែរ។

## ៣០/. រូបភាពទី៣០ស្ត្រីគ្រប់លក្ខណ៍ ឬលាក់(ជញ្ជាំងប្រាសាទបន្ទាយស្រី)

រូបភាពនេះ បង្ហាញពីស្ត្រីម្នាក់ ឈរខិនមុខ ដៃឆ្វេងកាន់ផ្កាឈូកមួយទងសំយ៉ុងចុះ ដៃស្ដាំកាន់ផ្កាឈូកព័ទ្ធពីខាងក្រោយក សំយ៉ុងទងផ្កាចុះមកក្រោម បម្រុងនឹងរីក តែរីកពុំរួច ហើយរូបគាត់ឈរនៅលើទម្រ ដែលមានក្បាច់ត្របកឈូកបំបែក។ នៅពីខាងក្រោមទម្រដែលគាត់ឈរ មានសត្វករវិក

កំពុងត្រដាងស្លាបឡើង ចំណែកឯនៅពីខាងលើរូបគាត់ មានគំរបខ្លោងទ្វាររាងដូចក្បាំងភ្លែង ដែលមាននិមិត្តរូបនាគសង្ខាង គ្របប្ដុក្រុងពីលើ។ ហើយនៅពីលើក្បាលគាត់ មានផ្កាឈូកដ៏ធំមួយសំយ៉ុងចុះក្រោម នៅពីលើក្បាច់ស៊ុមក្បាំងភ្លែង មានរូបទេពតាហោះសង្ខាង ហាក់បីដូចជាកំពុងចាប់បើកគម្របស៊ុមនេះឡើង។ ចំណែកនៅសង្ខាងមានក្បាច់ចង្វាយអង្គរអមរូប ដែលក្បាច់ចង្វាយអង្គរទាំងនោះ នៅដើមក្បាច់ មានរូបខ្លួនសត្វរាជសី ឬតោ ដៃឥតមានក្បាល ក្អែចេញជាក្បាច់ដុះបន្តគ្នា ទីបំផុតក្បាលរាជសី ឬតោ អាចកើតមានឡើង នៅចុងក្បាំងភ្លែងខាងលើឯនោះ នេះជាប្រស្នាកំបាំងក្នុងរូប។ តើរូបទាំងអស់ ដែលខ្ញុំបានរៀបរាប់នេះ គាត់ចង់និយាយពីអ្វី ក្នុងរឿងរបស់គាត់?



យើងបានដឹងហើយថា ឈ្មោះប្រាសាទនេះ គឺបន្ទាយស្រី គឺមានន័យថា ជាទីតាំងលាក់ទុក នៅមរតករឿងរបស់ស្ត្រី តែក៏មិនដឹងថា ទុកនៅរបស់អ្វីឡើយ លុះត្រាតែយើងមើលរូបរួចត្រិះរិះពិចារណា ហើយពិចារណាទៀត ឆ្ងល់ហើយ ឆ្ងល់ទៀត ទីបំផុតយើងនឹងដឹងរឿងក្នុងបេះដូង ប្រាសាទបន្ទាយស្រីនេះជាពុំខាន។ ព្រោះឈ្មោះរបស់សត្វ បុគ្គល សម្ភារៈ ទីកន្លែង...អាចកើតឡើងបាន ក៏ត្រូវមានហេតុបច្ច័យគ្រប់គ្រាន់ ទើបនាមបញ្ញត្តិ ឬឈ្មោះនោះ អាចឧប្បត្តិកឡើង នឹងឋិតថេរគង់វង្ស រហូតមកដល់សព្វថ្ងៃនេះ។ ដូចជាយើង ចង់ដាក់ឈ្មោះឲ្យបុត្រា បុត្រី ឬសត្វចិញ្ចឹម ទី១យើងត្រូវមើលពេលវេលាថ្ងៃខែឆ្នាំដែលកើត រួមផ្សំ នឹងពេលសុបិន្តឃើញគេមកចាប់កំណើតផង ឪពុកម្ដាយត្រូវរិះរកឈ្មោះណាមួយ ដែលមានន័យស័ក្តិសមទៅតាមកម្លាំងថ្ងៃកំណើត (ចំពោះឪពុកម្ដាយដែលចេះដឹង)។ យ៉ាងណាមិញ ឈ្មោះសត្វ បុគ្គល ទីកន្លែង សម្ភារៈ.....ផ្សេងៗ ក្នុងសម័យមុន ក៏

ឈ្មោះទាំងនោះ ប្រកបទៅដោយអាថ៌កំបាំងន័យប្រស្នា ទៅតាមកំរិតបញ្ញារបស់អ្នកដាក់ ព្រោះឈ្មោះទាំងនេះ (នាម និងគោត្រ) មានអាយុកាលវែង លុះត្រាតែអស់ពូជនៃជនជាតិដើម ជាអ្នកកកើត ទើបឈ្មោះនេះរលុបបាត់ទៅតាមកាលវេលានោះ (ឧ.ខេត្តខ្មែរពីរអតីតនគរស្រីល្វោ សព្វថ្ងៃលពបូរី ក្រុងព្រៃនគរ សព្វថ្ងៃហូជីមិញ....)។

ស្ត្រីគ្រប់លក្ខណ៍ ឬគ្រប់លាក់ ⇨ ក្រាក់លុប ពាក្យក្រាក់ គឺជាគល់ឈើដែលចាស់ របកសំបកដោយខ្លួនឯង ហើយមានអាយុយូរ (គល់ក្រាក់) ដូចជាពាក្យថា បុកល័ក្តធ្វើច្រេញ បន្សាបពិសនាគ តើអ្នកណាជានាគ? ពាក្យបុកល័ក្តម្យ៉ាងទៀត បើយើងសរសេរតាមសូរសព្ទនិយាយ បុកហើយលាក់ គឺមានន័យថា បុកឲ្យចុះទៅក្រោម រួចលាក់ទុកកុំឲ្យគេដឹង។ ស្ត្រីគ្រប់លក្ខណ៍ នៅក្នុងរូបនេះ គេឆ្លាក់ឲ្យគាត់ឈរនៅក្នុងស៊ុមទ្វារមួយដ៏ចង្អៀត មើលទៅហាក់បីដូចជាពុំមែននៅមាត់ទ្វារផ្ទះឡើយ ធម្មតាមាត់ទ្វារផ្ទះ ទោះបីជាតូចយ៉ាងណា ក៏ម្ចាស់ផ្ទះអាចចេញចូលដោយមិនចង្អៀតដែរ ដូច្នេះប្រស្នាក្នុងទីខ្លោងដ៏ចង្អៀតនេះ គាត់ទុកឲ្យយើងមើលរួចឆ្ងល់។ ហេតុអ្វីបានជារូបស្ត្រី សម័យមុនអង្គរ ឬសម័យអង្គរ គេឆ្លាក់រូបពួកគាត់លែងខ្លួនទទេខាងលើ មិនដូចជាជនជាតិឥណ្ឌា ចិន .....បរទេសដែលនៅជិតខាង? ក្នុងសៀវភៅប្រវត្តិសាស្ត្រខ្មែរ អ្នកប្រាជ្ញសម័យមុន ខ្មែរ និងបរទេស បានទាញពីកំណើតជនជាតិនេះ ថាមកពីឥណ្ឌា ឬបរទេសផ្សេងៗ ចុះហេតុអ្វីក៏រូបចម្លាក់យើង មិនឆ្លាក់ឲ្យមានសម្លៀកបំពាក់ដូចបរទេសទាំងនោះ? នេះជាហេតុដែលយើងត្រូវ រកអាថ៌កំបាំងឬសកែវ របស់ដូនតាយើង ក្នុងនាមជាពូជអ្នកកសាងប្រាសាទថ្ម ថាតើគាត់បានលាក់អាថ៌កំបាំងរបស់គាត់នៅឯណា? ដូចជាស្ត្រីដែលគាត់ឆ្លាក់ភាគច្រើនពុំមានស្លៀកដណ្ដប់ល្វែងខាងលើ គាត់ចង់ប្រាប់យើងទាំងអស់គ្នាថា គាត់គឺជាប្រមុខនៃពូជកេរមេ (ក្នុងភាគ១) ហើយក្មេរនេះ ក្រោយមកបានក្លាយជាខ្មែរ ដែលបានបន្សល់ទុកពាក្យមាតុភូមិមកដល់សព្វថ្ងៃ បើភូមិប្រទេសនេះ ជារបស់ម៉ែៗត្រូវតែបំបៅកូនបន្តគ្នា ទឹកដោះរបស់ពួកគាត់បានផ្សុំបន្តគ្នា រហូតក្លាយបានជាសមុទ្រ (សមុទ្រទឹកដោះ) ហេតុនេះ ទើបគាត់ឲ្យកូនសម័យនោះ ឆ្លាក់គាត់មិនឲ្យមានពាក់អាវ ព្រោះគាត់ចង់បង្ហាញប្រាប់យើងថា ពូជគាត់ពុំបានកើតចេញពីបរទេសឡើយ (ប្រស្នារូប ដែលពុំពាក់អាវ)។ គាត់ចង់ប្រាប់កូននាគសម័យខាងក្រោយ ឲ្យយល់ពីអាថ៌កំបាំងរបស់ពូជនាគ ព្រោះគាត់ជាមេនាគ ពុំមែនដូចបរទេសមួយចំនួន បានថានគរខ្មែរសម័យនោះពុំស៊ីវិល័យ ពុំមានអារ្យធម៌ ពុំមានពូជពង្សច្បាស់លាស់ នោះគឺពុំត្រឹមត្រូវទេ ប្រទេសមួយអាចពង្វាតទឹកដីឲ្យទៅជាចក្រភពបាន អាចកសាងប្រាសាទថ្មរាប់ពាន់បាន បើពួកគាត់ពុំមានវប្បធម៌អារ្យធម៌

ទៅដល់កំពូល ធ្វើដូចម្ដេចសមិទ្ធិផលទាំងនេះអាចកើតមាន និងស្ថិតស្ថេរមកដល់សព្វថ្ងៃបាន? ពេលដែលយើងពុំបានស្រាវជ្រាវពីអាថ៌កំបាំងរបស់ខ្លួន ទើបធ្វើឲ្យប្រវត្តិរបស់ជនជាតិនេះ ម្ដងថាកើតពីជាតិនេះ ម្ដងថាកើតពីប្រទេសនោះ (ប្រវត្តិសាស្ត្រខ្មែរ) ហាក់បីដូចជាជនជាតិនេះ កំពុងឈរលើក្បូន ម្ដងផ្អៀងទៅខាងនេះ ម្ដងផ្អៀងទៅខាងនោះ រកកំណត់លំនឹងខ្លួនគ្មាន។ តាមពិត ពូជនាគនៅតែជាពូជនាគ ព្រោះយើងមានមេនាគជាដើមហេតុ ព្រះមាតានាគនេះហើយ ដែលបានបន្សល់ទុកពូជនាគរាប់ពាន់ជំនាន់ រហូតមកដល់សព្វថ្ងៃ គ្រាន់តែយើងពុំបានមើល និងពិចារណាតែប៉ុណ្ណោះ ដោយរឿងរបស់ពួកគាត់ បានបាត់ដាន ហើយលិចចុះទៅក្នុងសមុទ្រទឹកដោះ រួមទាំងបរទេសចូលមកក្លែងបំភ័ន្ត (លុបដាន សាដាន លក់ដាន) ទៀតនោះ ធ្វើឲ្យកូននាគសម័យខាងក្រោយ ដែលប្រសូត្រចេញពីផ្ទៃមាតាទាំង១២ ដែលយក្សបានខ្វេះកែវភ្នែកយកទៅនោះ ត្រូវងងឹតមិនដឹងរឿងបន្តគ្នា (មើលភាគ១ និងភាគ២)។ ដូចមានរូបស្រីគ្រប់លក្ខណ៍នេះ ជាភ័ស្តុតាងស្រាប់ ដែលរូបនេះ គាត់ប្រតិស្ឋានទុក ក្នុងប្រាសាទបន្ទាយស្រី ព្រោះវាជារឿងរបស់ស្ត្រីដែលជាមេជាម៉ែ ហើយគាត់បានប្រាប់ដំណើររឿង គ្រប់ផ្ទៃរ ក្បាំងក្លែង ជញ្ជាំង ទុកឲ្យយើងមើលពីដំណើរកម្មរបស់គាត់ ក្នុងពេលជាប់ទោស ក្នុងពេលមានកូនចុះទៅជួយគាត់ និងពេលដែលគាត់រួចពីទោស។ តែបរទេសដែលធ្លាប់ធ្វើអណានិគម គេមានសិទ្ធិមានអំណាច ប្រែភាសារូបបង្វែងឲ្យទៅជារឿងរបស់សាសនា រួចឲ្យយើងទាំងអស់គ្នាជាកូននាគ រៀនសូត្រតាមគម្ពីររបស់ពួកគេ (បទសារិកាកែវ) ទីបំផុត យើងពុំអាចដឹងរឿងពិតក្នុងភាសារូបទាំងនោះឡើយ។ ហេតុអ្វីក៏តោមានតែជើង អត់ក្បាល? ព្រោះភាសាគំនិតក្នុងរូបនេះ គាត់ចង់ប្រាប់យើងថាទៅថ្ងៃអនាគតខាងមុខ នឹងកើតមានទីក្រុងមួយឈ្មោះថា ទីក្រុងព្រះសីហនុ (ទីក្រុងតោ) ព្រោះចង្វាយក្បាច់ដែលដុះបន្តគ្នាទៅលើនោះ គឺបញ្ជាក់ប្រាប់ពេលវេលាទៅថ្ងៃខាងមុខ ពេលដែលកើតមានទីក្រុងនេះហើយ លុះត្រាតែកើតមានរូបនិមិត្តសញ្ញាទេវតាថែមទៀត ទើបមានកូននាគអាចដឹងរឿងអាថ៌កំបាំងរបស់គាត់ ហើយរឿងប្រស្នាបណ្ដាំព្រះម៉ែនេះ គឺបានលេចចេញពីទីក្រុងតោនោះឯង ដូចនេះទើបអ្នកសរសេរទំនាយថ្ងៃសុក្រ ថ្ងៃសៅរ៍ គាត់បានប្រើពាក្យឱះឱអាសូររាជសីសត្វ ព្រោះប្រារព្ធទៅលើរឿងអាថ៌កំបាំងនេះ បានផុសចេញពីទីក្រុងតោពីរនេះ។ ដូច្នេះស្ទើរតែគ្រប់ប្រាសាទនានា តែងតែមានតោនៅពីក្រោយនាគ ព្រោះតោជានិមិត្តរូបជួយជ្រោងនាគ ឬស្រង់នាគ (ស្រះស្រង់)។

# ៣៧/.រូបភាពទី៣៧រូបតោនៅចុងក្បាំងភ្លែង(ប្រាសាទបន្ទាយស្រី)



រូបភាព ក្នុងចុងក្បាំងភ្លែងនេះ មានតោ កំពុងចេញពីមាត់យក្ស ដែលខ្ញុំបានពន្យល់ ពីភាសារូបភាពមុនៗរួចហើយ ព្រោះជើងតោនៅខាងក្រោម ទម្រាំតែអាចកើតចេញជារូបរាងតោពិតប្រាកដបាននោះ គឺមានរយពេល រាប់រយពាន់ឆ្នាំទៅខាងក្រោយ។ តោនេះ ទោះបីកើតមានរូបរាងពិតប្រាកដ ក្នុងសម័យខាងក្រោយក៏ដោយ ក៏តោនេះ នៅជាប់ឃុំក្នុងអំណាចយក្សដដែល (គឺក្នុងមាត់យក្ស) ទោះបីឡើងទៅដល់ទីខ្ពស់ក៏មិនទាន់រួចពីទោសដែរ តែវាគ្រាន់ជាងពីមិនទាន់ មានរូបរាងតោពិតប្រាកដ នោះបានន័យថា បាបទាំងឡាយរបស់គាត់ ជិតអស់ហើយ (មើលស្រីគ្រប់លក្ខណ៍ខាងក្រោម)។ ដូច្នេះរឿងរ៉ាវតោនេះ ខ្ញុំបានពន្យល់តាំងពីភាគមុនមកម្ល៉េះ ចំណែកភាគនេះ ខ្ញុំគ្រាន់តែយករូបភាពមកជាសម្អាង ដើម្បីឲ្យកូននាគប្រុសស្រីមើលរួចពិចារណា ព្រោះ**យើងជាកូននាគជាពូជនាគ ត្រូវតែដឹងរឿងពិតនៅក្នុងប្រាសាទថ្មរបស់ខ្លួន**។

# ៣២/.រូបភាពទី៣២រូបក្បាំងក្លែងបន្ទាយស្រី(សព្វថ្ងៃនៅសារមន្ទីជាតិភ្នំពេញ)



រូបភាពក្នុងក្បាំងក្លែងនេះ បានរៀបរាប់ពីសកម្មភាពរបស់ស្ត្រីម្នាក់នៅចំកណ្ដាល នៅសងខាងរូបស្ត្រីនោះ មានបុរសកំពុងលើកអាវុធគំរាម ទាញដៃដណ្ដើមស្ត្រីនៅកណ្ដាលម្នាក់មួយចំហៀង ហាក់បីដូចជាបង្ខំដោយអំណាចហឹង្សា ដើម្បីហែកស្ត្រីនេះ ឲ្យរយះជាពីរចំហៀង។ នៅសងខាងបុរស មានមនុស្សអង្គុយ រូបទីមួយមានដើមឈើរាងផ្លិតនៅពីក្រោយ កំពុងលើកដៃសំពះ ឯម្នាក់ទៀតនៅពីក្រោយ ពុំលើកដៃសំពះទេ រូបម្ខាងទៀតក៏មានសកម្មភាពដូចគ្នា។ នៅខាងក្រោយស្ត្រីមានដើមឈើជារាងផ្លិត ហើយនៅលើផ្លិតមានទេវតាពីរហោះពីលើ តើរូបភាពចម្លាក់គំនិតនេះ គាត់ចង់និយាយប្រាប់យើងពីអ្វី?

**ក**/.រូបស្ត្រីមានសម្លៀកបំពាក់ដូចជា ស្រីគ្រប់លក្ខណ៍នោះ គឺតំណាងឲ្យព្រះម៉ែមហានគរ ឯផ្លិតជាដើមឈើនៅពីក្រោយគាត់ គឺតំណាងឲ្យអំណាច យសសក្តិ កេរ្តិ៍ឈ្មោះ របស់គាត់ ពីអតីតកាល ព្រោះរាងផ្លិតនេះ ដូចជារាងផ្លិតតំណាងឲ្យយសសក្តិមន្ត្រីសង្ឃក្នុងរាជាគណៈ តាំងពីថ្នាក់សម្ដេចសង្ឃរាជរហូតដល់រាជាគណៈថ្នាក់កិត្តិយស។

ខ/.ក្រោយពីស្ត្រីនេះអស់អំណាចយសសក្តិ គាត់ត្រូវយក្សចាប់យកទៅឃុំ បុរសសង្វាងបានឆ្លៀតឱកាសលុកលុយឈ្លានពានមាតុភូមិនេះ ហែកគាត់ជាបីចំណែក (ដំរីក្បាលបី ឬស្ត្រីហែកខ្លួនជាបី) ព្រោះសកម្មភាពរូប បានបង្ហាញពីការហែកស្ត្រីនេះ ដោយអំណាចសង្គ្រាម គឺអាវុធ។

គ/.ចំណែកអ្នកអង្គុយសង្វាង ម្នាក់មានផ្ចិតពីខាងក្រោយ តែតូចជាងផ្ចិតរបស់មាតាមហានគរនោះ កំពុងសំពះអង្វរ តំណាងឲ្យកូនខ្មែរនាគកំពុងដឹកនាំប្រទេសសម័យក្រោយៗសំពះអង្វរបុរស កំពុងដណ្ដើមគ្នាហែកស្ត្រី (មាតុភូមិ) នោះ ឲ្យឈប់ប្រព្រឹត្តទៀតទៅ តែមើលទៅគេពុំព្រមឈប់ឡើយ ព្រោះសេចក្ដីលោភរបស់បុគ្គលមួយ គ្រួសារមួយ សមាគមមួយ ប្រទេសមួយ ពុំចេះស្កប់ស្កល់ឡើយ ដូចជាព្រះម៉ែមហានគរ ពីអតីតកាលយ៉ាងដូច្នោះ។ ឯម្នាក់ខាងក្រោយអង្គុយដាក់ដៃធម្មតា គឺតំណាងឲ្យកូននាគ ដែលពុំខ្វល់ ឬរើបម្រះ ពុំឈឺក្បាលវិលមុខពីរឿងអ្វីឡើយ គឺបានត្រឹមតែហៃអើៗអាជ័យធ្លាក់ទឹក គឺមានន័យថា ធនធានរបស់ជ័យគ្រប់ជំនាន់ពីអតីត តាំងពីជ័យដំបូង រហូតដល់ជ័យចុងក្រោយ បានធ្លាក់លិចទៅក្នុងទឹកទៅហើយ (មើលការពន្យល់ពាក្យក្រពើ នៅក្នុងភាគ១)។

ឃ/.ទេវតាខាងលើ តំណាងឲ្យនិមិត្តសញ្ញារបស់គណបក្សមួយដែលមានរូបទេវតា ពេលមានរូបនេះកើតឡើង ទើបដឹងរឿងរ៉ាវព្រះមាតាខាងក្រោម (អតីតកាល) បើរូបទេវតានេះពុំកើតឡើងទេ អាថ៌កំបាំងនេះ ត្រូវកប់ក្នុងអតីតកាលក្នុងសមុទ្រទឹកដោះដដែល។

សរុបសេចក្ដីមក ភាសាថ្មក្នុងរូបនេះ បានបើកបង្ហាញប្រាប់យើងជាមុនរួចទៅហើយ នៅក្នុងការដណ្ដើមហែកនគរ ឬហែកក្បាលដំរីឲ្យទៅជាបី ក្រោយពេលដែលគាត់ត្រូវទទួលទណ្ឌកម្មពីយក្សពេលនោះ អ្នកជិតខាងបានឆ្លៀតឱកាស ដណ្ដើមហែកយកមាតុភូមិនេះ។

# ៣៣/.រូបភាពទី៣៣រូបផ្តែរទ្វារ និងក្បាំងក្លែងខាងលើ(ប្រាសាទបន្ទាយស្រី)






ក្នុងរូបភាពផ្តែរនេះ បានបង្ហាញពីបុគ្គលិកលក្ខណៈ របស់បុរសម្នាក់មានពាក់ក្រវិលដូចរូបចម្លាក់ស្រីគ្រប់លក្ខណ៍ (ក្បាលរូបតំណាងព្រះម៉ែ) ចាប់ហែកក្បាលស្ត្រីម្ខាងមួយ រយៈរហូតដល់ផ្ចិត ដែលក្បាលត្រូវហែកសង្ខាងនោះ ពុំមានពាក់ក្រវិលត្រចៀកឡើយ។ រូបដែលហែកនេះ បានឈរលើផ្កាឈូកមួយ ហើយមានក្បាំងគ្របពីលើជិត ដែលក្បាំងនោះ កើតចេញពីរាជ្យបញ្ញាពីក្នុងមាត់យក្ស ដែលខាំក្បាច់និមិត្តរូបខ្លួននាគយក្សខាំទាំងសង្ខាងនោះ។ តើក្នុងផ្តែរនេះ គាត់ផ្តាំឲ្យយើងមើលឃើញពីរឿងអ្វី?

**ក**/.ក្នុងរូបភាពទី៣២មុន គឺមានបុរសពីរនាក់ ដៃកាន់អាវុធកំពុងចាប់ហែកដណ្តើមស្ត្រីម្នាក់ ឥឡូវកម្លាំងហែកដណ្តើម បានធ្វើឲ្យកាយស្ត្រីនោះ ត្រូវរយៈជាបី ក្បាលកណ្តាលតំណាងឲ្យនគរខ្មែរ

ព្រោះត្រចៀករូបកណ្ដាលមានក្រវិល ដែលជាមរតកម៉ែ (មាតុភូមិ) រូបសង្ខាងមានទម្លាក់សក់វែងជាស្រីដែរ តែត្រចៀកពួកគេពុំមានពាក់ក្រវិលទេ មានន័យថា គេពុំមែនជាពូជអ្នកទទួលកេរម៉ែឡើយ (ខ្មែរ)។ សកម្មភាពរូបមុន បង្ហាញពីពេលដែលកំពុងហែក ចំណែកសកម្មភាពរូបនេះ គឺបានហែកជាបីរហូតដល់ផ្ចិត មានន័យថា បេះដូងក្នុងចំណែករូបទាំងបី មានពណ៌សម្បុរភាសាខុសគ្នាហើយ ឯក្បាលកណ្ដាលអ្នកហែក មានរាងដូចជាបុរសពាក់ក្រវិលត្រចៀកនោះ មានន័យថា អ្នកដឹកនាំប្រទេសជំនួសគាត់សម័យក្រោយៗ គឺជាបុរសដែលជាពូជពង្សនាគ បានទទួលនូវមរកតព្រះម៉ែ ព្រោះពួកគេបានកើត កំពុងរស់នៅ និងទីបំផុតត្រូវកប់សាកសពនៅក្នុងមាតុភូមិនេះ។

ខ/.ក្បាំងក្លែងខាងលើ មានបុរសម្នាក់អង្គុយបញ្ឈរជង្គង់ លើទម្រផ្កាឈូកមួយ ដែលមានរូបតោបីកំពុងចំរើតឡើង ជ្រែងលើរូបខាងលើ ឯនៅខាងលើបុរសនោះ មានរូបបុរសពីរនាក់សង្ខាងបង្កប់ក្នុងក្បាច់ត្រឹមផ្ចិត ហើយនៅលើរូបបុរសទាំងពីរ មានក្បាលយក្សមួយខាំក្បាច់ខាងក្រោមជាប់ ហើយនៅពីលើក្បាលយក្សនោះ មានទេវតាពីរទៀតស្ថិតនៅសង្ខាង។ តើសកម្មភាពរូបទាំងអស់នេះ មានបង្កប់អត្ថន័យយ៉ាងណា?

១/.រូបដែលអង្គុយលើបល្ល័ង្ក តំណាងកូននាគដែលចុះមកក្នុងសមុទ្រទឹកដោះ ដើម្បីស្រាវជ្រាវ និងជួយម្ដាយ តែរូបតំណាងឲ្យគាត់នៅចំកណ្ដាល ភាគច្រើនត្រូវបានដាប់បំផ្លាញចោលស្ទើរគ្រប់ប្រាសាទ ព្រោះគេយល់ដឹងភាសារូប គេត្រូវឧបកិច្ចកាត់កឲ្យកូននាគនោះស្លាប់ (មើលពិធីឧបកិច្ចរបស់ស្ដេចជ័យវរ្ម័នទី២ កាត់កស្ដេចផ្វា)។

២/.តោតំណាងឲ្យទីក្រុងតោ តែក្នុងរូបនេះមានតោបី គឺតោទីមួយតំណាងអតីត តោទីពីបច្ចុប្បន្ន តោទីបីអនាគត និងតំណាងឲ្យសោឃុំអច្ឆរមាតាទាំងបីជាន់។

៣/.រូបបុរសពាក់កណ្ដាលខ្លួនសង្ខាង តំណាងឲ្យកូននាគមុននឹងចុះមកអង្គុយលើបល្ល័ង្កខាងក្រោម។

៤/.ក្បាលយក្ស តំណាងឲ្យអ្នកចាប់មាតាបិតា យកទៅដាក់ឃុំពីអតីត ហេតុនេះទើបក្បាលយក្ស ស្ថិតនៅខាងលើផង ខាងក្រោមផង ហើយរូបដែលស្ថិតនៅក្នុងអំណាចយក្សទាំងអស់ តំណាងឲ្យអ្នកដឹងរឿងរបស់ព្រះមាតាមហានគរ។

៥/.រូបទេវតាខាងលើ គឺតំណាងឲ្យនិមិត្តសញ្ញាគណបក្សនយោបាយ (គណបក្សប្រជាជន) ពេលមាននិមិត្តសញ្ញាទេវតា គឺជាសញ្ញាបង្ហាញថា រឿងមាតានាគបានត្រូវកូននាគបានដឹងហើយ។

សរុបសេចក្តីមក រូបទាំង**៣៣**ផ្ទាំងនេះ បានបើកបង្ហាញពីការទទួលទុក្ខទារុណកម្ម របស់មាតាបិតាមហានគរពីអតីតកាល ដែលពួកគាត់ស៊ូទ្រាំនៅរងចាំកូនរាប់ពាន់ឆ្នាំ ទ្រនៅទម្ងន់ទុក្ខជាពិសេសគឺមាតាមហានគរ។ ពួកគាត់ក៏មានក្តីសង្ឃឹមយ៉ាងមុតមាំថា ទៅថ្ងៃក្រោយនឹងមានកូននាគណាម្នាក់ចុះមកស្រាវជ្រាវរាវរករឿងពិតរបស់គាត់ រួចជួយស្រង់ពួកគាត់ឲ្យរួចផុតពីបាបកម្មនេះ។ ការពន្យល់បកស្រាយរបស់ខ្ញុំក្នុងរូបទាំង**៣៣**នេះ ហាក់បីដូចជារបស់ដែលធ្លាប់តែផ្កាប់ជារឿងក្នុងសាសនា ឥឡូវត្រូវផ្ងារមកជារបស់ព្រះម៉ែវិញ វាហាក់បីដូចពុំគួរឲ្យជឿឡើយ តែវាជារឿងពិត ព្រោះថ្មពុំចេះកុហកយើងឡើយ។ បើយើងពិតជាអ្នកទទួលមរតកព្រះម៉ែមែន ជាកូននាគមែន យើងត្រូវតែស្គាល់រឿងពិតរបស់ព្រះមេនាគ ព្រោះរឿងទាំងអស់ស្ថិតក្នុងក្បាំង (ក្បាំងភ្លែង) ដែលពាក់នៅលើក្បាល ហើយក្បាំងនោះ គឺជាក្បាំងរបស់ព្រះមាតានាគ ព្រោះជាតួខ្លួននាគពីរ បង្កើតបានជាក្បាំងរាប់ពាន់ម៉ឺនសែនក្បាំងនៅគ្រប់ប្រាសាទទូទាំងមាតុភូមិនេះ ទាំងអតីត និងបច្ចុប្បន្ន។ សូម្បីតែក្បាំងអប្សរកំពុងពាក់រាំរាល់ថ្ងៃក៏មាននាគពីរនៅជិតត្រចៀកដែរ គាត់ចង់ខ្សិបប្រាប់កូនឲ្យមើលរឿងម៉ែ ទីបំផុតអច្ឆរាទាំងអស់ត្រូវគថ្លង់ពុំអាចស្តាប់ឮ និងនិយាយបាន (អាចិកំបាំងអច្ឆរារាប់ពាន់ម៉ឺនមានតែពីរ គឺមួយលៀនអណ្តាត និងមួយទៀតញញឹមចេញធ្មេញ) ព្រោះហេតុតែបាបកម្មចាស់ ឲ្យផលបន្តន្តារហូតមកដល់សព្វថ្ងៃពុំទាន់អស់។ ដូច្នេះចូលកូននាគប្រុសស្រី ភ្ញាក់ឡើងជួយជ្រោងលើកពួកគាត់ រួមសាមគ្គីជានាគព័ន្ធរួមខ្លួនតែមួយ ក្នុងក្បាំង ដែលនៅលើក្បាលតែមួយ ដើម្បីចាកចេញពីអំណាចយក្ស ដោយហេតុតែកែវភ្នែកមាតាទាំង**១២** បានត្រូវភ្លឺឡើងវិញ កូននាគនឹង**មើលឃើញនូវសាសនពិតទាំងឡាយរបស់ព្រះមាតានាគ** ដែលធ្លាប់តែងងឹតពីអតីតកាលនោះ។

## II.រូបភាពបង្ហាញពីសកម្មភាពកូននាគ ច្បាននៅជួយមាតាឲ្យរួចពីអំណាចយក្ស

### ៣៤/.រូបភាពទី៣៤រូបកូនចាប់មាតាផ្គុំខ្លួនដែលហែក(ប្រាសាទបន្ទាយស្រី)



ក្នុងរូបភាពទី**៣២** គេកំពុងចាប់ដណ្ដើមហែកស្ត្រីជាមាតា តែមិនទាន់រហែក មកដល់រូបទី**៣៣** រូបស្ត្រីនោះត្រូវចាប់ហែកជាបី ចំណែកឯរូបទី**៣៤**នេះ ភាសារូបបានបង្ហាញប្រាប់យើងដូចម្ដេច? បើយើងពិនិត្យមើលសកម្មភាពរូបនេះ យើងឃើញបុរសម្នាក់មានមាឌមាំធំ ឈរអង្គុញជើងម្ខាងលើផ្កាឈូកមួយទង ជើងម្ខាងទៀត លើកអង្គុញផុតពីទម្រផ្កាឈូក ហើយគាបលើភ្លៅស្ត្រី ដែលដងខ្លួន និងក្បាលស្ត្រីនោះ ផ្ដេកទៅលើភ្លៅដែលកំពុងឈរ ដោយរូបស្ត្រីនោះទម្លាក់សក់ និងក្រវិលត្រចៀកចុះមកក្រោម។ ចំណែកដៃទាំងពីររបស់បុរសនេះ កំពុងចាប់ស្នាមដែលគេហែកនោះ (មើលរូបទី៣៣) ចិប្បាច់ស្នាមហែកឲ្យជាប់គ្នាវិញ នៅក្នុងកាយវិការមួយដ៏លំបាក ព្រោះគាត់បានឈរជើងបានតែមួយចំហៀង ហើយអង្គុញទៀត។ តើរូបបុរសតំណាងឲ្យអ្វី? ហើយរូបស្ត្រីតំណាងឲ្យអ្វី?

**ក**/.ក្នុងរូបភាពនេះ រូបបុរសដែលគេបានដាប់ក្បាលគាត់ចោលនោះ តំណាងឲ្យកូននាគត្រូវចុះមកជួយស្រង់ និងប្រស់មាតាដែលដេកស្លាប់រាប់ពាន់ឆ្នាំនោះ ព្រោះរាងកាយគាត់ត្រូវហែកជាបី កូននេះត្រូវមានភារកិច្ចផ្គុំផ្សាររូបគាត់ឲ្យទៅជាមួយឡើងវិញ។ ប៉ុន្តែគួរឲ្យអនិច្ចានិមិត្តរូបគាត់ណាស់ ពួក

ទុច្ចរិត ព្រោះហេតុតែប្រាក់ បានត្រូវគេដួលឲ្យដាប់បំផ្លាញ ដើម្បីឧបកិច្ចឲ្យកូននាគនេះស្លាប់ បើកូននាគនេះស្លាប់ ព្រះមាតាមហានគរក៏នៅដេកស្លាប់ដដែល ព្រោះពុំមានអ្នកណាមកប្រស់មកស្រង់ឲ្យគាត់រស់ក្នុងបេះដូងកូនក្មេរឡើងវិញបានឡើយ។ ហើយកូននាគនេះទៀតសោត មានជើងតែម្ខាងសម្រាប់ឈរ ឯជើងម្ខាងទៀតត្រូវលើកមកគាបទប់ខ្លួនម្តាយឲ្យមានលំនឹង ដើម្បីផ្សារស្នាមរបែកឲ្យទៅជាមួយវិញ ដូច្នេះគាត់ត្រូវមានការលំបាកណាស់ ទប់ខ្លួនឯងផង ទប់ខ្លួនព្រះម៉ែផង ព្រោះជើងមួយចំហៀងដែលឈរនេះ បានបង្ហាញពីការលំបាកឲ្យយើងដឹង។ រូបគាត់ត្រូវពួនសំងំម្នាក់ឯងនៅក្នុងព្រៃក្សាច់ គឺព្រៃមនុស្សនោះឯង (ប្រាសាទបាពួន) ដើម្បីបំពេញកិច្ចជាកូន ទោះបីមានជើងឈរតែម្ខាង ក៏សុខចិត្តស៊ូទ្រាំគ្រប់កាលលំបាក ដើម្បីប្រស់ម្តាយឲ្យរស់ឡើងវិញ ក្នុងសន្តានចិត្ត បេះដូងកូនក្មេរ។

**ខ**/.រូបស្ត្រីដែលដេកទន់ខ្លួនរងាកនោះ គឺតំណាងឲ្យព្រះមាតានាគ ឬមាតាមហានគរ ដែលគាត់បានដេកស្លាប់ចេញពីបេះដូងកូនក្មេររាប់រយឆ្នាំហើយ គឺក្រោយពេលដែលក្មេរបោះបង់ចោលក្រុងអង្គរ ឬយសោធបុរៈ ព្រោះគាត់ពុំអាចចេញពីទីឃុំបានទៀតឡើយ។ ហើយក្នុងរូបនេះ បានប្រាប់ថាមានកូននាគម្នាក់ កំពុងតែចុះស្រង់ និងប្រស់គាត់ឲ្យរស់ឡើងវិញ ក្នុងដួងចិត្តកូនក្មេរប្រុសស្រី **ចង់ឲ្យមាតុភូមិនេះ ក្លាយជារាជាណាចក្រអច្ឆរិយពិតប្រាកដ** យើងត្រូវតែស្វែងរកអាទិទេពដែលជាអ្នកបង្កើតដែនដីអច្ឆរិយនេះឲ្យឃើញ បើពុំនោះទេ ពាក្យអច្ឆរិយនេះ គឺមានតែស្រមោលនៃពាក្យតែប៉ុណ្ណោះ។

សរុបសេចក្តីមក អត្ថន័យភាសារូបក្នុងប្រាសាទបន្ទាយស្រី គឺបានបង្ហាញប្រាប់រឿងបន្តគ្នា ពីខ្លោងទ្វារមួយទៅខ្លោងទ្វារមួយ ពីផ្តែរមួយទៅផ្តែរមួយ ពីក្បាំងក្លែងមួយទៅក្បាំងក្លែងមួយ បន្តរហូតគ្រប់ប្រាសាទថ្ម ដែលមានក្នុងដែនដីព្រះម៉ែនេះ។ ព្រោះគាត់បានដឹងថា ទៅថ្ងៃអនាគត ពួកបរទេស និងកូននាគដែលពុំយល់ពុំដឹង ច្បាស់ជាបំផ្លាញប្រវត្តិសាវតាពិតរបស់គាត់ជាពុំខាន ព្រោះគាត់បានបង្កូរគំនិតចារឹកទុកក្នុងថ្មធ្វើឲ្យថ្មទាំងនោះ ចេះនិយាយប្រាប់នៅរឿងរ៉ាវពីអតីត បច្ចុប្បន្ន អនាគត សំរាប់ជាមរតកគំនិតទុកឲ្យកូននាគជំនាន់ក្រោយ មើលរួចពិចារណា។ បើប្រាសាទថ្មរបស់ក្មេរ ត្រូវបានដាប់គាស់បំផ្លាញអស់ទៅហើយនោះ មិនខុសណាពីពាក្យនិយាយរបស់កូននាគ ដែលពុំយល់ដឹងគាត់តែងពោលតគ្នាថា ទៅមើល**ប្រាសាទទាំងនោះ ពុំដឹងទៅមើលអ្វីទេ គឺទៅមើលតែដុំថ្មតែប៉ុណ្ណោះ** នេះជាសំដីពិត ដែលខ្ញុំធ្លាប់បានឮកូនក្មេរគេនិយាយ។

# ៣៥/.រូបភាពទី៣៥រូបក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)

រូបភាពក្នុងក្បាំងក្លែងនេះ ត្រូវបែងចែកជាពីជាន់ ជាន់ក្រោមមានរូបគ្រុឌមួយនៅកណ្ដាល ចំណែកនៅចុងសង្ខាង មានតោកំពុងផុសលេចចេញពីព្រៃក្បាច់ ដែលព្រៃក្បាច់នោះ មានរាងនិមិត្ត រូបជាខ្លួននាគ។ ចំណែកជាន់ខាងលើ មានស្ត្រីម្នាក់ពាក់មកុដទ្រង់គ្រឿងជាស្ដេច គង់លើផ្កាឈូកចំកណ្ដាលពីលើក្បាលគ្រុឌ បង្អែកបល្ល័ង្កខាងក្រោយ មានរាងជានិមិត្តរូបនាគក្បាល៩ ហើយនៅសង្ខាងស្ត្រីនោះ មានដំរីពីរកំពុងបូងរបស់អ្វីមួយរាងដូចជាត្រាផែនដី។ នៅខាងចុងក្បាំងក្លែង មានរូប



តោ កំពុងចេញពីមាត់យក្សសង្ខាង ដោយនៅក្នុងមាត់តោទាំងពីនោះ មានពាំគប់ភ្លើង ដែលចុងរបស់គប់ភ្លើងនោះ សំយ៉ុងចុះក្រោម តើរូបភាពទាំងអស់ក្នុងក្បាំងក្លែងនេះ គាត់ចង់និយាយប្រាប់យើងពីអ្វី?

**ក**/.រូបគ្រុឌតំណាងឲ្យសេនាយក្ស និមិត្តរូបសៀម ដែលដៃគ្រុឌទាំងពីរកំពុងចាប់ក្បាច់ និមិត្តរូបនាគសង្ខាង (មាតុភូមិ ឬភូមិនាគ) ហាក់បីដូចជាមិនចង់ឲ្យតោដែលនៅខាងចុងខ្លួននាគនិមិត្តរូបនោះចេញពីក្នុងព្រៃក្បាច់នោះរួច ដើម្បីស្រែកប្រាប់រឿងស្ត្រីខាងលើ។ តែគ្រុឌមិនអាចចាប់ជាប់រហូតបានឡើយ ព្រះអង្គទ្រង់ត្រាស់សម្ដែងថា **នត្ថកម្មំ សមំពលំ** កម្លាំងអ្វីស្មើដោយកម្លាំងកម្ម គឺពុំមានឡើយ បាបកម្មក្ដី បុញ្ញកម្មក្ដី តែដល់ពេលត្រូវឲ្យនៅកម្មវិបាកហើយ ទោះបីកម្លាំងឫទ្ធិរបស់បុគ្គលណាមួយ

ចង់ទប់ ឬឃាត់ គឺពុំបានឡើយ ដូចមានបង្ហាញក្នុងរូបភាពរបស់គ្រុឌនេះស្រាប់ ទោះបីជាខំប្រើកម្លាំងឫទ្ធិទាញទប់កុំឲ្យតោចេញមកខាងក្រៅ ដើម្បីស្រែកប្រាប់រឿង ក៏ពុំអាចឃាត់ឃាំងបានឡើយ។

**ខ**/.រូបតោពីរ តំណាងឲ្យទីក្រុងដែលមានតោពីរ (ក្រុងព្រះសីហនុ) តោនៅពីខាងឆ្វេងដៃគ្រុឌ ខំរើខ្លួនចេញ ខំស្រែក តែពុំទាន់អាចស្រែកប្រាប់រឿងខាងលើបានឡើយ ព្រោះក្បាច់ដែលចេញពីមាត់តោ តំណាងឲ្យសម្លេងនោះ មិនទាន់អាចតភ្ជាប់ទៅខាងលើបាន។ រីឯតោនៅខាងស្ដាំដៃគ្រុឌវិញ ខំរើថែមទៀត ទើបឃើញលេចចេញជើងមួយចំហៀងទៀត ចំណែកសម្លេងដែលចេញពីមាត់តោ គឺអាចស្រែកប្រាប់ពីរឿងអាថ៌កំបាំងស្ត្រីខាងលើបានហើយ ព្រោះក្បាច់ដែលចេញពីមាត់តោ មានសំណុំក្បាច់ធំ ហើយតភ្ជាប់គ្នារហូត។

**គ**/.រូបស្ត្រីដែលពាក់មកុដរាជ និងពាក់គ្រឿងអលង្ការ អង្គុយលើបល្ល័ង្កផ្កាឈូក ពីខាងលើក្បាលគ្រុឌនោះ តំណាងឲ្យមាតាមហានគរ ឬព្រះមាតានាគ ពេលដែលកូននាគទូទាំងនគរបានដឹងពីរឿងអាថ៌កំបាំងរបស់ខ្លួនហើយ អំណាចគាត់អាចអង្គុយ ឬសង្កត់ពីលើគ្រុឌបាន។ ឬទ្ធានុភាពរបស់គាត់អាចផ្សាយទូទៅក្នុងលោកបាន ព្រោះបង្អែកនៅពីខាងក្រោយគាត់នោះ បង្ហាញពីមហិទ្ធិឬទ្ធិដែលផ្សាយចេញពីខ្លួនគាត់ (និមិត្តរូបនាគក្បាល៩)។

**ឃ**/.ដំរីដែលនៅសង្ខាង តំណាងឲ្យក្បាលដំរី ដែលបែកចេញជាបី ឬស្ត្រីដែលត្រូវបែកជាបីនោះ ត្រូវបានបង្រួមឲ្យទៅជាមួយឡើងវិញ ព្រោះដំរីសង្ខាងបានបួងនៅត្រាផែនដី មកប្រគល់ឲ្យម្ចាស់ដើម ដែលជាអ្នកបង្កើតដែនដីនាគពីអតីត។ បើយើងមើលបង្អែកបល្ល័ង្កក្បាលនាគនិមិត្តរូបនៅពីខាងក្រោយ យើងច្បាស់ជាយល់ថា អនាគតកាលរបស់មាតានាគរបស់យើងគាត់មានមហិទ្ធិឬទ្ធិខ្លាំងណាស់ ព្រោះតែឫទ្ធិនេះ ទើបពួកបរទេសគេដឹង គេបិទសន្ធប់ មិនចង់ឲ្យគាត់ចេញមកខាងក្រៅរួច សូម្បីតែរូបគ្រុឌនៅខាងក្រោម ក៏ខំទប់ទាញកុំឲ្យតោរើខ្លួនចេញពីព្រៃរួច ដើម្បីស្រែកប្រាប់ពីអាថ៌កំបាំងរបស់គាត់។ ខ្ញុំធ្លាប់ឮចាស់ៗនិយាយតៗគ្នាថា "**នឹងមានស្ដេចសតូចស្ដើង សោយរាជ្យនគរបី**" ប្រហែលជាគាត់មើលរូបចម្លាក់នេះយល់ ហើយគាត់តាក់តែងទំនាយទុក សម្រាប់ជាមរតកកូនខ្មែរតទៅថ្ងៃអនាគតទេដឹង? ព្រោះបើមើលតាមអត្ថន័យរូប ដែលខ្ញុំបានពន្យល់ដោយសង្ខេបនេះ យើងអាចនឹងយល់បានថាក្នុងអនាគតខាងមុខ គាត់នឹងបង្រួមដែនដីនាគនេះ ដែលត្រូវបែកជាបីចំណែកនោះ ឲ្យរួមមកតែមួយវិញ (ដំរីក្បាលមួយ)។

**ង**/.រូបតោសង្ហាងនៅខាងចុងក្បាំងក្លែង ដែលកំពុងរើខ្លួនចេញពីមាត់យក្ស គឺតំណាងឲ្យទីក្រុងតោពីរនេះដដែល ខាងក្នុងក្បាំងក្លែងខំរើខ្លួនចេញពីអំណាចគ្រុឌជាសេនា តោពីរខាងក្រៅខំរើខ្លួនចេញពីអំណាចយក្ស ដែលជាម្ចាស់ពៀរ ហើយជាសោចាក់ឃុំម៉ែឪកូនពីដើមដំបូង (មើលការពន្យល់រូបភាពមុនៗ)។ ភាគច្រើននៅចុងក្បាំងក្លែងគ្រប់ប្រាសាទខ្មែរ គាត់តែងឆ្លាក់ក្បាលនាគត្រូវយក្សលេបមានភាគតិចណាស់ដែលគាត់ឆ្លាក់តោ គ្រុឌ រាជសី.....ចេញពីមាត់យក្ស ហើយប្រស្នារូបទាំងនេះ គាត់ទុកឲ្យយើងជាកូននាគ មើលរួចឆ្ងល់ៗរួចគិត ដើម្បីស្រាវជ្រាវរករឿងពិតរបស់រូប ព្រោះសិល្បព្រះម៉ែពុំមែនសិល្បដើម្បីសិល្ប គឺជាសិល្បអច្ឆរិយ ឬសិល្បអរូបីយ។ ចំណែកឯមាត់តោពាំគប់ភ្លើងសំយ៉ុងចុះ គាត់ចង់ប្រាប់យើងថា តោពុំទាន់មានកម្លាំងគ្រប់គ្រាន់ អាចលើកគប់ភ្លើងបញ្ឈរដើម្បីបំភ្លឺរឿងពិតពីអតីតរបស់គាត់ដែលត្រូវបានលុបក្នុងពិភពងងឹតឲ្យភ្លឺឡើងវិញ គប់ភ្លើងនោះ តំណាងឲ្យកែវភ្នែកមាតាទាំង**១២** ដែលយក្សបានខ្វេះយកទៅ។ សរុបសេចក្តីមក ភាសាគំនិតដែលបានបង្កប់ក្នុងចម្លាក់ក្បាំងនេះ គឺបានបង្ហាញនឹងបញ្ជាក់ប្រាប់យើង ពីពេលវេលាដែលព្រះម៉ែ និងតោអាចចេញពីមាត់យក្សរួច ហើយយើងក៏មានសេចក្តីសង្ឃឹមថា តោទាំងពីររួមទាំងព្រះម៉ែនាគនឹងអាចរួចផុតពីអំណាចបាបកម្មនេះជាពុំខាន។

## ៣៦/.រូបភាពទី៣៦រូបយក្សនិងក្មេងតូច(ប្រាសាទបាគង ឬបាគង់)



ក្នុងរូបភាពនេះបានបង្ហាញ ពីតួអង្គយក្សជាច្រើន ហើយក្នុងចំណោមយក្សដ៏ច្រើននោះ មានក្មេងតូចម្នាក់ កំពុងហោះកាត់ពីខាងមុខយក្ស តើក្នុងរូបភាពនេះ ព្រឹទ្ធដូនតាគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

**ក**/.យក្សតំណាងឲ្យ អ្នកដាក់ទោសមាតាបិតារួមទាំងញាតិវង្សាគាត់ពីអតីតកាល (មើលការពន្យល់រូបមុន)។

**ខ**/.រូបក្មេងតូចតំណាងកូននាគ ដែលត្រូវទៅស្រាវជ្រាវរឿងអាថ៌កំបាំង ដែលលាក់ម្ដាយទុកក្នុងទីឃុំដ៏ជ្រៅនៅឯឋានយក្ស សកម្មភាពរបស់ក្មេងតូចនេះ ហាក់បីដូចជាមានឫទ្ធិណាស់ ព្រោះគាត់អាច កាច់បំបាក់អាវុធរបស់យក្សបាន មិនតែប៉ុណ្ណោះ គាត់ហ៊ានទៅរុករុកក្នុងដែនដីយក្ស ដោយគ្មានខ្លាចញញើតចំពោះយក្សឡើយ។ តែគួរឲ្យអនិច្ចាចំពោះក្មេងនេះណាស់ បរទេសដឹងរឿង គេបានជួលជនទុច្ចរិតឲ្យដាប់បំបាក់ដៃស្ដាំរបស់គាត់បាត់ទៅហើយ ពេលដែលដៃនោះកំពុងឈោងយករបស់ម្យ៉ាងខាងក្រោយឆ្អកក្បិនយក្ស ព្រោះគេឧបកិច្ចឲ្យកូននាគនោះ ពិការ ឬស្លាប់ដើម្បីកុំឲ្យសម្រេចបំណងបាន។ ហេតុអ្វីបានជាបរទេសចូលចិត្តជួលពួកទុច្ចរិតឲ្យដាប់រូបចម្លាក់តាមប្រាសាទ? (ដែលភាសាអ្នកប្រកបរបរនោះ គេហៅថាអ្នកជួញដូរក្បាលអ្នកតា) ព្រោះបរទេសគេសិក្សាស្រាវជ្រាវទៅដឹងថា ប្រវត្តិពិតរបស់បុព្វជនជាតិនេះ បានចារឹករឿងរបស់ខ្លួនទុកនៅក្នុងថ្ម (សិលាចារឹក) ដែលនិយាយប្រាប់ពីរឿងក្នុងអតីតកាល បច្ចុប្បន្នកាល អនាគតកាល ពុំមែនសរសេររឿងទុកក្នុងស្លឹក ក្នុងស្បែក ឬក៏ក្នុងវត្ថុផ្សេងៗឡើយ គឺពួកគាត់យកទៅទុកក្នុងថ្ម ចំណែកឯរឿងដែលកើតក្នុងស្លឹក ស្បែក ក្រដាស គឺចម្លងចេញពីក្នុងថ្មទាំងនោះ។ ហើយភាសារូបនៅក្នុងថ្មទាំងនោះ គាត់បានឆ្លាក់លាយឡំបង្កប់ជាមួយនឹងក្បាច់លម្អ លាយឡំបំភាន់ជាមួយរឿងក្នុងសាសនា ដោយកូននាគជាអ្នកឆ្លាក់ទាំងនោះ ពុំបានបញ្ចេញឈ្មោះ ឬនាម នៅក្នុងថ្មចារឹកទាំងនោះឡើយ គឺអ្នកឆ្លាក់ទាំងនោះ ជាកំពូលជន**អនាមិក**។ ក្នុងវិជ្ជាមន្តរបស់ព្រហ្មញ្ញសាសនា មានវិជ្ជាមួយនៅក្នុងគម្ពីរអថវេទ វិជ្ជានេះ គេសូនរូបបុគ្គលដែលគេចង់ធ្វើបាបនោះ រួចសរសេរឈ្មោះថ្ងៃខែឆ្នាំកំណើត រួចគេប្រើមន្តសូត្រឧបកិច្ចកាត់ដៃកាត់ជើង ឬកាត់ក ដើម្បីឲ្យបុគ្គលដែលគេព្យាបាទនោះ វិនាស ដូចជាស្ដេចជ័យវរ្ម័នទី២ ធ្លាប់ឲ្យព្រាហ្មណ៍ជារាជគ្រូសម័យនោះ ធ្វើពិធីឧបកិច្ចកាត់កស្ដេចជ្វា ក្នុងពេលដែលព្រះអង្គធ្វើពិធីទេវរាជតែងតាំងខ្លួនជាស្ដេចចក្រវាល (ឥសូរ)។ ហើយវិជ្ជានេះ បានបន្សល់ទុករហូតមកដល់សព្វថ្ងៃ ក្នុងដែនសុវណ្ណភូមិ ដែលខ្មែរយើងនិយមហៅថា វិជ្ជាធ្មប់ (អ្នកចេះធ្វើអំពើធ្មប់) ហើយអ្នកដែលនៅចេះប្រើ

វិជ្ជាធ្មប់នេះ ពេលដែលគេចង់ព្យាបាទនរណាម្នាក់ គេតែងធ្វើដូចវិធីខាងលើ។ ដូច្នេះពួកបរទេសដែលបានដឹងអាថ៌កំបាំងក្នុងថ្ម គេដឹងថារូបចម្លាក់គ្រប់ប្រាសាទនៅតាមជញ្ជាំង ផ្ដែរ ក្បាំងក្លែង.....តែងមានមនុស្សម្នាក់មកជិះគ្រុឌ និងជាន់ ឬអង្គុយលើក្បាលយក្ស ដើម្បីឲ្យព្រមដោះលែងមាតា ដែលពួកគេបានចាប់ឃុំ ហើយរូបបុរសនោះ គេតាងនាមឲ្យគាត់តាមសម័យកាល ម្ដងព្រះវិស្ណុ ឥសូរ ព្រះព្រហ្មលោកេស្វរ:.... ក្នុងរឿងព្រេង គាត់តាងនាមឲ្យផ្សេង ឧ.បក្សីចាំក្រុង ព្រហ្មកិល ពុទ្ធសែន...។ល។ ហើយបុរសនោះ គេតាមរកគាត់ពុំឃើញឡើយ ព្រោះគាត់ស្ថិតក្នុងព្រៃមនុស្ស ចំណែកសំណាករបស់គាត់ដែលដូនតាបានឆ្លាក់ឡើង គឺមាននៅក្នុងថ្ម ដើម្បីសម្លាប់គាត់មានតែប្រើវិធីឧបកិច្ច កាត់ករូបក្នុងថ្មនោះម្យ៉ាងៗទៀត បើកាត់ករូបចម្លាក់នោះ ពុំបានជោគជ័យ ក៏គេបានប្រយោជន៍ពីរដែរ គឺបានបំផ្លាញឯកសារពិតក្នុងថ្ម។ បើមិត្តអ្នកអានបានទៅទស្សនា រូបតាមប្រាសាទនានាទើបដឹងថា ជារឿងគួរឲ្យសង្វេគ ព្រោះរូបចម្លាក់ក្នុងផ្ដែរខ្លះ មានទំហំប៉ុនមេដៃមេជើង ក៏គេដាប់បំផ្លាញចោលដែរ ឲ្យតែគេសង្ស័យថា ជារូបបុរសនោះ ទីបំផុតគ្រប់ប្រាសាទខ្មែរ រូបចម្លាក់ភាគច្រើនគឺពុំមានក្បាល ពុំមានដៃ....។ល។ ដោយគេមិនចង់ឲ្យបុរសនោះមានជីវិតនៅរស់ ដើម្បីមកជួយស្រង់ប្រស់មាតាឲ្យលោករស់ក្នុងសន្ដានចិត្តកូននាគប្រុសស្រីឡើយ ព្រោះមាតានាគគាត់បានដេកស្លាប់ រាប់រយឆ្នាំទៅហើយ សព្វថ្ងៃគឺនៅសល់តែកេរមរតកគាត់តែប៉ុណ្ណោះ ចំណែកឯអ្នកទទួលកេរមរតកនេះ គេពុំបានស្គាល់គាត់ឡើយ។ យ៉ាងណាមិញ រូបក្មេងតូចក្នុងប្រាសាទបាគងនេះ វាសនារបស់រូបក៏មិនសូវខុសពីរូបនៅប្រាសាទផ្សេងៗទៀតដែរ បើដៃ ឬក្បាលរបស់គាត់ ត្រូវគេដាប់បាត់ទៅហើយ តើគាត់មានកម្លាំង និងជីវិតអ្វីអាចមកជួយមាតាបិតាមហានគរបាន ឬគាត់ជាមនុស្សពិការ តើអាចធ្វើអ្វីកើត សូម្បីតែជួយខ្លួនឯង ក៏ជួយសឹងពុំបានផង។ នេះជាការពន្យល់ប្រៀបធៀបរូបចម្លាក់នៅតាមប្រាសាទនានា ដែលធ្លាក់ខ្លួនពិការបាក់បែក ព្រោះមានហេតុខាងដើមដូចដែលខ្ញុំបានពន្យល់ រៀបរាប់ដោយត្រួសៗមកនេះ ទុកជាទុនសម្រាប់កូននាគពិចារណា ពីហេតុដែលនាំឲ្យគេដាប់រឿងក្នុងបេះដូង មេនាគរបស់យើងដែលទុកក្នុងថ្ម។

# ៣៧/.រូបភាពទី៣៧រូបផ្តែរប្រាសាទបន្ទាយស្រី(សារមន្ទីរជាតិភ្នំពេញ)



តើក្នុងរូបភាពផ្តែរនេះ ព្រះមាតានាគលោកចង់ប្រាប់កូននាគពីរឿងអ្វី?

**ក**/.ចំកណ្តាលផ្តែរមានរូបព្រះវិស្ណុបែងភាគដៃបួន កំពុងជាន់ពីលើសត្វគ្រុឌ ដែលដៃគ្រុឌមួយចំហៀងលើកផ្ទារឡើង គាបជើងស្តាំជាប់ ដៃគ្រុឌមួយចំហៀងទៀតចាប់ជង្គង់ជើងឆ្វេង ដែលបត់ហាក់បីដូចជាមិនចង់ឲ្យព្រះវិស្ណុងើបឈរបានឡើយ។ ហើយនៅខាងលើក្បាលរបស់ព្រះវិស្ណុ មានគម្របមួយគ្របពីលើជិត ហើយគម្របនោះរាងដូចក្បាំង ឬខ្លោងទ្វារ ប្រៀបបីដូចជាអង្រឹតក្រុងពីលើដៃទាំងបួនរបស់រូប ដៃស្តាំពីរ ដៃមួយកាន់ដំបូល មួយទៀតមានសោផ្កាចន្ទន៍នៅពីលើបាតដៃ ដៃឆ្វេងម្ខាងកាន់ខ្យងស័ង្ខ ដៃមួយទៀតកាន់រាជសារ។

ព្រះវិស្ណុតំណាងឲ្យកូននាគ ដែលត្រូវចុះមកជួយស្រង់ប្រស់ព្រះមាតាមហានគរ ដែលគ្រុឌជាសេនាយក្ស កំពុងក្រុងគ្របលាក់ទុករូបគាត់កុំឲ្យកូននាគដឹង តែពេលនេះព្រះវិស្ណុគាត់ពុំទាន់មានកម្លាំងឡើងឈរជាន់លើគ្រុឌបានទេ តែគ្រុឌគេក៏ពុំព្រមចុះចាញ់ឡើយ ព្រោះអាងអំណាចរបស់យក្សដែលបានចាប់ព្រះម៉ែកនាគឃុំ ជាយូរយាណាស់មកហើយ រឿងអ្វីគេត្រូវដោះលែង។ ចំណែកសត្វគ្រុឌវិញ តំណាងឲ្យសៀម ព្រោះរាជវង្សសៀមនិមិត្តសញ្ញារបស់គេ គឺគ្រុឌ គ្រុឌនេះហើយដែលបានក្រុងគ្របរឿងពិតក្នុងនគរ (ពន្យល់ក្នុងរូបភាពទី១៦ ១៧ ១៨ និងក្នុងរឿងបក្សីចាំក្រុង)។ ដៃព្រះវិស្ណុទាំងបួន ដៃកាន់ដំបូល តំណាងឲ្យរឿងរបស់មាតាមហានគរ ដៃកាន់ផ្កាចន្ទន៍ តំណាងឲ្យកូនសោផ្កាចន្ទន៍

សម្រាប់បើកមេសោផ្កាចន្ទន៍ទាំងប្រាំ នៅលើទ្វារថ្មបញ្ឆោតដែលមានគ្រប់ប្រាសាទ ឯដៃកាន់ខ្សែសង្វាតំណាងឲ្យឧបករណ៍ សម្រាប់ផ្ដិតដាស់កូននាគកំពុងដេកលក់ ដៃកាន់រាជសារ តំណាងឲ្យសាសនព្រះម៉ែមហានគរ។

**ខ**/.រូបក្បាលនាគតូចៗចំនួនប្រាំ ដែលផុសចេញពីខ្លួននាគនិមិត្តរូបយក្សលេប តំណាងឲ្យមាតាមហានាគលោករួចចេញម្ដងបន្តិចៗ រហូតមកដល់ចុងផ្ដែរ ទើបគ្រុឌព្រមលើកដៃឡើង ក្អែនាគចេញមកក្រៅទាំងស្រុង (ព្រមចុះចាញ់ដោះលែងនាគ)។ ក្បាលនាគដែលក្អែចេញពីមាត់គ្រុឌនោះ មានទំហំធំខុសពីក្បាលនាគតូចៗប្រាំខាងដើម គ្រុឌទាំងសង្ខាងព្រមលើកដៃចុះចាញ់អំណាចកូននាគ គឺព្រះវិស្ណុ ដែលគាត់អាចមានឫទ្ធិ គឺគុណធម៌អាចជាន់គ្រុឌ និងយក្សឲ្យដោះលែងព្រះមាតានាគបាន។ សាច់រឿងនៅក្នុងផ្ដែរនេះ មានតួរអង្គតែបីប៉ុណ្ណោះ តួរអង្គទីមួយគឺព្រះវិស្ណុ តួរអង្គទីពីរគឺគ្រុឌ រីឯតួរអង្គទីបីគឺព្រះមាតាមហានាគ ដូច្នេះទើបរឿងនេះ ពុំអាចមាននរណាដឹងឡើយ ក្រៅពីតួរអង្គទាំងបីក្នុងផ្ដែរនេះ រួមទាំងយក្ស ដែលបានលេបនាគ (ខ្លួននាគក្នុងផ្ដែរនេះ និមិត្តរូបគឺយក្សលេប)។

**គ**/.ឯជាន់ខាងលើ គឺនិយាយពីតួរអង្គព្រះវិស្ណុ ដែលនៅតូចមិនទាន់មានកម្លាំងគ្រប់គ្រាន់ (គុណធម៌) ដើម្បីចុះក្នុងសមុទ្រទឹកដោះ ជាន់យក្ស និងគ្រុឌ ដែលបានចាប់ព្រះមាតាឃុំនោះ ហើយរូបតូចៗទាំងនេះ ចំណុចកណ្ដាល គឺកំពូលក្បាំងខាងក្រោម។ សកម្មភាព និងកាយវិការរូបខាងលើគឺជាអ្នកសិល្ប ព្រោះគេឆ្លាក់គាត់លើកដៃរាំ តែយើងមិនដឹងថា ជាសិល្បអ្វីឡើយ ព្រោះវាជាប្រស្នាគំនិតក្នុងភាសារូប ការពន្យល់ពីរូបភាពនេះ ខ្ញុំចង់ឲ្យកូននាគ ចេះពិនិត្យមើលអាថ៌កំបាំងក្នុងភាសារូប យើងជាកូននាគត្រូវតែដឹងរឿងក្នុងបេះដូងនាគ ដូចរឿងក្នុងផ្ដែរនេះ ជាតឹកតាងស្រាប់។ បើយើងមើលពុំបានពិនិត្យ និងល្បែងយល់ទេ យើងច្បាស់ជាមើលពុំឃើញក្បាលនាគតូចទាំងប្រាំ ដែលគាត់ឆ្លាក់បង្កប់ក្នុងក្បាច់ និងក្បាលទីប្រាំមួយ ដែលគ្រុឌក្អែចេញមកខាងក្រៅនោះឡើយ។ ហើយបើយើងពុំបានដឹងបុព្វហេតុពីខាងដើមទេ ហេតុខាងចុងក៏ពុំអាចរកសុខពិតបានដែរ ដូចជាអាថ៌កំបាំងព្យញ្ជនៈខ្មែរយ៉ាងដូច្នោះ តួរអក្សរ**ក**ជាអ្នកផ្ដើម **កកើត**នៅមរតកគ្រប់បែបយ៉ាងក្នុងទឹកដីនេះ ហើយចុងបញ្ចប់យើងអាចសប្បាយសុខស្រួលបាន ដោយព្យញ្ជនៈបញ្ចប់ គឺ**អ** ពាក្យថា**អអ**មានន័យថា **អ**មួយសែងស្ពានទៅភ្ជាប់**អ**ពីរ (អ អ) ទើបកើតជា**អអ**បាន។ **អ**ទីមួយគឺរឿងក្នុងអតីតកាល **អ**ទីពីរគឺរក្នុងបច្ចុប្បន្នកាល **អ**ទីបីគឺកូនដែលត្រូវសែងស្ពានទៅតភ្ជាប់**អ**ទីមួយ និង**អ**ទីពីរឲ្យរួមគ្នា ទើបអាចរកសេចក្ដីសុខត្រេក**អអ**បា

ន។ ហើយតួអង្គកូន ដែលត្រូវជួយស្រង់មាតាបិតាមហានគរ គឺមានឈ្មោះនៅគ្រប់តួព្យញ្ជនៈទាំង ៣៣តួនោះឯង ហើយយើងកុំច្រឡំគំនូសកណ្ដាលព្យញ្ជនៈ**ម** និង**អ** ថាវះពោះឲ្យសោះ ពាក្យថាវះពោះ គឺកាត់ផ្ដាច់ចេញពីគ្នា វាផ្ទុយពីដាក់ស្ពាន គឺតភ្ជាប់គ្នាពីម្ខាងទៅម្ខាង។ យើងកាន់តែស្រាវជ្រាវ ទើបយើងដឹងថា យើងជាពូជព្រះនាងនាគ យើងជាកូននាគពិត តែពូជនាគត្រូវបានគេបន្សាបពិសអស់ទៅហើយ សព្វថ្ងៃយើងជាកូននាគបានក្លាយទៅជានាគត្រូវគេបន្សាបពិសអស់ទៅហើយ ព្រោះពិសរបស់នាគ បានបន្សាបតៗមករាប់ពាន់ឆ្នាំហើយ (អាចិកំបាំងក្នុងមង្គលការ បុកល័ក្ខ ធ្វើធ្មេញ បន្សាបពិសនាគ គឺពិសព្រះនាងនាគ) ហើយកូននាគ និងព្រះនាងនាគ ដែលនៅមានសព្វថ្ងៃ សល់តែឈ្មោះប៉ុណ្ណោះ ហើយឈ្មោះនេះ និងត្រូវលុបបន្តិចម្ដងៗ ចេញពីសន្តានកូនខ្មែរទៀត ព្រោះសព្វថ្ងៃ វប្បធម៌បរទេស បានកំពុងលុកលុយចូលទៅក្នុងបេះដូងកូននាគស្រករក្រោយ។

## ៣៨/.រូបភាពទី៣៨រូបផ្ដែរ(ប្រាសាទព្រះគោ)



ក្នុងរូបភាព ចម្លាក់ប្រាសាទព្រះគោនេះ តើគំនិតដូនតាគាត់បាននិយាយប្រាប់យើង ពីរឿងអ្វី?

**ក**/.មនុស្សលើកដៃរាំ នៅលើក្បាលយក្ស គឺតំណាងឲ្យកូននាគ ដែលចុះមកបង្ក្រាបយក្ស ឲ្យលែង ព្រះមាតានាគហើយបុគ្គលនេះ ខ្ញុំបានពន្យល់ក្នុងរូបមុនៗរួចហើយ។

**ខ**/.យក្ស ដែលត្រូវកូននាគជាន់ក្បាលពីលើនោះ គឺតំណាងអ្នកចាប់ព្រះមាតានាគពីអតីតកាល កំពុងចាប់ហែកមាត់ខ្លួនឯង ដោយដៃទាំងពីរ។

ក្បាច់ដៃលយក្សចាប់ទាញនោះ តំណាងឲ្យរាជបញ្ជាខ្លួន ដែលបានចាប់

ឃុំព្រះម៉ែនាគ ព្រោះនៅដៃខាងឆ្វេង មានខ្លួននាគពាក់នៅលើកំភួនដៃ រីឯកនាគស្ថិតនៅក្នុងដៃគ្រុឌ។

**គ**/.គ្រុឌ ដែលកំពុងចាប់ខ្លួននាគបន្តពីយក្ស (សេនាយក្ស) ឈរជ្រែងចាប់នាគទាំងសង្ខាង ព្រោះរូបភាពនេះ មានក្បាលយក្សសង្ខាង ហើយនាគសង្ខាងនេះ គឺតំណាងឲ្យអតីតកាល និងបច្ចុប្បន្ន ព្រោះនៅពីខាងស្ដាំមុន ខាងឆ្វេងគឺក្រោយ។

**ឃ**/.ព្រះវិស្ណុ ដែលជាន់យក្ស ឥឡូវគាត់មកជាន់គ្រុឌហើយ រូបគាត់រីកធំជាងមុន មានបែងភាគដៃបួនរួចជិះពីលើគ្រុឌ កំពុងប្រឹងក្រោកឈរឡើង សង្កត់ឲ្យគ្រុឌលែងមាតានាគ ព្រោះក្បាលនាគនិមិត្តរូបឲ្យមាតានាគ ត្រូវគ្រុឌផ្ដក់ដៃទាញកជាប់។ រូបព្រះវិស្ណុ គឺតំណាងឲ្យកូននាគ ដែលត្រូវចុះទៅជួយដោះបាបកម្មចាស់ឲ្យដូននាគ ព្រោះពាក្យដូនក្លាយមកពីពាក្យសណ្ដូន ពាក្យជីដូន គឺមានន័យថា ជីទៅសណ្ដូនស្រង់ប្រស់យាយនាគ ពីក្នុងសមុទ្រទឹកដោះ (សមុទ្រទុក្ខ) ព្រោះពាក្យជីខ្ញុំបានពន្យល់នៅក្នុងភាគមុនរួចហើយ (ជីសូរ ជីក្រែង ជីលា ជីហែ...)។

សរុបសេចក្ដីមក រូបចម្លាក់ប្រាសាទព្រះគោនេះ (ឈ្មោះព្រះគោបានពន្យល់ហើយក្នុងភាគពីរ) អត្ថន័យក្នុង រូបក៏មិនខុសពីប្រាសាទផ្សេងៗទៀតឡើយ គ្រាន់តែការឆ្លាក់របស់ពួកគាត់ គឺជាសិល្បបំភាន់រូបទៅក្នុងក្បាច់ ដើម្បីកុំឲ្យគេចាប់អារម្មណ៍ បើយើងមើលពុំបានពិនិត្យឲ្យច្បាស់លាស់ទេ ពិតជាពុំឃើញសាច់រឿងក្នុងចិត្តរបស់គាត់ឡើយ។

## ៣៩/.រូបភាពទី៣៩រូបផ្ដែរ(ពុំដឹងប្រភព)



*រូបភាពផ្ទៃរនេះ មានរូបភាពស្រដៀង និងផ្ទៃរមុន គ្រាន់តែក្នុងផ្ទៃរនេះ ពុំមានរូបយក្សតែប៉ុណ្ណោះ តើម៉ែគាត់ផ្ដាំឲ្យយើងមើលរឿងអ្វី នៅក្នុងប្រស្នាចម្លាក់នេះ?*

***ក***/.*នៅចំកណ្ដាលផ្ទៃរជាន់ទីមួយមានរូបព្រះវិស្ណុ រូបគាត់បានបែងភាគដៃបួន ដែលកំពុងប្រឹងក្រោកឈរឡើងជាន់គ្រុឌ ឲ្យលែងនាគទាំងពីរជាន់ នាគមួយគូនៅក្នុងអន្ទាក់ដៃគ្រុឌ នាគមួយគូទៀតនៅក្រោមក្រញាំជើងគ្រុឌ ដើម្បីឲ្យគ្រុឌព្រមចុះចាញ់ ដោះលែងនាគទាំងពីរជាន់នោះ។*

***ខ***/.*រូបគ្រុឌនៅជាន់ទីពីរ ក្នុងដៃគ្រុឌទាំងសង្ខាង មានចាប់ត្រកងកនាគក្បាលបី ហើយចំណែកនៅក្រោមក្រញាំជើងគ្រុឌ មាននាគក្បាលមួយ រាងដូចជាពស់ ត្រូវជើងគ្រុឌជាន់ជាប់ត្រឹមក (មើលការពន្យល់រូបមុន)។*

***គ***/.*តើនាគក្បាលបី នៅពីលើដៃគ្រុឌសង្ខាង និងនាគក្បាលមួយ នៅក្រោមជើងគ្រុឌសង្ខាង តំណាងឲ្យអ្វី? នាគក្បាលបីនៅពីខាងលើ តំណាងឲ្យដូននាគ យាយនាគ ព្រះមាតានាគ ពីអតីតព្រោះសម័យមុនគាត់មានឫទ្ធិអាចបែងភាគខ្លួនបានជាបី ប្រាំ ប្រាំពីរ....។ល។ ឯនាគក្បាលមួយ នៅពីខាងក្រោមជើងគ្រុឌ គឺតំណាងឲ្យកូននាគសម័យខាងក្រោយ ព្រោះកន្ទុយនាគក្បាលមួយនេះ បានពាក់តពីខ្លួននាគខាងលើ មានន័យថា កូននាគខាងក្រោម ជាតំណពូជពង្សមេនាគខាងលើ។ តែគួរឲ្យអនិច្ចានឹងសង្វេគខ្លួនណាស់ នាគទាំងខាងលើ និងខាងក្រោម សុទ្ធតែជាប់ឃុំក្រុងក្នុងអំណាចគ្រុឌដែលជាសេនារបស់យក្សដូចគ្នា (មើលការពន្យល់អត្ថន័យរូបមុន)។ ដូច្នេះរូបផ្ទៃរនេះ គាត់គ្រាន់តែចង់ពន្យល់ប្រាប់យើងពីរឿងពិត ពីពូជនាគតំណខាងក្រោយ (កូននាគ) ត្រូវគេបន្សាបពិសបន្តគ្នាបានក្លាយខ្លួនទៅជានាគក្បាលមួយ ដូចជាពស់ធម្មតា ដោយពុំបានដឹងពីពូជ និងសារជាតិពិតរបស់ខ្លួន ដូចជាសុភាសិតអ្នកប្រាជ្ញភ្នំជីសូរ បានពោលទុកថា* ***ស្ដេចខ្លៅនាម៉ឺនខ្លៅ ដូចពស់ឆាងត្រែវពេននៅមាត់ជណ្ដើរ ស្ដេចប្រាជ្ញ នាម៉ឺនមហិទ្ធិយក្ស ដូចពស់ពញ្ញាក់ពេននៅមាត់ជណ្ដើរ ស្ដេចប្រាជ្ញ នាម៉ឺនប្រាជ្ញ ដូចពស់នាគរាជពាំកែវមនោរា។***

# ៤០/.រូបភាពទី៤០រូបទ្វារបញ្ឆោត ផ្ដែរ ក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)




រូបទ្វារថ្មបញ្ឆោតនេះ តើមាតានាគគាត់ចង់ប្រាប់យើងពីប្រស្នាអ្វី ទាក់ទងនឹងរឿងអាថ៌កំបាំងរបស់ពួកគាត់?

**ក**/.ទ្វារថ្មបញ្ឆោតនេះ បើយើងពិនិត្យមើលទៅតាមរូបភាពជាក់ស្ដែង ក្នុងសិល្បបំភ័ន្ត មើលទៅហាក់បីដូចជា ក្របទ្វារ និងបន្ទះទ្វារ ដែលអាចបើកបិទបាន តែតាមពិត គឺពុំអាចបើកបិទបានឡើយ ព្រោះវាគ្រាន់តែជាទ្វារបញ្ឆោតភ្នែកតែប៉ុណ្ណោះ។ ហើយនៅលើទីប្រជុំនៃមាត់ទ្វារទាំងសង្ខាង មានក្បាច់ផ្កាចន្ទន៍ប្រាំគ្រាប់ ឬប្រាំបន្ទះនៅពីលើ និមិត្តរូប គឺតំណាងឲ្យមេសោដែលចាក់ទ្វារថ្មនេះ កុំឲ្យបើករួច ហើយអ្នកដែលអាចបើកទ្វារថ្មនេះរួច ទាល់តែមានកូនសោជារាងផ្កាចន្ទន៍នេះ ទើបអាចបើកបាន ហើយទ្វារបញ្ឆោតថ្មទាំងនេះ មានស្ទើរគ្រប់ប្រាសាទនៅទូទាំងនគរនេះ។ នៅខាងមុខទ្វារបញ្ឆោត មានសសរមូលពីរដើម ដែលយើងតែងហៅថាសសរពេជ្រ ពាក្យសសរពេជ្រ គឺជាឈ្មោះរបស់មានតម្លៃ ស្មើនឹងពេជ្រ ហើយសសរពេជ្រនេះ បានទ្រនៅរឿងក្នុងផ្ដែរ និងក្នុងក្បាំងក្លែងខាងលើ ដែលជារឿងមានតម្លៃស្មើនឹងពេជ្រ ឬលើសពីពេជ្រ ដែលសសរនេះ នៅឈរទ្រទ្រឿងក្នុងផ្ដែរ និងក្បាំងរាប់រយពាន់ឆ្នាំហើយ (អាថ៌កំបាំងសសរពេជ្រ)។ រឿងរ៉ាវដែលនៅពីលើទ្វារបញ្ឆោតនោះ (ផ្ដែរ និង

ក្បាំង) គឺសុទ្ធតែជារឿងដែលលំបាក នឹងនាំចេញមកផ្សព្វផ្សាយខាងក្រៅ ហេតុនេះដូនតាគាត់ចង់ប្រាប់យើងថា រឿងចម្លាក់នៅលើទ្វារបញ្ឆោត មិនងាយនឹងមើលយល់ មើលយល់ហើយមិនងាយ និងនាំយកចេញមកខាងក្រៅ ដើម្បីផ្សព្វផ្សាយ ព្រោះហេតុអ្វី? ព្រោះទ្វារទាំងនោះ បានចាក់សោផ្កាចន្ទន៍ការពារដល់ទៅប្រាំជាន់ឯនោះ ហើយទ្វារនេះក៏មិនងាយនឹងបើកទៀត (ប្រស្នាជានិមិត្តរូបសោ) លុះត្រាតែមានកូនសោផ្កាចន្ទន៍ ទើបអាចបើកទ្វារទាំងនោះរួច ពេលដែលបើករួច ទើបអាចនាំបណ្ដាំដូនតាគឬបណ្ដាំព្រះមាតានាគ មកប្រាប់កូននាគខាងក្រៅឲ្យដឹងរឿងបាន (ប្រស្នាអាថ៌កំបាំងទ្វារថ្មបញ្ឆោត)។ ពេលយើងមើលរូប ហើយយើងពិចារណាត្រិះរិះ ទើបមើលឃើញគតិបណ្ឌិតក្នុងបេះដូងដូននាគ ដែលលោកខំលួចចេញពីគុកបាន ក្នុងសម័យមហានគរ គឺលោកមានបំណងឲ្យកូននាគទាំងនោះ ទុកបណ្ដាំប្រស្នាទាំងនេះ នៅលើផ្ទាំងថ្ម ព្រោះមានតែថ្មទេ ដែលអាចរក្សាឯកសារអាថ៌កំបាំងបណ្ដាំនេះទុកបានយូរ។ ហើយលោកក៏មានសេចក្ដីសង្ឃឹមថា នឹងមានកូននាគណាមួយ អាចបើកមេសោផ្កាចន្ទន៍នោះរួច មេសោរអាចបើករួច លុះត្រាតែមានកូនសោនាគ កូននាគណា ព្រមធ្វើជាសោចូលទៅក្នុងទ្រូងម៉ែ ទើបអាចជួយស្រង់ ជួយប្រស់ ជួយបើកបាន (អាថ៌កំបាំងពាក្យកូនសោ និងមេសោ។

## ៤១/.រូបភាពទី៤១រូបភាពបាតដៃផ្កាចន្ទន៍(នៅសារមន្ទីជាតិភ្នំពេញ)

ក្នុងចម្លាក់បាតដៃនេះ សព្វថ្ងៃក្នុងសៀវភៅបរទេស គេបានពន្យល់ថា ជាបាតព្រះហស្ដរបស់ព្រះសម្មាសម្ពុទ្ធ តែបើយើងមើលស្ដាប់សិក្សា ពីបុរិសលក្ខណៈ៣២ប្រការរបស់ព្រះសម្មាសម្ពុទ្ធនោះ ក្នុងបាតព្រះហស្ដរបស់ព្រះអង្គ គឺមានរូបចក្រដែលមានកាំមួយពាន់ឯនោះ។ ចំណែកបាតដៃក្នុងរូបនេះ មានកាំខាងក្រៅ១២ កាំខាងក្នុង៨ បានន័យថា គេបង្វែងការពិតរបស់យើង ទៅជារឿងមួយផ្សេងទៀត ព្រោះរូបស្រដៀងអាចឲ្យគេបំភាន់យើងបាន តើកាំទាំង១២ និងកាំ៨ តំណាងឲ្យអ្វី?

១/.កាំរស្មីទាំង១២ តំណាងឲ្យកែវភ្នែកមាតាទាំង១២ ឬតំណាង១២ខែ ព្រោះមួយឆ្នាំស្មើ១២ខែ ក្នុងខែថ្ងៃណាមួយ ក៏កូននាគរស់ក្នុងភូមិព្រះម៉ែ មានឈ្មោះថាអ្នកបានទទួលនៅមរតកព្រះម៉ែ ដូច្នេះបើកែវភ្នែកទាំង១២ងងឹត អ្នកទទួលមរតកពីគាត់ក៏ងងឹត បើកែវភ្នែកម៉ែភ្លឺឡើងវិញ អ្នកទទួលមរតកពីគាត់ក៏ភ្លឺដូចគាត់ដែរ នេះជាពន្លឺចក្រ ដែលផ្សាយចេញពីកាំទាំង១២ ន័យមួយទៀត គឺតំណាងឲ្យកូនសោដែលត្រូវយកមកបើក កាំផ្កាចន្ទន៍ដែលជា មេសោទាំងប្រាំ។



២/.ឯកាំទាំង៨ខាងក្នុង តំណាងឲ្យទិសតូច៤ ទិសធំ៤ ដូនកែវគាត់ចង់ប្រាប់យើងថា បើកូនចង់ប្រមូលពន្លឺ ដួងកែវរបស់ម៉ែទាំង១២ ឲ្យមកជុំគ្នាវិញ លុះត្រាតែកូនដើរប្រមូលដួងកែវនេះ ដែលស្ថិតនៅគ្រប់ទិសទាំង៨ក្នុងនគរ ព្រោះដួងកែវទាំង១២នេះ ម៉ែបានយកទៅពង្រាយ តាំងពីម៉ែជាប់ឃុំដំបូង រហូតដល់ម៉ែលែងចេញពីឃុំរួច (អាថ៌កំបាំងប្រាសាទហាន់ជ័យ)។ ដូននាគបានប្រាប់យើងទៀតថា ពេលណាដែលកូននាគរកកែវភ្នែក គ្រប់ចំនួនក្នុងបាតដៃហើយ កូនអាចទៅបើកសោលើទ្វារថ្មបញ្ឆោតទាំងអស់បាន ព្រោះមេសោផ្កាចន្ទន៍ទាំងនោះ ទាល់តែមានកូនសោ គឺបាតដៃផ្កាចន្ទន៍ ដែលមានកាំ១២ + ៨ + ១ = ២១ ⇔ ១២ នេះហើយទើបអាចធ្វើឲ្យសោថ្មដែលយក្សចាក់ពីអតីតកាលនោះ ឲ្យរបើកបាន (នេះជាប្រស្នាថ្ម)។ ចំណែកម្រាមដៃទាំង៥តំណាងឲ្យអ្វីដែរ?

១/.ម្រាមតូចជាងគេ មានឈ្មោះថាម្រាមកូនដៃ កូននេះហើយ ដែលគាត់បានសន្មត់ឈ្មោះទុកឲ្យយើងពិចារណា (កូនសោនាគ ចូលក្នុងទ្វងមេសោដើម្បីបើកទ្វារបេះដូងមេសោនាគ)។

២/.ម្រាមបន្ទាប់ មានឈ្មោះថា ម្រាមនាងដៃ ម្រាមនេះតំណាងឲ្យនាង ឬមេ មានន័យថា ព្រះនាងនាគ ឬព្រះមាតានាគ ដែលកូនត្រូវមកជួយនាងនោះ។

៣/.ម្រាមកណ្តាល គឺម្រាមចង្អុលខ្មោច ឬម្រាមចង្អុលកណ្តាល មានន័យថា សម្រាប់ចង្អុលខ្មោចព្រះមាតានាគ ដែលលោកបានដេកស្លាប់ទៅហើយនោះ ចង្អុលឲ្យបានរស់ឡើងវិញ ក្នុងសន្តានចិត្តកូននាគប្រុសស្រី។

៤/.ម្រាមចង្អុលដៃ

៥/.ម្រាមមេដៃ

ក្នុងរូបភាពបាតដៃនេះ គាត់បានប្រាប់យើងថា ព្រោះហេតុតែ**ចង្អុល** និង**មេ**នេះហើយ ធ្វើឲ្យពួកគាត់ជាប់ទោសរាប់ពាន់ឆ្នាំ ព្រោះហេតុអ្វី? ពេលអ្នកដែលមានឫទ្ធិអំណាច ចង់បានរបស់អ្វីមួយដោយរំលោភបំពាន តែងលើកដៃចង្អុលបង្ហាញទិស និងទីតាំង ពេលដែលលើកដៃចង្អុលនោះ មេដៃនិងចង្អុលដៃទៅព្រមគ្នា ឯម្រាមបីទៀត ត្រូវក្ដោបជាប់ពុំអាចរើខ្លួនរួចឡើយ។ ប្រស្នាក្នុងម្រាមដៃនេះ គាត់បានប្រាប់យើងថា ហេតុតែចង់ឲ្យកូននាគសម័យក្រោយ សោយសុខក្នុងគំនរកេរមរតកម៉ែឪ ទីបំផុតពួកគាត់បានត្រឹមតែក្លាយជាអ្នកទោសក្នុងអបាយភូមិតែប៉ុណ្ណោះ (កម្មវដ្ដ) ហើយបាបកម្មនេះបានអូសបន្លាយរហូតមកដល់សព្វថ្ងៃ។ ចំណែកឯម្រាមបីដែលបត់ជាប់មកខាងក្រោយនោះ គាត់ចង់ប្រាប់យើងថា តទៅអនាគតខាងមុខ និងមានកូននាគណាមួយ (កូនដៃ) មកជួយដោះទុក្ខនាង (នាងដៃ ឬនាងនាគ) ដែលដេកស្លាប់គេឈប់ស្គាល់ឈប់ដឹងនោះ កូននាគនឹងប្រើចង្អុលខ្មោច (ចង្អុលកណ្ដាល) ចង្អុលប្រស់គាត់ឲ្យរស់ឡើងវិញ នៅក្នុងសន្ដានចិត្តកូននាគប្រុសស្រី ដែលពីមុនបានភ្លេចគាត់ទៅហើយនោះ ឲ្យបានស្គាល់ការពិតរបស់គាត់ នឹងគោរពគាត់ឡើងវិញ (នេះជាអាថ៌កំបាំងប្រស្នាឈ្មោះម្រាមដៃទាំងប្រាំ)។ ប្លង់ប្រាសាទអង្គរតូចកំពូលប្រាំ ដែលប្រាំនេះ តំណាងឲ្យម្រាមដៃទាំងប្រាំ និងន័យមួយទៀត គឺតំណាងឲ្យបញ្ចក្ខន្ធ (ខន្ធប្រាំ) ដែលមានរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលខន្ធទាំងប្រាំនេះ បានចងពួកគាត់ជាប់ក្នុងទីទុក្ខ រាប់ពាន់ឆ្នាំ (មើលអាថ៌កំបាំងស្ករតាំងម៉ៃភាគមុន)។ ដូច្នេះបាតដៃដែលមានរូបចក្រជារាងផ្កាចន្ទន៍ និងឈ្មោះម្រាមដៃទាំងប្រាំ ដែលខ្ញុំបានពន្យល់ដោយសង្ខេបនេះ ទុកគ្រាន់ជាគំនិតតូចមួយសម្រាប់ឲ្យកូននាគត្រិះរិះពិចារណា ពីឈ្មោះម្រាមដៃដែលដូនតាយើងប្រសិទ្ធិនាមឲ្យឈ្មោះផ្សេងៗគ្នា (អ្នកមានក្រាំងផ្កាចន្ទន៍ទើបអាចបើកមេសោផ្កាចន្ទន៍បាន)។

# ៤២/.រូបភាពទី៤២រូបចម្លាក់លោត(សារមន្ទីជាតិភ្នំពេញ



តើរូបក្នុងផ្ទាំងនេះ គាត់ចង់និយាយប្រាប់ ពីដំណើររឿងអ្វី?

**ក**/.រូបព្រះ ដែលគង់លើសត្វនាគបើកពពារ ហើយគ្រងសំពត់ស្បង់ចីវរជាអ្នកបួសនោះ គឺតំណាងឲ្យព្រះសម្មាសម្ពុទ្ធ សមណគោតមបរមគ្រូនៃយើង ព្រោះព្រះអង្គជាមេនាគទីបី (មើលការពន្យល់ក្នុងមង្គលបីភាគពីរ) ដូច្នេះទើបដូនតាយើង ឆ្លាក់ព្រះអង្គគង់ពីខាងលើនាគ។ ក្នុងបឋមត្រាស់ ពេលដែលព្រះសម្មាសម្ពុទ្ធ គង់នៅក្នុងឈានសមាបត្តិ សោយនូវវិមុត្តសុខ នាមាត់ស្រះមុជ្ជលិន ចំនួនប្រាំពីរថ្ងៃ ដោយមាន ភ្លៀងធ្លាក់យ៉ាងខ្លាំង ពេលនោះ នាគនៅក្នុងស្រះមុជ្ជលិន បានលូនចេញពីក្នុងស្រះមកព័ទ្ធព័ន្ធជុំវិញ ព្រះសម្មាសម្ពុទ្ធ រហូតដល់ពីខាងលើ រួចនាគបើកពពារគ្របបាំង ដើម្បីកុំឲ្យព្រះអង្គទទឹកភ្លៀង។ ក្នុងពេលនោះបើគេមើលពីចំងាយ គេពុំបានឃើញរូបរាងព្រះសម្មាសម្ពុទ្ធឡើយ គឺឃើញដូចជារាងផ្ទះកំពូលមួយ ដោយនាគមុជ្ជលិនបានយកខ្លួនធ្វើជាជញ្ជាំងបាំង យកក្បាលធ្វើជាដំបូលប្រក់ ដូចនេះទើបគេមើលឃើញដូចជារាងផ្ទះកំពូលមួយ។ ចុះហេតុអ្វីបានជាសិល្បខ្មែរ ឆ្លាក់រូបព្រះសម្មាសម្ពុទ្ធ គង់ពីលើនាគទៅវិញ? សិល្បខ្មែរ គឺជាសិល្បអរូប សិល្បបង្កប់ទៅដោយគំនិតអច្ឆរិយសិល្បបំភាន់ បើសិនជាអ្នកមើលពុំបានឆ្ងល់រួចពិចារណា គឺពុំអាចមើលឃើញអាថិកំបាំងអរូបនេះឡើយ ព្រោះសំបកពីខាងក្រៅ ជារឿងមួយផ្សេង បេះដូងរូបខាងក្នុងជារឿងមួយផ្សេងទៀត។ ដូចក្នុង

រូបភាពនេះ គាត់ចង់បំភាន់អ្នកមើលថា ព្រះគង់លើនាគប្រក់ ពេលយើងស្រាវជ្រាវរូបភាពដើម ក្នុងបឋមត្រាស់ គឺរូបភាពខុសគ្នា ព្រោះបឋមត្រាស់ គឺខ្លួននាគព័ទ្ធជុំវិញធ្វើជញ្ជាំង ឯក្បាលធ្វើជាដំបូល ពុំមែនគង់ពីលើនាគឡើយ ឯរូបក្នុងសិល្បខ្មែរ ព្រះពុទ្ធគង់ពីខាងលើនាគ មានន័យថា ព្រះអង្គជានាគ (មើលរឿងដំបូកហុយផ្សែង)។ ហេតុអ្វីបានជាគាត់ឆ្លាក់ព្រះអង្គគង់លើនាគដូច្នេះ? ព្រោះមាតានាគចង់បញ្ជាក់ប្រាប់កូននាគថា រូបគាត់ក៏អង្គុយលើនាគដែរ (មើលរូបក្របមុខភាគមួយ) គឺគាត់ជាព្រះនាងនាគ ហើយនឹងមានរូបកូននាគ ជាអ្នកមកជួយស្រង់ប្រស់ពួកគាត់ ក៏គេឆ្លាក់រូបអង្គុយលើនាគដែរ ដែលសព្វថ្ងៃ យើងហៅថាព្រះទ្រង់គ្រឿង តាមពិតគឺពុំមែនព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងឡើយ ព្រោះព្រះអង្គជាអ្នកបួស ពុំពាក់គ្រឿងអលង្ការទេ រូបនោះ គឺជាកូននាគដែលត្រូវមកជួយមាតានាគ ដែលក្នុងទំនាយគេហៅថា តួអង្គព្រះសិអារ្យមេត្រី (ចូរមើលការពន្យល់ពីពាក្យនាគក្នុងភាគមួយ)។

**ខ**/.បុរសដែលអង្គុយពែនភ្នែន ក្នុងឥរិយាបថសមាធិ ដៃលើកសំពះកាន់ផ្កាឈូក ដែលលៃងខ្លួនខាងលើទទេនោះ តំណាងឲ្យអ្វី? បើយើងពិនិត្យមើលគន្លងផ្លូវរូបទាំងពីរ ព្រះសម្មាសម្ពុទ្ធ និងរូបបុរសខាងក្រោម គឺគន្លងផ្លូវតែមួយ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានត្រាស់ដឹង និងបរិនិព្វានទៅហើយ រីឯបុរសដែលនៅពីខាងក្រោម លោកនៅបំពេញបារមីជាពោធិសត្វនៅឡើយ ព្រោះហេតុអ្វី? ព្រោះទីមួយលោកបានស្ថិតនៅក្នុងគន្លងផ្លូវ ជាមួយនឹងព្រះសម្មាសម្ពុទ្ធ ទីពីរលោកពុំមានគ្រងសំពត់ចីវរ ជាអ្នកបួស ហើយដៃលោកទាំងពីមានកាន់ផ្កាឈូកក្រពុំ មានន័យថានៅសន្សំគុណធម៌ គឺបារមីនៅឡើយ ហើយបុគ្គលក្នុងរូបនេះទៀងតែនឹងបានត្រាស់ បន្ទាប់ពីព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ក្នុងចុងភទ្ទកប្បនេះ ព្រោះរូបនៅជាប់គ្នា។ ដូច្នេះហើយ ទើបយើងតែងឮចាស់ៗនិយាយទំនាយតៗគ្នាថា នឹងមានអ្នកមានបុណ្យជាតួអង្គព្រះសេរអារ្យមេត្រី មកលើកសាសនាព្រះសមណគោតមបរមគ្រូនៃយើង ប្រហែលជាអ្នកប្រាជ្ញបណ្ឌិតយើងពីមុន លោកមើលរូបភាពនេះយល់ រួចលោកតាក់តែងទំនាយទុកទេដឹង? ព្រោះរូបនេះ បានបង្ហាញពីអត្ថន័យដូចខ្ញុំបានបកស្រាយពន្យល់ខាងលើនេះ។

**គ**/.រូបនៅពីខាងស្តាំដៃ ត្រូវបានដាប់បំផ្លាញប៉ុន្តែរូបដែលគេដាប់ចោលនេះ គឺតំណាងឲ្យឪពុកឬបិតាឈរនៅលើផ្កាឈូក ដែលបែកចេញពីដៃព្រះពោធិសត្វជាកូននាគ ព្រោះទងផ្កាដែលទ្រនោះ បែកចេញពីកែងដៃ បុរសដែលអង្គុយនៅខាងក្រោម។ ចំណែកឯរូបតំណាងឲ្យឪពុកដែលត្រូវបំផ្លាញនោះ គេមិនចង់ឲ្យកូននាគមើលយល់រូបនៅក្នុងផ្ទាំងនេះ ទើបគេបំផ្លាញដើម្បីបំភាន់ ហើយរូបនេះគាត់សន្សំបារមីឲ្យបានជាពុទ្ធបិតាទៅអនាគតជាតិ។

ឃ/.រូបខាងឆ្វេងដៃ គឺរូបស្ត្រីឈរកាន់ផ្កាឈូកក្រពុំតូចមួយនៅក្នុងដៃស្ដាំ ហើយឈរនៅលើផ្កាឈូក ដែលទងផ្កាបានផុសចេញពីកែងដៃខាងឆ្វេងរូបខាងក្រោម ហើយស្ត្រីនេះ គឺតំណាងឲ្យព្រះមាតាមហានគរ ដែលគាត់សន្សំបារមីឲ្យបានជាពុទ្ធមាតាទៅអនាគតជាតិ។ អត្ថន័យរូបទាំងមូល គឺបានបង្ហាញពីសកម្មភាពកូននាគ ដែលត្រូវបែងភាគជ្រោងឪពុកម្ដាយឲ្យរួចពីទីទុក្ខ ដើម្បីបំពេញបារមីដូចជាព្រះពោធិសត្វសុវណ្ណសាម (កតញ្ញូ កតវេទី) គឺជួយជ្រោមជ្រែងម៉ែឪដែលរងទុក្ខក្នុងអបាយភូមិរាប់ពាន់ឆ្នាំនោះ ឲ្យលោកទាំងពីររួចផុតពីទម្ងន់ទុក្ខនេះ ហើយនឹងឲ្យខ្លួនបានបំពេញនូវបារមីដើម្បីឲ្យបានត្រាស់ដឹងជាព្រះពុទ្ធមួយអង្គទៅអនាគតជាតិ។ រូបនេះទៀតសោត ក៏បានបង្ហាញនៅអាចិកំបាំងឈ្មោះភ្នំដងរែក ដែលខ្ញុំបានពន្យល់រួចហើយនៅក្នុងភាគពីរ អាចិកំបាំងឈ្មោះប្រាសាទព្រះវិហារ និងឈ្មោះប្រាសាទដទៃៗទៀត រួមទាំងឈ្មោះភ្នំ ភូមិ ស្រុក.....ដែលខ្ញុំបានបកស្រាយក្នុងភាគមុនរួចហើយ។

## ៤៣/.រូបភាពទី៤៣រូបអង្គវិស្ណុតូចៗ(ព្រះខ័នកំពង់ស្វាយ)



ក្នុងឯកសារស្រាវជ្រាវភាគពីរ ខ្ញុំបានពន្យល់រួចហើយពីឈ្មោះអង្គរតូចឬអង្គរវត្ត ពេលនេះខ្ញុំយករូបចម្លាក់អង្គតូចៗក្នុងរូប មកបកស្រាយពន្យល់ជាបន្ថែម ដើម្បីឲ្យកាន់តែច្បាស់ នឹងងាយយល់ពីឈ្មោះអង្គរតូច ឬអង្គរវត្តនោះ។ ក្នុងរូបដុំសីមានេះ មានរូបវិស្ណុតូចៗ ដូចរូបវិស្ណុតូចនៅទ្រស្ពានខាងក្រោម ផ្លូវចូលទៅប្រាសាទអង្គរវត្តដែរ រូបទាំងនេះ មាន១៥ជាន់ក្នុងមួយជ្រុង មួយជាន់មានរូបវិស្ណុ១៧អង្គ ហើយដុំសីមានេះមាន៤ជ្រុង សរុបរូបទាំង៤ជ្រុង ស្មើនឹង១០២០រូប គឺ ១៧ x ១៥ x ៤ = ១០២០រូប។ នៅខាងលើដុំសីមាមានក្បាំងនាគ៤ទិស នៅខាងក្នុងក្បាំងមួយទិសមានរូបរឿងមួយ ហើយឈ្មោះរូបទាំងនោះ គឺផ្សេងៗគ្នា តើអត្ថន័យដុំសីមានេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី? រូបតូចៗគ្រប់ជ្រុងទាំងបួននេះ គាត់ចង់

និយាយពីការសន្សំគុណធម៌ គឺបារមីរបស់ព្រះវិស្ណុ ទម្រាំអាចក្លាយជារូបធំខាងលើបាន ហើយគាត់អាចទៅតតាំងនឹងយក្ស រួមទាំងបក្សពួកឲ្យព្រមចុះចាញ់ រួចទៅជួយរេក ទៅស្រង់ (មើលភ្នំដងរែក និងភ្នំស្រង់ភាគពីរ) មាតាបិតាដែលយក្សចាប់ឃុំពីអតីតកាល ឲ្យលោកបានរួចផុតពីទុក្ខ។ បើយើងមើលតាមសកម្មភាពក្នុងដុំសីមានេះ គាត់សន្សំបារមីបន្តិចម្ដងៗ ដោយស្ងៀមស្ងាត់ គ្មាននរណាដឹងរឿងក្រៅពីខ្លួនគាត់ឡើយ ពេលដែលគុណធម៌ផ្ដុំបានជារូបធំ គាត់ហ៊ានឡើងទៅជិះលើក្បាលយក្ស និងគ្រុឌនៅខាងលើ គឺមានតែយក្ស និងគ្រុឌទេ ដែលដឹងរឿងគាត់។ រូបខាងលើទាំងបួនទិសមានឈ្មោះព្រះវិស្ណុជិះគ្រុឌ ព្រះពោធិសត្វលោកេស្វរៈ ព្រះឥសូរ និងព្រះព្រហ្ម ហើយរូបធំខាងលើដែលអាចកើតឡើងបាន ដោយសារការផ្ដុំរូបតូចៗខាងក្រោម ប្រៀបបីដូចព្រះសម្មាសម្ពុទ្ធគ្រប់ៗព្រះអង្គ អាចត្រាស់ដឹងបាន ត្រូវសន្សំបារមីទាំង៣០ គឺបារមី១០ ឧបបារមី១០ បរមត្ថបារមី១០ រាប់អសង្ខេយ្យផែនដី ទើបធ្វើឲ្យបញ្ញាអាចត្រាស់ដឹងនៅសច្ចធម៌ដោយខ្លួនឯងបាន។ យ៉ាងណាមិញអាចកំបាំងភាសារូបក្នុងថ្មនេះ ក៏មិនខុសពីការសន្សំបារមីរបស់ព្រះពោធិសត្វអង្គមុនៗឡើយ ព្រោះដូនតាបានសរសេរទំនាយទុកនោះ ពួកគាត់បានបំបែកប្រស្នាក្នុងរូបភាពថ្មទាំងនេះ ម្យ៉ាងទៀត អ្នកឆ្លាក់បណ្ដាំគំនិតមាតាមហានគរ (បិសាចពស់) លោកចារឹករឿងទុកលើថ្មផង លោកនិយាយ និងសរសេរទំនាយផង ទុកជាមរតកសម្រាប់កូននាគសម័យក្រោយ យកទៅផ្សំផ្គុំបូកបញ្ចូលគ្នា ទើបអាចក្លាយជាសាសនមាតា (បណ្ដាំមាតា) មួយដែលមានរូបរាងពិតប្រាកដបាន។

## ៤៤/.រូបភាពទី៤៤រូបក្នុងក្បាំងភ្លែង(មិនដឹងប្រភព នៅសារមន្ទីរជាតិ)

តើសកម្មភាព ក្នុងរូបភាពចម្លាក់នេះ ព្រឹទ្ធដូនតាលោកចង់និយាយពីអ្វី?

**ក**/.ទីមួយ រូបចំកណ្ដាលពីខាងលើ គឺតំណាងឲ្យព្រះពោធិសត្វលោកេស្វរៈ ព្រោះសំពត់រូបពីខាងមុខមានផ្នត់បត់ជាបន្ទះជាន់គ្នា ខុសពីសំពត់ចីវររបស់ព្រះសម្មាសម្ពុទ្ធ។

ទីពីរបល្ល័ង្ក ដែលទ្រូរបពុំទាន់មានផ្កាឈូកនៅឡើយ ព្រោះព្រះពោធិសត្វនៅបំពេញបារមីនៅឡើយ ហើយរូបនេះ ពេលដែលតោមិនទាន់ជ្រោងបើករាំងនន ឬទ្វារនេះឡើង គឺពុំមាននរណាដឹង រឿងពួកគាត់ទាំងបី នៅខាងក្នុងទ្វារនោះឡើយ។ ហើយព្រះពោធិសត្វអង្គនេះហើយ ដែលហ៊ានឡើងជាន់លើក្បាលយក្ស (មើលការពន្យល់រូបមុន)



ឲ្យយក្សនៅខាងក្រោមខ្សោយកម្លាំង ពុំអាចចាប់ទាញជើងតោឲ្យចុះមកក្រោមទៀតបាន។

ខ/.រូបឥសីដែលអង្គុយលុតជង្គង់លើផ្កាឈូក នៅពីខាងស្ដាំដៃ កំពុងលើកបង្ហាញរបស់មួយនៅក្នុងដៃនោះ តំណាងឲ្យឥសីកម្ពុ ព្រះថោង កៅណ្ឌិន ...ដែលជាឪពុក ឬព្រះបិតា។

គ/.រូបស្ត្រីនៅខាងឆ្វេងដៃគឺតំណាងឲ្យដូននាគ ព្រះម៉ែនាគ ព្រះនាងនាគលិវយី សោមា ព្រះម៉ែសក់ក្រអូប ព្រះនាងគង្ហីង ទិព្វសេដាច័ន្ទ វិមានច័ន្ទ ក្រពុំឈូក រំសាយសក់ ឧមាវតី ខេមា....កំពុងអង្គុយបត់ជើងលើកដៃសំពះលើផ្កាឈូកមួយទង ដែលដុះចេញពីចំហៀងក្បាលយក្ស រូបគាត់មានពាក់មកុដរាជខុសពីឥសីដែលពុំមានពាក់មកុដ។

ឃ/.រូបយក្សដែលនៅពីខាងក្រោមមានមុខធំសម្បើម បើប្រៀបធៀបទៅនឹងរូបបីខាងលើ មិនស្មើនឹងក្បាលយក្សមួយផង ហើយយក្សនេះកំពុងលានអណ្ដាតជានិមិត្តរូបក្បាច់ ដោយធ្មេញយក្សខាំអណ្ដាតខ្លួនឯងជាប់ មានន័យថាបញ្ជាដាក់ទោសព្រះមាតាបិតាពីអតីតកាលត្រូវអស់សុពលភាពហើយ ព្រោះហេតុអ្វី? ដោយកូននាគនៅពីខាងលើកំពុងតែជាន់ផ្ចាញ់ឲ្យយក្សព្រមខាំអណ្ដាត គឺរាជបញ្ជារបស់គាត់ដែលដាក់ទោសពីអតីត ត្រូវបានបញ្ឈប់ (អាចិកំបាំងរាហ៍កន្លង និងរូបយក្សក្អែ ប្រាសាទបន្ទាយឆ្មារ) ព្រោះយក្សមិនអាចមានអំណាចចាប់ព្រះមាតាបិតាលេបបានទៀតឡើយ។ ដៃទាំងពីររបស់យក្ស កំពុងចាប់ទាញជើងតោទាំងសង្ខាង កុំឲ្យតោនេះជ្រោងបើកទ្វារខាងលើបាន តែកំឡាំងយក្សបានចុះខ្សោយទៅហើយ ព្រោះត្រូវកូននាគខាងលើជាន់ក្បាលជាប់ ធ្វើឲ្យអស់ឫទ្ធិអំណាច។

**ង**/.រូបគោពីរខាងក្រោម ដែលយក្សកំពុងចាប់ទាញជើងទាំងសង្ខាងនោះ នៅតែប្រឹងចំអើតជ្រោងបើកទ្វារ ដែលកាន់ទ្រផ្កាឈូកពីទង ឲ្យរបើកឡើង។ គោពីនេះ មានពាក់គ្រឿងអលង្ការដូចមនុស្ស ហើយច្រមុះគោមានដុះចុងប្រមោយដូចកូនដំរី គឺសត្វគុជសី (ពាក់កណ្ដាលដំរី ពាក់កណ្ដាលរាជសីហ្គោ)។ គោពីរនេះតំណាងឲ្យទីក្រុងគោពីរគឺក្រុងព្រះសីហនុ ព្រោះទីក្រុងនេះមានរូបសំណាកគោពីរធំៗ ហើយទីក្រុងគោនេះកំពុងបើកនូវអាថ៌កំបាំងដែលយក្សបានលេបលាក់រឿងទុកខាងលើគឺអាថ៌កំបាំងបណ្ដាំមាតាមហានគរខ្មែរ។ គោពីមុនមិនទាន់មានពាក់គ្រឿងអលង្ការឡើយពេលដែលគោបានក្លាយខ្លួនជាគុជសីទើបមានគ្រឿងអលង្ការ តើព្រោះហេតុអ្វី? ទីក្រុងសៀមរាបដែលជាទីក្រុងអច្ឆរិយនោះពីមុនឈ្មោះថាទីក្រុងដំរី (ទីក្រុងយសោធបុរៈ) ទីក្រុងគោពីរមានឈ្មោះថាទីក្រុងព្រះសីហនុ ទីក្រុងពីររលាយចូលគ្នាកើតបានសត្វមួយផ្សេងទៀតគឺ**សត្វគុជសី** ដែលមានខ្លួនពាក់កណ្ដាលដំរីពាក់កណ្ដាលរាជសី។ អាថ៌កំបាំងមាតាមហានគរបានបំបែកនិងផ្សព្វផ្សាយនៅក្នុងទីក្រុងរាជសី មានតែសត្វគុជសីនេះទេដែលអាចយកគ្រឿងអលង្ការព្រះមាតាពីអតីតកាលមកពាក់បង្ហាញប្រាប់ពិភពលោកឲ្យគេបានដឹង និងយល់ពីប្រស្នាបណ្ដាំពិតក្នុងភាសាថ្ម ដែលជាសិល្បអរូបីមានក្នុងទឹកដីនេះពីអតីតកាលនិងបច្ចុប្បន្នកាលគឺបានកើតចេញពីក្នុងបេះដូងអច្ឆរា (អប្សរា) ដែលជាប្រមុខខ្មែរ (មេ) ពីអតីតកាលនោះឯង (ពុំមែនជារឿងក្នុងសាសនាទេ)។

សរុបសេចក្ដីមកការពន្យល់រឿងរ៉ាវក្នុងរូបនេះ ពីមុនដែលគោមិនទាន់បើកក្បាំងទ្វារនេះរួចយើងពុំអាចដឹងរឿងអាថ៌កំបាំងក្នុងទ្វារនេះឡើយ តែឥឡូវនេះទ្វារត្រូវបានរបើក ដោយកម្លាំងគុជសីទាំងពីរ ទើបយើងដឹងរឿងមនុស្សបីនាក់ក្នុងរបាំងទ្វារនេះ ដែលដំណើររឿងរបស់អ្នកទាំងបីខ្ញុំបានរៀបរាប់ពន្យល់ដោយសង្ខេបពីខាងលើរួចហើយ។

# ៤៥/. រូបភាពទី៤៥រូបផ្ដែរ(នៅប្រាសាទភ្នំជីសូរ)




តើរូបក្នុងផ្ដែរនេះគាត់ចង់ពន្យល់ប្រាប់យើងពីរឿងអ្វី? ហើយរូបទាំងអស់តំណាងឲ្យអ្វី?

១/.រូបមនុស្សប្រុសដែលពាក់មកុដនៅចំកណ្ដាល កំពុងឈរជ្រែងលើកដៃម្ខាងបើកគម្របដែលគ្របពីលើ ហើយដៃម្ខាងទៀតច្រត់ជង្គង់ឈរលើក្បាលយក្ស គឺតំណាងឲ្យកូននាគ ដែលត្រូវមកជួយម្ដាយឪពុកដែលនៅសងខាង ( មើលការពន្យល់ក្នុងរូបមុន )។

២/.រូបបុរសខាងស្ដាំពាក់មកុដ ដែលលើកដៃសំពះបន្ទូលដាក់លើក្បាលនោះ តំណាងឲ្យឪពុក ឬឥសីកម្ម.....(មើលការពន្យល់ក្នុងរូបមុន)។

៣/.រូបស្ត្រីខាងឆ្វេងកំពុងអង្គុយលើកដៃសំពះទៅលើក្បាល មានពាក់មកុដដូចជាស្ដេចតំណាងឲ្យម្ដាយ ឬមាតានាគ...... ( មើលការពន្យល់ក្នុងរូបមុន )។

៤/.រូបយក្សចាប់កាន់ខ្លួននាគនិមិត្តរូបដោយដៃសង្ខាង តំណាងឲ្យអ្នកមានឫទ្ធិអំណាចដែលចាប់មាតាបិតាឃុំពីរអតីត គឺម្ចាស់ពៀរ (មើលការពន្យល់ក្នុងរូបមុន)។

៥/.រូបសត្វករវិកកំពុងទទះស្លាបរងាវនៅពីខាងលើមួយជួរ តំណាងឲ្យមនោគមវិជ្ជាបរទេស (មើលការពន្យល់ពីសត្វករវិកនៅរូបមុន)។ ក្នុងសកម្មភាពរូបក្នុងផ្តែរនេះ រូបសំខាន់ជាងគេគឺ រូបកូននៅកណ្តាល ទោះបីខ្លួនមានដៃតែម្ខាងក៏ដោយ ក៏គាត់នៅតែព្យាយាមបើកគម្របដែលគេបិទពីខាងលើនោះដែរ ព្រោះមាតាបិតា ដែលលោកនៅអង្គុយខាងក្រោមកំពុងសំពះលើកដៃបន្ទូលដាក់នៅលើក្បាល គឺអង្វរឲ្យកូននោះព្យាយាមជួយពួកគាត់បន្តទៅទៀត ដូច្នោះកូននោះមានតែតស៊ូព្យាយាមបើកគម្របនេះតទៅទៀត ទោះបីជាខ្លួនមានដៃតែម្ខាងក៏ដោយ។

## ៤៦/.រូបភាពទី៤៦រូបក្បាំងក្លែង(ប្រាសាទភ្នំជីសូរ)



តើរូបក្នុងបាំងក្លែងនេះ ដូនតាចង់និយាយពីរឿងអ្វី?

១/.រូបមនុស្សពីរនាក់ជិះគោ ដែលមានឆ្វេតឆ័ត្របាំងពីខាងលើ ដូចរាងដើមឈើ តើតំណាងអ្វី?

ក/.មនុស្សទីមួយ តំណាងឲ្យកូននាគដែលមកជួយព្រះមាតា (ក្នុងរូបគេហៅថាព្រះឥសូរជិះគោនន្ទិន) ដឹកនាំគាត់ចេញពីទីទុក្ខ (មើលការពន្យល់ពីឈ្មោះប្រាសាទភ្នំជីសូរភាគ២)។

ខ/.រូបទីពីរដែលនៅពីខាងក្រោយ គឺតំណាងឲ្យមាតាមហានគរ ដែលកូននាំចេញពីក្នុងសមុទ្រទឹកដោះ (មាតានាគ)។

គ/.គោតំណាងឲ្យសេចក្ដីព្យាយាម ខ្ញុំបានពន្យល់ក្នុងភាគមុនរួចហើយ ពីការធ្វើស្រែរបស់ព្រះសម្មាសម្ពុទ្ធ (កសិសូត្រ)។

ឃ/.ឆ្មេតឆ័ត្រ តំណាងឲ្យឫទ្ធិបារមីរបស់ព្រះមាតា និងតំណាងឲ្យពោធិញាណរបស់ព្រះពោធិសត្វលោកេស្វរៈ របស់កូននាគកំពុងសន្សំបារមី ជួយព្រះមាតាឲ្យបានរួចពីឃុំរបស់យក្ស។

២/.អ្នកអង្គុយសង្ខាងពីខាងមុខ និងពីខាងក្រោយ គឺតំណាងឲ្យកូននាគប្រុសស្រី ដែលបានដឹងរឿងពិតរបស់មាតានាគ ហើយអបអរសាទរ នឹងហែហមអមដំណើរគាត់ចេញពីទីឃុំឃាំង។ ក៏ប៉ុន្តែរូបភាពនេះ នៅជាប់ក្នុងក្បាំងក្លែង ដែលក្បាលនាគសង្ខាងនូវមានយក្សលេប គឺមានន័យថា មិនទាន់មានសេរីភាពពេញលេញនៅឡើយទេ ដូច្នេះទើបដូនតា គាត់ឆ្លាក់សកម្មភាពគោកំពុងដើរទៅមុខ។

## ៤៧/.រូបភាពទី៤៧រូបផ្តែរនិងក្បាំងក្លែង(ប្រាសាទភ្នំជីសូរ)



ក្នុងរូបភាពក្បាំងក្លែងនេះ អត្ថន័យរូប ក៏ដូចរូបទី៤៦ខាងលើ ដែលខ្ញុំបានពន្យល់បកស្រាយរួច គ្រាន់តែរូបភាពនេះ ពុំទាន់នរណាបានដឹងរឿងគាត់នៅឡើយ។ រូបគោនៅក្នុងក្បាំងក្លែងខាងលើ នៅខាងក្រោមពោះគោមានមនុស្សម្នាក់នៅអង្គុយពីក្រោម កំពុងអង្គុយលត់ជង្គង់ឱនចុះ រូបនេះតំណាងឲ្យ មនុស្សមានឈ្មោះដូចសត្វគោ ដែលកំពុងជួយជ្រោមជ្រែងអ្នកនៅខាងលើ ពេលដែលខ្លួនបានដឹងពីសាវតាពិត របស់ព្រះម៉ែ។ ចំណែកឯផ្តែរខាងក្រោមវិញ មានអត្ថន័យដូចការពន្យល់ក្នុងរូបទី៤៤ និង៤៥ ព្រោះអត្ថន័យរបស់រូបស្រដៀងគ្នា ដោយកូននាគសម័យមុនត្រូវយករឿងពិតរបស់ព្រះម៉ែទៅពង្រាយទុកគ្រប់ទីកន្លែងក្នុងទិសទាំង៨ សម្រាប់ឲ្យកូននាគសម័យក្រោយ ជួយព្រះមាតាពេលដែលដល់ឆ្នាំកំណត់ទោសដែលត្រូវចប់ និងមានកូននាគណាមួយអាចមើលយល់ភាសាគំនិតក្នុងបេះដូងរបស់ព្រះមាតាដែលបានចារឹកទុកក្នុងថ្មទាំងនេះ គេនឹងព្យាយាមជួយគាត់ជាពុំខាន។

## ៤៨/.រូបភាពទី៤៨រូបផ្តែរ(ប្រាសាទនាងខ្មៅ ខេត្តតាកែវ)



ក្នុងរូបភាពផ្តែរនេះ មានរូបមនុស្សតូចៗបង្កប់នៅក្នុងក្បាច់ជាច្រើន តើរូបតូចៗទាំងនេះ មានបង្កប់អត្ថន័យរឿងដូចម្តេច? ផ្ទាំងរូបភាពនេះ ចែកចេញជាបីជាន់ ជាន់លើ កណ្តាល និងក្រោម តើក្នុងជាន់នីមួយៗសកម្មភាពរូបគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

**ក**/.ជាន់ទី១ មានរូបមនុស្សមួយជួរត្រឹមពាក់កណ្តាលខ្លួន មានពាក់មកុដ និងគ្រឿងអលង្ការដូចជាស្តេច កំពុងលើកដៃសំពះត្រឹមទ្រូង អង្វរបួងសួងសុំឲ្យយក្សដែលនៅខាងក្រោមឲ្យព្រម ដោះលែង

ព្រះម៉ែ ចេញពីអំណាចឃុំគ្រងរបស់ខ្លួន ហើយខ្លួនឯងដែលជាអ្នកអង្វរបួងសួងសុំនោះ ក៏ជាប់ឃុំក្នុងចន្លោះខ្លោងទ្វារមួយដែរ។

ខ/.ជាន់ទី២នៅចំកណ្តាល មានរូបមនុស្សតូចមួយអង្គុយនៅលើក្បាលយក្ស និងនៅសង្ខាងមានរូបលើកដៃសំពះបន្ទូលដាក់លើក្បាល នៅក្នុងទ្រនុងខ្នងនាគ នឹងមានរូបក្បាលយក្សកំពុងខាំលេបនាគ។

១/.រូបអង្គុយលើក្បាលយក្សចំកណ្តាល តំណាងឲ្យកូននាគដែលត្រូវមកជាន់យក្ស ឲ្យសុខចិត្តលើករាជបញ្ញា ដែលបានដាក់ទោសព្រះមាតាបិតាពីអតីតកាល ហើយរូបគាត់លើកដៃសំពះត្រឹមដើមទ្រូង គឺមានន័យថា រឿងទុក្ខវេនារបស់ព្រះម៉ែមហានគរគាត់បានយកមកទុកក្នុងដើមទ្រូងរបស់គាត់ (ក្នុងបេះដូង) រូបកូននោះទៀតសោត ក៏នៅក្នុងឃុំដែរ ព្រោះមានក្បាំងមួយគ្របពីលើគាត់ជាប់ (បក្សីចាំក្រុង) មានន័យថា គាត់មិនទាន់មានកម្លាំងគ្រប់គ្រាន់អាចបញ្ចប់នៅទោសទាំងអស់ ពីអតីតឲ្យបានរួចស្រឡះនៅឡើយ។

២/.យក្សកំពុងលើកដៃទ្រចាប់ខ្លួននាគនិមិត្តរូបពីក្រោម ទាំងសង្ខាង គឺមានន័យថា ទោសដែលគេបានដាក់ទៅលើព្រះម៉ែនាគ ទាំងក្នុងអតីត និងបច្ចុប្បន្ន គេពុំទាន់ព្រមលើកលែងទោសឲ្យពួកគាត់ឡើយ លុះត្រាតែព្រះវិស្ណុតូចដែលនៅខាងលើ សន្សំគុណធម៌ឲ្យបានគ្រប់គ្រាន់ ទើបធ្វើឲ្យទម្ងន់នៃគុណធម៌នោះ អាចធ្វើឲ្យយក្សព្រមលើករាជបញ្ញា (លើកលែងទោស)។

៣/.រូបនៅពីខាងស្តាំ គឺតំណាងឲ្យអតីតកាល ហើយគ្រប់រូបទាំងបួនដែលនៅក្នុងទ្រនុងខ្នងនាគ គឺតំណាងឲ្យព្រះម៉ែមហានគរ ឬព្រះមាតានាគ ដែលជាប់ឃុំក្នុងសោទាំងបួនជាន់ (មើលការពន្យល់រូបទី១)។ ឯគាត់លើកដៃបន្ទូលបួងសួង គឺគាត់ចង់ឲ្យកូននាគដែលកំពុងទទួលមរតកគាត់សព្វថ្ងៃ ជួយស្រង់គាត់ផង ព្រោះគាត់រងទុក្ខវេទនាខ្លោចផ្សាណាស់ នៅក្នុងអបាយភូមិគឺសមុទ្រទឹកដោះ ព្រោះហេតុតែប្រមូលកេរមរតកទុកឲ្យកូន (កេរម៉ែ = ក្មែរ)។

៤/.រូបនៅពីខាងឆ្វេង គឺតំណាងឲ្យបច្ចុប្បន្ន គឺរូបគាត់នៅជាប់ទោសដដែល (មើលការពន្យល់ទី៣ខាងលើ)។

គ/.ជាន់ទី៣ រូបនៅខាងក្រោមមាត់យក្ស មានរាងជាក្បាច់ធ្លាក់ចុះមកក្រោម ដូចជាអណ្តាតយក្ស ហើយក្នុងអណ្តាតនិមិត្តរូបនោះ មានរូបស្ត្រីម្នាក់ពាក់មកុដ និងគ្រឿងអលង្ការ ជាប់នៅក្នុងរង្វង់

ក្បាំងបញ្ច្រាស់ នោះគឺតំណាងឲ្យព្រះមាតានាគ។ រូបនេះបានបង្ហាញពីការជាប់ឃុំរបស់ព្រះម៉ែនាគក្នុងរាជបញ្ជាដែលយក្សបានបញ្ចេញសំដីនិយាយដាក់ទោស ព្រោះរាជបញ្ជាកើតចេញពីសំដីនិយាយៗកើតចេញពីអណ្ដាតជាអ្នករលាស់ ដូច្នេះទើបគេឆ្លាក់គាត់ឃុំក្នុងអណ្ដាតយក្ស។ ពេលយើងមើលរូបរួច ពិចារណាត្រិះរិះតាមការពន្យល់ដោយសង្ខេបខាងលើនោះ ទើបយើងដឹងថា ការយករឿងក្នុងចិត្តបំឡែងជាសិល្បគំនិត រួចបញ្ចូលទុកក្នុងថ្ម ជាសាសនបណ្ដាំព្រះមាតានាគ ដ៏មានអត្ថន័យជ្រៅលំបាកនឹងគិតយល់បាន។ ព្រោះការបំភាន់នេះ គាត់បានយករូបទៅបំប្លែងលាយជាមួយនឹងក្បាច់ធ្វើឲ្យអ្នកមើលពុំបានចាប់អារម្មណ៍ ដូច្នេះបើយើងមើលនឹងភ្នែក គឺឃើញត្រឹមតែរូបលុះត្រាតែមើល នឹងថ្វាសទើបឃើញរឿងពិតក្នុងបេះដូងរបស់គាត់។ ហើយរឿងនេះទៀតសោត គឺមានតែកូននាគដែលហ៊ានចុះទៅអង្គុយនៅលើក្បាលយក្ស ទើបអាចដឹងរឿងនៅខាងក្នុងពោះយក្សបាន ហេតុនេះ ទើបនៅស្ទើរគ្រប់ប្រាសាទតែងមានរូបមនុស្ស អង្គុយលើក្បាលយក្សផង អង្គុយ នឹងឈរជាន់លើគ្រុឌផង ព្រោះមានតែបុគ្គលនេះទេ ដែលអាចធ្វើឲ្យយក្ស និងបក្សពួកចុះចាញ់ ហើយអាចជួយមាតាមហានគរបាន។

## ៤៩/.រូបភាពទី៤៩រូបអប្សរាឬអច្ឆរា(ជញ្ជាំងប្រាសាទបាណាន់)



រូបភាពចម្លាក់នេះ ត្រូវបានជនទុច្ចរិតដាប់បំផ្លាញ មុខគាត់អស់ទៅហើយ តើរូបនេះតំណាងឲ្យអ្វី? អត្ថន័យនៅក្នុងរូបនេះ ក៏មិនសូវខុសពីក្នុងរូបមុនៗទេ ដែលខ្ញុំយកមកបង្ហាញនេះ គ្រាន់តែចង់ឆ្លុះបញ្ចាំងប្រៀបធៀប ពីប្រាសាទមួយ ទៅប្រាសាទមួយ ពីរជ្ជកាលមួយ ទៅរជ្ជកាលមួយ។ ព្រោះចង់ឲ្យកូននាគ យល់ពីប្រស្នាកំបាំងក្នុងរូប កុំឲ្យចេះតែជឿរទៅតាមការបកពន្យល់ របស់អ្នកប្រាជ្ញបរទេស ដែលមានឯកទេស ខាងបកភាសារូប ដែលបានបំភាន់សតិបញ្ញាយើង ឲ្យយល់ឃើញស៊ប់ តែទៅក្នុងរឿង

សាសនា ដូច្នេះពលិកម្មដូនតាពូជនាគអ្នកកសាងប្រាសាទថ្មពីអតីត លោកច្បាស់ជាអស់សង្ឃឹម និង យើងជាកូននាគស្រុករក្រោយជាពុំខាន ហើយយើងស្លាប់ទៅ ក៏គ្មានមុខឯណាទៅជួបមុខដូនតាទាំង នោះទេ។ រូបស្ត្រីដែលគេដាប់ក្បាលនោះ គឺជាអច្ឆរាតំណាងឲ្យព្រះម៉ែមហានគរ ដែលនៅខាងលើ ក្បាំងគ្របនោះ មានរូបក្បាលយក្សកំពុងចាប់ខាំ គឺតំណាងឲ្យសោដែលចាក់ឃុំគាត់។ នៅសង្ខាងពី ក្រោមមានតោពីរ កំពុងជ្រោងបើកក្បាច់ក្បាំង ដែលខ្ញុំពន្យល់រួចហើយក្នុងរូបទី៤៤ រូបចម្លាក់នេះ ទោះបីជាគាត់ធ្លាក់ពុំបានផ្ចិតផ្ចង់ ឲ្យមានសោភ័ណភាពក៏ដោយ អត្ថន័យរូបបានបង្ហាញប្រាប់យើង ល្មមគ្រប់គ្រាន់អាចឲ្យយើងមើលយល់បាន ហើយអាចឲ្យជនបរទេសជួលជនខិលខូច ដាប់បំផ្លាញ ចោលឯកសារថ្មនេះបាន។

## ៥០/.រូបភាពទី៥០រូបអប្សរា ឬអច្ឆរា(ប្រាសាទបាណន់)

តើរូបនេះ គាត់ចង់បង្ហាញយើងពីរឿងអ្វី?

១/.នៅពីខាងលើក្បាលយក្ស មានបល្ល័ង្កមានរាងដូចជាក្បាលនាគ មានរូបមនុស្សម្នាក់អង្គុយ នៅលើបល្ល័ង្កនោះ ដែលក្នុងរូបនេះ យើងមើលឃើញនៅសល់តែជង្គង់ភ្នែនតែប៉ុណ្ណោះ ឯរូបដងខ្លួន ត្រូវបានបំផ្លាញរលុបអស់ហើយ ហើយមនុស្សនោះ តំណាងឲ្យកូននាគដែលខំសន្សំបារមី ដើម្បីអាច ឡើងទៅបង្ក្រាបយក្សឲ្យព្រមចុះចាញ់បាន។



២/.ខាងក្រោមបល្ល័ង្ក គឺមានក្បាលយក្សដ៏ធំ មួយ ដែលដៃយក្សទាំងពីរកំពុងចាប់ជើងកូននាគ ទាំងសង្ខាង មិនឲ្យឡើងទៅដាន់ពីលើក្បាលខ្លួនបាន ហើយយក្សនេះទីមួយ គឺតំណាងឲ្យមហាអំណាច ដែលដឹងរឿងគាត់តាមបិទសន្ធប់គាត់ ទីពីរគឺយក្ស ដែលកំពុងសោយនូវផលបុណ្យសព្វថ្ងៃ គឺរាហ៊ុ អសុរិន្ទ ព្រោះខ្មែរយើងមានពាក្យទំនៀមមួយឃ្លាថា កូនរាហ៍កន្លង (មើលការពន្យល់ក្នុងភាគពីរ)។

៣/.មនុស្សទាំងពីរនាក់សង្ខាង តំណាងឲ្យកូន

នាគ ក្នុងអតីតកាល និងបច្ចុប្បន្ន កំពុងតែរើខ្លួនចេញពីអំណាចដៃយក្ស ដែលចាប់ជើងគាត់ជាប់នោះ ដើម្បីឲ្យបាន រួចហើយឡើងទៅអង្គុយនៅបល្ល័ង្កខាងលើ ដើម្បីឲ្យយក្សព្រមដោះលែងទោសព្រះមាតា ដែលនៅខាងក្រោម តែក្នុងរូបនេះគុណធម៌គាត់មិនទាន់គ្រប់គ្រាន់ ព្រោះឋិតនៅក្នុងអំណាចយក្ស។

៤/. រូបស្ត្រីដែលគេដាប់ក្បាលគាត់ចោលនៅខាងក្រោមផ្តែរនោះ គឺតំណាងឲ្យព្រះមាតាមហានគរ គាត់ជាប់ក្រុងក្រោមអំណាចយក្ស ព្រោះក្បាំងនាគដែលគ្របពីលើគាត់នោះ គឺនាគដែលត្រូវយក្សលេបដល់ក ហើយដែលគេដាប់ក្បាលគាត់ចោលនេះ គេឧបកិច្ចឲ្យគាត់ស្លាប់ ដោយគេមិនចង់ឲ្យគាត់មានជីវិតរស់ ក្នុងបេះដូងកូនខ្មែរសព្វថ្ងៃឡើយ។ រូបភាពប្រាសាទនេះ ទោះបីការឆ្លាក់មិនសូវមានសោភ័ណភាព តែអត្ថន័យក្នុងបេះដូងថ្មអាចឲ្យយើងមើលយល់បាន បូកផ្សំនឹងឈ្មោះប្រាសាទផង (មើលការពន្យល់ក្នុងភាគ២) ទើបយើងអាចបំបែកប្រស្នាបំភាន់របស់គាត់ ក្នុងភាសារូបនេះបាន។

សកម្មភាពរូបទី៤៩ ពុំទាន់មានកូននាគចុះមកជួយគាត់ឡើយ ឯរូបទី៥០នេះ មានកូននាគម្នាក់បានចុះមកប្រយុទ្ធតតាំងជាមួយនឹងយក្ស ឲ្យព្រមដោះលែងម្តាយដែលជាប់ឃុំ ក្នុងអំណាចរបស់ខ្លួនរាប់ពាន់ឆ្នាំមកហើយនោះ។ ដូច្នេះក្នុងប្រាសាទនីមួយៗ ព្រះមាតានាគគាត់បានបើកបង្ហាញរឿងក្នុងបេះដូងរបស់គាត់ ដែលបានប្រតិស្ឋានទុកក្នុងថ្ម គាត់ប្រាប់ពីពេលដែលកំពុងជាប់ទោស ពីពេលកំពុងរួចពីទោស និងពីពេលដែលបានរួចផុតចាកទោស។ តែសកម្មភាពរូបភាគច្រើន ដែលខ្ញុំបានប្រទះឃើញ គឺគាត់កំពុងចាកចេញពីទោស ដូចនេះទើបអ្នកប្រាជ្ញកវី បណ្ឌិតខ្មែរ ពីសម័យដើម ដែលលោកបានដឹងពីអាថ៌កំបាំងក្នុងបេះដូងថ្មទាំងនេះ លោកបានចងក្រងជាប្រស្នា ទំនាយផ្សេងៗ ដែលប្រស្នាទំនាយទាំងនេះ គឺមានតែនៅក្នុងនគរនេះ តែប៉ុណ្ណោះ ព្រោះវាជាអាថ៌កំបាំងភាសាថ្ម ដែលបង្កប់រឿងក្នុងបេះដូងព្រះម៉ែ។



### ៥១/.រូបភាពទី៥១រូបផ្តែរ(ប្រាសាទបាណន់)

អាចិកំបាំងភាសារូបក្នុងផ្តែរប្រាសាទនេះ ក៏មិនខុសពីអត្ថន័យក្នុងផ្តែរមុនៗឡើយ ដែលខ្ញុំយករូបមកដាក់បង្ហាញ គ្រាន់តែចង់ឲ្យកូននាគចេះមើលរូប រួចប្រៀបធៀបពីប្រាសាទមួយ ទៅប្រាសាទមួយថា រឿងក្នុងបេះដូងរបស់គាត់ទោះបីជាស្ថិតក្នុងប្រាសាទ នៅក្នុងមាតុភូមិបច្ចុប្បន្ននេះក៏ដោយ ឬប្រាសាទដែលជាអតីតមាតុភូមិខ្មែរក៏ដោយ រឿងនៅក្នុងបេះដូងថ្មទាំងនោះ ត្រូវបានបរិយាយប្រាប់ពីអត្ថន័យក្នុងរូបចម្លាក់ដូចៗ គ្នា។

### ៥២/.រូបភាពទី៥២រូបអប្សរាឬអច្ឆរានៅជញ្ជាំង(ប្រាសាទអង្គរវត្ត)



តើអត្ថន័យរូបអច្ឆរាក្នុងជញ្ជាំងនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

១/.នៅខាងលើចំកណ្តាល មានបុរសម្នាក់ពាក់មកុដ និងគ្រឿងអលង្ការកំពុងអង្គុយបញ្ឈរជង្គង់ នៅពីលើក្បាលយក្ស ដែលនៅក្នុងដៃស្តាំមានកាន់អាវុធ រូបនោះគឺតំណាងឲ្យព្រះវិស្ណុ ឬព្រះនរាយណ៍ ដែលជាកូននាគ ត្រូវមកជួយព្រះមាតានាគ។ ហើយព្រះវិស្ណុនេះទៀតសោត គាត់ខ្លាចយើងមានការភាន់ច្រឡំថាជាអាទិទេពនៅ

បរទេស ទើបគាត់កសាងប្រាសាទអង្គរវត្តនេះឡើង ដើម្បីឧទ្ទិសដល់ព្រះវិស្ណុ ដែលប្លង់ប្រាសាទនេះ មើលពីខាងលើ គឺជារាងយោនី (តំណាងមាតុភូមិ) ព្រោះផ្លូវចូលប្រាសាទ មានចង្អូរផ្លូវយោនីដ៏វែង គឺ មានន័យថា ព្រះវិស្ណុកើតចេញពីមាតុភូមិនេះ ហើយគាត់ត្រូវសន្សំគុណធម៌ ប្រើពេលដ៏យូរដើម្បីនាំ អច្ឆរាឬព្រះមាតានាគចេញពីក្នុងសមុទ្រទឹកដោះខាងក្នុង។

២/.អប្សរាកំពុងហោះសង្វាង គឺតំណាងឲ្យទេវតាស្រី ដែលជានិមិត្តសញ្ញា តំណាងឲ្យគណបក្ស ប្រជាជន ដែលមានរូបទេវតាជាសញ្ញា ព្រោះគាត់ចង់ប្រាប់យើងថា ពេលណានិមិត្តសញ្ញាទេវតា និង និមិត្តសញ្ញាកូរសមុទ្រទឹកដោះ កើតមានឡើងព្រមគ្នានៅក្នុងនគរនេះ ពេលនោះ និងមានកូននាគដឹង រឿង លាក់ទុកក្នុងផ្ទះរបស់គាត់ ដែលត្រូវយក្សចាប់យកទៅឃុំកាលពីអតីត ហើយកូននាគដែលបាន ដឹងរឿងរបស់គាត់នោះ និងព្យាយាមជួយគាត់ (មើលការពន្យល់រូបមុនៗ)។

៣/.យក្សតំណាងឲ្យ ម្ចាស់ពៀរ ឬអ្នកចាប់មាតាបិតាមហានគរយកទៅឃុំ ហើយក្នុងសកម្ម ភាពរបស់យក្សក្នុងរូបនេះ គាត់នៅអាចបញ្ចេញឫទ្ធិចាប់ខាំពាំ រាជបញ្ចាដែលបានដាក់ទោសពីអតីត កាលនៅជាប់មាំដដែល។

៤/.រូបសង្វាង ដែលនៅជាប់ក្នុងរង្វង់ក្រោមអំណាចដៃ និងមាត់របស់យក្សនោះ តើតំណាង ឲ្យអ្វី?

ក/.រូបខាងឆ្វេងដៃ ជាប់ក្នុងរង្វង់ ដែលក្បាលរង្វង់មានរាងដូចជាសត្វហង្ស ឬមាន់ (រកា) គឺ តំណាងឲ្យឆ្នាំរកា ដែលកូនត្រូវនាំរឿងរបស់ព្រះមាតាត្រូវជាប់ឃុំ យកមកផ្សព្វផ្សាយខាងក្រៅនោះ តែពុំអាចផ្សាយរួចឡើយ ព្រោះពាក្យរកាសាដានចាស់ តែសាពុំរួច ព្រោះដល់ឆ្នាំរកាត្រូវកោង (រកា កោង) គឺត្រូវថែមរយពេលពាក់កណ្ដាលទៀត។

ខ/.រូបជាប់នៅក្នុងរង្វង់ខាងស្ដាំដៃយក្ស ដែលក្បាលរង្វង់មានរូបរាងជាសត្វគុជសី (ពាក់ កណ្ដាលដំរី ពាក់កណ្ដាលរាជសី) នោះ គឺតំណាងឲ្យទីក្រុងពីរបូកបញ្ចូលគ្នា (មើលការពន្យល់រូបមុន) ពេលណាដែលរូបគុជសីនេះ កាន់តែមានរូបរាងច្បាស់ (មានគ្រប់អវយវៈ) ពេលនោះ រឿងក្នុងបេះដូង របស់ព្រះមាតាកាន់តែមានពន្លឺច្បាស់ឡើង។ ចំណែកឯរូបតូចទាំងពីរ ដែលជាប់ក្នុងរង្វង់ឃុំនោះ គឺ តំណាងឲ្យព្រះវិស្ណុ កំពុងសន្សំនៅគុណធម៌ ដើម្បីចេញពីរង្វង់ឃុំ រួចឡើងទៅខាងលើអង្គុយលើក្បាល យក្ស (មើលរូបខាងលើ)។

៥/.រូបអច្ឆរាដែលជាប់ក្នុងក្បាំងនាគ មានយក្សលេប តំណាងឲ្យមាតានាគ នៅខាងក្រោយរូបគាត់ មានក្បាច់ឋាន ដែលមានរូបក្បាលយក្សខាំក្បាច់ គឺមានន័យថា នៅខាងក្នុងបន្ទប់ទៅហើយ ក៏មានយក្សនៅចាំយាម ដូច្នេះគាត់មិនអាចចេញមកក្រៅទៀតបានឡើយ។ នាគក្បាំងទាំងសង្ខាង មានពាំផ្កាកម្រង គឺមានន័យថា មានកូននាគដឹងរឿងរបស់គាត់ហើយៗគេបានបូជានូវផ្កាកំរង គឺឧទ្ទិសបុណ្យជូនទៅគាត់ ដែលគាត់ស៊ូទ្រាំនៅរងទុក្ខរាប់ពាន់ឆ្នាំមកនោះ គឺមិនអស់សង្ឃឹមឡើយ ព្រោះពេលនេះ មានកូននាគសុខចិត្តយកបេះដូងឲ្យទៅយក្ស ដើម្បីជួយគាត់។ រូបភាពចម្លាក់គ្រប់ប្រាសាទទាំងអស់ គាត់តែងឆ្លាក់បន្លំជាមួយនឹងក្បាច់ ព្រោះក្បាច់ គឺតំណាងឲ្យព្រៃក្នុងអតីត បច្ចុប្បន្ន និងអនាគត ដែលពុំមានអ្នកណាដឹង ហើយអ្នកដែលដឹង គឺមានតែតួអង្គដែលបង្កប់នៅក្នុងក្បាច់នោះ។

សរុបសេចក្ដីមកការពន្យល់បកស្រាយរូបដោយសង្ខេបខាងលើនេះ អត្ថន័យរបស់រឿង គឺមិនសូវខុសគ្នាពីរូបមុនៗឡើយ គ្រាន់តែរូបខាងក្នុងប្រាសាទ គាត់និយាយផ្សេង ចំណែករូបខាងក្រៅគាត់និយាយប្រាប់មានការធូរស្រាលជាង ព្រោះបាបកម្មរបស់គាត់ជិតអស់ហើយ។

## ៥៣/.រូបភាពទី៥៣រូបព្រះវិស្ណុអង្គធំ(ប្រាសាទអង្គរវត្ត)



ពាក្យថាអង្គរតូច ឬអង្គរវត្តខ្ញុំបានពន្យល់រួចហើយ នៅក្នុងឯកសារភាគពីរ ហើយរូបវិស្ណុអង្គធំនេះ កើតឡើងបានក៏ដោយសារការផ្ដុំរូបវិស្ណុតូចៗ ដែលនៅទ្រពីខាងក្រោមផ្លូវដើរចូលតែប៉ុណ្ណោះ យើងអ្នកទស្សនាពុំបានចាប់អារម្មណ៍ឡើយ ព្រោះនៅខាងក្រោមផ្ទាល់ដី។ ព្រះមាតាចង់ប្រាប់យើងថា តួអង្គព្រះវិស្ណុនេះ សុខចិត្តលំបាកវេទនាទ្រស្ពាន ឲ្យគេដើរឆ្លងកាត់រាល់ថ្ងៃ រូបសំណាកតូចៗ តំណាងឲ្យគាត់ ត្រូវគេនោមដាក់ ដើរជាន់ដូចសំរាម (ព្រោះទីនោះងាយបន្ទោបង់ទឹកមូត្រ) តែគាត់សុខចិត្តតស៊ូទ្រនូវទម្ងន់ស្ពាននេះ ដើម្បីបំពេញគុណធម៌គឺបារមី ស្រង់

ព្រះម៉ែចេញពីសមុទ្ទទុក្ខ (សមុទ្ទទឹកដោះ)។ ប្រស្នារូបនេះ ក៏បានប្រាប់យើងទៀតថា ផ្លូវកណ្ដាលគាត់ពុំអាចនាំរឿងព្រះមាតាចេញមកខាងក្រៅបានឡើយ មានន័យថាអាថ៌កំបាំងមាតាពុំអាចដឹងជាចំហបានឡើយ គឺត្រូវគេដឹងតាមច្រកតូច ដែលមានរូបនេះជាភស្ដុតាងស្រាប់ ព្រោះព្រះវិស្ណុនេះបើគាត់ចេញមកក្រៅ ត្រូវដើរលើផ្លូវដី ពុំមែនដើរលើផ្លូវថ្មឬផ្លូវដែលក្រាលកៅស៊ូឡើយ។ ហើយម្យ៉ាងទៀតមាតាដែលនៅខាងឆ្វេងដៃគាត់ ត្រូវដាក់ឲ្យឈរបញ្ច្រាសទិសចង្អុរយោនី គឺខ្ទប់មុខទៅជញ្ជាំង ឯក្បាលម្ដាយនិងដៃត្រូវមនុស្សទុច្ចរិត ដែលមានពៀរនឹងគាត់ បានវាយបំបាក់អស់ទាំងស្រុងទៅហើយ តើងាយអ្វីដែលកូនជាព្រះវិស្ណុអាចនាំគាត់ចេញមកខាងក្រៅបានដោយងាយនោះ។ ហើយរូបព្រះវិស្ណុធំនេះទៀតសោត ទម្រាំអាចផ្គុំបានជារូបធំនេះត្រូវគ្រុឌស្វាក់គ្រប់ជំហាន (មើលរូបក្រោមស្ពាន) តែគាត់ស៊ូទ្រាំព្យាយាម ដើម្បីជួយស្រង់ប្រស់ម៉ែឪមហានគរឲ្យលោកបានរួចពីបាបកម្មចាស់ ទោះបីខ្លួនត្រូវទ្រស្ពានដ៏វែងឆ្ងាយយ៉ាងណាក៏ដោយគាត់សុខចិត្តស៊ូទ្រាំ ព្រោះនេះជាក្ដីសង្ឃឹមរបស់ព្រះមាតាបិតានាគមកលើរូបគាត់ជាកូនតែមួយគត់ (ព្រះវិស្ណុ)។

## ៥៤/.រូបភាពទី៥៩រូបមាតាមហានគរ(អង្គរវត្ត)



រូបមាតាមហានគរនេះ ស្ថិតនៅពីខាងឆ្វេងព្រះវិស្ណុអង្គធំ ដែលខ្ញុំលើកយកមកដាក់បង្ហាញនេះ គ្រាន់តែចង់ឲ្យកូននាគមើលរូបរួចពិចារណាថា បើអាទិទេពរបស់យើងស្ថិតក្នុងសភាពបែបនេះ ពេលដែលយើងជាកូននាគទាំងអស់គ្នាមានភ័យអាសន្នកើតឡើង ហើយយើងនាំគ្នាបន់ស្រន់បួងសួង ឲ្យព្រះមាតាមហានគរ ឬអាទិទេពផ្សេងៗទៀតមកជួយ តើឲ្យពួកគាត់មកជួយយើងយ៉ាងដូចម្ដេច? បើរូបតំណាងអ្នកដែលត្រូវមកជួយយើងជាកូន ត្រូវបានដាប់បំផ្លាញអស់យ៉ាងនេះ តើយើងសង្ឃឹមលើអាទិទេពរបស់យើង យ៉ាងដូចម្ដេច? ទោះបីអ្នកយកសំពត់ទៅស្លៀក យកអាវទៅពាក់ តើមាន

ប្រយោជន៍អ្វី? បើពួកគាត់បាត់ក្បាល និងអវយវៈអស់ទៅហើយនោះ។

## ៥៥/.រូបភាពទី៥៥នាគ៣រួមខ្លួនតែមួយ(ប្រាសាទអង្គរវត្ត)



នាគបីរួមខ្លួនមួយនេះ នៅជិតផ្លូវចូលខ្លោងទ្វារ (គោបុរៈ) ហើយប្រស្នានាគបីរួមខ្លួនមួយនេះ មាននៅក្នុងរឿងធនជ័យ ដោះប្រស្នាអ្នកប្រាជ្ញចិន ដែលគាត់បានឆ្លើយប្រាប់លោកគ្រូសង្ក្រាជផ្សេង ប្រាប់សម្ដេចចៅពញាវាំងផ្សេង និងប្រាប់ស្ដេចផែនដីផ្សេង គឺអត្ថន័យពុទ្ធសាសនា ព្រហ្មញ្ញសាសនា និងសាសនមាតាមហានគរបូកបញ្ចូលគ្នា។ អាថ៌កំបាំងបេះដូងនាគក្នុងថ្មទាំងនេះ លុះត្រាតែកូននាគសម័យក្រោយ ព្រមហែក និងព្រមចុះទៅក្នុងទ្រូងមេនាគ ទើបដឹងរឿងក្នុងបេះដូងថ្មគ្រប់ប្រាសាទរាប់ពាន់ ដែលមាននៅក្នុងទឹកដីព្រះម៉ែនេះ។ ដូច្នេះហើយ ទើបនៅប្រាសាទព្រះវិហារក្នុងផ្ទៃរ និងក្បាំងក្លែងមួយ ដែលខ្ញុំធ្លាប់មើលប៉ះក្នុងទូរទស្សន៍ គឺគាត់បានឆ្លាក់រូបបុរសម្នាក់ ចាប់ហែកនាគជាពីរ ន័យរបស់រូប គឺមើលអាថ៌កំបាំងក្នុងបេះដូងនាគ (មើលការបកស្រាយប្រស្នាចាក់ទឹកដូងភាគ១ និងមង្គល៣ភាគ២)។ ដូនតាយើងជាពូជនាគ ជាអ្នកប្រាជ្ញ ជាបណ្ឌិត រាល់ការបន្សល់ទុកកេរមរតកគំនិតរបស់ពួកគាត់សុទ្ធតែមានបង្កប់ន័យនៅក្នុងស្នាដៃ មែនឆ្លាក់រឿងដោយពុំមានហេតុផលនោះទេ។ ដូចជារូបនាគរួមខ្លួនមួយ ជាភស្ដុតាងស្រាប់ ន័យរបស់រូបគឺ អតីត បច្ចុប្បន្ន អនាគត នាគម៉ែ នាគឪ នាគកូន ត្រូវរួមគ្នាជាខ្លួនតែមួយ (នាគព័ន្ធ) ទើបអាចរំដោះខ្លួនរួចផុតពីអំណាចយក្ស ដែលលេបពីអតីតបាន បើពុំរួមខ្លួនទេ គឺដូចសុភាសិតខ្មែរបានប្រាប់ថា **ចង្កឹះមួយច្បាច់កាច់ពុំបាក់ តែបើចង្កឹះតែមួយគេអាចកាច់បំបាក់បាន**។

ន័យមួយទៀតគាត់បានប្រាប់ថា បេះដូងពិតរបស់ព្រះម៉ែនាគ គឺបានលាក់ទុកនៅក្នុងព្រហ្មញ្ញសាសនា និងពុទ្ធសាសនាទាំងពីរនិកាយ គឺយើងត្រូវច្របាច់បញ្ចូលបីឲ្យក្លាយជាមួយ ដូចប្រស្នាធនជ័យប្រាប់ចម្លើយដល់យើងថា ក្នុងចម្លើយបីនេះ កើតឡើងពីបីរួមគ្នា គឺបានចម្លើយមួយពិត ហើយចម្លើយមួយនោះអាចកើតឡើងបាន លុះត្រាតែត្រិះរិះពិចារណាដោយខ្លួនឯង ពុំមែនទៅសួររកចម្លើយពីអ្នកដទៃឡើយ(បរទេស) ព្រោះ**ពុំមាននរណាស្រឡាញ់ខ្មែរជាងខ្មែរស្រលាញ់ខ្មែរឡើយ។**

## ៥៦/.រូបភាពទី៥៦រូបផ្តែរខាងក្នុងប្រាសាទ(មិនស្គាល់ប្រភព)



រូបផ្តែរដែលនៅខាងក្នុងប្រាង្គប្រាសាទ ប្រៀបបីដូចជានៅក្នុងទ្រូង ឬក្នុងបេះដូង ព្រោះទ្វារបន្ទប់នីមួយៗ បានលាក់ទុកនៅរឿងមួយ ដូចក្នុងចិត្តរបស់បុគ្គលម្នាក់ៗតែងលាក់រឿងទុកក្នុងចិត្តរបស់ខ្លួនដូច្នោះ ដែលរឿងនោះទៀតសោត មានច្រើនពុំអាចនឹងរាប់ចំនួនបាន។ ក្នុងបណ្តារឿងក្នុងចិត្តទាំងអស់ គឺមានតែរឿងទុក្ខសោកស្តាយក្រោយ ដែលខ្លួនបានប្រព្រឹត្តខុសតែប៉ុណ្ណោះ វាតាមដេរស្តីថាបន្ទោសឲ្យខ្លួនរហូត ដែលនាំឲ្យមានការក្តៅក្រហាយចិត្ត (កក្កុច្ចៈចេតសិត) ហើយអកុសលចិត្តនេះតែងឲ្យផលជាទុក្ខក្នុងអបាយភូមិ (ភូមិទុក្ខ)។ ព្រោះបុគ្គលដែលបរិបូណ៌ដោយញាតិ ដោយយសសក្តិ ដោយទ្រព្យសម្បត្តិ ពុំអាចជួយបុគ្គលនោះកុំឲ្យធ្លាក់អបាយភូមិបានឡើយ លុះត្រាតែបុគ្គលដែលបរិបូណ៌ដោយបុណ្យគឺទាន សីល ភាវនា បរិបូណ៌ដោយសម្មាទិដ្ឋិ (ការយល់ត្រូវ).....ទើបអាចជួយបុគ្គលនោះ ឲ្យបានសោយផលក្នុងសុគតិភពបាន ហើយទីបំផុតអាចត្រាស់ដឹងនូវសច្ចៈធម៌ (បើកទ្វារព្រះនិព្វាន្ត) ទៅតាមថ្នាក់មគ្គ និងផលរហូតដល់ទីបំផុតនៃមគ្គ និងផល។

រូបផ្ដែរនៅខាងក្នុងប្រាង្គប្រាសាទនេះ និយាយពីបុរសម្នាក់ ដែលអង្គុយលើក្បាលយក្ស ហើយនឹងរូបនៅពីសង្ខាងរូបកណ្ដាល យើងពុំអាចមើលយល់ឡើយ ព្រោះជនទុច្ចរិតបានដាប់បំផ្លាញក្បាលចោលអស់ហើយ គំនិតរបស់ពួកគេគឺមិនចង់ឲ្យអ្នកទាំងបី រស់រានមានជីវិតឡើយ។ អត្ថន័យក្នុងផ្ដែរនេះ ក៏មិនខុសពីផ្ដែរដែលនៅខាងក្រៅឡើយ គាត់គ្រាន់តែចង់ពន្យល់ពីអាថ៌កំបាំងប្រាប់យើងថា រឿងនៅផ្ដែរខាងក្នុងប្រាង្គ គឺរឿងក្នុងចិត្ត (ក្នុងទ្រូងក្នុងបេះដូង) រឿងនៅផ្ដែរ ឬក្បាំងក្លែងនៅខាងក្រៅ គឺរឿងដែលបាននាំចេញមកផ្សព្វផ្សាយហើយ (លែងលាក់ទុក) គឺរឿងនៅលើមុខ។

សរុបសេចក្ដីមករូបផ្ដែរក្នុងប្រាង្គដែលខ្ញុំបានយកមកបង្ហាញនេះ គ្រាន់តែចង់ឲ្យកូននាគមើលពីកម្លាំងបំផ្លាញរបស់សត្រូវ គឺទាំងខាងក្នុងទាំងខាងក្រៅ ព្រោះពួកគេមិនចង់ឲ្យរឿងដែលគេបានលុបបំបាត់ដាន់រាប់ពាន់ឆ្នាំមកហើយនោះ អាចរស់ឡើងវិញឡើយ។

## ៥៧/.រូបភាពទី៥៧រូបអច្ឆរាញញឹមចេញធ្មេញ(ប្រាសាទអង្គរវត្ត)



ក្នុងចំណោមរូបអច្ឆរារាប់ពាន់ ដែលមាននៅលើប្រាសាទអង្គរវត្ត ភាគច្រើនគឺបិទមាត់ ហើយក្នុងចំណោមរូបទាំងនោះ មានតែអច្ឆរាពីរប៉ុណ្ណោះបើតាមខ្ញុំដឹង គឺរូបមួយលានអណ្ដាត និងរូបមួយទៀតញញឹមចេញធ្មេញ។ ហើយរូបអច្ឆរាញញឹមចេញធ្មេញនេះ ក៏នៅក្នុងអំណាចក្រុងរបស់យក្សនៅឡើយ ព្រោះសុទ្ធតែក្បាច់ឋាន ដែលនៅបង្កប់ពីខាងក្រោយរូប តែមានរូបក្បាលយក្សដៃចាប់កាន់ និងមាត់ខាំពាំរាជបញ្ជារបស់ខ្លួន (មិនទាន់ព្រមលើកលែងទោស ឬលើករាជបញ្ជាឡើង) ដូចអត្ថន័យរូបមុន ដែលខ្ញុំបានពន្យល់ហើយ។ ធ្មេញគឺមានន័យថា គាត់អាចបង្ហាញនៅអាថ៌កំបាំងក្នុងមាត់ ដែលពីមុនពុំអាចហាមាត់រួច

នោះ ឥឡូវនេះគាត់ចាប់ផ្ដើមអាចបញ្ចេញរឿងអាថ៌កំបាំងក្នុងចិត្ត ចេញមកខាងក្រៅបានខ្លះហើយ តាមរយៈសូរសព្ទវាចា និងតាមរយៈអត្ថបទ។ ហើយរូបអប្សរានេះ ព្រឹទ្ធដូនតាគាត់បានឆ្លាក់នៅលើជញ្ជាំងជិតផ្លូវចេញមកខាងក្រៅ ច្រកចំហៀងវិស្ណុអង្គធំ (តារាជ) ព្រោះគាត់ដឹងថា រឿងរបស់អច្ឆរា ពុំអាចនាំចេញដោយបើកចំហបានឡើយ គឺអច្ឆរមាតាលោកចេញមកដោយលួចលាក់ និងស្ងៀមស្ងាត់ ព្រោះកូននាគដែលនាំរឿងរបស់លោកចេញ ពុំមានឫទ្ធិអំណាច និងកំឡាំងគ្រប់គ្រាន់ អាចធ្វើការផ្សព្វផ្សាយរឿងបានដោយងាយស្រួលនោះឡើយ។

នៅជាន់ខាងលើអច្ឆរា មានរូបមនុស្សកំពុងជិះសត្វក្ដាន់ឬរមាំង ហើយសត្វរមាំងនោះ ងើបឈរជើងពីរឡើងទៅលើ (កញ្ជ្រោល) ពុំព្រមដាក់ជើងមុខចុះទៅក្រោមឡើយ ដើម្បីដើរចេញតាមច្រកផ្លូវដែលគោកំពុងជ្រោងបើក។ ដូច្នេះទើបអ្នកជិះរមាំងនោះ យកជើងគាត់មួយចំហៀងទៅជាន់ជើងមុខរបស់សត្វរមាំងនោះ ឲ្យព្រមទំលាក់ខ្លួនឱនចុះ ទើបអាចចេញតាមទ្វារដ៏ទាប ដែលគោកំពុងប្រឹងជ្រោងបើកនោះរួច។ បុរសជិះរមាំងពីខាងលើនោះ តំណាងឲ្យព្រះវិស្ណុឬកូននាគមានភារកិច្ចត្រូវនាំរឿងរបស់អច្ឆរា ដែលបានលាក់កប់ទុករាប់ពាន់ឆ្នាំក្នុងសមុទ្រទឹកដោះនោះ ដើម្បីយកចេញមកផ្សព្វផ្សាយខាងក្រៅ។ ឯសត្វរមាំង តំណាងឲ្យយានជំនិះ ឬមនុស្សដែលមានកិច្ចក្នុងការជួយដល់អ្នកជិះខាងលើ ដើម្បីនាំរឿងចេញតាមច្រកទ្វារគោ គឺតាមច្រកទ្វារសត្វសីហៈ (មើលការពន្យល់ពីសត្វគោក្នុងរូបមុន) ព្រោះរឿងសាសនបណ្ដាំអច្ឆរមាតានេះ ត្រូវបានផ្សព្វផ្សាយចេញតាមច្រកទ្វារគោនេះ។ អច្ឆរមាតាអាចបង្ហាញពីធ្មេញ ដែលធ្លាប់តែលាក់បិទនោះ (បុកលាក់ ធ្វើធ្មេញ បន្សាបពិសនាគ) ត្រូវពឹងផ្អែកទៅលើកូននាគខាងលើ និងច្រកទ្វាររាជសីជ្រោងបើកខាងលើនោះឯង ព្រោះអាថ៌កំបាំងដែលគាត់រងទុក្ខ នៅក្នុងសមុទ្រទឹកដោះ គឺលោកសង្ឃឹមទៅលើកូននាគណាដែលព្រមចុះទៅក្នុងសមុទ្រទឹកដោះ ស្វែងរកដំណក់ទឹកអម្រឹតរបស់គាត់តែប៉ុណ្ណោះ (នេះជានិមិត្តរូបផ្លូវ ដែលកូននាគចេញ)។

សរុបសេចក្ដីមកមាតាមហានគរឬអច្ឆរមាតាលោកមានសង្ឃឹមថា រឿងដែលលោកទទួលទុក្ខរាប់ពាន់ឆ្នាំ ក្នុងសមុទ្រទឹកដោះនៅខាងក្នុងប្រាសាទនោះ ជិតចេញផុតពីទ្វារទុក្ខហើយ ព្រោះបេះដូងថ្មបាននិយាយប្រាប់យើងជាកូននាគប្រុសស្រី ឲ្យដឹងពីរឿងពិតក្នុងជីវិតថ្ម ដែលខំទ្រាំឈរហាលភ្លៀងហាលថ្ងៃ និងក្រោមគំនាបដាប់បំផ្លាញរបស់ជនទុច្ចរិត ពីគ្រប់ទិសទី ក្នុងពេលនេះ **អច្ឆរមាតាបានបង្ហាញធ្មេញ បញ្ចេញសូរសព្ទរបស់ខ្លួនហើយ**។

## ៥៨/.រូបភាពទី៥៨រូបផ្ដែរ(ប្រាសាទប្រែរូប)



ប្រាសាទនេះ អ្នកប្រាជ្ញបរទេសស្រាវជ្រាវភាសារូប បានពន្យល់ថាជាកន្លែងសម្រាប់បូជាសពព្រះរាជា ព្រោះអាចារ្យយោគីពេលដែលបូជាសពតែងប្រើពាក្យថា ប្រែរូបចាស់ផ្លាស់រូបថ្មី (រូបចាស់ត្រូវដុតឆេះអស់ រូបថ្មីសល់តែធាតុ) រូបចាស់គឺទឹក ដី ភ្លើង ខ្យល់ដែលមានពីមុន ឯរូបថ្មីគឺធាតុដែលនៅសល់ពីការបូជានោះ។ បើយើងមើលរូបក្នុងផ្ដែរដែលនៅសេសសល់នេះ បេះដូងរូបបានប្រាប់យើងថា មានបុរសម្នាក់មុខតោ ឬរាជសី កំពុងបីព្រះមាតាដាក់លើភ្លៅទាំងសង្ខាង ហើយកូននាគនោះផ្សះផ្សារ ប្រស់ឲ្យគាត់រស់ឡើងវិញ (មើលការពន្យល់រូបទី៣៤) គឺប្រែរូបពីស្លាប់ឲ្យរស់ ប្រែពីផ្កាប់មកផ្ងារ ប្រែរូបរឿងដែលនៅខាងក្នុងថ្មពីមុនកូននាគមិនដឹង ឲ្យមកដឹងរឿងពិតន័យរបស់រូបថ្មទាំងនោះ....។ល។ នៅក្នុងទ្រនុងខ្នងនាគនិមិត្តរូបទាំងសង្ខាង មានរូបមនុស្សកំពុងលើកដៃរាំ (មើលការពន្យល់រូបទី៣៧) ហើយចុងក្រោយរូបតូចៗទាំងនេះ បានរីកធំនៅក្នុងក្បាលនាគនិមិត្តរូបខាងចុង រូបនេះតំណាងឲ្យព្រះវិស្ណុ ឥសូរ លោកេស្វរ:......ដែលជាកូននាគត្រូវមកជួយមាតានាគ (មើលការពន្យល់រូបមុនៗ)។ នៅក្រោមក្បាច់តំណាងឲ្យខ្លួននាគនិមិត្តរូបនោះ មានរូបមនុស្សពាក់កណ្ដាលខ្លួនតូចៗបីសង្ខាង គឺតំណាងឲ្យព្រះមាតានាគ ដែលសកម្មភាពរូបកំពុងលើកដៃសំពះអង្វរ ចំពោះកូននាគប្រុសស្រីមានក្ដីអាណិតមេត្តាជួយដល់គាត់ផង (ទំនួញប្រែត) តើឲ្យកូននាគទាំងអស់ជួយដូចម្ដេចទៅ? កុំថាឡើយជួយ គ្រាន់តែដឹងរឿងរបស់ព្រះម៉ែមហានគរ ក៏ពុំមាននរណាដឹងផង ព្រោះដានស្នាមរបស់គាត់ត្រូវគេបិទ គេលុប គេចុក គេសន្ធប់ជិតអស់ទៅហើយ។ ក្នុងរូបនេះ រឿងរបស់គាត់បានលាក់ទុកក្នុងព្រៃ

ក្បាច់ជ័ញ្ជីកស្នេកស្ទះ សូម្បីតែចាប់អារម្មណ៍ក៏មិនចាប់ផង ព្រោះឯកសារក្នុងថ្មទាំងនេះ បរទេសបាន ពន្យល់ថា ជាផ្នូរ ប៉ាឆា ហើយពាក្យនេះបានជិតក្នុងសន្ដានកូនខ្មែររាប់រយឆ្នាំកន្លងមកហើយ។

សរុបសេចក្ដីមកអត្ថន័យរឿងក្នុងផ្ទៃរប្រាសាទនេះ ក៏មិនខុសពីផ្ទៃរក្នុងប្រាសាទដទៃទៀតដែរ ដែលខ្ញុំលើកយកមកបង្ហាញនេះ គ្រាន់តែចង់ឲ្យកូននាគឆ្លុះបញ្ចាំងជាមួយរូបទី៣៤ ដែលគេបានដាច់ ក្បាលរូបចោល យើងអាចមើលរូបក្នុងផ្ទៃរនេះ ទៅប្រៀបធៀបនឹងផ្ទៃរនោះ យើងនឹងដឹងថា បុគ្គល ដែលគេដាច់ក្បាលចោលក្នុងរូបទី៣៤ គឺមានក្បាលជាតោឬរាជសី ព្រោះសកម្មភាពរូប គឺស្រដៀង គ្នា។

## ៥៩/.រូបភាពទី៥៩រូបនៅជញ្ជាំង(ប្រាសាទអង្គរវត្ត)



រូបភាពក្នុងជញ្ជាំងនេះ បានបង្ហាញពីសកម្មភាពអច្ឆរមាតា កំពុងអង្គុយបញ្ឈរជង្គង់នៅលើ អង្រឹងស្នែង ដែលមុខមាត់គាត់ពុំមានភ្នែកច្រមុះពិតប្រាកដឡើយ គឺមានតែរាងមុខប៉ុណ្ណោះ (ប្រស្នា កំបាំងដែលកូននាគសព្វថ្ងៃពុំស្គាល់មុខមាត់ពិតរបស់គាត់)។ ហើយអ្នកដែលកំពុងសែងអង្រឹងស្នែង

ដងស្នែងទាំងសង្ខាងមានសុទ្ធតែក្បាលនាគ អ្នកសែងទាំងនោះមានដំណើរឈានទៅមុខយ៉ាងស្វាហាប់ តើក្នុងរូបនេះគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

១/.អច្ឆរាដែលអង្គុយក្នុងអង្រឹងស្នែង ដែលមានដំបូលគ្របខាងលើវិចិត្រទៅដោយក្បូរក្បាច់មានរាងដូចជាដំបូលប្រាសាទនោះ ស្ត្រីនេះតំណាងឲ្យ អច្ឆរមាតា ឬព្រះម៉ែមហានគរ ព្រោះគេបានឆ្លាក់មុខគាត់ពុំមានច្រមុះមាត់ឡើយ គឺមានតែទម្រង់មុខដែលមានពាក់ក្បាំងតំណាងឲ្យអច្ឆរាតែប៉ុណ្ណោះ។ ក្នុងរូបនេះគាត់ចង់ប្រាប់យើងថា សព្វថ្ងៃនេះមានកូននាគតិចណាស់បានស្គាល់អច្ឆរាដែលជាអ្នកបង្កើតភាពអច្ឆរិយៈនេះឡើង ព្រោះរឿងពិតរបស់គាត់គេបានលុបបំបាត់ដានអស់ទៅហើយ ប្រៀបដូចជាមុខរបស់គាត់ក្នុងរូបនេះ នៅសល់តែមកុដតែប៉ុណ្ណោះ រីឯមុខមាត់ពិតប្រាកដត្រូវបានរលុបអស់ហើយ។ ដៃគាត់ខាងស្ដាំ កំពុងហុចរបស់ម្យ៉ាងឲ្យកូនក្មេងដែលនៅឈរខាងក្រោម ព្រោះគាត់មានសង្ឃឹមថា ថ្ងៃក្រោយកូននោះនឹងស្គាល់មុខមាត់ពិតរបស់គាត់ តាមរយៈសសៃរខ្សែមានបន្ដោងដែលគាត់បានហុចឲ្យ គេនឹងធ្វើការស្រាវជ្រាវរកប្រភពដើមកំណើតពិតពីរបស់នោះ។ តែគួរឲ្យសង្វេគណាស់ កំភួនដៃគាត់ត្រូវបានជនទុច្ចរិតដាប់បំផ្លាញអស់ហើយ ព្រោះគំនិតអ្នកដាប់ គេមិនចង់ឲ្យអច្ឆរានេះ ហុចវត្ថុដែលនៅក្នុងដៃមកឲ្យក្មេងដែលឈរពីខាងក្រោមបាន។

២/.ក្មេងខាងក្រោមដែលកំពុងឈរនៅលើចិញ្ចើមផ្លូវខាងស្ដាំ ហើយដៃលើកទទួលនូវវត្ថុ ដែលស្ត្រីក្នុងអង្រឹងស្នែងខាងលើហុចឲ្យនោះ គឺតំណាងឲ្យកូននាគដែលបានទទួលប្រស្នាកំបាំង មរតករបស់ស្ត្រីអច្ឆរាខាងលើ ក្មេងនេះទៀតសោត ពូជពង្សឋានៈរបស់គាត់ស្មើនឹងអ្នកលក់ដូរតាមចិញ្ចើមថ្នល់ ព្រោះក្មេងនោះគឺជាកូនស្ត្រីម្នាក់ កំពុងអង្គុយលុតជង្គង់ដាក់កញ្ជើលក់នោះឯង។ ដូច្នេះអាថ៌កំបាំងមរតកស្ត្រីជាអច្ឆរា គ្មានមុខនៅក្នុងអង្រឹងស្នែងខាងលើនោះ រឿងរបស់គាត់ថ្ងៃក្រោយគឺមានតែក្មេងម្នាក់ ដែលជាពូជពង្សអ្នកលក់ដូរតាមចិញ្ចើមថ្នល់នេះទេ ដែលដឹងរឿងរបស់គាត់ ហើយក្មេងនេះអាចនឹងបើកមុខមាត់ពិត របស់ស្ត្រីដែលនៅក្នុងអង្រឹងស្នែងខាងលើបាន។ ចំណែកឯម្ដាយរបស់ក្មេងនោះវិញ គាត់ពុំបានដឹងរឿងដែលកូននេះ បានទទួលមរតកពីស្ត្រីដែលនៅក្នុងអង្រឹងស្នែងខាងលើឡើយ ព្រោះគាត់រវល់តែលក់ដូរងាកមើលទៅខាងក្រោយ (មើលរូប) សម្លៀកបំពាក់ដែលក្មេងនោះបានស្លៀក ស្រដៀងនឹងសំពត់ដែលអច្ឆរមាតាខាងលើបានស្លៀក គ្រាន់តែសំពត់របស់ក្មេងមានទំហំតូចជាងតែប៉ុណ្ណោះ។

ដំបូលដែលអ្នកជ្រោងទូដើរសង្ខាងតាមអង្រឹងស្នែងខាងលើនោះ គឺមានរូបរាងដូចជាគម្រប ម្ឈូសសព្វថ្ងៃនេះ មានន័យថា គេកំពុងសែងគាត់យកទៅឃុំ ទៅគ្របលាក់ទុក ប្រៀបបីដូចមនុស្សរស់ ក៏ប៉ុន្តែឈ្មោះថាដេកស្លាប់ ព្រោះរឿងពិតរបស់អច្ឆរមាតា (បិសាចពស់ ឬបិសាចនាគ) បានស្លាប់ពី ក្នុងសន្តានចិត្តកូននាគប្រុសស្រីអស់ទៅហើយ (ព្រោះខ្មែរពុំបានដឹងពីសាសនអច្ឆរមាតា) មនុស្សរស់ តែដេកក្នុងម្ឈូស។

## ៦០/.រូបភាពទី៦០រូបក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)

តើអត្ថន័យក្នុងក្បាំងក្លែងនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?



១/.ជាប់ខាងលើក្នុងក្បាំងក្លែង គឺរូបមនុស្សម្នាក់កំពុងរៀបងើបឈរ ដៃម្ខាងលើករាំ ដៃម្ខាង ទៀតកាន់រាជសាររឿងក្នុងដៃ រូបនេះត្រូវគ្របជាប់ក្នុងក្បាំងតូចមួយផ្សេងទៀត ហើយគាត់ជិះលើដំរី ក្បាលបី ដែលរូបដំរីត្រូវរលកទឹកបិទបាំងជើងខាងក្រោម។ ដៃកាន់រាជសារ តំណាងឲ្យរឿងមាតាលាក់ ទុកក្នុងបេះដូងថ្ម ដែលគាត់ត្រូវយកមកផ្សព្វផ្សាយប្រាប់ ដៃលើករាំតំណាងឲ្យ វិជ្ជាជីវៈរបស់គាត់ (ពន្យល់រួចហើយក្នុងរូបមុន) ហើយគាត់ជិះលើដំរីក្បាលបី គឺគាត់អាចដឹងពីអាថ៌កំបាំងក្នុងបេះដូងដំរី ទាំងនេះ ថាក្នុងអតីតកាលកន្លងទៅដំរីនេះ មានក្បាលតែមួយទេ (ពន្យល់រួចហើយ)។

២/.មនុស្សលើកដៃសំពះបន្ទូលទៅលើនៅពីសង្ខាង ដែលកំពុងងើបក្បាលរួចពីក្នុងទឹកត្រឹមចង្កេះនោះ គឺពួកគាត់តំណាងឲ្យមាតាទាំង១២ ឬឆ្នាំ និងខែទាំង១២ ក្នុងមាតុភូមិនេះ មានន័យថាកែវភ្នែកដែលធ្លាប់តែងងឹតដោយអំណាចយក្សខ្វេះជាយូរយារណាស់មកហើយនោះ ឥឡូវនេះពួកគាត់អាចមើលឃើញរឿងពិតរបស់ខ្លួនបន្តិចម្តងៗហើយ។ ស្ត្រីទាំងនោះ មានចំនួនម្ខាង៥នាក់ៗ សរុបទៅគឺមានចំនួន១០នាក់ ចំណែកឯពីរនាក់ទៀត នៅមិនទាន់ដឹងសារតាពិតរបស់ខ្លួនឡើយ ហើយពួកគាត់ទាំង១០នាក់នេះ កំពុងលើកដៃបន្ទូលងើយក្បាល ទៅមើលបុរសដែលជិះនៅលើដំរីក្បាលបីខាងលើ ហាក់បីដូចជាចង់ប្រាប់ថា ឲ្យកូននោះខំប្រឹងប្រែងព្យាយាមតស៊ូបន្តទៅទៀត ដើម្បីរើខ្លួនឲ្យរួចពីក្បាំង ឬអង្រិតដែលក្រុងគ្របពីខាងលើ តាំងពីក្បាំងតូចរហូតទៅដល់ក្បាំងធំទាំងបីជាន់ខាងលើ កុំឲ្យកូនដាក់ធុរៈធ្ងន់នេះចុះ ព្រោះពួកគាត់មានក្តីសង្ឃឹមទៅលើកូននាគនោះទាំងស្រុង។

៣/.ខាងក្រោមបន្ទាប់ គឺមានរលកទឹកត្រួតគ្នាជាន់ៗ ខាងក្រោមរលកទឹកជាន់ៗនោះ គឺមានបន្ទាត់ឆ្នូតៗពីរជាន់ មើលទៅហាក់បីដូចជាសសៃរទឹកភ្លៀង ដែលត្រូវហូរធ្លាក់ពីរលកទឹកខាងលើ តើទឹកនេះតំណាងឲ្យអ្វី? ទឹកនេះគឺតំណាងឲ្យ រលកទឹកចិត្ត មនោគមវិជ្ជាបរទេស ដែលធ្លាប់បានមកគ្របសង្កត់បិទបាំង និងធ្វើអាណានិគម មកលើទឹកចិត្តកូនខ្មែរបំភាន់នៅការពិត តាំងពីអតីតកាលមកនោះ ដូច្នេះទើបមនុស្សសត្វដែលនៅខាងក្រោមទឹកនោះ មិនលង់ទឹកស្លាប់ ហើយមិនត្រឹមតែមិនលង់ទឹកនោះស្លាប់ទេ រូបទាំងនោះកំពុងមានសកម្មភាពបររថប្រឈមមុខដាក់គ្នាថែមទៀត។

៤/.នៅខាងក្រោមរលកទឹកនោះ ចំកណ្តាលមានក្បាលនាគពីរកំពុងបន្តឡើងត្រួតគ្នា តើតំណាងឲ្យអ្វី? នាគទាំងពីនោះ គឺតំណាងឲ្យព្រះមាតានាគ ដែលខំប្រឹងប្រែងងើបចេញពីខាងក្រោមដើម្បីឲ្យរួចពីការឃុំគ្រងរបស់យក្ស និងបក្សពួក ដោយអំណាចកូនខាងលើបានជួយបើកទ្វារឃុំទាំង៣ ហើយការប្រឹងងើបរបស់គាត់ជាលើកទីពីរនោះ គឺអព្ភូតហេតុដែលកើតមានឡើង កាលពីឆ្នាំកន្លងទៅនៅក្នុងទន្លេបួនមុខ។ អព្ភូតហេតុក្នុងពេលនោះ គឺដូចជាខ្យល់ក្ងួចទឹកទៅលើ ដើម្បីទំលុះពពកនៅខាងលើ ដែលខ្យល់អព្ភូតហេតុធម្មជាតិនោះ មានរាងដូចជាខ្លួននាគ ប៉ុន្តែគាត់ពុំទាន់មានកម្លាំងឡើងទៅខាងលើរួចឡើយ គឺមានរូបក្នុងក្បាំងភ្លែងនេះ តំណាងឲ្យគាត់ជាភស្តុតាងស្រាប់។ អព្ភូតហេតុនេះទៀតសោត កើតឡើងក្នុងថ្ងៃ១៤រោច ខែភទ្របទ គឺមុនភ្ជុំបិណ្ឌមួយថ្ងៃ ដែលគាត់ខំស្ទុះឡើងមុខព្រះបរមរាជវាំងកណ្តាលក្រុងភ្នំពេញ ហើយក្នុងរដូវបិណ្ឌភ្ជុំទៀត ព្រោះគាត់ចង់ឲ្យកូននាគទាំងអស់ឧទ្ទិសបុណ្យជូនទៅឲ្យគាត់ (ពេលដែលត្រូវឧទ្ទិសបុណ្យជូនប្រេត) តែជាការឥតប្រយោជន៍សោះ ព្រោះគ្មាន

កូននាគណាម្នាក់បានដឹង ពីអាថ៌កំបាំងក្នុងបេះដូងរបស់គាត់ឡើយ បានត្រឹមតែទៅឈរមើលតែប៉ុណ្ណោះ។

៥/.សត្វករវិកមួយជួរកំពុងហើរបញ្ច្រាសទិសគ្នា តើតំណាងអ្វី? អាថ៌កំបាំងមហិទ្ធិឫទ្ធិសម្លេងសត្វករវិកនេះ ខ្ញុំបានពន្យល់ក្នុងរូបទី១ និងទី២រួចហើយ។ សត្វនេះតំណាងឲ្យសកម្មជនដែលជាអ្នកផ្សព្វផ្សាយ រលកមនោគមវិជ្ជាបរទេសខាងលើ ដែលបិទគ្របពីខាងលើនោះ ដើម្បីកុំឲ្យអ្នកដែលនៅខាងក្រោម ដឹងរឿងនៅពីខាងលើទឹក។

៦/.ឯជាន់ខាងក្រោម ដូចជានៅលើដី ឬលើភក់ មានរូបសត្វជាច្រើនដូចជា ដំរី គោ ក្ដាន់ រមាំង ឈ្លូស ស្វា...... និងមានមនុស្សជិះរថសង្វាង ដែលរថនោះទឹមដោយសេះដែលមានដុះស្នែងមួយ ហើយអ្នកដែលជិះរថនោះ មានកាន់អាវុធនៅក្នុងដៃ តើរូបទាំងនេះ តំណាងឲ្យអ្វី? រូបសត្វទាំងអស់ តំណាងឲ្យឈ្មោះខេត្តក្រុងពីអតីត ហើយសត្វដែលតំណាងឲ្យខេត្តក្រុងទាំងនេះ កំពុងតែផ្អើលរត់ជាន់គ្នាដោយភ័យខ្លាចនឹងការប្រយុទ្ធរបស់អ្នកទាំងសង្វាង ចំណែករូបមនុស្សដែលជិះរថទាំងសង្វាងនោះ តំណាងឲ្យកូននាគ។

៧/.ចុងនៃក្បាំងភ្លែងនេះ មានគោពីរ ឬគុជសីនៅសង្វាង កំពុងរើខ្លួនចេញពីមាត់យក្ស ដែលនៅក្នុងមាត់មានពាំចង្វាយផ្កាជារាងប្រទីប បានបាក់បែកខាងគល់អស់ទៅហើយ នៅសល់តែខាងចុង អាចឲ្យយើងមើលដឹងថាជាប្រទីប ដែលប្រទីបនេះមិនទាន់អាចលើកបំភ្លឺរួចនៅឡើយ។ ដៃគោកំពុងជ្រែងដូច្នេះគោនេះ មិនទាន់មានដៃអាចចាប់លើកគប់ភ្លើងឡើងរួចឡើយ នៅពីក្រោយគោមាននិមិត្តរូបក្បាលនាគគ្របពីខាងលើ មានន័យថាគោនេះ កើតចេញពីក្នុងភូមិនាគ ឬមាតុភូមិ។

៨/.ក្បាំងជាន់ទី២មានគ្រុឌសង្វាង កំពុងក្អែនាគចេញពីមាត់របស់ខ្លួន ហើយនឹងកំពុងចេញពីមាត់យក្ស (សូមមើលការពន្យល់ក្នុងរូបទី៨) ឯក្បាំងជាន់ទីបីពុំមានរូប ខ្ញុំពុំអាចពន្យល់បានឡើយ។

សរុបសេចក្ដីមកអត្ថន័យរូបនៅក្នុងក្បាំងភ្លែងនេះ បើយើងមើលមួយភ្លែតហាក់ដូចជាធម្មតា តែបើយើងមើលរួចគិតត្រិះរិះពិចារណា ទើបយើងស្ងើចសសើរបញ្ញាអច្ឆរមាតា គឺពិតជាអ្នកបង្កើតមាតុភូមិអច្ឆរយៈនេះមែន ព្រោះសូម្បីតែរូបក្នុងថ្ម ក៏បង្កប់ទៅដោយគតិបណ្ឌិតដ៏ជ្រាលជ្រៅ ដែលយើងជាកូននាគសម័យនេះ កំពុងបានទទួលនៅមរតករបស់គាត់ ក៏លំបាំកនឹងទម្លុះបំបែកគំនិតប្រស្នាអាថ៌កំបាំងក្នុងថ្មទាំងនោះណាស់។ សិល្បអច្ឆរិយៈទាំងអស់ មានតែនៅក្នុងក្បាំងដែលពាក់លើ

ក្បាលព្រះម៉ែអច្ឆរនាគទេ ឯបរទេសដែលគេថាសិល្បយើងចម្លងពីខាងក្រៅនោះ គឺពួកគេនិយាយបំផ្លើស បំភាន់ កុហកយើងតែប៉ុណ្ណោះ **វាមិនដែលក្នុងក្បាំងអច្ឆរា (មាតានាគ) ដល់ពេលចារឹករឿងរូបបែរទៅជាដាប់ឆ្លាក់រឿងខាងក្រៅក្បាលខ្លួនទៅវិញ** (នេះជាប្រស្នានៅក្នុងរឿងឥសីមាត់ទិព្វ ដែលព្រះចៅទិព្វវង្សបានជិះសត្វរមាស ទៅប្រស់អ្នកនគរដែលបានក្លាយជាថ្ម ឲ្យរូបថ្មទាំង នោះបានរស់ឡើងវិញ ពន្យល់នៅក្នុងភាគ២ពីប្រាសាទគុករមាស)។

## ៦១/.រូបភាពទី៦១រូបក្បាំងក្លែង(ប្រាសាទបន្ទាយស្រី)



រូបរឿងក្នុងក្បាំងក្លែងនេះ នៅចំកណ្ដាលមានរូបយក្សមួយកំពុងច្រានបុរសម្នាក់ មានពាក់មកុដឲ្យធ្លាក់ទៅក្រោម បើយើងមើលតាមសកម្មភាពរូប តើអត្ថន័យក្នុងក្បាំងនេះ អច្ឆរមាតាគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

១/.យក្សតំណាងឲ្យអ្នកដែលចាប់មាតាបិតាយកទៅឃុំពីអតីតកាល ហើយពេលនេះគាត់កំពុងច្រានទម្លាក់មនុស្សម្នាក់ឲ្យធ្លាក់ចុះមកក្រោម ព្រោះមិនចង់ឲ្យបុរសនេះ នៅរស់រានមានជីវិតឡើយ។

២/.មនុស្សប្រុសម្នាក់មានដុះពុកមាត់ ពាក់មកុដ ទងត្រចៀកមានពាក់ក្រវិលធ្លាក់យាចុះមកក្រោមតាមក្បាលនោះ គឺតំណាងឲ្យកូននាគ ដែលត្រូវមកជួយព្រះមាតាបិតាឲ្យរួចពីអំណាចឃុំរបស់យក្ស។ ទោះបីជាគាត់បានអធិដ្ឋានជីវិតរបស់គាត់ឲ្យទៅយក្សនេះក៏ដោយ ក៏គាត់នៅនៅតែព្យាយាមចាប់ទាញដៃយក្ស ព្រោះគាត់ពុំទាន់បានបញ្ចប់រឿងក្ដីយក្ស និងមាតាបិតាមហានគរនៅឡើយ។ គាត់

ត្រូវធ្លាក់មកក្រោម ដោយអំណាចអណ្ដាតយក្ស ដែលយារធ្លាក់មកលើខ្លួនគាត់ តែគាត់មិនទាន់អាចស្លាប់បានទេ ព្រោះព្រះមាតានាគកំពុងសំពះអង្វរកូននៅពីសង្ខាង ឲ្យកូននោះជួយគាត់ផង។

៣/.នៅខាងក្នុងរង្វង់សីមាក្បាច់ខាងឆ្វេង មានរូបស្ត្រីពាក់មកុដចេញពីក្នុងក្បាច់ បានពាក់កណ្ដាលខ្លួនចំនួនពីររូប ដែលដៃគាត់លើកបន្ទូលទៅលើ នឹងរូបមួយទៀត បានឡើងមកជិតស្មើនឹងកយក្ស។ រូបលើកដៃសំពះសំបូងសង្រ្វង គឺអង្វរដល់កូនដែលយក្សកំពុងរុញទម្លាក់នោះ ឲ្យប្រឹងប្រែងព្យាយាមតស៊ូបន្តទៅមុខទៀត ព្រោះគាត់បានចេញពីសោទាំងបីរួចហើយ ឯរូបទីបីគាត់បានប្រឹងឡើងមកខាងលើ ដៃរបស់គាត់ទាំងសង្ខាងកំពុងជ្រោងបើករង្វង់សីមាយក្ស។ ឯខាងស្ដាំដៃវិញ ក៏មានរូបដូចខាងឆ្វេងដែរ ហើយអត្ថន័យរូបគឺមានន័យដូចគ្នា គ្រាន់តែរូបមួយចំហៀង តំណាងឲ្យអតីតកាល និងមួយចំហៀងទៀតគឺបច្ចុប្បន្នកាល។ រូបស្ត្រីតូចទាំងបីសង្ខាងនេះ តំណាងឲ្យមាតាមហានគរឬអច្ឆរមាតា ដែលលោកកំពុងព្យាយាមចេញពីទ្វារគុកទាំងបួនជាន់ ដែលកូនត្រូវយក្សច្រានខាងលើ ជាអ្នកមកបើកទ្វារឃុំនេះ។

៤/.ចុងសង្ខាងក្បាំងក្លែងនេះមានរូបសត្វគុជសី កំពុងរើខ្លួនចេញពីមាត់យក្ស បានជិតពាក់កណ្ដាលខ្លួនហើយ ឯប្រមោយសត្វគុជសីកំពុងចាប់បួងគប់ភ្លើង (អាថិកំបាំងមាតា) តែពុំទាន់អាចលើករួច ព្រោះខ្លួនទើបតែចេញមកខាងក្រៅបានពាក់កណ្ដាល តើរូបនេះ តំណាងឲ្យអ្វី? គុជសីតំណាងឲ្យទីក្រុងពីររលាយចូលគ្នា (ពន្យល់រួចហើយ) គប់ភ្លើងតំណាងឲ្យកែវភ្នែកទាំង១២ ដែលត្រូវយកមកដាក់ឲ្យភ្លឺឡើងវិញ តែពុំទាន់អាចលើកបញ្ឈរគប់រួចឡើយ ដោយសារខ្លួនទើបតែរួចផុតពីអំណាចយក្សបានត្រឹមតែពាក់កណ្ដាល។

សរុបសេចក្ដីមកអច្ឆរមាតាក្ដី គុជសីក្ដី ជាពិសេសកូននាគដែលយក្សរុញច្រានទម្លាក់ពីខាងលើនោះក្ដី បានធ្លាក់ខ្លួនពិការ ត្រូវដេកវាលូន ដឹកនាំអច្ឆរមាតាចេញពីឃុំ ដែលនៅសល់ពាក់កណ្ដាលខ្លួនទៀត (មើលពាក្យល្បាទេ ឬវិស្ណុដេកក្នុងភាគ២) ទើបអាចលើកគប់ភ្លើងដែលជាកែវភ្នែកអច្ឆរមាតាមហានគរនេះ ឲ្យឈរឡើងបំភ្លឺរឿងពិតបាន ព្រោះក្រោយពេលដែលយក្សបានរុញច្រានទំលាក់ហើយនោះ គាត់ត្រូវធ្លាក់ខ្លួពិការ (នេះជាប្រស្នារូប)។

# ៦២/.រូបភាពទី៦២រូបនៅ(ប្រាសាទបន្ទាយស្រី)



តើសកម្មភាពក្នុងរូបនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

**ក**/.រូបខាងលើបល្ល័ង្ក មានបុរសម្នាក់ស្ត្រីម្នាក់ ហើយបុរស គឺតំណាងឲ្យកូននាគ ដែលនាំមាតាតាំងពីទ្វារគុកទីមួយ រហូតដល់ទ្វារគុកចុងក្រោយ។ សកម្មភាពរបស់កូនប្រុសនោះ ដៃម្ខាងគ្រាកចង្កេះម្ដាយអូសចេញ ដៃម្ខាងទៀតច្រានរុញខ្លោងទ្វារ ដើម្បីនាំព្រះម៉ែចេញ។ ឯព្រះម៉ែវិញ ដៃម្ខាងរុញចង្កេះកូនចេញ និងដៃម្ខាងទៀតតោងចាប់ខ្លោងទ្វារ ហាក់បីដូចពុំចង់ចេញពីមាត់ទ្វារឃុំឃាំងឡើយ តើមកពីមូលហេតុអ្វី?

នៅត្រចៀកស្ត្រីនេះ មានពាក់ក្រវិលដូចរូបស្ត្រីគ្រប់លក្ខណ គឺគាត់តំណាងឲ្យមាតាមហានគរ ដែលគេក្រុងបិទសន្ធប់គ្របលាក់ទុករឿងរបស់គាត់ រាប់ពាន់ឆ្នាំមកហើយ។ ហេតុដែលគាត់ពុំព្រមចង់ចេញ ព្រោះគាត់មានសេចក្ដីប្រកាន់មាំថា កាលគាត់ទៅទទួលទោស គែហែហមគាត់ទៅដោយមានគ្រែស្នែងដ៏វិចិត្រ (មើលរូបទី៥៩) ហើយមានកូននាគមួយនគរ ហែហមគាត់ ព្រោះគេបានដឹងពីឧបការគុណរបស់គាត់។ តែឥឡូវមានតែកូននាគម្នាក់មកយាងអញ្ជើញ មកទទួលគាត់ចេញ ដូចនេះ

គាត់គិតត្រិះរិះក្នុងចិត្តថា កូនគាត់មានរាប់លាននាក់កំពុងទទួលមរតករបស់គាត់ (ខ្មែរ) តែគ្មាននរណាមកហែហមអបអរសាទរ ទទួលដំណើរដែលគាត់ចេញពីទីទុក្ខសោះ ហេតុនេះទើបវាចាគំនិតក្នុងរូបនេះ បានបញ្ជាក់ពីសកម្មភាពរបស់គាត់ក្រាញពុំព្រមចេញ។

**ខ**/.នៅពីខាងក្រោមបល្ល័ង្កចំកណ្តាល មានរូបសេះចង់ក្រាបមួយ តើតំណាងឲ្យអ្វី? ហេតុអ្វីសេះនេះមានដុះថៃដូចជាជ្រូក? សេះតំណាងឲ្យឆ្នាំមមី តែសេះនេះបើមើលតាមភិនភាគ ដែលមានដុះថៃនោះ គាត់ចង់ប្រាប់យើងថា សេះនោះមានវ័យចាស់ទៅហើយ តាមពិតសេះគ្មានដុះថៃទេ គឺមានតែជ្រូក ហេតុអ្វីបានជាគាត់ឆ្លាក់សេះយ៉ាងដូច្នេះ? ព្រោះដូនតាយើងគាត់ចង់ប្រៀបធៀប បុគ្គលដែលកើតឆ្នាំនេះ គាត់ស៊ូទ្រាំនៅទ្របល្ល័ង្កដ៏ធ្ងន់ ដែលមានមនុស្សនៅឈរខាងលើ បុគ្គលនោះឈរយូរពេកទៅគាត់ពុំអាចព្រំបានក៏ទ្រោមចុះ ម្យ៉ាងទៀតគាត់ចង់ប្រាប់ពីអាយុរបស់បុគ្គលនោះ មានវ័យចម្រើនហើយ (ដុះថៃ) តែគាត់នៅតែជួយស៊ូទ្រាំហែហមលើកជ្រោងព្រះម៉ែចេញ។

**គ**/.រូបគោដែលជួយលើកដៃទ្របល្ល័ង្ក លើខ្នងសេះទាំងសង្ខាងកំពុងងើយក្បាល ហើយអណ្តាតក្បាច់ចេញពីមាត់នោះ តំណាងឲ្យខេត្តក្រុង ដែលមានរូបសំណាករបស់ខ្លួន កំពុងងើយស្រែកប្រាប់កូននាគដែលបានទទួលមរតកអច្ឆរមាតា (ខ្មែរ) ឲ្យបានដឹងដំណឹងពីសាវតាពិតរបស់ខ្លួន និងតំណាងឲ្យច្រកទ្វារ។

សង្ខេបសេចក្តីមកអត្ថន័យភាសាគំនិតក្នុងបេះដូងថ្មនេះ គឺបានបញ្ជាក់ប្រាប់យើង ពីការតស៊ូព្យាយាមអត់ធ្មត់ទ្រាំទ្រនៅការលំបាកគ្រប់បែបយ៉ាង ទាំងអ្នកនៅពីខាងលើ ទាំងអ្នកនៅពីខាងក្រោម ដើម្បីនាំរឿងអច្ឆរមាតាចេញ ទោះបីគេជួយគាំទ្រក្តី ឬក៏រារាំងក្តី ដាច់ខាតកូននាគនោះ ត្រូវតែជួយស្រង់ និងប្រស់អច្ឆរមាតា និងនាំរឿងពិតរបស់គាត់ ដែលបានរួចពីបាបកម្ម (ទុក្ខក្នុងសមុទ្រទឹកដោះ) មកប្រាប់ដល់កូននាគ ដែលកំពុងរស់នៅ និងបានទទួលមរតករបស់គាត់ឲ្យបានដឹង។

## ៦៣/.រូបភាពទី៦៣រូបនៅជញ្ជាំង(ប្រាសាទតាព្រហ្ម)

រូបភាពក្នុងជញ្ជាំងនេះ មើលទៅហាក់បីដូចជាមានសកម្មភាពរស់រវើក ទោះបីជាការដាប់ឆ្លាក់ពុំសូវមានសោភ័ណភាពក៏ដោយ ក៏រូបក្នុងផ្ទាំងនេះ មានបង្កប់អាថ៌កំបាំងមួយដ៏ជ្រាលជ្រៅ តើអាថ៌កំបាំងក្នុងសិលាចារឹករូបនេះ គាត់ចង់ប្រាប់យើងពីរឿងអ្វី?



***ក/***.រូបនៅចំកណ្ដាល គឺតំណាងឲ្យអប្សរមាតា (ព្រះមាតាមហានគរ) ដែលលោកកំពុងចាកចេញពីភក់ខាងក្រោម (ថ្មភក់) ព្រោះដោយរូបលោកឈរនៅលើផ្កាឈូក ដែលកំពុងដុះចេញពីភក់ ផ្កាឈូកនោះបានរុញច្រានលោក ឲ្យបានឡើងទៅបល្ល័ង្កធំខាងលើវិញ (មាតុភូមិ)។ បល្ល័ង្កធំខាងលើនេះពីមុននៅទទេ (មើលការពន្យល់ប្រាសាទបាយ៉ង់កោរភាគ១ និងភាគ២) ដោយម្ចាស់បល្ល័ង្ក (មាតានាគ) បានចុះទៅកប់ក្នុងភក់ (អបាយភូមិ) ហើយភក់ដែលកប់ម្ចាស់បល្ល័ង្កនោះ បានរឹងក្លាយទៅជាថ្មគឺ***ថ្មភក់*** ដែលកូនគាត់បានយកមកកសាងប្រាសាទថ្មរាប់ពាន់ ហើយឆ្លាក់រឿងក្នុងបេះដូងរបស់អច្ឆរមាតា ដូច្នេះទើបគាត់យកឈ្មោះថ្មនេះ មកធ្វើជានិមិត្តរូប តំណាងឲ្យបាបកម្មរបស់គាត់ (មើលរឿងឥសីមាត់ទិព្វ)។ ផ្កាឈូកតំណាងឲ្យការបំពេញបុណ្យ សន្សំកុសល អ្នកដែលគោរព និងជឿតាមឱវាទព្រះសម្មាសម្ពុទ្ធ (អ្នកកាន់ព្រះពុទ្ធសាសនា) ឯដៃដែលគាត់លើកបញ្ឈរទល់គ្នា តំណាងឲ្យការអង្វរកសូមអភ័យ ចំពោះអ្នកដែលកំពុងចងពៀរនឹងគាត់ ដែលអ្នកចងពៀរនឹងគាត់នោះ គាត់ធ្លាប់បានរំលោភបំពានគេ កាលពីអតីតកន្លងមក។

***ខ/***.នៅពីខាងឆ្វេងដៃរូបអច្ឆរមាតា មានមនុស្សពីរជាន់ (ជាន់ក្រោម និងជាន់លើ) ដែលនៅក្នុងដៃអ្នកទាំងនោះ មានកាន់អាវុធ សកម្មភាពរបស់រូប ជើងមួយបញ្ឈរ ជើងមួយទៀតបត់ទៅក្រោយដូចកាយវិការកំពុងហោះ ដៃរុកដំបង ឬលំពែង ចាក់សំដៅទៅរកអច្ឆរមាតា មានន័យថា គេមិនចង់ឲ្យគាត់រួចពីទុក្ខទោស ទៅអង្គុយលើបល្ល័ង្កធំខាងលើវិញឡើយ។ ឯអ្នកជិះដំរីខាងក្រោមបន្ទាប់ គឺ

តំណាងឲ្យអ្នកដែលបំបែកយកនគរដំរី (យសោធបុរៈ) ន័យក្នុងសកម្មភាពរបស់បក្សពួកគេ គឺដូចគ្នា (មើលរូបទី៣៣) ព្រោះគេមិនចង់ឲ្យម្ចាស់ទ្រព្យ (ម្ចាស់ដើម) រួចពីទុក្ខទោស ឬពីឃុំឡើយ។

**គ**/.នៅពីខាងស្តាំដៃវិញ ក៏មានមនុស្សមករារាំងគាត់ដែរ មនុស្សម្នាក់នៅពីខាងលើ ជើងម្ខាងរបស់គេជាន់លើក្បាលដំរី ជើងម្ខាងទៀតកំពុងលូកទៅជាន់ផ្កាឈូក ដែលអច្ឆរមាតាកំពុងឈរ កុំឲ្យដុះឡើងទៅលើរួច ចំណែកឯអ្នកនៅខាងក្រោមវិញ ជួយដោលទ្រជើងជាកម្លាំង ដើម្បីឲ្យអ្នកដែលមានពៀរខាងលើនោះ អាចក្រោកទៅឈរលើផ្កាឈូកនោះបាន។

**ឃ**/.នៅពីលើខាងស្តាំ មានរូបមនុស្សជិះសេះ គឺតំណាងឲ្យកូនដែលត្រូវមកជួយអច្ឆរមាតា ដែលរូបនេះមានបកស្រាយក្នុងរឿងព្រេងខ្មែរ **ព្រហ្មកិល** (មើលប្រាសាទតាព្រហ្មរំកិលភាគ២) ព្រហ្មកិលនេះហើយ បានដេញស្តេចដំបងគ្រញូង ដែលជាមនុស្សព្រៃគ្មាននគរពីអតីតកាលនោះ។ ស្តេចដំបងគ្រញូងនេះ រើសបានដំបងមួយក្នុងស្រុកមោង (ពីមុនខេត្តមោងឬស្សី) គឺមោងឬស្សី (មោងសក្តិយក្ស) ដែលជាដំបងមានឫទ្ធិអស្ចារ្យ ជាអំណោយរបស់យក្ស (ត្រកូលបក្សពួកយក្ស) បានដេញវាយកូននាគ (ស្តេច) ឲ្យរត់ខ្ចាត់ខ្ចាយសម័យក្រោយអង្គរ រួចដណ្តើមហែកយករាជបល្ល័ង្ក (ដំរីក្បាលបី) បង្កើតបានជានគរវាយកូនខ្មែរ ឲ្យស៊ីថ្លៃដំបងតៗគ្នា (មើលបទសារិកាភាគ១)។ ក្រោយមកមានស្តេចមួយអង្គ ជាពូជពង្សកូននាគជំនាន់មុន ប៉ុន្តែពិការដើរពុំរួច បានត្រឹមវារ និងលូន (មើលពាក្យល្បាទេរកាកោង ភាគ២) តែដោយអំណាចបុណ្យរបស់គាត់ ក្នុងរឿងព្រេងខ្មែរបានប្រាប់ថា ព្រះឥន្ទ្រាធិរាជ្យបានប្រែភេទជាតាចាស់ម្នាក់ស្លៀកសពាក់ស យកសេះមួយ និងសម្លៀកបំពាក់សម្រាប់គ្រងរាជមួយបង្វេច មកចងដៃផ្ញើរនឹងបុរសពិការនោះ។ គ្រាន់តែតាចាស់ (ព្រះឥន្ទ្រ) ចេញផុត សេះក៏កញ្ច្រោលទាញដៃបុរសពិការនោះឲ្យលាត្រង់ ព្រហ្មកិលឃើញយ៉ាងដូច្នេះ ក៏យកខ្សែសេះទៅចងដៃ និងជើងទាំង ២ឲ្យសេះទាញលាត្រង់បាត់ភាពពិការ ទើបគាត់យកសម្លៀកបំពាក់ដែលមានក្នុងបង្វេចនោះ មកស្លៀកពាក់ រួចឡើងជិះសេះសនោះទៅ។ ពេលដែលសេះបោលរត់ សេះនោះបានហោះឡើងក្រវែលជុំវិញក្រុងអង្គរធំ (បាយ័ន) ធ្វើឲ្យស្តេចដំបងគ្រញូងជាស្តេចជ្រែករាជខឹងក្រោធ រួចក៏ចាប់ទាញដំបងឫទ្ធិចោលសំដៅទៅរកអ្នកជិះសេះសនោះ តែពុំត្រូវគាត់ឡើយ ហើយដំបងនេះបានធ្លុះបាត់ក្នុងដែនដីខេត្តបាត់ដំបងសព្វថ្ងៃ។ ទើបខេត្តនេះសន្មត់ឈ្មោះទៅតាម រឿងព្រេងព្រហ្មកិល (ពាក្យព្រេងក្លាយមកពីពាក្យព្រេងព្រិទ្ធអ្នកតាក់តែងទុក) ហើយដំបងគ្រញូងវិញ គឺតំណាងឲ្យកុក (សៀម) ព្រោះខ្មែរយើងមានឈ្មោះសត្វកុកមួយប្រភេទដែលមានមាឌធំចង្រ្កៃងឈ្មោះថា កុកដំបងគ្រញូង (មើលក្នុងចាក់ទឹក

ដូងទីពីរត្រង់កន្ទុយត្រីប្រាក្បាលនាងកុក) ដូច្នេះហើយទើបរឿងពិតរបស់អច្ឆរមាតាបានបាត់ដាន ជាបន្តបន្ទាប់មកសម័យខាងក្រោយ ព្រោះដំបងគ្រញូងបានវាយឲ្យយើងស៊ីផ្លែដំបងបន្តគ្នា (មើលបទសារិការកែវភាគ១)។

បង្រួមសេចក្តីមកបើយើងមើលទៅតាមអត្ថន័យក្នុងរូប រួចយកមកប្រៀបធៀបនឹងរឿងផ្សេងៗ (រឿងព្រេង ទំនាយ ប្រស្នា ទំនៀមទម្លាប់ឈ្មោះរបស់ភូមិស្រុក ប្រាសាទ....) យើងអាចយល់បានថាក្នុងរឿងទាំងនោះ បានទាក់ទងនឹងរឿងដែលនៅក្នុងថ្ម ព្រោះរូបរឿងនៅក្នុងថ្មវាពុំចេះប្រែក្លាយ ដូចជារឿងព្រេង ទំនាយ ឈ្មោះ...ឡើយ ដោយរឿងនៅក្នុងថ្មទាំងនោះ បានបង្ហាញពីរឿងក្នុងចិត្តរបស់បុគ្គលណាម្នាក់ ដែលបានយករឿងពិតក្នុងចិត្តទៅទុកក្នុងថ្មទាំងនេះ ឲ្យជួយរក្សានៅរឿងអាថ៌កំបាំងរបស់ខ្លួន។

## ៦៤/.រូបភាពទី៦៤រូបអង្គរវត្ត(ប្លង់មើលពីខាងលើ)



រូបប្លង់អង្គរមើលពីលើនេះ ដែលខ្ញុំយកមកដាក់បង្ហាញ ព្រោះខ្ញុំចង់ប្រាប់កូនតាគឲ្យយល់ថាភាគច្រើននៃប្លង់ប្រាសាទរបស់ខ្មែរ គឺមានរាងតំណាងឲ្យយោនីអច្ឆរមាតាមហានគរ (មាតុភូមិ) ហើយប្លង់រាងយោនីនេះទៀតសោត គឺមានតែប្លង់អង្គរតូច និងប្រាសាទព្រះវិហារទេ ដែលទរចង្អូរយោនី គឺផ្លូវចូលវែងជាងគេ ហេតុអ្វីក៏ប្រាសាទខ្មែរ ព្រឹទ្ធដូនតារៀបចំប្លង់ជារាងយោនីដូច្នេះ? ហេតុ

ដូចម្ដេចបានជាគ្រប់ប្រាង្គប្រាសាទ សុទ្ធតែមានតម្កល់យោនី ដែលមានលិង្គនៅចុកបិទពីខាងលើយ៉ាងនេះ?

ខ្ញុំពុំថាតាមឯកសារភាសារូបរបស់បរទេស ដែលបានធ្លាប់បកស្រាយហើយនោះទេ ខ្ញុំចង់ឲ្យកូននាគទាំងអស់មើលថ្មទាំងនោះ មកជាមរតករឿងរបស់អច្ឆរព្រះម៉ែមហានគរវិញ ព្រោះការពន្យល់ក្នុងភាគ១ ភាគ២ និងភាគ៣នេះ គឺខ្ញុំបានបើកបង្ហាញពីបេះដូងថ្មដែលព្រះមេ និងព្រះម៉ែ (ក្មេរ និងក្មែរ) ត្រូវគេឃុំក្រោមយោនីរបស់ខ្លួនឯង ព្រោះយោនីតំណាងភេទស្រ្តី (មាតុភូមិ)។ ភូមិម៉ែនេះហើយដែលបានបង្កើតនូវកុលបុត្រខ្មែរប្រុសស្រី រាប់រយពាន់ជំនាន់មក ហើយក្នុងបណ្ដាកេរមរតកព្រះម៉ែដែលទុកឲ្យកូនប្រុសស្រីនោះ កេរដែលនៅរឹងមាំជាងគេ គឺប្រាង្គប្រាសាទថ្មរាប់ពាន់ ដែលប្រាសាទទាំងនេះ បានផ្ទុករឿងក្នុងបេះដូងម៉ែគ្រប់ផ្ទៃរ ក្បាំង ជញ្ជាំង។ មរតកផ្សេងៗត្រូវវិនាស ត្រូវក្លាយ ត្រូវល្អៀងតែមរតកថ្មនៅរក្សាភាពបរិសុទ្ធដដែល រឿងក្នុងចិត្តរបស់គាត់បានចារឹកទុកពីមុនយ៉ាងណា សព្វថ្ងៃក៏នៅតែយ៉ាងនោះ គ្រាន់តែត្រូវបំផ្លាញដោយជនទុច្ចរិតឈ្លានពាន និងដោយសារធម្មជាតិខ្លះប៉ុណ្ណោះ។ ប្លង់ប្រាសាទមានរាងជាយោនីទាំងអស់ គឺមានតែប្លង់ប្រាសាទនាគព័ន្ធមួយទេ ដែលមានផ្លូវបែកជា៤ ជាសញ្ញាលេខបូក ឬលេខគុណ ហើយក្នុងចុងនៃសញ្ញាលេខបូក ឬលេខគុណនេះ គឺមានទឹកហូរចេញតាមមាត់គ្រប់ទិស។ ក្នុងបណ្ដាបង្ហូរទឹកទិសទាំង៤ គឺមានតែទិសខាងកើតទេ ដែលមានរូបសេះ **ពលាហក** និងមានមុខអច្ឆរមាតាមហានគរកប់ត្រឹមក រួចទូលទ្រយោនីខ្លួនឯង (មើលការពន្យល់ក្នុងរូបទី៦)។ ដូនតាយើងកសាងប្រាសាទភាគច្រើនក្នុងប្លង់ជារាងយោនី ខ្លះមានចង្ហូរផ្លូវចូលវែង ខ្លះមានចង្ហូរខ្លី ខ្លះមានមួយទិស ខ្លះទៀតមានចង្ហូរបួនទិស ដោយគាត់ចង់ប្រាប់យើងថា អាទិទេពទាំងអស់ (ឥសូរ លោកេស្វរៈ វិស្ណុ ព្រះព្រហ្ម.....)ដែលប្រតិស្ថានទុកគ្រប់ប្រាសាទនោះ គឺសុទ្ធតែប្រសូតចេញពីផ្ទៃរបស់គាត់ទាំងអស់ (មាតុភូមិ) ហើយបានទទួលកេរមរតកពីគាត់គ្រប់ៗគ្នា។ គ្រប់សំណាកយោនីដែលតម្កល់ទុកក្នុងប្រាសាទ សុទ្ធតែមានលិង្គចុកបិទសង្កត់ពីខាងលើ ឯប្រាសាទបាណន់មានរូបផ្នាំឈរសង្កត់ពីលើ ដោយដូនតាគាត់ឆ្លាក់ទម្រជារាងស្នឹងស៊កបញ្ចូលទៅក្នុងរន្ធយោនី ហើយនៅពីខាងលើក្បាលស្នឹង គាត់ឆ្លាក់រូបផ្នាំ តំណាងឲ្យបក្សពួកយក្សឈរសង្កត់ពីលើ រូបឈរពីលើនេះ សព្វថ្ងៃគេដាប់យកទៅបាត់ហើយ (អត្ថន័យរូបនេះ ចូរមើលការពន្យល់ភាគមុន និងរូបទី១)។ ចំណែកប្លង់អង្គរវត្តនេះ មានរបាំងព័ទ្ធបីជាន់ (មើលទោសទាំងបីជាន់រូបទី១) ហើយបង្ហូរទរយោនី គឺផ្លូវចូលទៅសព្វថ្ងៃដ៏វែងនោះ គាត់ចង់ប្រាប់ពីការនាំអច្ឆរព្រះមាតាចេញពីសមុទ្រទឹកដោះ ត្រូវឆ្លងកាត់ទ្វារទាំងបីជាន់ក្នុង

ចង្អូរផ្លូវដ៏វែងឆ្ងាយ ហើយចង្អូរផ្លូវចូល ឬចេញនោះទៀតសោត មានអង្គព្រះវិស្ណុតូចៗនៅឈរទ្រស្ពាន នេះពីខាងក្រោម (មើលការពន្យល់រូបទី៤៣) ទម្រាំគាត់ផ្ដុំរូបឲ្យធំបាន ទើបអាចមានកម្លាំងរែកព្រះមាតាបិតា ទៅដាក់លើកំពូលភ្នំប្រាសាទព្រះវិហារវិញ។ ផ្លូវចូលប្រាសាទព្រះវិហារក៏ចង្អូរយោនីវែង ហើយចោតខ្ពស់ ព្រោះគាត់ត្រូវសន្សំបារមីរែកព្រះមាតាបិតាឡើងទៅដាក់លើកំពូលភ្នំប្រាសាទព្រះវិហារ គឺមានន័យថា ពីពាក់កណ្ដាលផ្ចិតទៅចុងជើង ត្រូវស្មើនឹងពាក់កណ្ដាលបីដង់ផ្លូវចូលអង្គរតូចនេះ (មើលការពន្យល់ឈ្មោះប្រាសាទព្រះវិហារ និងរកាកោងភាគ២)។

បង្រួមសេចក្ដីមកអច្ឆរមាតាមហានគរលោកចង់ប្រាប់កូននាគប្រុសស្រី សម័យខាងក្រោយកុំឲ្យយល់ច្រឡំថា **អាទិទេពខ្មែរទាំងនោះ ប្រសូតនៅបរទេស គឺអាទិទេពខ្មែរ កើតឡើងក្នុងភូមិព្រះម៉ែរក្សានិងជួយស្រង់ប្រស់ព្រះម៉ែ** (អាទិទេពអ្នកបង្កើតខ្មែរ និងខ្មែរក្នុងភាគ១) ដែលដេកស្លាប់ចេញពីសន្ដានចិត្តកូននាគប្រុសស្រីនោះ ឲ្យមានជីវិតរស់ឡើងវិញ ក្នុងមាតុភូមិដ៏សែនកំសត់នេះ។ រឿងរបស់អច្ឆរព្រះមាតា បានចារឹកទុកក្នុងក្បាំងតាំងពីខាងក្រោម រហូតទៅដល់កំពូលខាងលើ ព្រោះទៅដល់ទីណា ក៏ព្រះម៉ែនាគនៅទៅតាមបាំងរក្សាថែរហូតដល់ទីនោះ ដោយមរតកទាំងនេះ គឺជារឿងក្នុងបេះដូងរបស់គាត់(ក្បាំងនាគរួមខ្លួនតែមួយ)។

## ៦៥/.រូបភាពទី៦៥រូបយោនីនៅខាងក្រោមទឹក(ក្បាលស្ពាន)



តើរូបយោនីដែលនៅក្នុងទឹកនេះ ដូននាគគាត់និយាយប្រាប់យើងពីរឿងអ្វី? យើងដឹងថាតាំងពីប្រភពទឹកដំបូង ចេញពីកំពូលភ្នំគូលែន ដូនតាយើងគាត់បានឆ្លាក់រូបបន្ទគ្នាលាក់ទុកក្នុងទឹក នៅលិង្គ

មួយពាន់ មានរូបវិស្ណុធុំតូចៗ និងវិស្ណុធុំធំនៅក្រោមខ្សែទឹកលិង្គមួយពាន់....។ល។ ហេតុអ្វីបានគាត់ធ្លាក់រូបទាំងនេះ នៅក្នុងទឹក? បើរូបទាំងនោះ ជារូបមនុស្សមានជីវិតវិញ មិនលង់ស្លាប់ទេឬ?

រូបចម្លាក់យោនីដ៏ធំនេះ នៅខាងក្នុងមានដុំមូលរាងជាកងចំនួនប្រាំគ្រាប់ នៅខាងចុងទ្វារយោនីមានដុំកងមួយរុញបិទមាត់ទរឲ្យរួមតូច និងមានកងជាច្រើនគ្រាប់ទៀត នៅព័ទ្ធជុំវិញពីខាងក្រៅ តើប្រស្នាក្នុងគំនិតថ្មនេះ គាត់ចង់និយាយប្រាប់ពីរឿងអ្វី?

***ក***/.យោនីដ៏ធំនេះ តំណាងឲ្យផ្ទៃរបស់អច្ឆរមាតានាគ (មាតុភូមិ) ដែលផ្ទៃនេះ បានងបង្កើតពូជពង្សនាគរាប់ពាន់ជំនាន់មកហើយ តែជាអកុសលយោនីដែលជានិមិត្តរូបតំណាងឲ្យអប្សរមាតានេះត្រូវឃុំជាប់នៅពីខាងក្រោមទឹក (មើលការពន្យល់រូបទី៦០) ដែលទឹកនេះ តំណាងឲ្យមនោគមវិជ្ជាបរទេស (បិទបាំងលាក់សន្ធប់)។

***ខ/.ន័យទី១*** កងទាំងប្រាំដែលនៅក្នុងយោនី តំណាងឲ្យការបង្អាក់កំណើតពូជពង្សនាគ ព្រោះសព្វថ្ងៃម្ដាយដែលចង់ពន្យាកំណើត គាត់ដាក់កងតែមួយទេ គឺស្ត្រីជាមាតានោះ ពុំអាចមានបុត្រឡើយ ចុះហេតុអ្វីក្នុងរូបយោនីនោះ មានកងដល់ទៅប្រាំគ្រាប់យ៉ាងនេះ? ហើយនៅខាងចុងទរ មានកងមួយមកបិទបង្រួមទរយោនីឲ្យរួមតូច ដើម្បីកុំឲ្យកងប្រាំខាងក្នុងចេញមកក្រៅរួច។ អច្ឆរមាតាគាត់ចង់ប្រាប់កូនខ្មែរថា បើកូនដោះប្រស្នាកងទាំងប្រាំ រួមទាំងកងទីប្រាំមួយ ដែលរុញបិទទ្វារខាងក្រៅឲ្យរួមតូចនោះពុំរួចទេ អនាគតភូមិម៉ែ លែងអាចប្រសូតកូននាគប្រុសស្រីបានទៀតហើយ ព្រោះភាសាថ្មក្នុងទឹក បាននិយាយប្រាប់យើងយ៉ាងនេះ។

***ន័យទី២*** នៅក្នុងរឿងធនជ័យ អ្នកប្រាជ្ញចិនបានយកប្រស្នាមកដាក់ភ្នាល់យកនគរ ដែលក្នុងប្រស្នានោះ ធនជ័យបានលើកដៃជាសញ្ញា ដើម្បីឆ្លើយបញ្ហាដែលអ្នកប្រាជ្ញចិនយកមកសាកសួរនោះ ទីបំផុតប្រស្នាជាសញ្ញានេះ គាត់អាចបំបែកបាន (ចិនលើកម្រាមប្រាំ ធនជ័យលើកម្រាមមួយ)។

***ន័យទី៣*** នៅក្នុងភាសាបរមត្ថធម៌ អច្ឆរមាតាគាត់ចង់ប្រាប់យើងថា កងទាំងប្រាំនោះ តំណាងឲ្យឧបាទានក្ខន្ធ (សេចក្ដីប្រកាន់មាំ) ការប្រកាន់មាំនេះហើយ ដែលបានទម្លាក់គាត់ទៅក្នុងអបាយភូមិត្រូវគេបិទសន្ធប់លាក់រឿងពិតរបស់គាត់ទុកមកដល់សព្វថ្ងៃ។ ដូចមានប្រស្នាក្បាលនាគទាំង១៤នៅលានព្រះគម្លង និងនៅក្បាលស្ពានកំពុងក្ដី ក្នុងលានព្រះគម្លង់ក្បាល៥នៅលើក្បាល៧ និងក្បាល៩ (មើលរូបទី១៣ ១៤ ១៥) នៅក្បាលស្ពានកំពុងក្ដីនាគក្បាល៩នៅពីលើក្បាល៥ ដែលមានខ្លួនរួមតែ

មួយចម្លើយនៃប្រស្នាក្បាលនាគនេះ មាននៅក្នុងគម្ពីរព្រះអភិធម្មឯណោះ ព្រោះហេតុអ្វី? ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ព្រះអង្គបានយាងទៅប្រោសពុទ្ធមាតានៅឋានតាវត្តិង្ស ព្រះអង្គបានយកព្រះអភិធម្មទាំង៧គម្ពីរទៅសម្ដែងប្រោស ព្រោះមានតែគុណរបស់បរមត្ថអភិធម្មទេ ដែលអាចយកទៅថ្លឹងឬតបគុណរបស់ព្រះមាតាបាន។ ក្នុងការសម្ដែងប្រោសនោះទៀតសោត លើកទីមួយព្រះពុទ្ធមាតាពុំអាចសំរេចនូវមគ្គផលអ្វីឡើយ ដោយលោកវង់តែជាប់ជំពាក់ក្នុងសេចក្ដីប្រកាន់មាំ ថាបានធ្វើជាព្រះមាតាព្រះសម្មាសម្ពុទ្ធ នឹងជាប់ជំពាក់ក្នុងមហាបុរិសលក្ខណ៣២ប្រការ របស់ព្រះអង្គ ទើបព្រះអង្គប្រោសសម្ដែងជាលើកទីពីរ ពេលនោះព្រះមាតាបានសម្រេចមគ្គផល ជាលោកានាមិស្ស សោតាវិលងវិលត្រឡប់មកកាន់មនុស្សលោកទៀតហើយ លោកទៀងតែនឹងបរិនិព្វាននៅស្ថានព្រហ្មលោក។ យ៉ាងណាមិញប្រស្នាក្នុងថ្មនេះ ក៏មានន័យយ៉ាងនោះដែរ ព្រោះយោនីតំណាងព្រះមាតាដូចគ្នាគ្រាន់តែអច្ឆរព្រះមាតាមហានគរលោកនៅជាបុថុជ្ជន តែអត្ថន័យដោះស្រាយនៅប្រស្នានេះគឺដូចគ្នាព្រោះអច្ឆរមាតាមហានគរ លោកបាននាំយកព្រះពុទ្ធសាសនា មកទុកជាមរតកឲ្យកូននាគ (ខ្មែរ) ព្រោះលោកសង្ឃឹមថា នឹងមានកូននាគណាមួយជួយបំបែកប្រស្នាកងនេះជួយគាត់ជាពុំខាន។

សរុបសេចក្ដីមកការពន្យល់ដោយត្រួសៗពីអត្ថន័យរបស់រូបនេះ គឺមានន័យបង្កប់បីយ៉ាងដូចបានបកស្រាយហើយ សូមកូននាគកុំយល់ច្រឡំថា ដូនតាយើងទៅរៀនឆ្លាក់ ឬទៅឆ្លាក់លេងឲ្យសោះ បើយើងយល់ខុសនោះ អច្ឆរមាតាលោកពិតជាអស់សង្ឃឹមចំពោះយើងជាកូននាគ ដែលកំពុងទទួលមរតករបស់គាត់សព្វថ្ងៃនេះជាពុំខាន។

## ៦៦/.រូបភាពទី៦៦រូបព្រះវិស្ណុធំ(នៅក្បាលស្ពាន)

តើរូបព្រះវិស្ណុធំនៅក្បាលស្ពាននេះ មានបង្កប់អត្ថន័យយ៉ាងដូចម្ដេច?

**ក**/.យើងដឹងហើយថា រូបព្រះវិស្ណុនៅក្នុងបាតស្ទឹងភ្នំគូលែន មានរូបព្រះវិស្ណុនេះតាំងពីលិង្គមួយពាន់មកម្លេះ ដំបូងរូបគាត់តូចៗក្រោយមកទើបបានរីកធំ នៅទន្ទឹមប្រាសាទរោងចិន វិស្ណុអង្គតូចៗន័យរបស់រូប ដូចព្រះវិស្ណុតូចៗនៅទ្រក្រោមស្ពានផ្លូវចូលអង្គរវត្តដែរ។ ហើយរូបព្រះវិស្ណុតូចៗនោះ គឺជាការសន្សំនៅគុណធម៌គឺបារមីរបស់គាត់ ទោះបីជារូបទាំងនោះនៅក្នុងទឹកក៏ដោយ ក៏គាត់សន្សំគុណធម៌រហូតក្លាយជាព្រះវិស្ណុដែលមានរូបរាងធំ ដែលអាចនាំរូបព្រះមាតានៅពីខាងចុងជើង (មើលការ



ពន្យល់ក្នុងរូបមុន) តែគាត់នៅលិចក្រោមអំណាចទឹកដដែល (មនោគមវិជ្ជា) ហើយរូបរឿងរបស់គាត់ក៏ត្រូវដាច់ត្រឹមជ្រោះទឹកធ្លាក់ទៅក្រោម (បាត់ដានស្នាម)។

*ខ*/.ផ្លូវទឹកដីសែនវែងឆ្ងាយបានហូរធ្លាក់មកដល់ក្បាលស្ពាន ទើបកើតមានឡើងរូបព្រះវិស្ណុនោះវិញ ព្រោះតែតំណរូបគាត់បានលាក់កំបាំងក្នុងទឹក និងក្នុងព្រៃ ធ្វើឲ្យរឿងនាំព្រះមាតាចេញពីទីទុក្ខ ត្រូវបាត់ដានដោយខ្លួនគាត់បានធ្លាក់ខ្លួនពិការដោយយក្សច្រានទម្លាក់ (មើលរូបទី៦១)។ តែទោះបីជាគាត់ផ្ងុំ ឬដេកក៏ដោយ គាត់នៅតែព្យាយាមតស៊ូ នាំអច្ឆរមាតាចេញពីទីទុក្ខ រហូតមកដល់ក្បាលស្ពាន រូបគាត់ចាប់ផ្ដើមអណ្ដែតផុតពីទឹក មានន័យថា គាត់ឈប់នៅក្រោមការបំភាន់បន្លំ របស់បរទេសទៀតហើយ ដោយគាត់បានដឹងពីសាវតាពិតរបស់អច្ឆរមាតា។ តើពាក្យក្បាលស្ពានមានន័យដូចម្ដេច? ក្បាលគឺអវយវៈប៉ែកខាងលើរបស់មនុស្ស សត្វ ចំណែកពាក្យថា ក្បាលស្ពានវិញមានន័យថា ក្បាលខាងនាយ និងក្បាលខាងអាយ ព្រោះស្ពានពុំមានជើង ឬកន្ទុយឡើយ គឺមានក្បាលទាំងសង្ខាង។ អាថ៌កំបាំងប្រស្នារបស់ពាក្យនេះ គាត់ចង់ប្រាប់យើងជាកូននាគថា រឿងរបស់គាត់បានមកជិតដល់ទីបញ្ចប់ហើយ **ទីមួយ**រូបព្រះវិស្ណុដែលបាននាំព្រះម៉ែចេញពីសមុទ្រទឹកដោះនោះ បានងើបផុតពីអំណាចទឹកហើយ **ទីពីរ**ដល់ពេលដែលកូនរបស់គាត់ព្រះវិស្ណុ ចាប់ផ្ដើមភ្ជាប់ស្ពានពីក្បាលម្ខាងឲ្យជាប់ទៅក្បាលម្ខាងទៀត មានន័យថា រឿងពិតរបស់គាត់ក្នុងអតីតកាលភ្ជាប់ និងបច្ចុប្បន្នកាល (មើលការ

ពន្យល់ប្រស្នាព្យញ្ជនៈទាំង៣៣តួក្នុងរូបទី៣៧) ឲ្យជាប់គ្នាទើបសេចក្តីសុខ និងត្រេកអរអាចកើតមានឡើងបាន (មើលរូបនាគសង្វាងក្បាលស្ពានកំពុងភ្លឺ)។

**គ**/.ការភ្ជាប់ស្ពាននាគបច្ចុប្បន្ន ឲ្យជាប់នឹងស្ពាននាគពីអតីត (រឿងពីអតីតផ្សព្វផ្សាយក្នុងបច្ចុប្បន្ន) គឺត្រូវប្រើពេលវេលាដ៏យូរ ព្រោះគេធ្លាក់រូបគាត់ដេកមិនទាន់អាចក្រោកឡើងបាន ម្យ៉ាងទៀតគាត់ត្រូវអូសរឿងអច្ឆរមាតាដ៏ធំមួយពីអតីត និងបច្ចុប្បន្នឲ្យជាប់គ្នានោះ កម្លាំងមនុស្សម្នាក់ដែលដេក (ជានិមិត្តរូប) ដូចមនុស្សពិការឬឈឺ គឺត្រូវប្រើសេចក្តីអត់ធ្មត់ព្យាយាមប្រឹងប្រែងអស់កាលដ៏យូរ ទើបអាចដើរទៅដល់ទីបញ្ចប់បាន។ ដូចជាព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ហេតុតែព្រះអង្គចង់សាងស្ពានមួយ ដើម្បីចម្លងសត្វលោកឲ្យចាកចេញពីភពបី (កាមភព រូបភព អរូបភព) ព្រះអង្គត្រូវហែលឆ្លងសមុទ្រវដ្តសង្សារ អស់រយពេលបួនអសង្ខេយ្យ និងមួយសែនមហាកប្ប ដើម្បីសន្សំគុណធម៌គឺបារមីទាំង៣០ឲ្យពេញបរិបូណ៌ទើបអាចលើកស្ពាន (ភ្ជាប់ត្រើយនាយ និងត្រើយអាយ) គឺការត្រាស់ដឹងនូវសច្ចធម៌ដោយខ្លួនឯងបាន ដើម្បីចម្លងសត្វលោកទៅដាក់ត្រើយនាយ គឺព្រះនិព្វាន ដែលជាទីស្ថានរួចផុតចាកទុក្ខទាំងពួង។

**ឃ**/.រូបភាពព្រះវិស្ណុផ្ទុំនេះ គឺគាត់ផ្ទុំលើនាគហើយនៅចុងជើងគាត់មានរូបអច្ឆរមាតាមហានគរ នៅពីខាងក្រោយចំកណ្តាលផ្ចិតមានដុះទងឈូកមួយ ហើយនៅលើផ្កាឈូកនោះ មានរូបព្រះព្រហ្មអង្គុយពីលើ។ ព្រះវិស្ណុ តំណាងឲ្យកូននាគ ដែលដេកនាំព្រះម៉ែចេញពីសមុទ្រទឹកដោះ ស្ត្រីដែលនៅខាងចុងជើង តំណាងឲ្យអច្ឆរមាតានាគ ដែលជាម្ចាស់មាតុភូមិនេះពីអតីតកាល ព្រះព្រហ្មតំណាងឲ្យរឿងព្រះវិស្ណុពេលនាំរឿងព្រះមាតាមកដល់ពាក់កកណ្តាល (ចំណុចផ្ចិត) គាត់ត្រូវប្រែរូបទៅជាព្រះព្រហ្មគង់លើផ្កាឈូក ដែលព្រហ្មនេះ តំណាងឲ្យពោធិសត្វលោកេស្វរៈនូវបំពេញបារមី សត្វនាគតំណាងឆ្នាំដែលគាត់ចេញពីគុក តំណាងឲ្យពូជពង្សកូន ជាពូជនាគ (ខ្មែរ) ផ្កាឈូកតំណាងឲ្យការសន្សំបញ្ញារបស់អ្នកកាន់ព្រះពុទ្ធសាសនា និងតំណាងឲ្យការរួចផុតពីការឃុំគ្រង របស់បរទេសពីអតីតកាល។

បង្រួមសេចក្តីមកការបកស្រាយដោយសង្ខេបនេះ គឺបញ្ជាក់ពីន័យរបស់ថ្ម ទីតាំងដែលយើងត្រូវតែរែកញែក រករឿងពិតក្នុងបេះដូងថ្ម ថាតើហេតុអ្វីបានជាពួកគាត់ត្រូវធ្លាក់រូបនៅក្នុងទឹក នៅក្បាលស្ពាន......?

# ៦៧/.រូបភាពទី៦៧រូបព្រះវិស្ណុផ្ទំនៅលើក្បាំងខ្លែង(ប្រាសាទព្រះខាន់ឬជ័យស្រី)



តើភាសារូបក្នុងក្បាំងខ្លែងនេះ អច្ឆរមាតាលោកចង់ប្រាប់យើងពីអ្វី?

១/.ព្រះវិស្ណុតំណាងឲ្យកូននាគ កំពុងនាំមាតានាគចេញពីទីទុក្ខ (មើលការពន្យល់រូបមុន) ដៃបែកជាបួន ដៃពីរខាងក្រោម ដៃមួយទប់ក្បាល តំណាងឲ្យការត្រិះរិះពិចារណា និងទប់លំនឹង ដៃមួយទៀតច្រត់កែង នឹងមានរាជសារក្នុងដៃ តំណាងឲ្យការបំបែកប្រស្នាអាថ៌កំបាំងក្នុងសារបណ្ដាំ (ក្នុងថ្ម) ដៃពីរខាងលើ ដៃមួយកាន់ដុំមូល តំណាងឲ្យរឿងដែលគាត់ប្រមូលបាន ដៃមួយទៀតកាន់ផ្កាឈូកហុចទៅឲ្យព្រះមាតានៅចុងជើង តំណាងឲ្យបញ្ញាក្នុងព្រះពុទ្ធសាសនា (ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងសីលសមាធិ បញ្ញា) គាត់ចង់ឲ្យព្រះមាតាសមាទានសីលសមាធិបញ្ញាឡើងវិញ។ ឥរិយាបថដេកតំណាងឲ្យភាពពិការ ឬការងើបឈរនាំព្រះមាតាចេញមិនទាន់បាន (មើលការពន្យល់រូបមុន)។

២/.រូបស្ត្រីនៅចុងជើងមានពាក់ក្បាំងមកុដដូចអច្ឆរា តំណាងឲ្យអប្សរមាតាមហានគរ ដែលជាអ្នកបង្កើតពូជខ្មែរ និងពូជខ្មែរ ដៃឱបជើង គឺគាត់ប្រឹងប្រែងចាកចេញពីទុក្ខ ដៃម្ខាងទៀតពុំទាន់ព្រមទទួលផ្កាឈូកពីកូនគាត់ហុចឲ្យ គឺមានន័យថា គាត់នូវមានចិត្តចង់សងសឹកអ្នកធ្វើបាបគាត់ និងអ្នកដែលមិនដឹងគុណគាត់ (គាត់ពុំទាន់ព្រមរក្សាសីល)ឥរិយាបថនៅអង្គុយ ហើយព្រះវិស្ណុគងពីលើ មានន័យថា គាត់ពុំទាន់មានគុណធម៌គ្រប់អាចងើបឈរបាន (គឺបុណ្យឧទ្ទិសជូនគាត់ពុំទាន់គ្រប់)។

៣/.រូបសត្វគុជសី គឺតំណាងឲ្យទីក្រុងពីររលាយចូលគ្នា (ខ្ញុំបានពន្យល់រួចហើយ) ហើយឥរិយាបថកំពុងដើរទៅមុខ គឺមានន័យថា កំពុងនាំរឿងនៅខាងលើខ្លួនព្រះវិស្ណុ និងព្រះមាតាចេញទៅខាងក្រៅ ឲ្យកូនខ្មែរទាំងអស់បានដឹង។

៤/.រូបភាពខាងលើមើលទៅ ហាក់ដូចធ្លាក់ពុំទាន់ហើយ គឺតំណាងឲ្យរលកទឹកចិត្តមនោគមវិជ្ជា (មើលរូបទី៦០ពីទឹក) បរទេស ដែលគ្របពីលើគាត់ ទើបគាត់ពុំទាន់អាចផ្សាយរឿងទៅខាងលើបាន។

៥/.នៅខាងក្រោមពោះសត្វគុជសី មានសត្វត្រី និងអណ្ដើក

ក/.សត្វត្រីតំណាងឲ្យលាភសក្ការៈ មានន័យថា ត្រី ឬលាភសក្ការៈ មិនអាចឡើងទៅរំខានគាត់ខាងលើទៀតឡើយ។

ខ/.សត្វអណ្ដើក គឺតំណាងឲ្យឧបាទានក្ខន្ធ គឺអណ្ដើកឈប់ឡើងទៅរំខានគាត់ទៀតហើយ។ នៅក្នុងពិធីមង្គលការតែងមានមេអណ្ដើក និងកូនអណ្ដើត មេអណ្ដើកតំណាងឲ្យស្ត្រីម្នាក់ ដែលដឹកនាំបុរសឲ្យទៅជួបស្ត្រី គឺមានន័យថា ដឹកខន្ធមួយ ទៅជួបនឹងខន្ធមួយទៀត ឯខ្លួនឯងអ្នកដឹកក៏ជាខន្ធមួយដែរ។ ប្រស្នានេះ មាននៅក្នុងព្រះពុទ្ធសាសនា ដែលយើងសព្វថ្ងៃ តែងយល់ច្រឡំថា អណ្ដើកតំណាងឲ្យភេទស្ត្រីទៅវិញ ព្រោះភេទគ្រាន់តែជានាមបញ្ញត្តិមួយ ក្នុងបរមត្ថធម៌តែប៉ុណ្ណោះ។ ន័យម៉្យាងទៀតអណ្ដើក និងត្រី គឺបង្ហាញពីឋាន គឺគុជសីបានងើបផុតពីទឹកហើយ ព្រោះសត្វទាំងនេះ តែងរស់នៅក្នុងទឹក តែយើងត្រូវមើលរឿងទាំងនេះ គាត់ប្រតិស្ឋានទុកនៅលើក្បាល គឺក្នុងក្បាំងមកុដនាគ ពុំមែនស្ថិតនៅក្នុងទឹកដូចរូបនៅភ្នំគូលែនឡើយ។ ដូចនេះកូននាគប្រុសស្រី ត្រូវចេះពិចារណារាវរកហេតុផលពិតដោយខ្លួនឯងតាមរយៈការបកស្រាយពន្យល់ដោយសង្ខេបនេះថា តើវាជារឿងសាសនា ឬរឿងរបស់យើង?

៦/.រូបឥសីសង្ខាង គឺតំណាងឲ្យអ្នកបួស តែនៅជឿមង្គលភ្ជាក់ផ្អើលនៅឡើយ មានន័យថា អ្នកបួសក្នុងព្រះពុទ្ធសាសនាក្ដី អ្នកបួសក្រៅព្រះពុទ្ធសាសនាក្ដី ឲ្យតែអ្នកដែលមានជំនឿទៅលើមង្គលភ្ជាក់ផ្អើល ឬសីលវត្តខាងក្រៅ គឺសុទ្ធតែក្រុមឥសីទាំងអស់។ ម៉្យាងទៀតបើអ្នកបួសទាំងនោះ គ្មានពោធិបក្ខិយធម៌ទាំង៣៧ ដែលមានសតិបដ្ឋាន៤ជាខាងដើម និងមគ្គដែលមានអង្គ៨ជាខាងចុងសម្រាប់ប្រតិបត្តិនោះទេ គឺពុំមែនជាសមណពិតឡើយ ហើយផ្លូវទាំង៨ដែលត្រូវដើរនោះ គឺមានសម្មាទិដ្ឋិជាខាងដើម (ការយល់ត្រូវ) និងសម្មាសមាធិ (តំកល់ចិត្តត្រូវ) ជាខាងចុង សម្រាប់ឲ្យចិត្តធ្វើដំណើរ

បើពួកគេពុំមានផ្លូវ (មគ្គ) ទាំង៨នេះទេ គឺសុទ្ធតែជាឥសីទាំងអស់។ ហើយរូបទាំងនោះ អង្គុយបញ្ឈរជង្គង់ រួចលើកដៃសំពះ ដែលមានទឹកមុខញញឹម មានន័យថា ពួកគាត់ចាប់ផ្តើមបានដឹងរឿងរបស់ខ្លួន ហើយៗអបអរសាទរទទួលស្គាល់នូវរឿងពិត របស់អច្ឆរមាតា ដែលពីមុនពួកខ្លួនស្ថិតនៅក្រោមអំណាចទឹកចិត្តយក្សគ្របសង្កត់បិទបាំង ឥឡូវបានព្រះវិស្ណុមកជួយបើក ជួយស្រង់ឲ្យរួចផុតពីភាពងងឹត ដែលពុំបានដឹងនៅការពិតនេះ។

សរុបសេចក្តីមកការបកស្រាយដោយសង្ខេបពីអត្ថន័យក្នុងរូបនេះ គ្រាន់តែចង់ពញ្ញាក់បញ្ញាស្មារតីកូននាគ ឲ្យចេះមើលឃើញរឿងពិតរបស់មេនាគ ចេះប្រៀបធៀបពីការវិវឌ្ឍន៍របស់រូបចម្លាក់ពីប្រាសាទមួយទៅប្រាសាទមួយ ដើម្បីស្វែងរករឿងពិតក្នុងបេះដូងថ្ម ដែលជាមរតកគំនិតមិនអាចកាត់ថ្លៃបាន ដែលជនទុច្ចរិតតែងវាប់បំផ្លាញចោលនោះ ឲ្យក្លាយមកជារតនទ្រព្យដ៏មានតម្លៃកាត់ថ្លៃពុំបាន ដែលយើងគួរនាំគ្នាការពារ និងថែរក្សា ដូចជាថែរក្សាកេរ្តិ៍ខ្មែរកទាំងគូ។

## ៦៨/.រូបភាពទី៦៨រូបព្រះវិស្ណុដេកនៅក្បាំងភ្លែង(ប្រាសាទបន្ទាយសំរែ)



តើភាសាររូបក្នុងក្បាំងក្លែងនេះ មានអត្ថន័យយ៉ាងណាចំពោះសាសនអច្ឆរមាតា? ពាក្យថា បន្ទាយសំរិរ ឬបន្ទាយអ្នកស្រែ ខ្ញុំបានពន្យល់រួចហើយនៅក្នុងភាគពីរ ពេលនេះខ្ញុំគ្រាន់តែយករូបភាពដែលបានលាក់បំប្លែង ដែលបានលាក់ក្នុងក្បាំងដែលពាក់លើក្បាលអច្ឆរមាតា មកបកស្រាយពន្យល់នៅការពិតតែប៉ុណ្ណោះ។ រូបព្រះវិស្ណុដេកនេះ បើយើងមើលទៅតាមភាពជាក់ស្ដែង គាត់បានឆ្លាក់ពង្រាយស្ទើរគ្រប់ទីកន្លែង គ្រាន់តែកន្លែងខ្លះរូបតូច កន្លែងខ្លះរូបធំ កន្លែងខ្លះមានរូបវិស្ណុផ្ទុំលើនាគរួចគងលើព្រះម៉ែ កន្លែងខ្លះផ្ទុំលើសត្វគុជសី ចំណែករូបព្រះវិស្ណុផ្ទុំនៅប្រាសាទបន្ទាយសំរិរនេះ គាត់ផ្ទុំលើសត្វនាគផង គាត់ផ្ទុំលើសត្វគុជសីផង ហេតុអ្វីក៏រូបនេះ គាត់ឆ្លាក់ខុសពីរូបមុនៗ?

**ក**/.ព្រះវិស្ណុក្នុងរូបនេះ មានអត្ថន័យដូចរូបមុន ខុសត្រង់ដៃខាងលើមានទប់ទងផ្កាដែលដុះចេញពីផ្ចិតរបស់គាត់ ឯដៃខាងលើមួយទៀត ដែលហុចផ្កាឈូកឲ្យព្រះមាតានោះ ផ្កានេះមានទំហំធំហើយមានស្រទាប់ផ្កាច្រើន។

**ខ**/.ស្ត្រីដែលនៅខាងចុងជើង តំណាងឲ្យអច្ឆរមាតា ក្នុងរូបនេះ គាត់ប្រឹងក្រោកឈរ ហើយដៃឆ្វេងរបស់គាត់ ព្រមទទួលទផ្កាឈូកដែលកូនបានហុចឲ្យ គឺខុសពីរូបមុន ដែលគាត់ពុំព្រមទទួលឡើយ ឯដៃស្ដាំវិញ ប្រឹងច្រត់ជើងកូនដើម្បីងើបឈរ ខុសពីរូបមុន ដែលគាត់ប្រឹងឱបជើងកូន។

**គ**/.ដោយការខំប្រឹងប្រែងងើបឈររបស់គាត់ ទីបំផុតគាត់បានឡើងទៅឈរលើខ្នែងផ្កាឈូកដែលដុះចេញពីផ្ចិតរបស់ព្រះវិស្ណុ ដែលរូបនៅលើផ្កាឈូកខ្នែងម្ខាង តំណាងឲ្យអច្ឆរមាតា និងរូបម្ខាងទៀត តំណាងឲ្យបិតា ចំណែករូបកណ្ដាល តំណាងឲ្យរូបព្រះវិស្ណុ ដែលបំបែកខ្លួនត្រឹមផ្ចិត ត្រូវផ្លាស់នាមថ្មី ជាព្រះព្រហ្ម ឬព្រះពោធិសត្វលោកេស្វរៈ ហេតុអ្វីបានជាទៅដល់ពាក់កណ្ដាលផ្ចិត គាត់ត្រូវបំបែកខ្លួនយ៉ាងដូច្នេះ? ព្រោះផ្ចិតជាចំណុចកណ្ដាល បានន័យថា ពាក់កណ្ដាលខាងលើ និងពាក់កណ្ដាលខាងក្រោម គឺស្មើគ្នា (មើលការពន្យល់ក្នុងមង្គលបីភាគ២)។ ទៅដល់ចំណុចកណ្ដាលនោះគុណធម៌របស់គាត់ ត្រូវរុញច្រានឲ្យគាត់ផ្លាស់ប្ដូររូប ជាព្រះព្រហ្ម ឬព្រះពោធិសត្វលោកេស្វរៈ ព្រោះបញ្ញារបស់គាត់បានយល់ច្បាស់ពីបរមត្ថសច្ចៈ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងថា (នត្ថិកម្មំសមំពលំ) **កម្លាំងអ្វីស្មើដោយកម្លាំងកម្ម គឺពុំមានឡើយ** ដោយគាត់បានយល់ពាក្យភាសិតនេះ ថាគាត់ពុំអាចប្រើនៅកម្លាំងចិត្ត បង្ខំឲ្យព្រះមាតាព្រះបិតាឆាប់រួចពីឃុំតាមចិត្តចង់ របស់គាត់បានឡើយ សូម្បីតែព្រះសម្មាសម្ពុទ្ធ ក៏ព្រះអង្គមិនអាចគេចផុតពីកម្លាំងកម្ម ដែលត្រូវឲ្យផលនោះបានទេ។ ផ្លូវកណ្ដាលមួយបានកើតឡើង ពេលដែលទៅដល់ចំណុចផ្ចិត ដែលទងផ្កាទាំងបីត្រូវកើតឡើង គាត់លូនវារទៅមុខផង

បណ្ដុះទងផ្កាគឺគុណធម៌ឡើងទៅលើផង តែគួរឲ្យអនិច្ចាបរទេសគេបានដឹងពីអាថ៌កំបាំងថ្មទាំងនេះ គេបានជួលពួកទុច្ចរិតឲ្យដាប់បំផ្លាញក្បាលរបស់គាត់ ព្រោះគេមិនចង់ឲ្យគាត់នៅរស់ ជួយស្រង់អ្នកទាំងពីរ លើកទៅដាក់លើបល្ល័ង្កឈូក ដែលនៅទំនេរពីខាងលើនោះ (មើលការពន្យល់រូបទី៤២)។ ក្នុងអត្ថន័យរូបនេះ និងរូបទី៤២ដែលបានពន្យល់ហើយ បានបញ្ជាក់ប្រាប់យើងពីឈ្មោះភ្នំដងរែក ដែលគាត់ត្រូវរែកម៉ែឪទៅដាក់លើកំពូលភ្នំព្រះវិហារវិញ ដែលអ្នករែកនោះជាពូជសំរែ ឬអ្នកស្រែ ព្រោះរូបវិស្ណុផ្ទុំបន្ទាយសំរែនេះ បានបញ្ជាក់ពីសាវតាពិតរបស់បុគ្គលនេះ ទៅតាមឈ្មោះរបស់ប្រាសាទ ដែលគេបានឆ្លាក់រូបនិមិត្តទុកនេះ (មើលការពន្យល់ពីឈ្មោះប្រាសាទបន្ទាយសំរែភាគ២)។

**ឃ**/.គាត់ផ្ទំលើសត្វនាគផង លើសត្វគុជសីផង (មើលការពន្យល់រូបទី៦៦និងរូបទី៦៧) អត្ថន័យគឺរឿងអាថ៌កំបាំងមេនាគ ដែលបានហាន់ជាចំណិតៗ (ហាន់ជ័យ) ពីអតីតនោះ ត្រូវបានផ្គុំបញ្ចូលគ្នាវិញ គឺប្រស្នាក្នុងព្យញ្ជនៈខ្មែរទាំង៣៣តួ និងអាថ៌កំបាំងក្នុងមរតកព្រះម៉ែ ដែលមានសល់មកដល់សព្វថ្ងៃ។

សង្ខេបសេចក្ដីមកអត្ថន័យរូបនេះ ខុសពីរូបមុន ត្រង់គាត់ព្រមក្រោកឈរ ហើយខំប្រឹងប្រែងឡើងទៅកាន់ទីខ្ពស់វិញ ដោយពួកគាត់ព្រមរួមគ្នាមិនបែកគ្នាដូចរូបមុន គឺមានតែមាតា និងកូន ឯក្នុងរូបនេះ កូនបានស្រង់រែកមាតា និងបិតា ដូចជាព្រះពោធិសត្វសុវណ្ណសាម បានរែកមាតាបិតាយ៉ាងដូច្នោះ (បំពេញនូវកតញ្ញូកតវេទី)។

## ៦៩/.រូបភាពទី៦៩រូបក្រពើសាមពាន់(នៅក្បាលស្ពាន)



តើសត្វក្រពើនេះ តំណាងឲ្យអ្វី? ពាក្យក្រពើនេះ ខ្ញុំបានពន្យល់រួចហើយ ក្នុងភាគមួយ និងភាគពីរ ពេលនេះខ្ញុំយករូបភាពចម្លាក់មកដាក់បង្ហាញ ព្រោះចង់ឲ្យបានដឹងថា រឿងហេតុភាគច្រើន គឺកើតចេញពីថ្ម ព្រោះព្រឹទ្ធដូនតាយើងលោកចងក្រងរឿងព្រេង ទំនាយ និងពាក្យទូន្មានផ្សេងៗ ភាគច្រើនគាត់បានដកយកចេញពីក្នុងថ្ម។ រូបចម្លាក់ក្រពើនេះ មានឈ្មោះថា ក្រពើសាមពាន់ ព្រោះពាក្យថាសាមពាន់ គឺគុណបន្តគ្នា បានន័យថា ក្រពើបានបែងភាគចូលគ្រប់កូននាគ ដូច្នេះទើបពេលស្លាប់ទៅ គេតែងលើកទង់ក្រពើស ឲ្យម្នាក់មួយៗ ហើយដែលគាត់យករូបនេះ ទៅឆ្លាក់នៅក្នុងទីតាំងក្បាលស្ពាន អច្ឆរមាតាគាត់ចង់ប្រាប់យើងថា អាថ៌កំបាំងនៃពាក្យក្រពើ និងទង់ក្រពើ បានបើកបង្ហាញហើយ ព្រោះបានទៅដល់ទីបញ្ចប់ ព្រោះក្បាលស្ពានពីអតីត និងក្បាលស្ពានបច្ចុប្បន្ន បានភ្ជាប់ ធ្វើឲ្យយើងអាចដើរឆ្លងទៅមើលអាថ៌កំបាំងក្នុងថ្ម ពីអតីតកាលបាន។

## ៧០/.រូបភាពទី៧០រូបបុរសជ្រោងក្រពើឡើង(មិនដឹងប្រភព)



តើក្នុងរូបភាពនេះ អត្ថន័យរបស់រូបគាត់ចង់និយាយប្រាប់ពីអ្វី? រូបនេះ បានបង្ហាញពីបុរសម្នាក់ជ្រោងក្រពើដៃម្ខាងឡើងទៅលើ ដោយបុរសនោះឈរលើកជើងមួយចំហៀង។ ក្រពើនៅខាងលើឈរនៅលើទំរមួយ នៅពីខាងលើក្រពើមានសន្លឹកក្បាច់មួយ ដូចជារាងបេះដូង ឯរាងសង្ខាងក្បាច់ទាំងមូលព័ទ្ធជុំវិញ មានរាងជាត្រីកោណ រាងខ្លែង និងរាងដូចទង់។ នៅសង្ខាងបុរសកំពុងជ្រោងក្រពើ មានស្ត្រីពីរនាក់មានពាក់មកុដ និងមានស្លៀកសំពត់ដូចជាអច្ឆរា ឈរនៅលើបល្ល័ង្គ ទាបជាងបុរសនោះ។ បុរសដែលមានពាក់ខ្សែអង្កាំ ឈៀងស្មាម្ខាងនោះ (ធនជ័យមើលប្រស្នាចាក់ទឹកដូងភាគ១) តំណាងឲ្យអ្នកដឹងពីអាថ៌កំបាំងទង់ក្រពើនេះ ដៃម្ខាងកាន់ដងធ្នូ ច្រត់លើចង្កេះ ដៃម្ខាងទៀត គាត់ជ្រោងទ្រនាប់ដែលទ្រសត្វក្រពើ មិនឲ្យក្រពើនោះ

មកប៉ះនឹងដៃគាត់ឡើយ ហាក់ដូចជាចង់បង្ហាញប្រាប់ ពីអត្ថន័យកំបាំងរបស់សត្វក្រពើនេះ ឲ្យអ្នកផង ទាំងពួងបានដឹង។ ឯក្បាច់ដៃលមានរាងដូចជាបេះដូងនោះ គឺជានិមិត្តរូបនៅក្នុងប្រស្នាចាក់ទឹកដូង លើកទី១ ដែលចាក់ទឹកក្នុងបេះដូងម៉ែដំបូង ពុំបានឃើញរឿងក្នុងចិត្តគាត់ឡើយ គឺឃើញតែក្បាល ក្រពើ ហើយក្រពើនោះក៏ដេញតាមខាំបុរសនោះ (មើលចាក់ទឹកដូងក្នុងភាគមួយ) ព្រោះក្នុងរូបនេះ និមិត្តរូបបេះដូង និងសត្វក្រពើ គឺនៅក្នុងរង្វង់ជាមួយគ្នា។ ឯរូបស្ត្រីពីរនាក់ ដែលឈរនៅសង្ខាងនោះ តំណាងឲ្យអច្ឆរមាតា ដែលកូនជ័យបានចាក់ទឹកក្នុងបេះដូងរបស់គាត់ទាំង២លើក ចាក់លើកទី១ គឺ ក្នុងអតីត ចាក់លើកទី២ គឺក្នុងបច្ចុប្បន្ន មានន័យថាយករឿងពិតក្នុងអតីត មកភ្ជាប់ស្ពានជាមួយ បច្ចុប្បន្ន (ប្រស្នាក្នុងព្យញ្ជនៈ)។

បង្រួមសេចក្ដីមករូបក្រពើនៅក្បាលស្ពាន និងរូបក្រពើនេះ ដែលបង្កើតឲ្យមានភ្នំក្រពើ ទង់ ក្រពើ ផ្កាយក្រពើ.....ឈ្មោះភូមិស្រុក និងក្នុងពាក្យទូន្មានអប់រំ ដែលគាត់យកសត្វក្រពើមកប្រៀប ធៀប គឺអត្ថន័យពាក្យទាំងនោះ សុទ្ធតែចេញពីក្នុងបេះដូងថ្ម ក្នុងរូបចម្លាក់ដែលមាននៅសល់ទាំងអ ស់។

## ៧១/.រូបភាពទី៧១រូបផ្ដែរនៅប្រាសាទវត្តភូ(ប្រទេសលាវ)



តើអត្ថន័យភាសាថ្មក្នុងរូបនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី? អត្ថន័យក្នុងរូបនេះ ខ្ញុំ បានពន្យល់ម្ដងហើយ នៅក្នុងភាគ២ រឿងមង្គលបីប្រការ តែដែលខ្ញុំយកមកបញ្ចូលក្នុងភាគ៣ជាបន្ត នេះ ខ្ញុំចង់ពន្យល់ប្រៀបធៀបរូបហែកជាបីក្នុងរូបភាពទី៣៣ តើវាមានអត្ថន័យខុសគ្នាដូចម្ដេច? រូប

នេះ ក្បាលដែលត្រូវហែកចេញទាំងសង្ខាង គឺមានពាក់មកុដ ក្រវិល គ្រឿងអលង្ការ ដែលខុសពីរូបស្ត្រីទី៣៣ ដែលហែកសង្ខាងដូចគ្នា តែគ្មានពាក់មកុដ ក្រវិល គ្រឿងអលង្ការឡើយ ហើយការហែកក្នុងរូបនេះ ផុតពីបេះដូងតែបន្តិច ឯរូបភាពទី៣៣ គឺហែករហូតដល់ផ្ចិត ដែលជាចំណុចកណ្ដាលនៃដងខ្លួនមនុស្ស។ ដោយការប្រៀបធៀបរូបចម្លាក់ទាំងពីរនេះ អត្ថន័យក្នុងការហែកគឺផ្សេងគ្នា ហែកទីមួយ គឺហែកដណ្ដើមកេរមរតកព្រះម៉ែ ហែកទីពីរ គឺហែកមើលរឿងក្នុងបេះដូងព្រះម៉ែ បើគ្រាន់តែមើលពុំបានយកមកពិចារណាប្រៀបធៀប និងឈ្វេងយល់ ច្បាស់ជាយល់ថា មានអត្ថន័យដូចគ្នាពុំខាន ឧ. ដូចជានៅក្នុងភាសាខ្មែរ ពាក្យសរសេរ ”ក ក៏ ករ” សម្លេងអានមានសូរដូចគ្នា តែន័យខុសគ្នា។

សង្ខេបសេចក្ដីមកសិល្បបំភាន់របស់ដូនតា ក៏យ៉ាងដូច្នោះដែរ បើយើងពុំបានយកឈ្មោះប្រាសាទមកវែកញែក រួមទាំងរឿងផ្សេងៗ ដែលជាប់ទាក់ទងនឹងរូប មកបូកបញ្ចូលជាមួយគ្នានោះទេ យើងច្បាស់ជារកចម្លើយឲ្យសមហេតុ និងផល ពុំបានឡើយ ព្រោះកែវភ្នែករបស់មាតាយើង ត្រូវយក្សដកយកទៅលាក់ទុកអស់ហើយ (ប្រស្នានៅក្នុងរឿង)។

## ៧២/.រូបភាពទី៧២រូបក្បាច់ចង្វាយក្នុងសសរ(ប្រាសាទទន្លេបាត់ទី)



តើនៅក្នុងក្បាច់ចង្វាយទាំងនេះ មានបង្កប់រឿងក្នុងបេះដូងរបស់គាត់ យ៉ាងដូចម្ដេច? ហើយគាត់ចង់ប្រាប់យើងពីរឿងអ្វី?

១/.កងក្បាច់ខាងក្រោម នៅក្នុងកងនោះ មានរូបគ្រុឌកំពុងចាប់សន្លឹកក្បាច់សង្ខាង ដែលនិមិត្តរូបសន្លឹកក្បាច់នោះ គឺជាសត្វដំរី ព្រោះក្បាលដំរីធ្លាក់ទៅក្រោម ដោយដៃគ្រុឌចាប់ជើងក្រោយដំរីលើកឡើង។ រូបនេះ បើយើងមើលហើយ មិនបានពិនិត្យឲ្យដិតដល់ទេ ច្បាស់ជាពុំឃើញរូបដំរីឡើយ គឺឃើញតែសន្លឹកក្បាច់តែប៉ុណ្ណោះ ព្រោះការឆ្លាក់បំភាន់នេះ គឺពួកគាត់មានទេពកោសល្យ

ខ្ពស់។ តើគ្រុឌនៅកណ្ដាល ដំរី ក្បាច់ព័ទ្ធជុំវិញ តំណាងឲ្យអ្វី?

ក/.គ្រុឌតំណាងឲ្យសៀម (ពន្យល់រួចហើយ)

ខ/.ដំរីតំណាងឲ្យឈ្មោះនគរ យសោធបុរៈ (នគរដំរី) ដែលពីមុននគរនេះ ដើបឈរត្រដែត ក្រោយមកត្រូវគ្រុឌចាប់លើកជើងឡើង ឲ្យសំយ៉ុងក្បាលចុះ (មើលការពន្យល់រូបទី៦៣ពីដំបងក្រញូង) ។

គ/.ក្បាច់កងដែលព័ទ្ធជុំវិញ តំណាងឲ្យសីមា ឬគុករបស់យក្ស ត្បិតថាក្នុងរូបនេះគ្មានយក្ស តែសត្វគ្រុឌគឺជាសេនារបស់យក្ស ដែលតំណាងឲ្យយក្ស។

ឃ/.ហេតុអ្វីបានជាគ្រុឌនៅចំកណ្ដាលទៅវិញ ក្នុងរូបនេះ? ក្នុងការដណ្ដើមឈ្លានពានហែកយកនគរដំរីនេះ ដំបូងពួកគ្រុឌឬដំបងក្រញូងនេះ ដែលជាមនុស្សព្រៃគ្មានប្រទេសគ្មាននគរ បានលុកលុយឈ្លានពាន វាតទីដណ្ដើមយកកេរមរតកព្រះម៉ែមុនគេ នេះជាហេតុទី១។ យើងបានដឹងហើយថា បេះដូងនគរមេ ឬនគរស្រីល្វោពីអតីតនោះ សព្វថ្ងៃគឺនៅក្នុងខេត្តល្វោ ឬលពបុរី (បុរីដែលត្រូវគ្រុឌលុបដាន) ជាបេះដូងមេដំបូង ដែលខ្ញុំបានពន្យល់ក្នុងភាគ១ ពីការបង្កើតពូជនាគ ឬពូជក្មេរ (កេរមេ) ដែលក្រោយមកក្លាយជាពូជខ្មែរ (កេរម៉ែ)។ ចំណុចកណ្ដាលនេះ សព្វថ្ងៃត្រូវគ្រុឌហែកដណ្ដើមយកទៅ ហេតុនេះ ទើបដូនតាឆ្លាក់ក្នុងក្បាច់រង្វង់ដាក់គ្រុឌនៅចំកណ្ដាលនេះ ហើយនៅក្នុងទីតាំងសសរប្រាសាទទន្លេបាត់ទី (មើលការពន្យល់ក្នុងភាគ២ ឈ្មោះទន្លេបាត់ទី) ដែលជាឈ្មោះបង្ហាញ ពីកាបាត់ប្រភពមេ (ទឹកតំណាងឲ្យព្រះម៉ែ មេគង្គ ឬមេកុង)។

២/.តើរូបស្ត្រីដែលនៅក្នុងឃុំ រង្វង់ជាបន្ទាប់នោះ តើគាត់ជានរណា? រូបស្ត្រីដែលមានពាក់មកុដ គ្រឿងអលង្ការ ដែលកំពុងលើកដៃរាំជ្រោងទៅលើ ដៃម្ខាងដាក់ត្រឹមដើមទ្រូង ជើងម្ខាងលើកឡើង និងជើងម្ខាងទៀត ឈរនៅលើផ្កាឈូកមួយទងនោះ គឺតំណាងឲ្យអច្ឆរមាតាមហានគរ (មើលការពន្យល់រូបទី៥៣) ដែលគាត់កំពុងជាប់ទោសក្នុងរង្វង់សីមាយក្ស។ ព្រោះកាំក្បាច់ដែលនៅជុំវិញគាត់នោះ គឺជាធ្មេញយក្សដែមាននៅខាងក្នុង និងខាងក្រៅជុំវិញ ហើយរង្វង់នេះ បានវិលដុះជាបន្តទៅខាងលើទៀត សម្រាប់ភ្ជាប់រឿងទៅខាងលើ។

៣/.តើរូបមនុស្សអង្គុយក្នុងកងរង្វង់ទី៣ តំណាងឲ្យអ្វី?

រូបដែលអង្គុយឈ្ងោកចុះក្រោម នៅលើផ្កាឈូកនោះ គឺតំណាងឲ្យពោធិសត្វលោកេស្វរៈ ឬព្រះវិស្ណុ ដែលជាកូននាគត្រូវចុះទៅខាងក្រោម (សមុទ្រទឹកដោះ) ដើម្បីរាវរករឿងព្រះម៉ែ (មើលការពន្យល់ក្នុងរូបមុនៗ)។

៤/.រូបទី៤ ដែលស្ថិតនៅក្នុងរង្វង់សីមានេះ ក៏តំណាងឲ្យកូននាគដែរ តែគាត់ចាប់ផ្ដើមដឹងរឿងអច្ឆរមាតារួចងើបមុខឡើង គឺមានន័យថា ចាប់ផ្ដើមនាំព្រះមាតាឡើងទៅខាងលើវិញ ហើយអ្នកទាំងពីរសុទ្ធតែនៅជាប់ក្នុងរង្វង់សីមា ដែលមានកាំក្បាច់ធ្មេញយក្សដូចគ្នា។

៥/.រូបក្នុងរង្វង់ទី៥ គឺគាត់ចាប់ផ្ដើមដេកលើបល្ល័ង្កផ្កាឈូក ដឹកព្រះមាតាចេញមានន័យថា គាត់នាំព្រះមាតាចេញពីទីឃុំរបស់យក្សទៅដល់ចំណុចផ្ចិតហើយ (មើលការពន្យល់វិស្ណុដេក ឬផ្ទុំ)។

៦/.ក្នុងរង្វង់សីមាទី៦ គឺបានដាច់រូបគាត់បាត់ទៅហើយ គឺមានន័យថា ទៅដល់ចំណុចផ្ចិតភ្លាមគាត់ត្រូវបាត់ដំណឹង លែងមាននរណាបានដឹងពីរឿងគាត់ទៀតហើយ។ ព្រោះពាក្យថាដេក គឺនៅក្នុងផ្ទះ ក្នុងបន្ទប់ នៅលើគ្រែ បើអ្នកណាចង់ជួបគាត់ ទាល់តែចូលទៅក្នុងផ្ទះ ក្នុងបន្ទប់ ទើបឃើញគាត់ នេះជាអត្ថន័យថ្មបាននិយាយប្រាប់យើង ពីឥរិយាបថបុគ្គលដែលកំពុងដេក។

សរុបសេចក្ដីមកការបកពន្យល់ដោយសង្ខេប ក្នុងរូបចង្វាយឃុំទាំង៦នេះ គឺបានបញ្ជាក់ប្រាប់ពីការខំប្រឹងប្រែង វារងើបឡើងរបស់កូន ដែលចុះស្រង់ព្រះមាតានៅបាតខាងក្រោម។ ហើយដែលការខិតខំនេះ ធ្វើឲ្យរូបគាត់បានរីកធំនៅខាងលើ ពេលដែលគាត់បានលើករែកព្រះមាតានិងបិតា ទៅដាក់ដល់កំពូលរបស់ពួកគាត់វិញ នៅចុងបញ្ចប់នៃក្ដី។



## ៧៣/.រូបភាពទី៧៣រូបវិស្ណុនៅក្បាំងភ្លែងខាងលើ(ប្រាសាទទន្លេបាត់ទី)

នៅក្នុងរូបភាពចម្លាក់នេះ ត្រូវបានចែកចេញជា៦ជាន់ ហើយក្នុងជាន់នីមួយៗ បានបង្ហាញសកម្មភាពរូបផ្សេងៗពីគ្នា តើអត្ថន័យក្នុងរូបទាំងនេះ គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី? រូបនៅផ្ទៃរខាងក្រោម ចែកចេញជា៣ជាន់ ហើយក្នុងជាន់ទាំង៣នេះ កើតមានរូបឡើងបន្តគ្នារហូតដល់ចុងក្បាំងខាងលើ ក៏ដោយសារការព្យាយាមសន្សំគុណធម៌ តាំងពីរូបតូចៗក្នុងរង្វង់សីមា នៅឯសសរខាងក្រោមឯណោះ។ ដោយការព្យាយាមវាឡើងរបស់គាត់ ទីបំផុតរូបរបស់ពួកគាត់ ត្រូវបានស្រង់រែកយកទៅដាក់ ដល់កំពូលក្បាំងខាងលើមែន (មើលរូបភាព)។

១/.រូបជាន់ទី១ មានមនុស្សមួយជួរ មានពាក់មកុដ កំពុងអង្គុយចំអើត បញ្ឈរជង្គង់លើកដៃសំពះ ពុំមានពាក់អាវឡើយ តើរូបនេះ តំណាងឲ្យអ្វី? រូបកំពុងលើកដៃសំពះនេះ តំណាងឲ្យព្រះវិស្ណុសន្សំនៅគុណធម៌ គឺបារមី ឲ្យក្លាយខ្លួនជាពោធិសត្វលោកេស្វរៈ (មើលការពន្យល់រូបមុនៗ)។ ក្នុងចន្លោះរូបមួយ មានសន្លឹកក្បាច់ខណ្ឌមួយ សន្លឹកក្បាច់នោះ គឺក្បាច់ត្របកឈូកបំបែកផ្កាប់ចុះ មានន័យថា ផ្កាឈូកគឺបញ្ញារបស់គាត់ ពុំទាន់អាចត្រាស់ដឹងនៅសច្ចធម៌បានទេ គឺនៅបំបែកសន្សំបារមីនៅឡើយ។ សភាវៈពិតរបស់ផ្កាឈូក ទងផ្កាត្រូវដុះឡើងទៅលើ ពុំមែនដុះសំយ៉ុងផ្កាប់ចុះក្រោមឡើយ បើផ្កាប់ចុះ គឺពុំអាចធ្វើឲ្យផ្កានោះរីករួច បើរីករួចគឺត្រូវរលួយជាពុំខាន។

២/.រូបជាន់ទី២ ក៏បង្ហាញពីមនុស្សមួយជួរអង្គុយបញ្ឈរជង្គង់ ពុំមានពាក់មកុដ តែមានពាក់អាវ កំពុងលើកដៃទ្រផ្កាឈូកតូចមួយ នៅចន្លោះមនុស្សម្នាក់ៗមានរូបដាវសំយុងចុងផ្លែចុះក្រោម តើរូបទាំងនេះ តំណាងឲ្យអ្វី? រូបដែលមានពាក់អាវ គឺពួកគេពុំមែនជាពូជនាគ ឬពូជខ្មែរទេ ព្រោះពូជម៉ែ

ជាពូជលែងខ្លួនទទេល្វែងខាងលើ ទាំងបុរសទាំងស្ត្រី (រូបចម្លាក់ពីអតីត) មានន័យថា ពួកគេតំណាងឲ្យជនជាតិខាងក្រៅ គឺបរទេស។ ដៃដែលពួកគេទ្រផ្កាឈូកគ្រប់គ្នានោះ ន័យទីមួយ គឺពួកគេកំពុងសន្សំគុណធម៌ គឺបញ្ញាតាមការគោរពព្រះពុទ្ធសាសនាទាំងពីរនិកាយ (ហិនយាន មហាយាន) ន័យទីពីរ គឺពួកគេព្រមទទួលចុះចាញ់ឫទ្ធិបារមីរបស់ព្រះវិស្ណុខាងលើ ពេលដែលគាត់សន្សំបុណ្យ គុណធម៌បានគ្រប់គ្រាន់អាចលើកព្រះមាតាបិតាមហានគរ យកទៅដាក់ក្នុងទីខ្ពស់វិញបាន គឺពួកគេកំពុងចុះចាញ់ រួចបូជាផ្កាភ្ញីចំពោះអ្នកនៅខាងលើ។ ហើយអាវដែលពួកគេពាក់ បង្ហាញពីសារជាតិជនជាតិមួយ បានផ្ដាច់ចេញពីជនជាតិខ្មែរ ដែលមានទម្លាប់លែងខ្លួនទទេ រូបភាពមនុស្សមានពាក់អាវនេះ យើងច្រើនឃើញដូនតាឆ្លាក់លើជញ្ជាំងប្រាសាទ ដោយពួកគាត់ចង់ញែកលក្ខណខាងក្រៅឲ្យដាច់ពីគ្នា។ ដាវដែលសំយុងចុងចុះខណ្ឌរូបនីមួយៗឲ្យដាច់ពីគ្នានោះ តំណាងឲ្យការចុះចាញ់របស់ពួកគេនៅទីបញ្ចប់ ព្រោះការតាមព្យាបាទ ឈ្នានីស ដែលពួកគេខំបិទ លាក់ សន្ធប់ ដោយប្រើរូបភាពគ្រប់បែបយ៉ាង គឺពុំអាចឃាត់ឃាំង ការព្យាយាមរបស់កូនក្នុងការស្រង់ប្រស់ និងនាំមាតាបិតា ចេញពីទីឃុំបានទេ។ ដូចកាលក្នុងបឋមត្រាស់ មារាធិរាជបាននាំពលសេនាដ៏ច្រើន ទៅផ្ចាញ់ដើម្បីដណ្ដើមយករតនបល្ល័ង្កក្រោមដើមពោធិព្រឹក្សពីព្រះសម្មាសម្ពុទ្ធនោះ ការចុះចាញ់របស់មារាធិរាជ និងបក្សពួក គឺមានន័យដូចការចុះចាញ់ក្នុងរូបចម្លាក់នេះ ដោយព្រះវិស្ណុ ឬព្រះពោធិសត្វលោកេស្វរៈ លោកបានផ្ចាញ់ដោយការមិនតបត (ពៀររម្ងាប់ដោយការមិនចងពៀរ) ដូចមានសុភាសិតខ្មែរបុរាណបានពោលទុកថា **"អ្នកផ្ចាញ់គឺព្រះ ឈ្នះលើពួកមារ"**។

៣/.រូបជាន់ទី៣ គឺចែកចេញជាបី មានរូបកណ្ដាល រូបខាងឆ្វេង និងរូបខាងស្ដាំ ក្នុងរូបទាំងនេះមានឥរិយាបថផ្សេងៗគ្នា។

**ក**/.រូបកណ្ដាលតំណាងឲ្យព្រះវិស្ណុ ឬព្រះនរាយណ៍ កំពុងអង្គុយក្នុងឥរិយាបថសមាធិ ដែលមានរាងដូចជាក្បាំងតូចមួយ គ្របពីលើគាត់ជាប់ (មើលការពន្យល់ក្បាំងគ្របក្នុងរូបមុន)។

**ខ**/.ខាងឆ្វេងដៃគាត់ មានរូបមនុស្សតូចពីរនាក់ មួយឈរកាន់ច្រត់ ដែលមានសម្លៀកបំពាក់ដូចអច្ឆរា និងមួយទៀតលើកដៃសំពះ គឺតំណាងឲ្យអច្ឆរមាតាកំពុងងើបឈរឡើងកាន់ច្រត់ ហើយនៅក្រោយរូបតូចទាំងពីរ មានមនុស្សអង្គុយបត់ជើងបញ្ឈរជង្គង់ លើកដៃសំពះមានពាក់អាវ អត្ថន័យរូបដូចរូបខាងក្រោម។

គ/.ខាងស្តាំក៏មានរូបកំពុងក្រោកឈរ និងអង្គុយបញ្ឈរជង្គង់ ក្នុងឥរិយាបថដូចរូបខាងឆ្វេង ចំណែកន័យរូបក៏ដូចរូបខាងឆ្វេងដែរ ព្រោះរូបក្នុងជាន់ទីបីនេះរលុបៗ មើលពុំសូវច្បាស់ឡើយ ដូចនេះការបកស្រាយពន្យល់ គឺទៅតាមលក្ខណរូបរាងដែលនៅសល់ ហើយច្បាស់តែប៉ុណ្ណោះ។

៤/.ក្នុងរូបជាន់ទីបួននេះ មានរូបមនុស្សស្រី និងរូបមនុស្សប្រុស នៅសង្ខាងបល្ល័ង្កកណ្តាល ដែលរូបទាំងពីរ មានឥរិយាបថអង្គុយបត់ជើងបញ្ឈរជង្គង់ បម្រុងងើបឈរដូចគ្នា រូបនេះបានមកស្ថិតក្នុងក្បាំងក្លែងហើយ ដោយបានឆ្លងផុតសោជាន់ទីពីរ គឺផ្តែរ។

ក/.រូបស្ត្រីដែលស្ថិតនៅពីខាងឆ្វេងបល្ល័ង្ក មានពាក់មកុដក្បាំងដូចអច្ឆរា ដៃឆ្វេងប្រឹងច្រត់ទប់ខ្លួនឡើង ដៃស្តាំមានកាន់វត្ថុមួយក្នុងដៃ គឺតំណាងឲ្យអច្ឆរមាតាមហានគរ ដែលលោកត្រូវប្រឹងប្រែងងើបឈរឡើងទៅខាងលើជាបន្តទៅទៀត។ នៅខាងក្រោយរូបអច្ឆរមាតា មានសញ្ញាឆ្លាក់ជារូបផ្លែព្រួញមួយ ចង្អុលចុងព្រួញទៅខាងលើ គឺមានន័យថា គាត់ត្រូវប្រឹងឡើងទៅខាងលើបន្តទៅទៀត ដើម្បីចេញពីអំណាចក្រុងឃុំរបស់យក្ស។

ខ/.រូបនៅពីខាងស្តាំបល្ល័ង្កវិញ មានរូបមនុស្សប្រុសម្នាក់មានពាក់មកុដ បែងភាគដៃជាបួន កំពុងអង្គុយបត់ជើងបញ្ឈរជង្គង់ ដៃឆ្វេងដែលបែងនោះ ខាងលើកាន់ខ្យងស័ង្ខ ខាងក្រោមដាក់លើដើមទ្រូង ឯដៃស្តាំខាងលើកាន់ដុំមូល ខាងក្រោមឱបទ្រូងពីលើដៃឆ្វេង តើរូបទាំងនេះ តំណាងឲ្យអ្វី? ខ្យងស័ង្ខ តំណាងឲ្យសម្លេងផ្សព្វផ្សាយរឿងពិតរបស់អច្ឆរមាតា ដុំមូលតំណាងឲ្យ ការប្រមូលរឿងដែលហាន់ជាចំណែកៗ (ប្រាសាទហាន់ជ័យ) ឲ្យមូលជុំឡើងវិញ ដៃឱបវត្ថុមួយលើទ្រូងតំណាងឲ្យ រឿងនេះតម្លៃស្មើនឹងជីវិត ឬបេះដូងរបស់គាត់ (មើលការពន្យល់ពាក្យទ្រូងក្នុងភាគ២)។

គ/.រូបព្រះវិស្ណុធំឈរលើបល្ល័ង្កកណ្តាល លើកជើងបញ្ឈរមួយចំហៀង ហាក់ដូចទើបក្រោកឈររួច មានដៃបែកជាបួន ដៃឆ្វេងខាងលើកាន់ខ្យងស័ង្ខ ដៃឆ្វេងខាងក្រោមដាក់ស្មើដើមទ្រូង រួចផ្ងារបាតដៃ ឯដៃស្តាំខាងលើវិញ កាន់ដុំមូល ដៃស្តាំខាងក្រោមដាក់ត្រឹមទ្រូង ផ្ងារបាតចេញមកខាងក្រោម ដូចដៃឆ្វេងដែរ ហើយរូបវិស្ណុធំនេះ មានពាក់គ្រឿងអលង្ការ កងដៃ កងជើង និងក្បាលមានពាក់មកុដ។ រូបនេះបើយើងមើលមួយភ្លែត ហាក់បីដូចរូបស្ត្រី រួមទាំងមានកាយវិការលើកដៃផ្ងារ មួយលើកទៅលើមួយលើកទៅក្រោម និងលើកជើងម្ខាងទៀត ដូចជាកាយវិការអប្សរារាំលើកជើងយ៉ាងដូច្នោះ តើរូបនេះ តំណាងឲ្យអ្នកណា? រូបនេះតំណាងឲ្យព្រះវិស្ណុ ព្រោះដៃលាបាតដៃរាំនៅលើដើមទ្រូងនោះ គឺបាន

*បង្ហាញប្រាប់រឿងក្នុងបាតដៃ ចង្អុលបាតដៃចុះក្រោម តំណាងឲ្យរឿងក្នុងអតីតកាល របស់អច្ឆរមាតា ដែលនៅកប់ក្រោមដី គឺក្នុងភក់ក្នុងទឹក ដែលពុំមាននរណាដឹងរឿងគាត់ រីឯបាតដៃផ្ងារចង្អុលទៅលើ តំណាងឲ្យ រឿងរបស់គាត់ទៅអនាគត នឹងបានរួចផុតពីអំណាចឃុំរបស់យក្ស គឺមានន័យថា រឿងពិតរបស់គាត់ ដែលធ្លាប់តែផ្កាប់ចុះពុំមាននរណាដឹង ឥឡូវនេះ ត្រូវបានផ្ងារឡើងបើកបង្ហាញក្នុងលោកទាំង៦ ឲ្យបានដឹងពីរឿងពិតនេះ។ ដៃពីរទៀត ដៃមួយកាន់ស័ង្ខ ដៃមួយទៀតកាន់ដុំមូល អត្ថន័យដូចការពន្យល់ខាងលើ ខាងឆ្វេងដៃគាត់មានអប្សរាតូចមួយកំពុងហោះ មានន័យថា អច្ឆរមាតាត្បិតតែរឿងគាត់ពុំមាននរណាដឹង (រូបតូច) គាត់អាចអណ្ដែតទៅខាងលើបានហើយ តែមិនទាន់រួចផុតពីក្បាំង ដែលមានយក្សលេបខ្លួននាគទាំងសង្ខាង មានន័យថា រូបដែលស្ថិតក្នុងក្បាំងទាំងនេះ គឺនៅក្នុងអំណាចឃុំរបស់យក្សនៅឡើយ។*

*៥/.រូបនៅក្នុងជាន់ទីប្រាំនេះ តើគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?*

***ក/.**រូបកណ្ដាល ដែលនៅក្នុងទ្រនុងខ្នងនាគក្បាំង តំណាងឲ្យព្រះពោធិសត្វលោកេស្វរៈ ឬព្រះវិស្ណុ ដែលការប្រឹងប្រែង តស៊ូ ព្យាយាម តាំងតែពីរូបតូចជាប់នៅក្នុងសីមាសសរខាងក្រោមនោះ នៅទីបំផុត ការព្យាយាមរបស់គាត់ អាចឲ្យគាត់លើកអ្នកទាំងពីរ ដែលជាប់ក្នុងអំណាចឃុំរបស់យក្សឲ្យបានឡើងផុតពីអំណាចឃុំនេះ។ នៅខាងក្រោយបល្ល័ង្ក មាននិមិត្តរូបជារាងក្បាលនាគ ន័យទីមួយគឺគាត់ជាពូជពង្សរបស់ព្រះនាងនាគ ន័យទីពីរ ព្រះពោធិសត្វអង្គនេះ ទៀងតែនឹងបានត្រាស់ដឹងជាព្រះពុទ្ធមួយអង្គ ទៅអនាគតជាតិ (មើលរូបទី៤២)។*

***ខ/.**រូបក្នុងទ្រនុងខ្នងនាគពីខាងឆ្វេងខាងលើ តំណាងឲ្យព្រះថោង ឥសីកម្ពុ កៅណ្ឌិន ហ៊ុនទៀន....(ការពន្យល់រូបទី១២ និងរូបទី៤៤) ព្រោះគាត់ត្រូវបានព្យួរទោស តាំងពីអតីតកាលមកហើយៗក្នុងពេលនេះ គាត់ត្រូវរួចពីការព្យួរទោសនេះ។*

***គ/.**រូបខាងឆ្វេងដៃខាងក្រោមក្នុងទ្រនុងខ្នងនាគ តំណាងឲ្យអច្ឆរមាតាមហានគរ ដែលលោកបានរួចចេញពីឃុំ តាំងពីសោទ្វារដំបូងក្នុងសមុទ្រទឹកដោះ រហូតមកទល់នឹងក្នុងរូបនេះ បានរួចផុតពីការឃុំរបស់យក្សហើយ តែពួកគាត់ពុំទាន់អាចរីកធំនៅឡើយ បើមើលតាមរូបភាពនេះ ព្រោះហេតុអ្វី? ព្រោះកូននាគទូទាំងនគរដំរី ដែលបែកជាបី ពុំទាន់មាននរណាទទួលស្គាល់រឿងពិតរបស់ពួកគាត់នៅឡើយ ហើយភាគច្រើនពុំទាន់មាននរណាហៅគាត់ថា ម៉ែឡើយ ឋានៈម៉ែឪអាចឡើងរួច លុះត្រា*

តែកូនដឹងគុណ ព្រមទទួលស្គាល់ការពិតរួចហៅ តែបើមានកូនរាប់សិបលាននាក់ ហើយកូនពុំព្រម ហៅថាម៉ែឱ៊ឋាន:នោះ ពុំអាចឡើងរួចឡើយ។

**ឃ**/.រូបពីខាងស្ដាំ រូបកណ្ដាល បើយើងមើលតាមឥរិយាបថរូប គឺមិនខុសពីរូបខាងឆ្វេងឡើយ ឯអត្ថន័យរូបវិញ ក៍ប្រហាក់ប្រហែលគ្នា គ្រាន់តែមួយនៅខាងឆ្វេង មួយនៅខាងស្ដាំតែប៉ុណ្ណោះ មួយតំណាងអតីត មួយទៀតតំណាងឲ្យបច្ចុប្បន្ន មានន័យថា **ក**នៅខាងដើម និង**អ**នៅខាងចុង (មើលការពន្យល់ព្យញ្ជនៈ)។

បង្រួមសេចក្ដីមកការបកពន្យល់ពីរូបទី៧២នេះ ទោះបីមានការខ្វះចន្លោះពុំបានគ្រប់គ្រាន់ ក៏ចាត់ទុកដូចកូនសោមួយ អាចចាក់បើកមេដែលមានច្រែះនិងស្និមជាយូរមកហើយនោះឲ្យរបើកឡើងបាន ហើយវាជាការងាយស្រួលក្នុងការទៅទស្សនាប្រាសាទដើម្បីធ្វើការសិក្សាស្រាវជ្រាវ។

## ៧៤/.រូបភាពទី៧៤រូបផ្ដែរកូរសមុទ្រទឹកដោះនៅផ្ដែរ(ប្រាសាទទន្លេបាត់ទី)



រូបផ្ដែរនេះសព្វថ្ងៃបានធ្លាក់ជ្រុះមកខាងក្រោម ហើយបានទុកនៅពីខាងមុខផ្លូវចូលប្រាសាទ មើលទៅគួរឲ្យសង្វេគណាស់ ដែលពីមុនផ្ទាំងផ្ដែរនេះបានទទួលដោយសសរពេជ្រមួយគូ ហើយផ្ដែរនេះជាកែវមរតកដ៏មានតម្លៃដែលពុំអាចកាត់ថ្លៃបាន ព្រោះវាជារឿងនៅក្នុងចិត្តរបស់អច្ឆរមាតាឥឡូវត្រូវធ្លាក់មកដីដោយរងការបំផ្លាញពីធម្មជាតិនិងសង្គ្រាម។ តើផ្ដែររឿងកូរសមុទ្រទឹកដោះនេះ ខុសគ្នាពីរឿងកូរសមុទ្រទឹកដោះនៅប្រាសាទដទៃឬ? ក្នុងរូបផ្ដែរនេះចែករូបជាបួនថ្នាក់ហើយចែកជាបីចំណែក ចំណែកខាងក្បាល ចំណែកកណ្ដាលនិងចំណែកខាងកន្ទុយ។

ក/.ថ្នាក់ជាន់ទីមួយខាងក្រោមត្រង់កណ្ដាល មានរូបអណ្ដើកមួយនៅស្មើនឹងជើងអ្នកឈរ ហើយនៅពីក្រោយអណ្ដើកនោះមានរូបមនុស្សពាក់កណ្ដាលខ្លួន តើអណ្ដើកតំណាងឲ្យអ្វី? មនុស្សពាក់កណ្ដាលខ្លួននោះតំណាងឲ្យអ្វី? អណ្ដើកតំណាងឲ្យឧបាទានក្ខន្ធប្រាំ (មើលការពន្យល់ក្នុងភាគមួយ) មនុស្សនៅពីក្រោយអណ្ដើកតំណាងឲ្យកូននាគគឺព្រះវិស្ណុ ដែលត្រូវចុះមកក្នុងសមុទ្រទឹកដោះស្វែងរកដំណក់ទឹកដោះដំបូងដែលជាទឹកអម្រិត (មិនចេះស្លាប់) គឺមានអាយុរាប់ពាន់ឆ្នាំហើយដែលដំណក់ទឹកដោះនេះបានបង្កើតពូជពង្សខ្មែរបន្តគ្នា។

ខ/.ថ្នាក់ជាន់ទីពីរត្រង់រូបកណ្ដាល មានរូបខ្លួននាគព័ទ្ធជុំវិញដងស្នូលសម្រាប់បង្វិលកូរ មានមនុស្សខាងឆ្វេងឈរទាញខាងកន្ទុយ ឯខាងស្ដាំឈរទាញខាងក្បាល នៅខាងក្រោមក្បាលនាគមានមនុស្សតូចម្នាក់អង្គុយបញ្ឈរជង្គង់នៅលើផ្កាឈូក កំពុងទប់ក្បាលនាគកុំឲ្យអ្នកទាំងសង្ខាងទាញកូររួច។ តើរូបទាំងអស់នេះតំណាងឲ្យអ្វី? ហេតុអ្វីក្នុងរូបនេះឥតមានយក្សក្បាល១០ចាប់ខាងក្បាលនាគ ហនុមានចាប់ខាងកន្ទុយដូចរូបកូរសមុទ្រទឹកដោះនៅថែវអង្គរវត្ត?

១/.ស្នូលកណ្ដាលនិមិត្តរូបតំណាងឲ្យការបញ្ចប់នៅពៀរវេរា រវាងអ្នកទាំងសង្ខាងព្រោះរូបកំពុងទាញខាងក្បាលតំណាងឲ្យអ្នកចាប់មាតានាគយកទៅដាក់ឃុំ អ្នកទាញខាងចុងកន្ទុយតំណាងឲ្យអ្នកចង់ជួយព្រះមាតានាគឲ្យរួចពីឃុំ តែការប្រទាញនេះត្រូវប្រើរយពេលអស់ជាង ពីរពាន់ឆ្នាំកន្លងមកហើយ។

២/.ក្រោយមកមានជីក្រែង ដែលត្រូវឡើងចេញពីភក់ ពីទឹកដើម្បីបញ្ចប់នូវពៀរនេះ (មើលការពន្យល់ពាក្យជីសូរ និងជីក្រែងស្ពានកំពុងក្ដីភាគ២)។ ហើយជីក្រែងនេះ (ជីក្រែង ជីសូរ ព្រះវិស្ណុ...) គឺរូបដែលអង្គុយលើផ្កាឈូក ដែលកំពុងយកដៃទៅទប់ក្បាលនាគ (មើលរូប) ឈប់ឲ្យអ្នកទាំងសង្ខាងទាញកូររួចទៀត ព្រោះបើពុំមានព្រះវិស្ណុ ឬជីក្រែងទៅធ្វើអាជ្ញាកណ្ដាលទេ រឿងកំពុងក្ដីក្ដាំនេះ (ស្ពានកំពុងក្ដី) មិនអាចចប់ដោយគ្មានហេតុបានឡើយ។ ពេលនេះទុក្ខវេទនារបស់អច្ឆរមាតាមហានគរ ចាប់ផ្ដើមធូរស្រាលបន្តិចម្ដងៗ ព្រោះនិមិត្តរូបនាគដែលតំណាងឲ្យគាត់នោះ គេឈប់ចាប់ទាញគាត់យកទៅដាក់ឃុំក្នុងសមុទ្រទឹកដោះទៀតហើយ (មើលការពន្យល់ក្នុងភាគ១)។

**គ**.ថ្នាក់ជាន់ទីបីត្រង់ចំណុចកណ្តាល មានរូបព្រះវិស្ណុឱបបង្គោលស្នូលមានដៃបួន និងមានរូបមួយទៀត កំពុងសំយ៉ុងក្បាលចុះមកខាងក្រោម នៅពីសង្ខាងព្រះវិស្ណុគឺមានសត្វករវិកជាជួរ តើរូបទាំងអស់នេះ តំណាងឲ្យអ្វី?

១/.រូបដៃបួនកំពុងឱបបង្គោលតំណាងឲ្យព្រះវិស្ណុ ដែលចុះមកស្រង់រឿងអច្ឆរមាតាមហានគរនៅក្នុងសមុទ្រទឹកដោះ ក្នុងការស្រង់នោះទៀតសោត ពេលដែលបានដឹងរឿងហើយ គឺលំបាកនឹងយកមកផ្សព្វផ្សាយឲ្យគេជឿណាស់ នេះបើយើងមើលតាមឥរិយាបថ ដែលគាត់ប្រឹងឱបរឿងឡើងតាមបង្គោលស្នូលនេះ។ ពីមុនយើងធ្លាប់តែឃើញគាត់ក្នុងឥរិយាបថដេក ដឹកនាំអច្ឆរមាតាចេញពីគុក (វិស្ណុដេក) មើលទៅហាក់ដូចជាធម្មតា បើមើលដោយពុំបានគិតពិចារណា ឥឡូវដូនតាគាត់ឆ្លាក់ឲ្យយើងមើលសកម្មភាពតោងបង្គោលនាំរឿងឡើងមកខាងលើ ទើបយើងឃើញថាមានការលំបាក។ ព្រោះបើមើលក្នុងរូបនេះ គាត់ឱបរឿងមាតាផងយឹតយោងខ្លួនឯងផង ដោយមានតែជើងមួយចំហៀងគាប នឹងដៃមួយចំហៀងឱបបង្គោលតោងឡើង ចំណែកឯដៃទាំងពីរទៀត ជាប់កាន់វត្ថុផ្សេងៗពុំអាចជួយតោងបានឡើយ។ ហើយជាន់ទីបីនេះ ក៏ជាចំណុចផ្ចិតគឺជាចំណុចកណ្តាលក្នុងមង្គលទី៣ ដែលខ្លួនត្រូវដេក ឬឱបរឿងឡើង ហើយក៏ជាចំណុចបំបែកខ្នែងដើម្បីរើកម៉ែឪ យកទៅដាក់លើកំពូលព្រះវិហារវិញ (មើលការពន្យល់វិស្ណុដេក ឬផ្ទុំរូបមុន)។

២/.រូបសំយុងក្បាលចុះនៅខាងឆ្វេងដៃនោះ ក៏តំណាងឲ្យព្រះវិស្ណុដែរ តែរូបនេះមានន័យបង្កប់ពីរយ៉ាង។

**អត្ថន័យទី១**គាត់ត្រូវទម្លាក់ខ្លួនចុះមកក្នុងសមុទ្រទឹកដោះ ដើម្បីជ្រាវរករឿងពិតរបស់អច្ឆរមាតាដែលកំពុងរងទុក្ខ ព្រោះរឿងនេះបានរលុបបាត់ដានស្នាមអស់ទៅហើយ (មើលប្រស្នាលុបដានសាដាន លក់ដានក្នុងមង្គល៣ភាគ២)។

**អត្ថន័យទី២**តំណាងឲ្យរូបព្រះវិស្ណុងនេះ ពេលដែលបាននាំរឿងមកដល់ចំណុចផ្ចិត ឬចំណុចកណ្តាលនេះ ត្រូវយក្សរុញច្រានគាត់ទម្លាក់ពីលើ (មើលការពន្យល់រូបទី៦១) តែដោយអំណាចបុណ្យរបស់គាត់នៅមាន ជីវិតនេះមិនទាន់បែកធ្លាយទេ គាត់អាចនៅជួយស្រង់ប្រស់ព្រះម៉ែឪជាបន្តទៅទៀត ព្រោះភារកិច្ចនាំរឿងចេញនេះនៅមិនទាន់ចប់នៅឡើយ។

៣/.សត្វករវិកសង្វាង តំណាងឲ្យការផ្សព្វផ្សាយមនោគមវិជ្ជាសណ្ដំរបស់បរទេស សង្កត់អ្នកខាងក្រោមមិនឲ្យដឹងការពិត (មើលការពន្យល់សត្វករវិករូបទី១ និងរូបទី២)។

ឃ/.ថ្នាក់ជាន់ទីបួនចំណុចកណ្ដាលមានរូបនៅកណ្ដាល នៅខាងឆ្វេងដៃនិងខាងស្ដាំដៃមានរូបមនុស្សពីរនាក់នៅជាប់ក្នុងរង្វង់សីមា ហើយបន្ទាប់ពីខាងឆ្វេងដៃរូបក្នុងសីមា មានរូបអង្គុយលើបន្ទាត់កំពុងលើកដៃសំពះ និងរូបឈរជ្រែងបែងភាគដៃបួន។ នៅខាងស្ដាំដៃរូបជាប់ក្នុងសីមាក៏មានរូបអង្គុយលើបន្ទាត់ កំពុងលើកដៃសំពះដូចខាងឆ្វេងដែរ ហើយនៅខាងចុងមានរូបមួយស្ថិតក្នុងឥរិយាបថហោះ កំពុងទម្លាក់ខ្លួនចុះមកខាងក្រោម ដោយនៅក្នុងដៃរបស់រូបមានកាន់ផ្កាឈូកមួយទងផង។ តើរូបទាំងអស់នេះ មានអត្ថន័យដូចម្ដេច?

១/.រូបកណ្ដាលអង្គុយលើដងស្នូលដែលមានរាងបល្ល័ង្កជាផ្កាឈូកនោះ គឺការខំប្រឹងឡើងរបស់ព្រះវិស្ណុពីខាងក្រោមមកខាងលើ ពេលមកដល់ចំណុចនេះគាត់បានក្លាយជាព្រះព្រហ្ម ដោយគុណធម៌របស់គាត់គ្រប់គ្រាន់ អាចបំឡែងរូបគាត់ឲ្យទៅជាព្រហ្មបាន ហើយព្រហ្មនោះទៀតសោតគឺជាកូននាគ ដែលចុះទៅស្រង់អច្ឆរមាតា កប់នៅខាងក្រោមភក់ (អាថ៌កំបាំងឈ្មោះថ្មភក់)។ ទីបំផុតនៃសេចក្ដីព្យាយាមបានមកដល់ចំណុចទ្វារទីបួននេះ បានស្ថាបនាឲ្យគាត់ក្លាយជាព្រះព្រហ្ម (និមិត្តរូប) ហើយរូបព្រហ្មបានបែងភាគដៃបួន ដៃពីរខាងក្រោមបិតនៅក្នុងឥរិយាបថសមាធិ ឯដៃពីខាងលើកំពុងព្យាយាមបើកគម្រប នៅសល់ចុងក្រោយដែលគ្របពីលើ (មើលការពន្យល់រូបទី៧២) ឯរូបអង្គុយលើបល្ល័ង្កផ្កាឈូក តំណាងឲ្យពោធិសត្វកំពុងសន្សំបារមី។

២/.រូបសង្វាងស្ថិតក្នុងរង្វង់សីមា មួយតំណាងឲ្យអច្ឆរមាតាមហានគរមួយទៀតតំណាងឲ្យបិតាមហានគរ ដែលអ្នកទាំងពីសុទ្ធតែជាប់ក្នុងឃុំដូចគ្នា គ្រាន់តែបិតានៅក្រៅឃុំគឺព្យួរទោស ឯមាតាវិញសុខចិត្តទទួលទោសទាំងពីររបស់ស្វាមីនិងកូន (មើលការពន្យល់ក្នុងរូបទី១២)។

៣/.រូបអង្គុយសង្វាងកំពុងលើកដៃសំពះ គឺតំណាងឲ្យមាតាទាំង១២ ដែលរង់ចាំកូនយកកែវភ្នែកមកឲ្យខ្លួនវិញ ព្រោះពួកខ្លួនត្រូវបាត់បង់កែវភ្នែក ដោយហេតុបាបកម្មចាស់តាមឲ្យផល (មើលរឿងពុទ្ធិសែននាងកង្រី) ឥឡូវពួកគាត់មានក្ដីសង្ឃឹមថានឹងមានកូននាគណាមួយ ដែលសល់ពីពួកគាត់ហែកស៊ី គេនឹងយកកែវភ្នែកមកឲ្យពួកគាត់វិញជាពុំខាន។ ចំណែកឯរូបឈរជ្រែងមានដៃបែកជា

បួន មិនដឹងជារូបយក្ស ឬព្រះវិស្ណុឡើយ ព្រោះមើលពុំច្បាស់ដោយសភាពមុខរបស់រូប បានបាក់បែកអស់ហើយ។

៤/.រូបទេវតាដែលកំពុងហោះចុះមកក្រោម កាន់ផ្កាឈូកក្រពុំដ៏ធំមួយទងនៅក្នុងដៃនោះ។

**ទី១តំណាងឲ្យ**គណបក្សដែលមាននិមិត្តរូបដែលមានសញ្ញាសំគាល់រូបទេវតា (គណបក្សប្រជាជន)។

**ទី២តំណាងឲ្យ**អ្នកនាំយកផ្កាឈូក (និមិត្តរូប) មកឲ្យព្រះវិស្ណុដែលនៅជាប់ខាងក្នុងសមុទ្រទឹកដោះ ឲ្យលោកបានដឹងថា រូបលោកគឺជាពោធិសត្វលោកេស្វរៈ ដែលក្នុងជាតិនេះលោកត្រូវបំពេញបារមីគឺអធិដ្ឋានបរមត្ថបារមី គឺអធិដ្ឋានជីវិតឲ្យទៅយក្ស ដើម្បីឲ្យយក្សដោះលែងអច្ឆរមាតាឈប់យកគាត់ធ្វើជាខ្សែទាញបន្តទៅទៀត។ បើគ្មានទេវតាមកដាស់តឿនពន្យល់ដល់គាត់ទេនោះ (សុបិន្ត) គាត់ពុំអាចបំពេញនៅគុណធម៌គឺបរមត្ថបារមីនេះបានឡើយ ព្រោះធម៌ទាំងឡាយអាចកើតមានឡើងដោយមានហេតុនឹងបច្ច័យនៃធម៌ បើពុំមានហេតុនឹងបច្ច័យទេ ចក្រគឺវដ្តសង្សារនេះពុំអាចវិលទៅមុខបានឡើយ បើវដ្តសង្សារពុំមានការសន្សំនៅគុណធម៌ គឺបារមីក៏ពុំមានដែរ (មើលការបរិនិព្វានរបស់ព្រះអរហន្តទាំងឡាយគឺវដ្តសង្សារ ឈប់វិលទៅមុខទៀតហើយ )។

សរុបសេចក្ដីមកការបកពន្យល់ក្នុងរូបភាពនេះ គ្រាន់តែជាការប្រៀបធៀបរូបកូរសមុទ្រទឹកដោះក្នុងប្រាសាទមួយ ទៅប្រាសាទមួយទៀត ដែលមានសកម្មភាពរូបផ្សេងៗគ្នានោះ ព្រោះដូនតាគាត់ចង់ឲ្យកូននាគឆ្ងល់ថា ឈ្មោះរូបកូរសមុទ្រទឹកដោះដូចគ្នា ហេតុអ្វីបានជាសកម្មភាពរូបផ្សេងៗគ្នាទៅវិញ?

## ៧៥/.រូបភាពទី៧៦រូបក្នុងរង្វង់បេះដូង(មិនដឹងប្រភព)



តើរូបក្នុងរង្វង់ជារាងស្លឹកពោធិ ឬស្លឹកម្លូនេះ តើដូនតាយើងគាត់ចង់និយាយប្រាប់យើងពីរឿងអ្វី?

**ក**/.រង្វង់ព័ទ្ធពីខាងក្រៅដែលមានរាងជាបេះដូង ស្លឹកពោធិ ស្លឹកម្លូ....តំណាងឲ្យអ្វី? បើចង់រើកញែករូបរង្វង់នេះ យើងត្រូវមើលការបកពន្យល់ពីល្បែងចាក់ទឹកដូងទាំង២បែប ព្រោះរាងរូបរង្វង់នេះព័ទ្ធពីខាងក្រៅ ចំណែកឯរូបរឿងនៅពីខាងក្នុងរង្វង់នេះ ដូចជារឿងក្នុងចិត្ត ឬក្នុងបេះដូង ដែលបានប្រព្រឹត្តនូវកម្មទាំងកម្មខ្មៅ ទាំកម្មស(កម្ម = អំពើ) អំពើទាំងនេះ តែយកទៅលាក់ទុកក្នុងចិត្ត (ហទយៈ) គឺក្នុងបេះដូងនេះឯង។ ក្នុងបេះដូងដ៏ធំនេះ គឺមានរូបទាំងអស់៥ រូបពីរជាសត្វឯរូបបីទៀតជាមនុស្ស តើរូបទាំងនេះ ព្រឹទ្ធដូនតាយើងគាត់ចង់និយាយប្រាប់យើងជាកូននាគពីអ្វីខ្លះ? ចង់ដឹងពីរឿងម៉ែ ទាល់តែចាក់ទឹកក្នុងបេះដូង (ទឹកចិត្ត) ចេញពីទ្រូងម៉ែ ទើបដឹងរឿងរបស់ពួកគាត់ ព្រោះរឿងរបស់ពួកគាត់បានលាក់ទុកនៅក្នុងចិត្ត ក្នុងបេះដូង ក្នុងទ្រូង (មើលការពន្យល់ក្នុងចាក់ទឹកដូងភាគ១)។

**ខ**/.រូបកណ្តាលតំណាងឲ្យព្រះវិស្ណុ ព្រះឥសូរ ព្រះពោធិសត្វលោកេស្វរៈ....ដៃស្តាំខាងក្រោមរបស់គាត់កាន់ច្រត់ទប់ខ្លួន ដៃស្តាំខាងលើកាន់ខ្សែផ្តាំសម្រាប់ភាវនារម្ងាប់ចិត្ត ដៃឆ្វេងខាងក្រោមឱបដុំមូលផ្ទិបទ្រូង ដៃឆ្វេងខាងលើលើកឡើងទៅលើជាប់នឹងរង្វង់។ ចំណែកជើងខាងឆ្វេង ជាន់ស៊ប់នៅលើខ្នងគោ ឯជើងខាងស្តាំវិញ ដាក់បន្តើរពីលើ គឺជាន់មិនទាន់ស៊ប់ឡើយ ក្នុងសកម្មភាពរបស់រូបនេះ បានបង្ហាញប្រាប់ថា គាត់បានងើបឈរហើយ ទោះបីជើងទាំងពីររបស់គាន់ មិនទាន់ឈរស៊ប់ក៏ដោយ ក៏គាត់ប្រឹងទប់ច្រត់ឈរឡើង នាំរឿងក្នុងបេះដូងនេះយកចេញទៅខាងក្រៅ ដើម្បីឲ្យកូននាគអ្នកទទួលមរតកម៉ែបានដឹងរឿងក្នុងបេះដូងព្រះម៉ែ (មើលចាក់ទឹកដូងភាគ១)។

**គ**/.រូបសត្វគោខាងក្រោមតំណាងឲ្យសេចក្តីព្យាយាម តែក្នុងរូបនេះគោដេកផងងើយមើលអ្នកឈរនៅពីខាងលើផង មានន័យថាព្រះវិស្ណុខាងលើទោះបីជាក្រោកឈរបាន តែសេចក្តីព្យាយាមរបស់គាត់ពុំទាន់អាចងើបឈរបានឡើយ (ក្នុងសីល សមាធិ បញ្ញា)។ ដូចនេះក្នុងការដឹកនាំរឿងអច្ឆរមាតាពីខាងក្នុងបេះដូងព្រះម៉ែគឺពុំអាចមានកម្លាំងគ្រប់គ្រាន់នាំរឿងចេញ ទៅផ្សព្វផ្សាយខាងក្រៅបានឡើយ ព្រោះកម្លាំងព្យាយាមរបស់គាត់មិនទាន់គ្រប់គ្រាន់។

**ឃ**/.រូបស្ត្រីដែលនៅពីខាងក្រោយ តំណាងឲ្យអ្នកដែលជួយជាកម្លាំងដល់គាត់ គឺភរិយា ដៃរបស់ស្ត្រីនោះម្ខាងឱបកូនឯដៃម្ខាងទៀត កាន់ដំបងគោះគោឲ្យក្រោកឡើង។ មានន័យថាស្ត្រីនេះមានកូនម្នាក់ក្នុងបន្ទុក ហើយភារៈកិច្ចរបស់គាត់ គឺជួយដាស់សេចក្តីព្យាយាមរបស់ព្រះវិស្ណុ (គោ) ឲ្យប្រឹងក្រោកឡើង ជួយនាំរឿងព្រះម៉ែចេញ។ ឯកូនដែលឱបក្នុងដៃ ពុំបានបង្ហាញពីសកម្មភាពអ្វីឲ្យដឹងបានឡើយ ប្រហែលជាគេនៅក្មេង ឬតូចពេកមិនទាន់អាចជួយបាន។

**ង**/.ស្វាក៏តំណាងឲ្យកូននាគដែលត្រូវជួយនាំរឿងដែរ តែស្វាក្នុងរូនេះគឺកំពុងរវល់ហូបអាហារ គឺមានន័យថាគេកំពុងជាប់រវល់ក្នុងកិច្ចការងារចិញ្ចឹមជីវិត។ ដោយការស្វះស្វែងរកទ្រព្យចិញ្ចឹមគ្រួសារ ក្នុងរូបនេះ ស្វាមិនទាន់ក្រោកឡើងឡើយ គឺនៅអង្គុយហើយស្វានេះទៀតសោត គ្មានគ្រឿងអលង្ការទេតំណាងឲ្យអ្នកពុំសម្បូរយសសក្តិ និងទ្រព្យសម្បត្តិឡើយ។

សរុបសេចក្តីមកការពន្យល់ដោយសង្ខេបនេះ ទោះបីក្នុងផ្ទាំងរង្វង់បេះដូងនេះមានរូបភាពតិចក៏ដោយ ប៉ុន្តែសកម្មភាពបានពន្យល់ពីអត្ថន័យគ្រប់គ្រាន់ អាចឲ្យយើងពិនិត្យមើលអត្ថន័យក្នុងរូប

ដែលប្រាប់ពីហេតុនៅក្នុងបេះដូងទាំងមូលនេះបាន ហើយអាចឲ្យយើងដឹងពីការឃើតឃូរក្នុងការនាំរឿងអច្ឆរមាតាចេញមកខាងក្រៅ ប្រាប់ដល់កូននាគប្រុសស្រី។

## ៧៦/.រូបភាពទី៧៦រូបយោនីមានស្នឹងចុកបិទ(នៅប្រាសាទបាណន់)



តើរូបយោនីដែលនៅសេសសល់នេះ គាត់ចង់ប្រាប់យើងពីរឿងអ្វី? រូបយោនីតំណាងឲ្យមាតុភូមិ (ទ្វារមាសរបស់ស្ត្រី) នៅប្រាសាទបាណន់នេះ បើយើងមើលសំណល់ ដែលនៅសេសសល់ពីការដាប់បំផ្លាញ យើងអាចយល់ពីអត្ថន័យរូប ដែលព្រឹទ្ធដូនតាលោកបានទុកប្រស្នារូបឲ្យយើងឆ្ងល់ថា ហេតុអ្វីបានជារូបយោនីនេះ មានស្នឹងមួយចុកពីខាងលើជាប់? ដែលនៅពីខាងលើក្បាលស្នឹងមានរូបមនុស្សម្នាក់ ឈរសង្កត់ពីលើថែមទៀត តើឲ្យអច្ឆរមាតាដែលនៅទ្រពីខាងក្រោមយោនីនោះ លោកចេញមកម្ដេចរួច (មើលរូបទី៦)? ប្រស្នាក្នុងរូបនេះ បើយើងមើលរួចពិចារណាត្រិះរិះគិត យើងកាន់តែមានក្ដីអាណិតអាសូរដល់លោកអ្នកមានគុណ គឺមាតាបិតាបច្ចុប្បន្ន និងអច្ឆរមាតាពីអតីត ដែលលោកខិតខំបង្កើតនគរម៉ែនេះទុក ទីបំផុតបានត្រឹមតែទូលភោទរបស់ខ្លួន គឺចាត់ទុកថានៅគ្រាន់បើ។ តែក្នុងរូបនេះ ទោសរបស់គាត់ពុំមែនតែប៉ុណ្ណឹងទេ គឺគេបោះស្នឹង (ប្រាសាទស្នឹង) ចុកបិទរន្ធយោនីនោះថែម

ទៀត ដោយខ្លាចគាត់លួចចេញមកខាងក្រៅ គេថែមមនុស្សម្នាក់ទៀត (បក្សពួកយក្ស) ឲ្យជាន់សង្កត់ពីលើក្បាលស្នឹង។ នៅលើម្រាមជើងរូបដែលឈរនៅលើក្បាលស្នឹង រូបខ្លះមានកងសោចាក់ជាប់គ្រប់ម្រាមទាំងប្រាំ មានន័យថាមិនឲ្យរូបឈរនៅលើក្បាលស្នឹងដែលចុកបិទនេះ ដើរទៅណារួចឡើយ នេះជាហេតុដែលអច្ឆរមាតាឬបិសាចពស់ លោកលែងចេញមកខាងក្រៅ ដើម្បីជួបនឹងកូនបានទៀត។ ចំណែកមាតាបិតាបច្ចុប្បន្នវិញ លោកមើលការបកពន្យល់នេះហើយ លោកគួរតែតក់ស្លុតរួចភ្ញាក់ស្មារតីឡើង កុំភ្លេចធ្វើទីពឹងឲ្យខ្លួនឯង ហើយរវល់តែធ្វើទីពឹងឲ្យអ្នកដទៃ បើមិនដូច្នោះទេដំណើរផ្លូវគឺមិនខុសពីបុព្វដូនតាយើងឡើយ ត្រូវរងទុក្ខទោសក្នុងអបាយភូមិតែឯង រង់ចាំកូនឲ្យគេជួយគឺមានសង្ឃឹមតិចតួចណាស់ បើនិយាយពីកូនសព្វថ្ងៃនេះវិញ ភាគច្រើនគឺពួកគេលែងជឿកម្មឲ្យផលទៀតហើយ ព្រោះមនោគមវិបែបថ្មី (សំភារៈនិយម បច្ចេកវិជ្ជាសម័យថ្មី និងគ្រឿងញៀន) កំពុងលុកលុយពង្វក់ស្មារតីពួកគេ។

សរុបសេចក្ដីមករូបនេះត្បិតតែនៅសល់រាងហេតុតិចតួចអាចមើលយល់ តែវាមានសារសំខាន់ណាស់ សម្រាប់ឲ្យយើងជាកូននាគងាយមើលយល់ពីទម្ងន់ទុក្ខវេនា ដែលអច្ឆរមាតាកំពុងទទួលនូវបាបពីអតីតរបស់លោក ហើយក៏ជាប្រយោជន៍មួយជួយដាស់ស្មារតីកូននាគ ដែលកំពុងទទួលមរតកព្រះម៉ែឲ្យជួយថែទាំសំណល់កេរដែលនៅសល់ និងជួយឧទ្ទិសមហាកុសល (ឧទ្ទិសបុណ្យ) ជូនទៅឲ្យពួកគាត់។ ព្រះពុទ្ធសាសនាជាចំណែកកេរមរតកម៉ែមួយដ៏សំខាន់ ដែលព្រះមាតាមហានគរលោកបាននាំមកប្រតិស្ឋានទុកសម្រាប់គោរពបូជានិងសិក្សារៀនសូត្ររហូតមកដល់សព្វថ្ងៃ ដើម្បីទុកជាប្រយោជន៍ដល់កូននាគទាំងពីរភេទ (ឧត្តមភេទ ហីនភេទ) ហើយលោកសង្ឃឹមថា ពួកគេនឹងនឹកឃើញនៅឧបការគុណរបស់ពួកគាត់ហើយគេនឹងព្យាយាមជួយគាត់ (នេះជាហេតុដែលព្រះពុទ្ធសាសនាមកប្រតិស្ឋានក្នុងមាតុភូមិ) ។

## ៧៧/.រូបភាពទី៧៧រូបលើជញ្ជាំង(ពុំដឹងប្រភព)

រូបភាពចម្លាក់នេះ បើយើងមើលមួយភ្លែតហាក់បីដូចជាធម្មតា តែបើយើងមើលឲ្យយូរបន្តិចទើបគួរឲ្យអាណិតសង្វេគគាត់ណាស់ ព្រោះហេតុអ្វី? មនុស្សម្នាក់ដែលត្រូវផ្លែព្រួញដោតពីលើខ្លួនច្រើនម្ល៉ឹងៗ តើគាត់មានការឈឺចាប់យ៉ាងណាទៅ? តើនៅក្នុងរូបនេះ តំណាងឲ្យអ្វីខ្លះ? ក្នុងរូបដែលមាននេះ ចែកចេញជាបួនជាន់ ជាន់ទីមួយ ទីពីរ ទីបី និងជាន់ទីបួន។

ក/.រូបខាងក្រោមបង្ហាញពីរូបស្ត្រីមួយជួរកំពុងអង្គុយកាន់ដងក្លស់ និងដងថ្នោលដោលទៅលើ គឺតំណាងឲ្យ (មេនឹងម៉ែ) អ្នកបាំងក្លស់ និងជួយជ្រោងមនុស្សនៅខាងលើ។



ខ/.មនុស្សកំពុងអង្គុយបញ្ឈរជង្គង់លើកដៃសំពះ តំណាងឲ្យអ្នកអង្វរចំពោះអ្នកដែលដេកនោះ ឲ្យប្រឹងក្រោកឈរតស៊ូព្យាយាមបន្តទៅទៀត ដើម្បីស្រង់រឿងព្រះមេនិងព្រះម៉ែខាងក្រោម យកទៅបង្ហាញកូននាគខាងលើ ឲ្យពួកគេបានដឹង។

គ/.រូបដេកដែលត្រូវដោលទ្រពីខាងក្រោមនោះ តំណាងឲ្យព្រះវិស្ណុដេក តែព្រះវិស្ណុដេកនេះខុសពីព្រះវិស្ណុមុនៗ ព្រោះហេតុអ្វី? រូបព្រះវិស្ណុមុនៗ បើយើងមើលដោយពុំបានគិតពិចារណា យើងនឹងពុំបាននឹកឃើញទុក្ខវេទនារបស់គាត់ក្នុងការនាំរឿងអច្ឆរមាតាចេញពីទីឃុំឡើយ។ ព្រោះខ្លួនត្រូវដេកផង វារលូនផង នាំព្រះមាតាចេញផង តើមានការលំបាកយ៉ាងណា? យើងគ្រាន់តែវារលូនម្នាក់ឯងលំបាកណាស់ទៅហើយ ចុះទម្រាំមានអូសស្ត្រីម្នាក់ចេញពីទីទាប យកទៅដាក់ទីខ្ពស់នោះ (ភ្នំព្រះវិហារ) តើមានការលំបាកយ៉ាងណា? នេះជាន័យដែលបង្កប់នៅក្នុងប្រស្នារូប។ ចុះចំណែកព្រះវិស្ណុធំនៅក្នុងរូបនេះវិញ ដូនតាគាត់បានប្រាប់បង្ហាញយើងពីសកម្មភាព ដែលដេកនៅលើទម្រថ្នោលដែលស្ត្រីខាងក្រោមដោលឡើង វាងាយនឹងធ្លាក់ចុះមកខាងក្រោមណាស់ តែដើម្បីបុព្វហេតុព្រះមេ និងព្រះម៉ែ គាត់សុខចិត្តដេកស៊ូទ្រាំលំបាក នៅលើទ្រនើរឈើដោលដែលយោលចុះយោលឡើង ទៅតាមកម្លាំងទប់របស់ស្ត្រីដែលកាន់នៅខាងក្រោម។ ហេតុតែរឿងព្រះម៉ែដែលបានកប់លុបអស់រយពេលរាប់ពាន់ឆ្នាំ

នេះ ធ្វើឲ្យគាត់លំបាកនឹងរកលំនឹងឬតឹកតាំង ដើម្បីពន្យល់កូននាគក្នុងសម័យនេះ ឲ្យគេជឿបាន ណាស់ ព្រោះរឿងរបស់អច្ឆរមាតាបានត្រូវគេលុបដាន សាដាន និងលក់ដានអស់ហើយ (មើលលុប ដាន សានដាន លក់ដានមង្គលពាភាគ២)។ នៅលើដងខ្លួនគាត់ពីខាងលើ មានផ្លែព្រួញដ៏ច្រើនបាន ដោតចាក់លើខ្លួនគាត់ តើផ្លែព្រួញទាំងនោះ តំណាងឲ្យអ្វី? ផ្លែព្រួញតំណាងឲ្យការឈឺចុកចាប់ ពេល ដែលត្រូវផ្លែព្រួញនោះដោតនៅលើសាច់ ផ្លែព្រួញមួយគឺឈឺចាប់មួយ បើផ្លែព្រួញដ៏ច្រើនយ៉ាងនេះ ដោតនៅលើខ្លួន តើគាត់ឈឺចាប់ពើតដូចម្ដេចទៅ? (មើលការពន្យល់ពីប្រាសាទគក់ទ្រូងនៅអង្គរវត្ត ភាគ២)។ ព្រោះតែបុព្វហេតុមេ និងម៉ែ គាត់សុខចិត្តដេកទ្រាំក្នុងការឈឺចុកចាប់គ្រប់បែបយ៉ាង ដើម្បី នាំរឿងទុក្ខវេទនារបស់អច្ឆរមាតា នាំយកចេញមកបង្ហាញឲ្យកូននាគទាំងពីភេទ បានដឹងពីសាវតា ពិតរបស់ខ្លួន ព្រោះព្រះម៉ែមហានគរ លោកឈឺចុកចាប់រងទុក្ខវេទនាជាងរាប់ពាន់ម៉ឺនសែនដង លើស គាត់ទៅទៀត ក្នុងសមុទ្រទឹកដោះខ្លួនឯង ដែលជាសមុទ្រគម្រង់ (មើលការពន្យល់ក្នុងភាគ២) ព្រោះ ហេតុតែតាំងខ្លួនជាម៉ែគេ (ស្គរតាំងម៉ែ មើលរូបពន្យល់មុនៗ)។

**ឃ/**.ចំណែកឯរូបមនុស្សដែលនៅខាងចុងជើងគាត់ ដៃម្ខាងកាន់ខែលនិងដៃម្ខាងទៀតកាន់ អាវុធ បើមើលតាមសកម្មភាពរូបនេះ ហាក់ដូចជាកំពុងលើអាវុធដែលនៅក្នុងដៃ យកមកចាក់ពីលើ ខ្លួនរបស់ព្រះវិស្ណុដេកនេះបន្ថែមទៀត ព្រោះរូបនេះត្រូវដាច់ត្រឹមនេះ ដូច្នេះរូបព្រះវិស្ណុដេកនេះគាត់ត្រូវ រងនូវការឈឺចាប់មួយថ្មីថែមទៀត។

សង្ខេបសេចក្ដីមកយើងអាចយល់បានថា រូបនេះពុំមែនជាសាកសពមនុស្សដេកស្លាប់ឡើយ ព្រោះមនុស្សស្លាប់គេតែងដាក់ក្នុងម្ឈូស ឬដំកល់នៅលើជើងថ្ករសម្រាប់បូជា គឺពុំមែនដាក់នៅលើ ឈើមនុស្សដោលពីខាងក្រោមដូច្នេះឡើយ។ សកម្មភាពរូបនេះ អាចអណ្ដែតនៅពីខាងលើថ្មោល ដែលដោលដោយព្រះមេ និងព្រះម៉ែបាននោះ ក៏ដោយសារគាត់បានបំពេញកាតព្វកិច្ចជាកូននាគ មាននូវកតញ្ញូ និងកតវេទីចំពោះអច្ឆរមាតាមហានគរ តែឥរិយាបថរបស់គាត់ហាក់ដូចជាមនុស្ស ស្លាប់ (មើលការពន្យល់ពីវិស្ណុដេក) គាត់សុខចិត្តដេកស្លាប់ឲ្យតែអាចប្រស់មាតាមហានគរឲ្យរស់ឡើង វិញ ក្នុងសន្ដានចិត្ត (បេះដូង) កូននាគប្រុសស្រី ដែលកំពុងទទួលមរតកព្រះម៉ែក្នុងបច្ចុប្បន្ននេះ។

# ៧៨/.រូបភាពទី៧៨រូបយក្សនិងទេវតានៅលើជើងទម្រ(សព្វថ្ងៃនៅសារមន្ទីរ)

នៅក្នុងរូបភាពនេះ មានរូបចម្លាក់ពីរផ្ទាំង។



១/. នៅលើបល្ល័ង្កមួយ មានយក្សក្បាល ១០បែងភាគដៃម្ខាង៨ ជាន់នៅលើរូបមនុស្ស មានក្បាល៤ (ព្រហ្ម) ហើយនៅជុំវិញយក្ស នោះ មានស្ត្រីនៅសល់ចំនួន៦នាក់ កំពុងឈរ នៅលើផ្កាឈូកជុំវិញ។

ក/.រូបភាពទីមួយ រូបយក្សនៅចំ កណ្តាលកំពុងឈរជើងឆ្វេងម្ខាង និងជើងស្តាំ លើកជាន់រូបព្រហ្មខាងក្រោមនោះ គឺតំណាង ឲ្យយក្ស ដែលបានចាប់មាតាយកទៅឃុំ (មើលការពន្យល់រូបទី១៩និងទី២០) គ្រាន់តែ ក្នុងរូបនេះ គំនិតគាត់ក្នុងការឆ្លាក់ជារូបក្បាល ព្រហ្ម សម្រាប់ឲ្យយើងចេះឆ្ងល់។ រីឯដៃម្ខាង៨ គឺតាងឲ្យទិសតូច៤ និងធំ៤ ព្រោះរឿងអាថិ កំបាំងនគរ បានលាក់ទុកនៅគ្រប់ទិសទាំង៨ ក្នុងមាតុភូមិនេះ ទាំងនៅក្នុងអតីតកន្លងមក ទាំងនៅក្នុងបច្ចុប្បន្ន ដែលជាតំណពីអតីត។ តាមពិតទិស មានរហូតដល់ទៅ១០ឯណោះ គឺ២ទៀតទិសខាងលើ និងទិសខាងក្រោម ហើយអាថិកំបាំងដែលលាក់ ទុកក្នុងទិសលើ និងទិសក្រោមនេះ ទាល់តែបុគ្គលមានឧបនិស្ស័យខ្ពស់ ទើបអាចដឹងនូវអាថិកំបាំង របស់គាត់បាន។ នៅក្នុងដៃរបស់យក្ស មានកូនក្មេងតូច១នៅគ្រប់បាតដៃ (ចូលមើលការពន្យល់ក្នុង រូបទី១៩ ទី២១ នឹងរូបនៅជញ្ជាំងប្រាសាទបន្ទាយឆ្មារ រូបភាពទី២៥ និងទី២៦)។ រូបយក្សដ៏ធំនេះ គឺ មានពាក់គ្រឿងអលង្ការ ហើយមានស្លៀកខោខើចខ្លីស្ទើរជិតដល់ក្រលៀនទៅហើយ ដែលឥទ្ធិពល ខោខើចខ្លីនេះ បានជះឥទ្ធិពលមកដល់ស្ត្រីខាងក្រោមឲ្យស្លៀកតាម។

ខ/.រូបភាពទីពីរ ក្នុងរូបភាពនេះ មានរូបស្ត្រីឈរលើផ្កាឈូកចំនួន៦នាក់ តែតាមពិតគឺមាន៧នាក់ ហើយស្ត្រីជាអច្ឆរាទាំង៧នាក់នេះ គឺតំណាងឲ្យទេពធីតាគ្រប់ថ្ងៃទាំង៧ ក្នុងមួយសប្ដាហ៍ ដែលបានហែក្បាលកបិលមហាព្រហ្មរាល់ៗឆ្នាំនោះឯង។ ទេពធីតាជាកូននោះ មានរហូតដល់១២នាក់ឯណោះ (មាតាទាំង១២) តែ១២នាក់នេះ មានតែ៧នាក់ទេ ហើយ៧នាក់នេះតែងបញ្ចាំគ្នាទៀត (មើលការពន្យល់ពីដូងខៃស៊ីក្នុងភាគ២) គឺមានតែម្នាក់ប៉ុណ្ណោះក្នុងមួយឆ្នាំ ដែលមកជង្ហៃ និងថែរក្សារំលឹកដល់គុណម៉ែឪរបស់ខ្លួនពីអតីត។ ស្ត្រីដែលឈរលើកជើងស្ដាំជាន់លើផ្កាឈូក ជើងខាងឆ្វេងស្លៀកខោខើចខ្លី ដៃមានកាន់ឧបករណ៍តំណាងឲ្យសំភារៈសម្រាប់ចិញ្ចឹមជីវិត ដៃម្ខាងទៀតលើកទ្រទៅលើ គឺតំណាងឲ្យស្ត្រីជាកូននាគដែលកំពុងទទួលឥទ្ធិពល ស្លៀកខោខើចខ្លីពីយក្ស ព្រោះយក្សមានសេនាគឺគ្រុឌៗនេះតំណាងឲ្យសៀម ដែលកំពុងនាំវប្បធម៌ស្លៀកខោខើចខ្លី ចូលមកលុបវប្បធម៌ស្លៀកសំពត់ក្បិន ស្លៀកហូល (ក្មេងស្រីសព្វថ្ងៃ)។ ព្រោះគ្រុឌនេះនៅគៀក ងាយនឹងផ្សព្វផ្សាយវប្បធម៌ស្លៀកពាក់នេះណាស់ តើក្នុងនាមយើងជាកូនព្រះនាងនាគបានដឹងពីការលុបដាន របស់អ្នកខាងក្រៅដែរឬទេ? ឯស្ត្រីដែលស្លៀកសំពត់នៅសល់ម្នាក់ នោះគឺតំណាងឲ្យស្ត្រីខ្មែរដែលនៅរក្សាប្រពៃណី កេរមរតកព្រះម៉ែ គឺនៅស្លៀកសំពត់ហូល ផាមួង....ជាសរសៃដែលបានកើតឡើងពីសំបុកនាង ដែលដង្កូវនាង (ព្រះនាងនាគ) សុខចិត្តដេកស្លាប់ក្នុងសំបុក (ឃុំក្នុងសីមា) ឲ្យគេស្ងោរក្នុងទឹកក្ដៅ (អបាយភូមិ) ដើម្បីឲ្យគេហូតយកសរសៃសូត្រទុកសម្រាប់រុំព័ទ្ធព័ន្ធនគរខ្លួន ដែលសរសៃសូត្រនេះ តំណាងឲ្យមហាពលិកម្មរបស់អច្ឆរមាតាមហានគរ ហេតុតែដើម្បីកូននាគប្រុសស្រី (គោមសំពត់ហូល តំណាងឲ្យស្រកានាគៗ ⇨ និមិត្តរូបអច្ឆរមាតា)។ សព្វថ្ងៃអាចារ្យតែងនាំគ្នាធ្វើតៗគ្នា ពិធីក្រុងពលីនៅក្នុងបុណ្យប្រពៃណីទំនៀមទម្លាប់ និងក្នុងមង្គលផ្សេងៗ គឺធ្វើដោយពុំដឹងពីសាវតាពិតរបស់ពិធីនេះឡើយ ពាក្យក្រុងពលីមានន័យថា កូននាគប្រុសស្រីត្រូវតែឧទ្ទិសនៅបុណ្យ គឺមហាកុសលជូនទៅអច្ឆរមាតានិងបិតា ដែលយក្សនិងគ្រុឌជាសេនា កំពុង**ក្រុង**ឃុំពួកគាត់ជាប់ (មើលការពន្យល់រូបពីទី១រហូតមក) ហើយពួកគាត់សង្ឃឹមថា នឹងមានកូននាគឧទ្ទិសបុណ្យឲ្យគាត់។ ដូច្នេះហើយទើបនៅក្នុងពិធីនេះ គេតែងរៀបដង្វាយ គឺគេយកពូជធញ្ញជាតិដូចជាស្រូវ សណ្ដែក ល្ង ដំឡូង អំពៅ ចេក និងគ្រឿងសក្ការៈ....យកមកដាក់បូជា ព្រោះភោគផលទាំងនេះ ត្រូវយកទៅដាំដុះនៅលើដីមេ ឬម៉ែ ហើយម៉ែដែលជាម្ចាស់មាតុភូមិនេះបានបំពេញពលិកម្មដ៏ធំ ដើម្បីប្រមូលកេរមរតកមកទុកឲ្យកូននាគប្រុសស្រី ទីបំផុតបានត្រឹមតែជាប់ក្នុងក្រុងរបស់យក្ស និងគ្រុឌ ព្រោះហេតុតែពលិកម្មនេះ (ក្រុងពលី)។ ក្នុងវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជជួន ណាត ភាគ១ និងភាគ២ ន័យក្នុងព្រះពុទ្ធសាសនា ពលីមាន៥យ៉ាង ទី១ញាតិពលី(ការស

ផ្គ្រោះញាតិ) ទី២អតិថិពលី(ការទទួលភ្ញៀវពន្លឺ) ទី៣បុព្វបេតពលី(ការធ្វើទានរួចឧទ្ទិសផ្សាយចំណែកបុណ្យចំពោះអ្នក ដែលចែកឋានទៅកាន់បរលោក) ទី៤រាជពលី(កិច្ចការបង់ពន្ធដារសួយសារអាករ) ទី៥ទេវតាពលី(ការចែកនូវចំណែកបុណ្យចំពោះពួកទេវតា តាមបែបព្រះពុទ្ធសាសនា ការសែនព្រេនផ្សេងៗ តាមលិទ្ធិក្រៅពុទ្ធសាសនា) បើយើងមើលពលីទាំង៥យ៉ាងនេះ គ្មានពាក្យក្រុងពីខាងដើមឡើយ ដូចនេះក្រុងពលីគឺមានន័យដូចដែលខ្ញុំពន្យល់ខាងលើ គឺមានន័យថា ឧទ្ទិសបុណ្យទៅឲ្យបុគ្គលដែលគាត់បានបំពេញ**ពលិកម្ម** ហើយត្រូវគេ**គ្រុខ**ជាប់។ ពាក្យថាសរសៃសូត្រសំរាប់យកមកត្បាញសំពត់ហូល ផាមួង អន្លូញ....គឺតំណាងឲ្យការទន្ទេញឲ្យចាំ (សូត្រទន្ទេញ) តែពុំដូច្នោះឡើយ កូននាគប្រុសស្រីបែរជាភ្លេចបណ្ដាំព្រះម៉ែ (មើលឈ្មោះភូមិតាប្រាប់ ឬាត់ដឹងភាគ២)។

សរុបសេចក្ដីមករូបចម្លាក់នេះត្បិតតែមានទំហំតូច តែបានបង្កប់នៅអត្ថន័យរឿងរបស់អច្ឆរមាតានិងកូន ដែលត្រូវទទួលមរតកពីគាត់បន្តគ្នា ហើយចុងក្រោយយើងបែរជាធ្វើតាមឥរិយាបថរបស់យក្សនិងគ្រុឌ ដែលជាអ្នកឃុំក្រុងអច្ឆរមាតានិងបិតា ហើយពួកគាត់ក៏មានសង្ឃឹមថា ពេលណាដែលកូនបានដឹងបណ្ដាំគាត់ហើយ ពួកគេនឹងនាំគ្នាសូត្រទន្ទេញឡើងវិញពីរអាថ៌កំបាំងសំពត់ ដែលនៅសល់តិចតួចនេះ។ ហើយរូបនេះទៀតសោត ក៏បានបង្ហាញពីការអស់សង្ឃឹមទៅលើកូននាគក្នុងថ្ងៃទាំងប្រាំពីរ ដែលគ្រាន់តែលើកដៃចោល ពុំបានជ្រោងលើកយក្ស ដែលជាន់គាត់នោះចេញឡើយ ដូច្នេះគាត់មានតែដេកចាំមើលកូននាគណា ដែលហ៊ានចូលទៅក្នុងទ្រូងម៉ែ (មើលល្បែងចាក់ទឹកដូងនិងរូបទី៤២ ៤៤)។

## ៧៩/.រូបភាពទី៧៩ រូបពពិលពីសម័យដើម(នៅសារមន្ទីរ)

ពពិល = មាតាគង់លើនាគបើកពពារ មានក្បាលព៧ (ប្រាំពីរ ឬប្រាំពិលពាក្យនិយាយ)

ពពិល = ប្រដាប់សំរាប់ឆ្លុះស្រមោល (វៃនតា) សិល្បចម្លាក់ខ្មែរ ជាសិល្បនិមិត្តរូប ជាសិល្បស្រមោល ឬអរូបី ដែលសិល្បៈនេះបានក្លាយជាតំណតគ្នារហូតមកដល់សព្វថ្ងៃ ហើយសព្វថ្ងៃរូបភាពចម្លាក់ទាំងនេះ គ្រាន់តែជាស្រមោលបង្ហាញពីភាពអច្ឆរិយ ក្នុងអតីតកាលតែប៉ុណ្ណោះ។ ហើយស្រមោលអច្ឆរិយទាំងនេះ សព្វថ្ងៃយើងតែងយល់ច្រឡំថា ជារឿងនៅក្នុងសាសនាទៅទៀត តែតាមពិត ពុំមែនដូច្នោះឡើយ អ្នកដែលបង្កើតភាពអច្ឆរិយនេះ គឺអច្ឆរមាតា ឬអប្សរមាតាដែលគេបានហៅគាត់ថា បិសាចពស់ ឬបិសាចនាគនោះឯង។



នៅក្នុងរូបនេះមានស្ត្រីម្នាក់ គង់ក្នុងឥរិយាបថសមាធិ នៅពីខាងលើនាគបើកពពារ (ពាក្យនិយាយបើកពពែរ) ដែលមានពាក់មកុដ និងគ្រឿងអលង្ការផ្សេងៗនៅលើដងខ្លួន តើស្ត្រីនោះគាត់ជានរណា? ឈ្មោះក្នុងអតីតកាលរបស់គាត់គឺព្រះនាងនាគ មកដល់បច្ចុប្បន្នព្រះមាតានាគ ព្រោះគាត់បានបង្កើតពូជពង្សនាគតជាប់គ្នា ជាងពីរពាន់ជំនាន់មកហើយ ដែលយើងជាកូននាគប្រុសស្រី បានទទួលកេរមរតកគាត់គ្រប់ៗគ្នានោះ គឺជនជាតិខ្មែរ (សូមមើលការពន្យល់ក្នុងអាថ៌កំបាំងបណ្ដាំមាតាមហានគរភាគ១ និងភាគ២)។ រូបភាពដែលគេឆ្លាក់គាត់នៅពីលើដងមួយ បន្តពីខ្លួននាគ គឺគោបីឈរជ្រោងបន្ទាប់ពីគោទាំងបី គឺចន្លោះដងទទេ បន្ទាប់ពីចន្លោះទទេ មានក្បាលយក្សនៅពីខាងក្រោម វត្ថុនេះយើងហៅថាពពិល។ ពពិលគឺជាឧបករណ៍មួយសំខាន់ណាស់ ក្នុងពិធីមង្គលផ្សេងៗ ដូចជាពិធីកោរជុក បំបួសនាគ ចូលម្លប់អាពាហ៍ពិពាហ៍..... (មើលក្នុងមង្គលបីភាគ២) គេតែងយកទៀនធ្វើពីក្រមួនសុទ្ធទៅបិទភ្ជាប់នឹងពពិល រួចដុតបង្វិលព័ទ្ធសីមាជុំវិញចំនួនបីជុំ (មើលការពន្យល់ពីសរសៃសូត្រ) រួចចុងក្រោយអាចារ្យបានយកស្លឹកម្លូទៅពន្លត់ (ប្រស្នាយកស្លឹកម្លូទៅពន្លត់នេះ មើលរូបទី៦)។ អាចារ្យក្ដី អ្នកដែលជួយបង្វិលព័ទ្ធជុំវិញក្ដី បានត្រឹមតែបក់ផ្សែងឲ្យអ្នកនៅខាងក្នុងសីមា ហិតស្រូបតែប៉ុណ្ណោះ ព្រោះអ្នកបក់និងអ្នកហិតសុទ្ធតែពុំបានដឹងពីអាថ៌កំបាំងក្នុងប្រស្នានេះដូចគ្នា ដោយហេតុអ្វី?

ព្រោះសព្វថ្ងៃរឿងដែលទាក់ទងនឹងពពិលនេះ គេបានទម្លាក់ទៅក្នុងរឿងព្រហ្មញ្ញសាសនាបាត់ទៅហើយ ដោយគេចាត់ទុកថាទៀនតំណាងឲ្យលិង្គព្រះឥសូរ រីឯពពិលវិញតំណាងឲ្យយោនីព្រះនាងឧមាវតី ឬឧមាភគវតី ដោយហេតុកែវភ្នែកមាតាទាំង១២ ដែលជាអ្នកទទួលមរតកអច្ឆរមាតានោះ

ត្រូវបានយក្សដកខ្សែៈយកទៅបាត់ហើយ។ ដូចនេះពន្លឺទៀន ដែលឆេះបំភ្លឺលើក្បាលនាគបើកពពារទាំងប្រាំពីរនោះ គ្មាននរណាអាចមើលឃើញនៅពន្លឺទាំងនោះឡើយ បានត្រឹមតែស្រូបក្លិនក្រមួនទៀនដែលឆេះនៅសល់តែប៉ុណ្ណោះ (មើលប្រវត្តិសាស្ត្រខ្មែរ ដែលទាក់ទងនឹងពាក្យខេត្តក្រមួនស ឬក្រមួនសុទ្ធពីអតីតកាល)។ នេះជាប្រស្នាអរូបីទាក់ទងនឹងវត្ថុនេះ (ពពិល) ដែលយើងជាកូននាគខាងក្រោយ បានធ្វើតៗគ្នាដោយពុំបានធ្វើការស្រាវជ្រាវរកការពិតរបស់ខ្លួន បានត្រឹមតែនាំគ្នាហិតក្លិនដែលនៅសេសសល់តែប៉ុណ្ណោះ ហើយក្លិនដែលនៅសល់នេះពុំបរិសុទ្ធទៅទៀត ព្រោះក្រមួនដែលយកមកលញ់ធ្វើទៀនសព្វថ្ងៃ សុទ្ធតែជាក្រមួនសិប្បនិមិត្ត។ សូម្បីតែពន្លឺទៀនដែលបំភ្លឺខាងលើ យើងមើលប្រស្នានេះពុំយល់ផង ធ្វើដូចម្ដេចអាចមើលឃើញអច្ឆរមាតា គង់នៅពីលើនាគខាងក្រោមបាន តើនាគក្បាលពក្នុងរូបតំណាងអ្វី? តោទាំងបីតំណាងអ្វី? ក្បាលយក្សខាងក្រោមតំណាងអ្វី?

**ក**/.នាគក្បាលពតំណាងឲ្យនិមិត្តរូបព្រះមាតានាគ ក្នុងមួយសប្ដាហ៍ត្រូវភ្លឺឡើងវិញគ្រប់ថ្ងៃ ព្រោះពីខាងលើក្បាលនាគមានចំណិតកាំរស្មីពន្លឺ ផ្សាយជះចេញទៅខាងក្រៅ ដោយអំណាចមហិទ្ធិឫទ្ធិព្រះមាតាមហានគរដែលគង់លើនាគ។ ពីមុនយើងពឹងទៅលើពន្លឺរបស់ទៀន ដែលតំណាងឲ្យលិង្គព្រះឥសូរ (ឆ្នុកចុករន្ធយោនីរូបទី៧៥) ឥឡូវនេះកូននាគបានដឹងពីសាវតាពិត របស់អច្ឆរមាតាខ្លួនវិញហើយ។ ដូច្នេះពន្លឺរបស់ព្រះមាតានាគ (មើលពីភាពរុងរឿងរបស់ព្រះនាងនាគក្នុងភាគ១) ត្រូវបានផ្សាយចេញជាថ្មីឡើងវិញហើយ ក្រោយពីកូននាគទាំងប្រុសស្រីបានដឹងពីអាថ៌កំបាំងមនោគមវិជ្ជាបរទេស (ប្រស្នាលិង្គចុកបិទ) ដែលបានគ្របសង្កត់មកលើខ្លួនពីមុននោះ ពេលឥឡូវនេះអំណាចព្រះមាតានាគ ត្រូវផ្សាយទៅគ្រប់ទិសទីដូចពីមុន (ព្រះមាតាសក់ក្រអូប)។

**ខ**/.តោបីគឺតំណាងឲ្យទីក្រុងតោ ឬទីក្រុងសីហ ដែលប្រឹងប្រែងបើកប្រស្នាសោទាំងបី ក្នុងមង្គលបី (មើលមង្គលបីក្នុងភាគ២) ឲ្យបានភ្លឺឡើងវិញ ពេលបានដឹងពីអាថ៌កំបាំងក្នុងមង្គលទាំងបីហើយ ពេលនោះមហិទ្ធិឫទ្ធិព្រះមាតានាគ ចាប់ផ្ដើមរះចែងចាំងជះពន្លឺឫទ្ធិបារមីរបស់លោក ផ្សព្វផ្សាយទៅគ្រប់ទិស។ ក្នុងរូបពពិលជាប្រស្នានេះ មានរូបតោដល់ទៅបីខុសពីរូបផ្សេង ព្រោះហេតុអ្វី? ព្រោះមង្គលរបស់កូននាគពីដើម ឪពុកម្ដាយធ្វើឲ្យកូនធំៗតែបីដងប៉ុណ្ណោះ ឯពិធីផ្សេងទៀតគ្រាន់តែជាពិធីបន្ទាប់បន្សំ ម្យ៉ាងទៀតពពិលនេះ សម្រាប់ប្រើក្នុងមង្គលទាំងបីនេះជាសំខាន់ ដូច្នេះទើបប្រស្នារូបពពិលនេះមានរូបសត្វតោបី ឬរាជសីបី (តំណាងឲ្យរឿងព្រះមាតាគង់លើកពពិលនេះ ត្រូវបើកសោទាំងបី ក្នុងទីក្រុងតោ)។

គ/.ក្បាលយក្សនៅខាងក្រោមតំណាងឲ្យម្ចាស់ពៀរ ដែលធ្លាប់ចាប់យកគាត់ទៅឃុំក្នុងសមុទ្រទឹកដោះពីរអតីតកាល ក្នុងរូបនេះយក្សឈប់មានអំណាចចាប់គាត់បានទៀតហើយ ព្រោះដើមឈូករបស់គាត់ បានដុះផុតពីក្បាលយក្សខាងក្រោម គាត់កំពុងគង់លើនាគផ្សាយឫទ្ធិរស្មីឡើងវិញ (មើលការពន្យល់រូបទី៦៣)។

ឃ/.ដងវែងខាងក្រោមនាគ និងក្រោមតោ តំណាងឲ្យពេលវេលាលូតលាស់របស់ដើមឈូក ដែលដើមឈូកទ្របល្ល័ង្កនាគនេះ អាចដុះផុតចេញពីអំណាចរបស់យក្ស (មើលរូប៦៣) ហើយទងផ្កាឈូកនេះតំណាងឲ្យបញ្ញាអ្នកគោរពព្រះពុទ្ធសាសនា ព្រោះព្រះសម្មាសម្ពុទ្ធ បានចាត់ទុកបញ្ញារបស់សត្វលោក ដូចជាផ្កាឈូកបួនពួកនៅក្នុងជលសា។

១/.ពួកផ្កាដែលកំពុងដុះចេញពីភក់

២/.ពួកផ្កាដែលដុះចេញពីភក់តែនៅក្នុងទឹក

៣/.ពួកផ្កាដែលដុះចេញពីភក់ហើយតែផុតពីទឹក

៤/.ពួកផ្កាដែលដុះចេញពីភក់ពីទឹកហើយរងចាំព្រះសូរ្យសែងចាំងមករអាលនឹងរីក

ដូច្នេះក្នុងរយៈពេល៤៥ព្រះវស្សា ព្រះអង្គមានពុទ្ធកិច្ចប្រាំយ៉ាងក្នុងមួយថ្ងៃ ក្នុងពុទ្ធកិច្ចទាំងប្រាំនោះ ពុទ្ធកិច្ចចុងក្រោយគឺព្រះអង្គប្រមើលមើលនិស្ស័យសត្វមានភ័ព្វ ឬឥតភ័ព្វ រួចព្រះអង្គយាងទៅប្រោសទេសនា ដើម្បីឲ្យផ្កាឈូកគឺបញ្ញា រីកទទួលព្រះសូរ្យសែង គឺព្រះធម៌នេះឯង។ ហេតុនេះសិល្បៈខ្មែរគ្រប់ៗប្រាសាទ ពុំចោលក្បាច់ត្របកឈូកឡើយ ប៉ុន្តែក្បាច់ត្របកឈូកទាំងនោះ ត្រូវពួកគាត់បំបែកក្នុងត្របកមួយសន្លឹកៗនោះ ឲ្យមានក្បាច់ល្អិតៗនៅខាងក្នុងបន្តទៅទៀត ដើម្បីទុកជាប្រស្នាកំបាំងក្នុងនិមិត្តរូបត្របកឈូកនេះ (ក្បាច់ត្របកឈូបបំបែក)។

សរុបសេចក្ដីមកការពន្យល់ពីរូបពពិលដោយសង្ខេបនេះ គ្រាន់តែជាការស្រាយនៅអាថ៌ប្រស្នាជាស្រមោល របស់អច្ឆរមាតាពីអតីត ដែលពីមុនយើងបានត្រឹមតែស្រូបហិតក្លិន ចំហេះទៀនដែលនៅសល់ពុំបរិសុទ្ធនោះ ឲ្យមកមើលឃើញដោយភ្នែកគឺបញ្ញា។ ក្នុងរឿងពិតដែលលាក់កប់ក្នុងពពិលនេះ តាមការបកស្រាយពីខាងលើ កូននាគប្រុសស្រីច្បាស់ជាឈប់យល់ច្រឡំដោយធ្វើការពិចារណាសាជាថ្មីឡើងវិញ ថាឧបករណ៍ពពិលនេះ ពុំមែនជាសំណល់សល់ពីព្រហ្មញ្ញសាសនានោះឡើយ

ព្រោះពពិលពិតប្រាកដគឺព្រះមាតានាគគង់លើនាគបើកពពារ រួចមកព័ទ្ធសីមាថែរក្សាកូនប្រុសស្រីក្នុងមង្គលទាំងបី ចំណែកព្រហ្មញ្ញសាសនានៅបរទេស គឺពុំមានពពិលនេះឡើយ (ខ្លួនជាប់ទោសទៅហើយ នៅតែគិតពីកូនទៀត)។

## ៨០/.រូបភាពទី៨០រូបអច្ឆរមាតាឬបិសាចពស់(មិនដឹងប្រភព)



តើរូបភាពចម្លាក់នេះព្រឹទ្ធដូនតា គាត់ចង់និយាយប្រាប់យើងពីរឿងអ្វី នៅក្នុងថ្មនេះ? នៅក្នុងភាគទីមួយខ្ញុំបានពន្យល់ពីបិសាចពស់ ដែលអ្នកការទូតចិនជិវតាក្វាន់ គាត់បានឮអ្នកស្រុកខ្មែរសម័យនោះ និយាយពីរឿងបិសាចពស់នេះ តែងតែឡើងមកជួបនឹងស្ដេចក្នុងវេលារាត្រី។ ក្នុងរូបនេះមានស្ត្រីម្នាក់ពាក់មកុដដូចអច្ឆរា កំពុងហែកនាគក្បាល៦ចេញមកក្រៅ ហើយខ្លួនគាត់គឺជាក្បាលទី៧ (មើលការពន្យល់ក្នុងរូបទីមួយ) ដោយគាត់ចង់ប្រាប់យើងតាមរយរូបចម្លាក់នេះថា នាគគឺជានិមិត្តរូបរបស់គាត់។ តើគាត់ចេញពីខ្លួននាគមកខាងក្រៅធ្វើអ្វី? គាត់ចេញដើម្បីមកប្រាប់កូននាគប្រុសស្រីក្នុងសម័យនោះ ចង្អុលប្រាប់ពីរបៀបដឹកនាំនគរ ដើម្បីពង្រីកអំណាច និងប្រាប់ពីការកសាងប្រាសាទឆ្លាក់រឿងរបស់គាត់ទុក រួមទាំងកិច្ចពិធីផ្សេងៗទៀតទុកជាប្រស្នា ទំនៀមទម្លាប់ ព្រោះគាត់ដឹងថាតទៅថ្ងៃក្រោយ គាត់មិនអាចចេញមកខាងក្រៅទៀតបានឡើយ (មើលការពន្យល់ក្នុងរូបមុន និងក្នុងភាគមុន)។ ហើយរូបនេះទៀតសោតខ្ញុំពុំបានដឹងថា ដូនតាឆ្លាក់ក្នុងប្រាសាទណាឡើយ ព្រោះខ្ញុំបានដករូបភាពនេះ ចេញពីសៀវភៅរបស់ជប៉ុន ដែលបានបោះពុម្ពកាលពីទសវត្ស៦០ ដែលរូបនេះកាលសម័យនោះ

មិនទាន់រងនៅការបំផ្លាញនៅឡើយ ដោយក្នុងពេលនោះពួកបរទេសជិតខាង ពុំទាន់ចាប់អារម្មណ៍យល់ពីរអាថ៌កំបាំងក្នុងភាសារូបទាំងនោះ។ ឯរូបសង្ខាងកំពុងចុះតាមកាំជណ្ដើរ ដែលមានបួនថ្នាក់ (មើលការពន្យល់រូបទី១ ពីសោចាក់ទាំងបួនជាន់) ម្ខាងរូបស្ត្រី ម្ខាងទៀតរូបបុរស ដែលតំណាងឲ្យកូននាគអ្នកទទួលមរតកផ្ទាល់ក្នុងសម័យនោះ (អ្នកដឹកនាំ) ចុះទៅក្រោមដើម្បីជួបអច្ឆរមាតា (បិសាចនាគ ឬពស់) ទទួលនូវឱវាទយកមកប្រតិបត្តិតាម ដោយកូននាគសម័យនោះបេះដូងរបស់ពួកគាត់ គឺជាបេះដូងទេវតា (បេះដូងកូននាគពោរពេញដោយការដឹងគុណ មើលរាជបំណាងរបស់ស្ដេចជ័យវរ្ម័នទី៧ ដែលគាត់ចង់ឲ្យប្រជារាស្ត្រក្លាយជាទេវតា និងដែនដីគាត់ក្លាយជាឋានសួគ៌)។ កាំជណ្ដើរទាំងសង្ខាងមានក្រៅមានក្នុង គឺតំណាងឲ្យអតីតកាល និងបច្ចុប្បន្ន ដែលតទៅខាងមុខនឹងមានកូននាគណាមួយ ដឹងរឿងក្នុងបេះដូងថ្មទាំងនេះ គេនឹងចុះទៅជួយគាត់ក្នុងទីឃុំឃាំងនោះ។ សេះនៅខាងលើ និងសេះនៅខាងក្រោម តំណាងឲ្យឆ្នាំមមីក្នុងអតីត និងឆ្នាំមមីក្នុងបច្ចុប្បន្នកាល ដែលឆ្នាំនេះតាងឲ្យបុគ្គលជាស្ត្រីឈរនោះឯង ដែលគាត់ត្រូវចុះមកជួយស្រង់អច្ឆរមាតា ឯដើមឈើតំណាងឲ្យការបិទបាំងលាក់រឿងក្នុងអតីតកាល (មើលរូបមុនៗ បង្កប់លាក់ក្នុងព្រៃក្បាច់) ផ្កាឈូកក្រពុំមួយទងនៅជិតអច្ឆរមាតា តំណាងឲ្យបញ្ញាក្នុងព្រះពុទ្ធសាសនា និងតំណាងឲ្យឈ្មោះរបស់គាត់ គឺព្រះមាតាក្រពុំឈូក ឬឈូកក្រពុំ។ ឯខាងបុរសវិញយើងពុំឃើញមានរូបតំណាងឲ្យឆ្នាំឡើយ ព្រោះផ្ទាំងថ្មនេះត្រូវប្រេះរយះធ្វើឲ្យបាត់សភាពដើម តែយើងអាចយល់បានថា អច្ឆរមាតាលោកសង្ឃឹមបុរសនោះជាង ព្រោះហេតុអ្វី? ទីមួយ អច្ឆរមាតាបានងាកបែរមុខ ទៅរកបុរសដែលជាកូននាគនោះ ទីពីរមានតែបុរសទេដែលអាចបំពេញបារមី ជាព្រះពោធិសត្វលោកេស្វរៈបាន ព្រោះគ្រប់ពោធិសត្វទាំងអស់ដែលបំពេញបារមីដើម្បីឲ្យបានត្រាស់ដឹងជាព្រះពុទ្ធ គឺពុំមានស្ត្រីឡើយ នេះជាក្រិតក្រមរបស់ធម្មជាតិ។

សង្ខេបសេចក្ដីមករូបភាពដែលខ្ញុំបានយកមកបកពន្យល់ដោយត្រួសៗនេះ គ្រាន់តែចង់ឲ្យកូននាគប្រុសស្រី បានស្គាល់ពីបិសាចពស់ឬនាគ ក្នុងឯសារអ្នកការទូតចិនជាវតាក្វាន់ ថាតើបិសាចនោះជានរណា? កុំឲ្យយើងជាអ្នកទទួលមរតកមេនាគហើយ មិនដឹងសាវតាររបស់គាត់វាជារឿងមួយគួរឲ្យខ្មាស់អៀនណាស់ ព្រោះភាសាគំនិតដែលគាត់ឆ្លាក់ទុកក្នុងថ្ម វាគឺជាត្រីវិស័យនិងភស្តុតាងមួយដ៏សំខាន់ សម្រាប់ឆ្លុះបញ្ចាំងមើលរឿងអតីតកាលកន្លងមក នឹងការវិវឌ្ឍន៍ទៅរកអនាគតកាលខាងមុខ។ ហើយរូបនេះទៀតសោត បានបើកបង្ហាញពីការពិតរបស់បិសាចពស់ (ចិនអ្នកថា) ដែលជាប្រមុខអ្នកបង្កើតនគរខ្មែរ នឹងជាអ្នកបង្កើតនូវអរិយធម៌អច្ឆរិយ គឺគាត់ជាអច្ឆរមាតាមហានគរ។ ភស្តុតាងនេះ

កូននាគប្រុសស្រីក្នុងសម័យបច្ចុប្បន្ន ត្រូវតែទទួលស្គាល់ថា បិសាចពស់ដែលគួរឲ្យខ្លាចពីអតីតកាល នោះ ការពិតគឺជាអ្នកខំប្រមូលទ្រព្យសម្បត្តិកេរមរតកទុក ហើយនឹងបានបន្សល់ទុកឲ្យយើងជាកូនខ្មែរទទួលមរតករបស់គាត់គ្រប់ៗគ្នា ក្នុងបច្ចុប្បន្ននេះ។

## ៨១/.រូបភាពទី៨១រូបចម្លាក់នៅលើបល្ល័ង្កតែមួយ(មិនដឹងប្រភព)



តើរូបទាំងបីនេះតំណាងឲ្យអ្វី? ហេតុអ្វីបានជារូបអង្គុយលើបល្ល័ង្កនាគ និងរូបស្ត្រីឈរបិទភ្នែក ហើយបើកភ្នែកតែរូបបុរសដែលមានដៃច្រើន?

**ក**/.រូបចំកណ្ដាលកំពុងអង្គុយពែនភ្នែន លើនាគពែនបើកពពារ រួចមានពាក់មកុដនឹងគ្រឿងអលង្ការ ស្ថិតក្នុងឥរិយាបថសមាធិ ដែលនៅលើបាតដៃត្រួតគ្នានោះ មានផ្កាឈូកក្រពុំមួយទង ហើយនៅទងត្រចៀកមានពាក់ក្រវិល តើរូបនេះតំណាងឲ្យអ្វី? រូបនេះតំណាងឲ្យកូននាគដែលជាព្រះពោធិសត្វលោកេស្វរៈ ដែលត្រូវមកបំពេញបារមីជួយស្រង់ប្រស់អច្ឆរមាតាមហានគរ (មើលការពន្យល់រូបទី៤២ និង៤៤) ហេតុអ្វីបានជារូបនេះពុំអាចបើកភ្នែកបាន? ព្រោះរឿងអាថ៌កំបាំងរបស់ព្រះ

ម៉ែមហានគរ ពុំទាន់មានកូននាគណាព្រមទទួលយកនូវកែវភ្នែកនេះ ទៅដាក់មើលរឿងពិតរបស់ខ្លួនឡើយ គឺនៅបិទភ្នែកដដែល បុគ្គលបិទភ្នែកមិនអាចមើលអ្វីឃើញឡើយ។

**ខ**/.រូបខាងឆ្វេងដៃរូបកណ្ដាល គឺស្ត្រីឈរលើទម្រពាក់មកុដនិងគ្រឿងអលង្ការ ដៃគាត់ម្ខាងកាន់ផ្កាឈូកក្រពុំនិងដៃម្ខាងទៀតកាន់គម្ពីរ ហើយបិទភ្នែកដូចរូបនៅកណ្ដាលដែរ តំណាងឲ្យអច្ឆរមាតាមហានគរ គាត់កំពុងចាកចេញពីការដាក់ទណ្ឌកម្មរបស់យក្ស។ រូបគាត់គេបានឆ្លាក់បិទភ្នែកដដែលមានន័យថាពីឆ្នាំ១៩៩៨មកទល់នឹងឆ្នាំពី២០១០នេះ (មើលអារម្ភបទភាគ១) អាថ៌កំបាំងរឿងរបស់គាត់នូវលាក់បិទដដែល ព្រោះកែវភ្នែកមាតាទាំង១១កន្លះ ពុំទាន់បានយកទៅដាក់បញ្ចូលឲ្យពួកគាត់ទាំង១២ឡើយ។ ដូច្នេះហើយទើបរូបកូនដែលអង្គុយលើបល្ល័ង្កនាគក៏បិទភ្នែក មាតាឈរក៏បិទភ្នែក ព្រោះអ្នកនាំរឿងមាតាយកមកផ្សព្វផ្សាយ ពុំទាន់អាចបញ្ច្រាបរឿងចូលទៅក្នុងបេះដូងកូនក្មេរបាននៅឡើយ។ នេះជាប្រស្នាថ្មដែលគាត់ឆ្លាក់មនុស្សពីរនាក់បិទភ្នែក ព្រោះធម្មតាបុគ្គលដែលបិទភ្នែក គឺមើលអ្វីពុំឃើញឡើយ ទោះបីជាបើកភ្នែកមើលឃើញរូប តែពុំបានគិតពិចារណា ក៏ទុកដូចជាបិទភ្នែកដ៏ដែល ដូច្នេះទើបមានពាក្យជេរទូន្មានរបស់ចាស់បុរាណថា "**កុំមើលនឹងភ្នែក ត្រូវចេះមើលនឹងថ្ងាស**"។

**គ**/.ហេតុអ្វីដែលរូបបុរសដែលកំពុងឈរ បែងភាគដៃបួន នៅលើទម្រតែមួយហើយបើកភ្នែក?

**ន័យទី១** ក្រោយពេលដែលមាតាចុះទៅទទួលទោស នៅក្នុងសមុទ្រទឹកដោះនោះ រឿងរបស់អច្ឆរមាតាត្រូវបានគេលុបដានចោលអស់ទៅហើយ (មើលមង្គលពាភាគ២) ហេតុនេះបុរស (ប្អា) ត្រូវដណ្ដើមសិទ្ធិធ្វើជាមេ ព្រោះមនោគមវិជ្ជាបរទេសដែលយកមកសង្កត់នគរនេះ គឺយកបុរសជាធំ (កុងម៉ា ≠ មេប្អា)។ ហេតុតែតាំងខ្លួនជាមេ បុរសគាត់ត្រូវធ្វើកិច្ចការជាច្រើន នៅក្នុងផ្ទះក្រៅផ្ទះ គ្រប់គ្រងគ្រួសារ គ្រប់គ្រងនៅសិទ្ធិគ្រប់បែបយ៉ាងជំនួសមេ ឯមេគឺមាននៅសល់តែឈ្មោះប៉ុណ្ណោះ។

**ន័យទី២** តំណាងឲ្យកូននាគដែលត្រូវមកជួយម្ដាយ ពេលដែលគាត់នៅជាព្រះវិស្ណុ ឬព្រះឥសូរគាត់ត្រូវបែងភាគដើម្បីប្រមូលផ្ដុំរឿងរបស់អច្ឆរមាតា ដែលត្រូវបានហាន់ជាចំណិតៗ (ប្រាសាទហាន់ជ័យ) ដើម្បីយកមកផ្គុំឲ្យក្លាយបានជារូបរាងមួយ អាចធ្វើឲ្យកូននាគមើលយល់ពីការពិត នូវរឿងរបស់អច្ឆរមាតានេះបាន។ ឯភ្នែកបីតំណាងឲ្យគាត់ត្រូវមើលនឹងភ្នែកផង ត្រូវយកមកគិតត្រិះរិះពិចារណាក្នុងភ្នែកទីបី នៅកណ្ដាលថ្ងាសផង មានន័យថាត្រិះរិះដោយបញ្ញាដោយយកគោលក្នុងព្រះពុទ្ធសាសនា និងក្នុងព្រហ្មញ្ញសាសនា មកវែកញែករាវរកការពិត ក្នុងមរតកម៉ែទាំងអស់ តើមួយណាជា

របស់ក្នុងសាសនា មួយណាជារបស់ព្រះម៉ែ? ហេតុនេះហើយទើបព្រឹទ្ធដូនតា គាត់ឆ្លាក់ប្រស្នាគំនិតទុកក្នុងរូបទាំងបីនេះ ដែលឈរនិងអង្គុយលើជើងទម្រតែមួយរូបគ្នា ពីរនាក់បិទភ្នែកម្នាក់បើកភ្នែក ព្រោះកុំឲ្យអ្នកមើលយល់ច្រឡំថា គាត់ភ្លេចឆ្លាក់ឲ្យបើកភ្នែក។ នៅមានរឿងមួយទៀត ក្នុងទំនៀមទំលាប់ខ្មែរទាក់ទងនឹងព្រះពុទ្ធសាសនា គឺពិធីបុណ្យអភិសេកព្រះពុទ្ធបដិមា ក្នុងបុណ្យនេះមានកិច្ចមួយគេហៅថា ពិធីបើកព្រះនេត្រព្រះ ហេតុអ្វីចាំបាច់បើកព្រះនេត្រព្រះ បើជាងអ្នកឆ្លាក់គេបានបើករួចទៅហើយនោះ? ដែលបញ្ញារបស់ព្រះសម្មាសម្ពុទ្ធ បានសន្សំបារមីទាំង៣០ អស់រយៈពេលបួនអសង្ខេយ និងមួយសែនផែនដី ព្រះអង្គមានបារមីគ្រប់គ្រាន់ អាចត្រាស់ដឹងដោយខ្លួនឯងបាន ចុះហេតុអ្វីក៏ចម្លែកម្លេះ យើងមានពិធីបើកព្រះនេត្រព្រះអង្គ បើយើងគ្រាន់តែជាអ្នកទទួលនូវឱវាទ ដែលជាមរតករបស់ព្រះអង្គសោះ តើយើងមានឫទ្ធិបារមីអ្វីទៅបើកព្រះនេត្រព្រះអង្គបាន? នេះហើយដែលជាប្រស្នាសម្រាប់កូននាគប្រុសស្រី ដែលជាអ្នកគោរពកាន់ព្រះពុទ្ធសាសនា គួរពិចារណាថា តើកិច្ចដែលត្រូវបើកព្រះនេត្រនោះ គឺបើកព្រះនេត្ររបស់ព្រះណាឲ្យពិតប្រាកដ? ចម្លើយគឺសូមមើលការពន្យល់គ្រប់ភាគទាំងបីថា តើព្រះនេត្រព្រះណាដែលកូនខ្មែរប្រុសស្រី ត្រូវបើកដោយពិតពុំមែនបើកដោយព្រាវនោះ? ព្រោះព្រះនេត្រ ឬចក្ខុរបស់ព្រះសម្មាសម្ពុទ្ធមានប្រាំគឺ៖

១/.មំសចក្ខុ (ចក្ខុ គឺសាច់ដួងភ្នែក)

២/.ទិព្វចក្ខុ (ចក្ខុដូចជាទិព្វ)

៣/.បញ្ញាចក្ខុ (ចក្ខុ គឺបញ្ញា)

៤/.ពុទ្ធចក្ខុ (ចក្ខុ គឺប្រាជ្ញាត្រាស់ដឹង)

៥/.សមន្តចក្ខុ (ចក្ខុឃើញដោយជុំវិញ)

សរុបសេចក្ដីមកព្រឹទ្ធដូនតាយើង គាត់ពូកែយកគំនិតទៅលាក់ទុកក្នុងថ្មណាស់ តែដោយយើងទុកសិទ្ធិឲ្យបរទេសជាអ្នកស្រាវជ្រាវបកស្រាយភាសារូបនេះ យើងត្រូវបានគេខ្ទប់បិទរឿងពិតរបស់ព្រះម៉ែនាគ ដែលលោកខំព្យាយាមទុករឿងខ្លួនក្នុងថ្ម ពួកគេបានបកប្រែភាសារូបឲ្យក្លាយជារឿងរបស់សាសនាទៅវិញ។ ពេលនេះកូននាគប្រុសស្រីត្រូវចេះមើលប្រវត្តិពិតរបស់ខ្លួន ដែលលោកបានចារឹក និងប្រតិស្ឋានទុកក្នុងថ្ម ទំនៀមទម្លាប់ រឿងព្រេង ទំនាយ ឈ្មោះភូមិស្រុក....ដើម្បីស្វែងរកការពិតរបស់អាទិទេពខ្មែរ ដែលបានបង្កើតភាពអច្ឆរិយនេះ។

## ៨២/.រូបភាពទី៨២រូបនៅជញ្ជាំងគ្រលុកនៅខាងឆ្វេង(លានជល់ដំរី)

## ៨៣/.រូបភាពទី៨៣រូបនៅជញ្ជាំងគ្រលុកនៅខាងឆ្វេង(លានជល់ដំរី)







រូបនេះបានចែកចេញជាពីរផ្ទាក់ តើរូបទាំងអស់នេះ ព្រឹទ្ធដូនតាយើងគាត់ចង់និយាយប្រាប់ពីរឿងអ្វី? ពាក្យថាលានជល់ដំរី គឺមានន័យថាទីលានសម្រាប់យកដំរីទៅប្រជល់គ្នា ក៏ប៉ុន្តែក្នុងន័យភាសារូបក្នុងលាននេះ គឺពុំនិយាយដូច្នេះឡើយ បែរជានិយាយពីហ្មដែលជិះនៅលើក្បាលដំរីទាំងបី ចុះមកប្រយុទ្ធដណ្ដើមរារាំង សម្លាប់ក្មេងម្នាក់ដែលនៅជាប់ឃុំក្នុងទីនោះ កុំឲ្យឡើងមកខាងលើរួច។ ហ្មលើដំរីទាំងបីនោះ (មើលរូបហ្មនៅក្បាលដំរីខ្លោងទ្វារចូលទីក្រុងអង្គរធំ) តាមពិតនៅឯជាន់ទីបីខាងលើឯណោះ ហេតុតែដើម្បីតាមរកក្មេងម្នាក់នេះ ពួកគេបាននាំគ្នាចុះមកក្នុងអន្លង់គុកដ៏ជ្រៅ តាមរារាំងចាប់សម្លាប់បុគ្គលនោះ។ ក្នុងរូបទាំងពីរផ្ទាំងខាងលើនេះ តាមពិតរូបស្ថិតក្នុងជញ្ជាំងតែមួយ ដោយរូបមុនថតយកពុំបានអស់ ទើបខ្ញុំចាប់ផ្ដើមយករូបទី២មកដាក់បន្តឲ្យជាប់គ្នា ដើម្បីងាយស្រួលក្នុងការពន្យល់ ដូច្នេះទើបក្នុងរូបនេះមានរូបពីរសន្លឹកជាប់គ្នា។ ក្នុងរូបទី៨២យើងឃើញមានមនុស្សបីនាក់មានពាក់មកុដ ដូចជាមកុដស្ដេចក្នុងល្ខោនបាសាក់ អ្នកទាំងបីនោះដៃខាងស្ដាំមានកាន់អាវុធ លើកគំរាមឡើងលើ ចំណែកជើងទាំងពីររបស់មនុស្សទាំងបីនាក់នោះ ជាន់នៅលើផ្កាឈូកកំពុងរីក។ នៅ

ពីក្រោយអ្នកទាំងបី មានរូបមនុស្សម្នាក់តូចដូចជាកូនក្មេង ដែលគាត់នៅឈរពីខាងក្រោយអ្នកលើកអាវុធ ឬហ្មដំរីទាំងបី (មើលការពន្យល់បន្ថែមរូបទី៣៣) គាត់កំពុងរកផ្លូវគេចដើរចេញ ពីការរារាំងរបស់អ្នកទាំងបី ដើម្បីឡើងទៅខាងលើ។ ពេលដែលក្មេងនោះដើរមកដល់ទន្ទឹម ជើងឆ្វេងសេះក្បាលប្រាំ គាត់បានឈរជាន់លើផ្កាឈូកមួយទង ដែលរំលងពីផ្កាឈូកគាត់ជាន់ មានផ្កាឈូកទំនេរមួយបន្ទាប់ពីផ្កាឈូកទំនេរ ទើបដល់ផ្កាឈូកដែលហ្មដំរីជាន់ (ពីជើងគាត់រំលងផ្កាឈូកមួយ) តែក្បាលក្មេងនោះពួកជនទុច្ចរិតបានដាប់ចោលអស់មួយចំនួនទៅហើយ ព្រោះគេឧបកិច្ចឲ្យក្មេងនោះស្លាប់ (មើលការឧបកិច្ចរបស់ស្តេចជ័យវរ្ម័នទី២ពេលប្រកាសតែងតាំងខ្លួនជាស្តេចចក្រវាលលើភ្នំគូលែន)។ បន្ទាប់មកក្មេងនោះបានឡើងទៅលើជាន់ទីពីរ គាត់បានលុតជង្គង់សំពះអង្វរហ្មទាំងបី តែអ្នកទាំងបីដែលឡើងតាមគាត់មកខាងលើនោះ គឺពុំព្រមអត់ឱនលើកលែងឲ្យគាត់ឡើងទៅលើទៀតឡើយ សកម្មភាពរបស់ពួកគេគឺ លើកអាវុធឡើងគំរាមរារាំងគាត់ដដែល (មើលរូបភាព)។ ក្នុងរូបបន្តទី៨៣ដោយគាត់ពុំអាចឡើងទៅលើរួច គាត់ចុះមកជ្រកខាងក្រោមសេះក្បាលប្រាំ សកម្មភាពរូបគាត់លុតជង្គង់លើបល្ល័ង្កផ្កាឈូក ដៃកាន់ទំពក់ស្ថិតនៅខាងក្រោមពោះសេះ កំពុងរកផ្លូវដើម្បីចាកចេញ។ ទើបរូបគាត់បានមកស្ថិតឈរពីខាងស្តាំជើងសេះ នៅលើផ្កាឈូកមួយទង ដែលក្នុងរូបនេះជើងហ្មដំរីបានលើករំលងផ្កាឈូកពីរ មកជាន់ពីលើជើងផ្កាឈូករបស់ក្មេង ដើម្បីកុំឲ្យគាត់ឡើងទៅលើរួច កាលនៅពីខាងឆ្វេងជើងសេះ ហ្មដំរីជាន់នៅសល់ផ្កាឈូកមួយទំនេរ តែមកដល់ខាងស្តាំជើងសេះវិញ ហ្មបានជាន់រំលងមកដល់ផ្កាឈូកដែលក្មេងនោះឈរ មានន័យថាគេតាមឈ្នានីស ព្យាបាទ រុកគួន ព្រោះគេមិនចង់ឲ្យគាត់នាំរឿងអច្ឆរមាតាដែលជាប់ក្នុងគុកនេះ មកផ្សព្វផ្សាយនៅខាងលើឡើយ។ ក្នុងសកម្មភាពរូបបានពន្យល់ប្រាប់យើងថា គាត់ព្យាយាមដកជើងចេញពីការជាន់របស់ហ្ម រួចប្រឹងឡើងទៅខាងលើ រូបខាងលើជាបន្តគាត់អង្គុយបញ្ឈរជង្គង់ងើយក្បាលមើលទៅលើ ប្រុងប្រៀបខ្លួននឹងឡើងទៅទៀត តែត្រូវមានរូបស្ត្រីធំមួយឡើងទៅតាមស្ទាក់លើកជើងដាក់ពីខាងលើក្បាលគាត់ ដើម្បីរារាំងដំណើរផ្លូវរបស់គាត់។ បើយើងមើលតាមសកម្មភាពរូបទី៨២ និង៨៣នេះ គួរឲ្យសង្វេគ នឹងអាណិតគាត់ណាស់ ព្រោះដើម្បីនាំរឿងអាថ៌កំបាំងអច្ឆរមាតាឡើងទៅខាងលើ គាត់ត្រូវមានសត្រូវធំៗមកស្ទាក់រារាំង តាំងពីដើមទីមកម្ល៉េះ ព្រោះហ្មទាំងបីដែលខំចុះមកក្នុងគ្រលុកនេះ ពួកគេមិនចង់ឲ្យក្មេងនេះនាំរឿងអាថ៌កំបាំងមាតាមហានគរឡើងទៅខាងលើឡើយ ពួកគេបានប្រើគ្រប់រូបភាព រារាំង ឈ្នានីសព្យាបាទ គ្រប់ជំហានដំណើររបស់គាត់ (មើលសកម្មភាពរូប)។ ហេតុតែពូជនាគដែលជាពូជអច្ឆរាបានដេកលក់រាប់រយជំនាន់មកហើយ (លុបដាន សាដាន លក់ដាន) ដូច្នេះពួកហ្មទាំងបីគេមិនអាចឲ្យ

ពូជអច្ឆរិយនេះ ដឹងពីសាវតាពិតក្នុងអតីតរបស់ខ្លួនឡើយ នេះជាគំនិតបង្កប់ក្នុងភាសារូប ដែលបាន ប្រាប់យើងពីសកម្មភាពរារាំង ព្យាបាទ ឈ្នានីសរបស់ពួកគេ។

## ៨៤/.រូបភាពទី៨៤រូបនៅជញ្ជាំងគ្រលុកខាងស្ដាំផ្លូវចុះ(លានជល់ដំរី)



នៅក្នុងរូបភាពលានជល់ដំរី លើជញ្ជាំង ពីខាងស្ដាំដៃផ្លូវចុះនេះ សកម្មភាពរូបអត្ថន័យ មិនសូវខុស ពីរូបនៅខាងឆ្វេងដៃឡើយ គ្រាន់ តែក្នុងរូបនេះបានបង្ហាញពីអត្តសញ្ញា ដែល យើងជាកូននាគ គួរដឹងថា តើគាត់ព្យាយាម គេចវេះចេញ ពីការតាមព្យាបាទ របស់ពួកហ្ម ទាំងបីព្រោះរឿងអ្វី? ក្នុងរូបនេះនៅខាងឆ្វេង ជើងសេះក្បាលប្រាំ ពីខាងក្រោម មានរូបបុរស ម្នាក់ឈរអង្គុញលើកជើង ម្ខាងខ្ចប់មុខទៅ ជញ្ជាំង កំពុងរុញនិមិត្តរូបក្បាលនាគ យ៉ាងធំ មួយទៅលើ។ ក្នុងការព្យាយាមរបស់គាត់ត្រូវ ពួកហ្មដំរី ដែលនៅបន្ទាប់គាត់ កំពុងលើក យាវអាវុធឡើងវាយប្រហាគាត់ រារាំងគាត់មិន ឲ្យរុញនិមិត្តរូបកូននាគនេះឡើង ទៅខាងលើ បាន។ អត្ថន័យរបស់រូបដែលខ្ចប់មុខទៅជញ្ជាំង បានពន្យល់ប្រាប់យើងថា គាត់ពុំមាននរណាស្គាល់ ដឹងពីសកម្មភាពនឹងមុខមាត់ពិតរបស់គាត់ឡើយ ទោះបីជាគាត់នៅក្នុងទីទាបក៏ដោយ ក៏ពុំបានបង្ហាញ មុខឲ្យគេបានដឹងឡើយ។ ចំណែកឯក្បាលនាគដែលគាត់កំពុងប្រឹងរុញច្រានទៅខាងលើនោះ គឺ តំណាងឲ្យអាថ៌កំបាំងបណ្ដាំរឿងរបស់ព្រះមាតានាគ ដែលបានលិចកប់ទៅក្នុងមហាសមុទ្រទឹកដោះ ពីអតីតកាលកន្លងផុតទៅ សកម្មភាពរូបបានបង្ហាញប្រាប់យើងថា អ្នកដែលព្យាបាទគេ និងអ្នកដែល ត្រូវគេព្យាបាទ សុទ្ធតែឈរលើទម្រផ្កាឈូកដូចគ្នា។ រូបភាពនេះបើលោកអ្នកអានចង់ដឹងការពិតឲ្យ កាន់តែច្បាស់ សូមអញ្ជើញទៅមើលរូបជាក់ស្ដែង រួចពិចារណាតាមសាច់រឿង ដែលខ្ញុំបានពន្យល់ ដោយសង្ខេបនេះ ព្រោះការពន្យល់បកភាសារូប យើងពុំអាចនិយាយអ្វីឲ្យហួសពីការ ដែលយើងបាន

មើលឃើញនោះឡើយ ខ្ញុំក៏សូមអភ័យទោសដោយខ្វះលទ្ធភាពក្នុងការប្រមូលឯកសារឲ្យបានគ្រប់គ្រាន់។ ក្នុងឯកសារថ្មដែលបានលាក់ទុកក្នុងលានជល់ដំរីនេះ បើយើងមើលរួចហើយ ពិចារណាអត្ថន័យរូប ទើបយើងដឹងថាព្រឹទ្ធដូនតាលោកបានដឹងជាមុនរួចទៅហើយ នៅការតាមព្យាបាទឈ្នានីសចំពោះកូននាគ ដែលត្រូវចុះទៅជួយប្រស់រុញច្រានស្រង់គាត់ឡើង ហើយពួកគាត់ទុកប្រស្នានេះជាហេតុសំរាប់ចង្អុលប្រាប់កូននាគ ឲ្យខិតខំព្យាយាមអត់ធ្មត់គ្រប់ការលំបាកវេទនា ដែលខ្លួនត្រូវទទួល ទើបអាចឲ្យសម្រេចកិច្ចការដ៏ធំនេះទៅដល់ទីបញ្ចប់បាន។

## ៨៥/.រូបភាពទី៨៥រូបជញ្ជាំងខាងលើ(លានជល់ដំរី)



ទីតាំងលានដំរីក្បាលបីខាងលើ បើយើងមើលរូបភាពពីចម្ងាយ យើងឃើញគ្រលុកគុកសេះក្បាលប្រាំ នៅពីខាងក្រោម (មើលរូប៨២ ៨៣ និង៨៤) ចំណែកឯផ្ទាំងរូបដំរីក្បាលបី គឺនៅពីខាងលើយើងអាចមើលឃើញ គ្រលុកសេះក្បាលប្រាំនេះតាមរយៈរូបថតដែលមើលពីចម្ងាយ។ ក្នុងរូបនេះយើងមើលឃើញក្បាលដំរី មានប្រាំមួយគឺម្ខាងបីៗ តែក្នុងប្រស្នារូបនេះ បើយើងមើលដោយពុំបានគិតពិចារណាល្វែងយល់ ច្បាស់ជាយល់ច្រឡំតាមសិល្បបំភាន់នេះជាពុំខាន ព្រោះព្រឹទ្ធដូនតាយើងគាត់ចង់ប្រាប់កូននាគថា បើចង់ដឹងរឿងពិតក្នុងនគរដំរី (យសោធបុរៈ) ត្រូវមើលក្នុងទ្រូង ឬក្នុងបេះដូងដំរី ទើបអាចដឹងរឿងក្នុងចិត្តរបស់នគរដំរី។ បើសិនជាគាត់ឆ្លាក់ដំរីក្បាលបី គាត់ពិបាកចែកញែកក្បាលសម្រាប់សរសេររឿងណាស់ ដូច្នេះគាត់ត្រូវតែឆ្លាក់ក្បាលដំរីម្ខាងបីៗ ចំណែកឯរឿងកណ្ដាលទុកដូចជារឿង នៅក្នុងទ្រូងដំរី ន័យម្យ៉ាងទៀតក្បាលបីម្ខាង ចាត់ទុកដូចជាម្ដាយ ម្ខាងទៀតដូចឪពុក ព្រោះធាតុទឹក**១២** = **៣** ធាតុដី**២១** = **៣** ឬក៏ព្យញ្ជនៈទាំង**៣៣តួ** ក៏មានន័យដូចក្នុងរូបផ្ទាំងនេះដែរ។ នៅលើខ្នងដំរីមានបល្ល័ង្កផ្កាឈូកដ៏ធំមួយយើងហៅថារយាងដំរី ចំណុចកណ្ដាលនៃរយាងនេះហើយ ទើបយើងយល់ពីសិល្បបំភាន់របស់ពួកគាត់ តាមពិតដំរីមានក្បាលតែបីប៉ុណ្ណោះ ព្រោះយើងមើលរូបដំរីក្បាលបីខាងក្រោម នៅជញ្ជាំងខាងមុខជាប់ថ្នល់ និងមើលរូបដែលគេដណ្ដើមហៅកនគរជាបី (រូបទី៣២ ៣៣ និង៣៤)។ ក្នុងដំណាក់កាលទីមួយ មនុស្សប្រុសតូចនោះត្រូវប្រើពេលវេលា

ដើម្បីចុះទៅក្នុងត្រលុកគុកសេះក្បាលប្រាំវាវរករអាចិកំបាំងអច្ឆរមាតានាគ ដំណាក់កាលទីពីរ ពេលដែលបានដឹងអាចិកំបាំងអច្ឆរមាតាហើយ គាត់ត្រូវរុញច្រានរឿងដ៏ធំនេះ ចេញពីត្រលុកគុកខាងក្រោមឲ្យមកឋិតនៅខាងលើ ដំណាក់កាលទីបី គាត់ត្រូវព្យាយាមវារលូនអូសរឿងអច្ឆរមាតានាគ យកទៅដាក់នៅលើបល្ល័ង្កផ្កាឈូក ដែលជារយាងដំរីវិញ។ ហេតុនេះហើយ ទើបហ្មដំរីទាំងបីសុខចិត្តនាំគ្នាចុះពីលើក្បាលដំរី មករារាំងក្មេងនេះ ក្នុងត្រលុកគុកសេះក្បាលប្រាំខាងក្រោម តាមព្យាបាទរហូតទៅដល់ជាន់ខាងលើ ព្រោះមិនចង់ឲ្យក្មេងនេះ នាំរឿងអាចិកំបាំងក្នុងបេះដូងដំរីចេញមកខាងក្រៅឡើយ ដូច្នេះទើបនៅលើកំពូលភ្នំគូលែន មានទីកន្លែងមួយគេហៅថា អន្លង់ដំរី ព្រោះគាត់ចង់ប្រាប់យើងឲ្យមើលរឿងក្នុងអន្លង់លានជល់ដំរីនេះ។

## ៨៦/.រូបភាពទី៨៦រូបក្នុងជញ្ជាំងកណ្ដាលទ្រូងដំរី(លានជល់ដំរី)



រូបនៅជញ្ជាំងកណ្ដាលក្បាលដំរីសង្ខាងនេះ ដូននាគយើងបានលាក់រឿងរបស់គាត់ទុកក្នុងទ្រូងដំរី ដែលជាដំណាក់កាលចុងក្រោយរបស់គាត់ គាត់ដឹងថា នឹងមានកូននាគណាម្នាក់ត្រូវស្រង់យកគាត់ទៅដាក់លើបល្ល័ង្កឈូកធំនោះវិញ ហេតុតែក្មេងម្នាក់នេះ ដំរីទាំងបីត្រូវជល់គ្នាយ៉ាងដូចម្ដេចដើម្បីដណ្ដើមគ្នាបោចឲ្យដោយផ្កាឈូកមួយទងនេះ? (មើលរូបដំរីបោចដើម និងផ្កាឈូកចោល)

នៅចំកណ្ដាលមានរូបក្បាលយក្សមួយដ៏ធំ បានចាប់ខាំក្បាលនាគម្ខាងបីៗ ឯក្បាលនាគនោះគឺតំណាងឲ្យអច្ឆរមាតានាគ (មើលការពន្យល់រូបទី១ និងរូបទី៨០) ដែលមកដល់ដំណាក់ចុងក្រោយនេះ ទើបព្រឹទ្ធដូនតាយើង បានបង្ហាញពីអ្នកចាប់គាត់យកទៅឃុំ។ នៅខាងឆ្វេងក្បាលយក្សមានហ្មដំរីពីរ

នាក់ អ្នកទាំងពីរនេះ បានតាមរាវាំងតាំងពីក្នុងអន្លង់សេះក្បាលប្រាំខាងក្រោមឯណោះ មកដល់ខាងលើនេះ ពួគេប្រឹងលើកដៃទ្រផ្កាឈូក ដើម្បីបន្តថ្នោល ឬរន្ទារបស់ខ្លួន តាមរាវាំងកូននាគដែលកំពុងនាំអច្ឆរមាតាឡើងទៅខាងលើ។ នៅខាងឆ្វេងដៃហ្មឈរទាំងពីរ មានមនុស្សម្នាក់អង្គុយលុតជង្គង់ ដោយលើកដៃស្តាំចង្អុលប្រាប់ហ្មដំរីទាំងពីរនាក់ មានន័យថាចង្អុលប្រាប់ទិសអ្នកនាំអច្ឆរមាតាចេញ ឲ្យហ្មទាំងពីរបានដឹង ដើម្បីឡើងទៅស្ទាក់ផ្លូវ។ ឯថ្នាក់ជាន់ទីពីរពីខាងឆ្វេងក្បាលយក្ស ហ្មទាំងពីរនៅសល់តែហ្មមួយ បានឡើងជាន់លើផ្កាឈូក ដែលខ្លួនបានបណ្តុះទ្រពីក្រោមទៅ ដែលហ្មនោះខំប្រឹងឡើងជាន់រន្ទាផ្កាឈូកឲ្យទាន់ក្មេងនោះ ដើម្បីទប់ស្កាត់កុំឲ្យក្មេងនោះឡើងទៅលើផ្កាឈូកធំបាន។ ឯអប្សរាតូចដែលឈរពីលើផ្កាឈូក ពីខាងលើក្បាលមនុស្សអង្គុយលុតជង្គង់នោះ ឡើងមកដល់ថ្នាក់ទីពីរអប្សរានេះបានរីកខ្លួនធំ ដោយជើងម្ខាងជាន់លើផ្កាឈូកខ្លួនឯង និងជើងម្ខាងទៀតជាន់ប្របេះលើផ្កាឈូករបស់ហ្ម ដែលជាសេនាយក្ស ហេតុនេះទើបអប្សរានេះអាចរីកធំបាន ដោយអំណាចចំហាយពីផ្កាឈូកសេនាយក្ស។ រូបនៅចំពីលើក្បាលយក្សកណ្តាល គឺតំណាងឲ្យហ្មទីពីរដែលឡើងពីក្រោមទៅតែមិនទានរីកធំ ទៅដល់ជាន់ទីបីទើបហ្មនេះរីកខ្លួនធំ ដោយជាន់លើផ្កាឈូកដែលខ្លួនទ្រនៅជាន់ទីពីរព្រោះរូបជាន់ទីបីនេះ ខ្លួនមានផ្កាឈូកពីរសម្រាប់ជាន់ ខុសពីជាន់ទីពីរដែលមានតែមួយ។ នៅខាងស្តាំហ្មទីពីរ គឺហ្មទីបី ដែលកំពុងលើកដៃទ្ររន្ទាផ្កាឈូកបន្តទៅលើទៀត នៅជាន់ទីពីរខាងលើហ្មទីបីនេះបានរីកខ្លួនធំ ព្រោះជើងមានទម្រជាន់ទាំងសង្ខាង ហើយហ្មទីបីនេះពុំមានរូបក្នុងជាន់ទីមួយឡើយ។ នៅពីខាងស្តាំក្បាលយក្សវិញ រូបភាពទីមួយកូននាគនោះអង្គុយបញ្ឈរជង្គង់ ជ្រោងរុញក្បាលនាគទៅលើ ដែលក្បាលនាគនេះ គាត់ជ្រោងរុញឡើងតាំងពីអន្លង់ខាងក្រោមមក។ ជាបន្ទាប់រូបភាពទីពីរ គាត់ចាប់ផ្តើមក្រោកឈរជើងម្ខាងជាន់លើផ្កាឈូក ឱបរឿងអច្ឆរមាតាជាប់នឹងទ្រូង ហើយគាត់ព្យាយាមនាំរឿងអច្ឆរមាតា ឡើងទៅខាងលើទៀត ដោយមុខគាត់បានបែរចេញមកក្រៅ ខុសពីរូបមុនដែលគាត់បែរមុខខ្ទប់ទៅជញ្ជាំង។ ឡើងទៅដល់ជាន់ទីពីរ គាត់បានអង្គុយលុតជង្គង់លើផ្កាឈូក ដោយយកដៃឆ្វេងដាក់លើដើមទ្រូង តែរូបនេះបានដាប់ក្បាលបាត់ទៅហើយ ដោយអត្ថន័យក្នុងរូបនេះ បើយើងមើលសកម្មភាពរូបដែលនៅសល់ គាត់ចង់ប្រាប់យើងថារឿងអច្ឆរមាតា គឺជារឿងក្នុងបេះដូងរបស់គាត់ ព្រោះដៃឱបលើទ្រូងជានិមិត្តសញ្ញាបង្ហាញប្រាប់ ពីអត្ថន័យរូប។ ឡើងទៅដល់ថ្នាក់ទីបី រូបគាត់បានត្រូវផ្អោបខ្ទប់ទៅជញ្ជាំង ដើម្បីរុញច្រានអច្ឆរមាតានាគជាចុងក្រោយ ឲ្យដល់រយាងផ្កាឈូកដ៏ធំខាងលើនោះ តែគួរឲ្យអនិច្ចារូបគាត់បានបាត់ក្បាលទៅហើយក្នុងវគ្គបញ្ចប់ ព្រោះថ្ម

មួយដុំមានរូបក្បាលគាត់ និងក្បាលហ្លួពីខាងស្ដាំនោះ ត្រូវគេយកចេញបាត់ទៅហើយ ដូច្នេះយើងពុំដឹងថាទីបញ្ចប់នៃរឿង តើមានន័យយ៉ាងណាឡើយ?

បើនិយាយពីដំរីក្បាលប្រាំមួយឬក្បាលបីវិញ ប្រមោយរបស់វាច្រឹងបោចដើមឈូកនិងផ្កាឈូកចោល ព្រោះយើងដឹងហើយថាផ្កា និងដើមនេះ ពេលណាដែលគេបោចដាច់ចេញពីគល់វា គឺត្រូវតែងាប់ពុំអាចរីករួចឡើយ តើផ្កាឈូកតំណាងឲ្យអ្វី? ផ្កាឈូកតំណាងឲ្យប្រជារាស្ត្រអ្នកកាន់ និងគោរពព្រះពុទ្ធសាសនា (មើលការពន្យល់មុនៗ) បើបុគ្គលនោះត្រូវបោចដាច់ចេញពីគល់ទៅហើយ តើផ្កានោះរស់ ឬស្លាប់? ក្នុងប្រស្នានេះ កូននាគប្រុសស្រីត្រូវពិចារណាឈ្វេងយល់ថា បើហ្លួបញ្ជាដំរីឲ្យបោចផ្កាឈូកចោលច្រើនម្លឹងៗ ហេតុតែដើម្បីរកផ្កាឈូកមួយទងនៅអន្លង់ខាងក្រោមនោះ តើព្រឹទ្ធដូនតាយើងគាត់ចង់ប្រាប់យើងពីអ្វី? សូមពិចារណាភាសាថ្ម រួចស្វែងរកចម្លើយពិតប្រាកដមួយដោយខ្លួនឯង នោះ**កូននាគនឹងដឹងពីភាពប្រែប្រួលពីរបបដឹកនាំរបស់នគរខ្មែរពុំចេះចប់ក្នុងអតីតកាល សាវតាររឿងទាំងអស់ដែលមានក្នុងបេះដូងថ្ម លានជល់ដំរីនេះបានប្រាប់យើងពីហេតុគេទុកជាមុនដែលត្រូវកើតមាននៅក្នុងនគរនេះ។**

បង្រួមសេចក្ដីមកការយករឿងក្នុងថ្មលានជល់ដំរី មកបកស្រាយដោយសង្ខេបនេះ គ្រាន់តែចង់ឲ្យកូននាគចេះមើលរឿងរបស់ខ្លួន ដែលដូនតាលោកព្យាយាមចារឹកថ្មទុក ព្រោះលោកបានដឹងមុនរួចទៅហើយ នៅដំណើរផ្លូវរបស់អ្នកនគរនេះ ពេលដែលអច្ឆរមាតាជិតអស់បាបកម្ម នគរនេះនឹងត្រូវគេតាមចង់ពៀរជាមួយនឹងគាត់ ជាមួយនឹងកូននាគ និងអ្នកដែលត្រូវចុះទៅជួយស្រង់គាត់។ ហើយប្រស្នាក្នុងថ្មនេះ គឺត្រូវយកថ្លុកទៅលុបត្រពាំង មានន័យថាកូនដែលត្រូវចុះទៅក្នុងអន្លង់ដំរីក៏ជាប់ឃុំ (តិចជាង) ឯអច្ឆរមាតាដែលកូនត្រូវទៅជួយក៏ជាប់ឃុំនៅក្នុងទឹកដូចគ្នា គ្រាន់តែទឹកថ្លុកវារាក់និងតូចជាងទឹកត្រពាំងតែប៉ុណ្ណោះ។ ដូច្នេះហើយទើបលានទាំងពីរគាត់កសាងឡើងទន្ទឹមគ្នា គឺលានព្រះគម្លង់ និងលានជល់ដំរី កូនជាប់ឃុំក្នុងអន្លង់លានជល់ដំរី ឯអច្ឆរមាតាជាប់ឃុំក្នុងលានព្រះគម្លង់ ព្រោះជញ្ជាំងបាំងគុកលានព្រះគម្លង់ជ្រៅជាង និងផ្លូវវែងឆ្ងាយជាង។ ហេតុនេះទើបប្រស្នាក្នុងថ្មចង់ពន្យល់ប្រាប់ថា ពុំងាយមានអ្នកណាអាចទៅដឹងរឿងពិតនៅក្នុងថ្ម ទីលានទាំងពីរនោះឡើយ ភាគច្រើនបានត្រឹមតែដើរ ឬបើកបរកាត់ពីខាងមុខលានតែប៉ុណ្ណោះ។ ក្នុងលានព្រះគម្លង់រូបចុងក្រោយជិតនឹងរួចពីទោស គាត់បានឆ្លាក់ប្រាប់យើងពីស្នាមអេះចូលជ្រៅទៅក្នុងសាច់ថ្ម ***"កូនហ្មើយយក្សបានចាប់លេបម៉ែ***

***អស់ជាង៥ពីរពាន់ឆ្នាំហើយ ខ្លួនម៉ែពុំដែលស្គាល់ការផ្ងូតទឹក ឬអេះនៅរមាស់ឲ្យបានដល់សាច់ឡើយ”*** ដូចនេះរូបស្នាមដែលអេះចូលជ្រៅទៅក្នុងសាច់ថ្មនោះហើយ ជាឈ្មោះរបស់ទីលាននេះ ហើយក៏ជាឈ្មោះរបស់បាបកម្ម ដែលព្រះម៉ែទទួលទោសកន្លងមក ព្រោះហេតុតែស្វែងរកមរតកទុកឲ្យកូនខ្មែរ។ ភាសាថ្មក្នុងទីតាំងលាននេះ ទោះបីជាខ្ញុំបានបកពន្យល់ត្រួសៗក៏ដោយ ខ្ញុំជឿជាក់នូវបញ្ញារបស់ពូជនាគច្បាស់ជាយល់ ហើយនឹងជួយផ្គុំ ជួយស្រាវបន្តនូវបុព្វហេតុទាំងឡាយ ដែលខ្វះចន្លោះនោះឲ្យកាន់តែច្បាស់ឈប់ស្រពិចស្រពិល ឬភាន់ច្រឡំដូចពីមុនទៀត ដើម្បីឲ្យរឿងទាំងនោះក្លាយជាការពិតរបស់យើងទាំងអស់គ្នា។ កូននាគទាំងឡាយអ្នកគួរសង្វេគ នៅការតាមចងពៀរវេរានឹងគ្នា (មើលការពន្យល់រូប) ហេតុនេះទើបព្រះសម្មាសម្ពុទ្ធ បានសម្ដែងនូវគាថាប្រារព្ធពួកភិក្ខុក្នុងដែនកោសម្ពី ដែលបានឈ្លោះទាស់ទែងគ្នាព្រោះតែហេតុបន្តិចបន្តួច ដោយព្រះអង្គប្រារព្ធរឿងព្រះបាទទីឃាតិទូន្មានកូនទីឃាវុថា **“ទីឃាវុកូនចូរកូនកុំឃើញកាលវែង កុំឃើញកាលខ្លី នៃទីឃាវុកូនធម្មតាពៀររមែងរម្ងាប់ដោយការមិនចងពៀរ”** ក្នុងគាថានេះ ព្រះអង្គចង់ឲ្យយើងទម្លាក់ចោលនូវភារៈដ៏ធ្ងន់ ដែលយើងបានរែកទូលអស់មួយសង្សារវដ្ដមកហើយ។

## ៨៧/.រូបភាពទី៨៧ រូបព្រះមាតាមហានគរ(នៅប្រាសាទរលស់)



រូបអច្ឆរមាតាឈរក្នុងខ្លោងទ្វារនេះ ខុសពីរូបនៅប្រាសាទនានា ព្រោះហេតុអ្វី? ដោយរូបភាគច្រើននៅក្នុងខ្លោងទ្វារតាមប្រាសាទនានា គេច្រើនឆ្លាក់បុរស ឬស្ត្រីនៅក្នុងស៊ុមខ្លោងទ្វារដែលមានក្បាលនាគត្រូវយក្សលេប (ម្ករ) ហើយទ្រនុងខ្នងនាគនិមិត្ត ច្រើនឆ្លាក់ជាសន្លឹកក្បាច់ពេញ។ ចំណែកក្នុងរូបនេះខុសពីរូបដែលរៀបរាប់ខាងលើ ព្រោះចុងក្បាំងស៊ុមទ្វារជាក្បាលសត្វគុជសី (ពន្យល់រួចហើយ) រីឯទ្រនុងដែលជាក្បាច់ពីមុន ត្រឡប់បែរជាមានប្រាសាទផុសបន្តគ្នាបន្តិចម្ដងៗ រហូតដល់កំពូលខាងលើ។ ប្រស្នាថ្មនេះបើគ្រាន់តែមើលគឺឃើញត្រឹមរូប តែបើមើលរួចគិតទើបឃើញរឿងក្នុងបេះដូងម៉ែ ដែលអច្ឆរមាតាលោកបានបំប្លែងបំភាន់

លាក់ទុកក្នុងប្រាសាទរាប់ពាន់ ដែលកើតចេញពីគំនិតព្រឹទ្ធដូនតា បន្សល់ទុកនូវមរតកនេះ គឺគំនិតរបស់ "**អច្ឆរា ឬអច្ឆរិយ**"។ តើរូបនេះមាតាគាត់ចង់ប្រាប់យើងពីរឿងអ្វី តទៅអនាគត?

**ក**/. ស្ត្រីម្នាក់ពាក់មកុដ ពាក់ក្រវិល និងគ្រឿងអលង្ការ ដៃសង្ខាងមានពាក់កងជារង្វង់ៗបន្តគ្នា ដៃស្តាំកាន់ដំបងរំពាត់រោមកន្ទុយចាមរី ដៃឆ្វេងចង្អុលចុះក្រោម ស្លៀកសំពត់មានក្បាច់លម្អ រំយោលឈរពីលើកាំជណ្តើរទាំងបួនកាំ តើស្ត្រីនេះតំណាងឲ្យអ្វី?

១/.រូបស្ត្រីនេះតំណាងឲ្យព្រះមាតាមហានគរ ឬអច្ឆរមាតាមហានគរខ្មែរ

២/.ពាក់មកុដតំណាងឲ្យគាត់ជាប្រមុខ ជាស្តេច ក្នុងអតីតនិងបច្ចុប្បន្នដែលត្រូវមកអភិបាលគ្រប់គ្រងថែរក្សាកេរមរតកចាស់គាត់វិញ (មើលការពន្យល់រូបទី៣៥)។

៣/.ពាក់កងដែលមានរង្វង់ជាន់ៗគ្នា តំណាងឲ្យគាត់ជាអ្នកបង្កើតពូជខ្មែរមន ព្រោះកងពាក់នៅលើដៃគាត់ និងកងដែលពាក់នៅកស្ត្រីជនជាតិមន (មើលរូបទី២១) គឺដូចគ្នា ឯរូបស្ត្រីពាក់កងជាន់ៗដូចរូបនេះខ្ញុំឃើញមានរូបគាត់នៅប្រាសាទភ្នំបូក។

៤/.ដៃស្តាំកាន់ដំបងមានរោមកន្ទុយចាមរី តំណាងឲ្យអាវុធរបស់គាត់ឈ្មោះ កន្សែងបក់ប្រោយ

៥/.ដៃឆ្វេងចង្អុលចុះក្រោម ដែលម្រាមចង្អុលដៃគាត់ធំជាងមេដៃនោះ គាត់ចង់បង្ហាញប្រាប់យើងឲ្យមើលទៅខាងក្រោម តាមសញ្ញាចង្អុលប្រាប់នេះ។ **សញ្ញាចង្អុលដៃនេះ ពេលដែលខ្ញុំបានឆ្លាក់រូបនេះហើយ ខ្ញុំឆ្ងល់រួចគតពិចារណាអស់រយៈពេលពីរឆ្នាំ** ទើបអាចរកឃើញចម្លើយដោយសមស្របមួយ ក្នុងពេលដែលមានក្មួយម្នាក់បានយកសំណួរល្បែងចាក់ទឹកដូង (មើលការពន្យល់ល្បែងចាក់ទឹកដូងក្នុងភាគ១) មកសួរខ្ញុំថា តើល្បែងនេះមានអត្ថន័យយ៉ាងដូចម្តេច? ប្រស្នាក្នុងដៃចង្អុលចុះក្រោមនេះគាត់ចង់ប្រាប់យើងថា "កូនឲ្យម៉ែចេញមកក្រៅម្តេចរួច បើម៉ែនៅទូលយោនីខ្លួនឯងយ៉ាងនេះ កូនត្រូវតែវែកបំពង់ស្រីនេះសិន ទើបអាចចាប់ស្រង់ម៉ែចេញពីក្នុងបំពង់យោនីនេះបាន ហើយម៉ែអាចឡើងមកខាងលើរួច" (មើលមាតាប្រសូតកូន) ដែលក្នុងល្បែងចាក់ទឹកដូងលើកទីពីរបានប្រាប់យើងថា៖

ចាក់ទឹកដូងពីទ្រូងមាតា កន្ទុយត្រីប្រាក្បាលនាងកុក

អកកំប្រោរចាំកូនស្រង់ បំពង់ស្រី (យោនី) ចាំកូនវែក

ក្បាលម៉ែព្រែក ក្អែកនាំគ្នាជុះអាចម៍ដាក់ក្បាលម៉ែប៉ក់។

អាថ៌កំបាំងរឿងចង្អុលដៃរបស់គាត់ចង្អុលទៅខាងក្រោមនេះ ខ្ញុំបានពន្យល់ក្នុងរូបទី៧៥នៅភ្នំបាណន់ ដែលព្រឹទ្ធដូនតាបានធ្វើជារាងស្នឹងយកទៅបោះដោតសង្កត់ សន្ធប់រន្ធយោនីនោះជាប់ ដើម្បីកុំឲ្យគាត់ចេញមកខាងលើរួច (មើលន័យពាក្យប្រាសាទស្នឹង) ដូចនេះទើបគាត់ចង្អុលដៃទៅក្រោមទុកជាសញ្ញា សម្រាប់ឲ្យយើងពិចារណាឈ្វេងយល់ ហើយជួយស្រង់គាត់។

៦/.កាំជណ្ដើរទាំងបួនកាំ តំណាងឲ្យការឡើងពីទីទុក្ខខាងក្រោមចំនួនបួនលើក (មើលការពន្យល់រូបទីមួយ) ពេលដែលគាត់មកឈរលើកាំទីបួនហើយ គាត់នៅតែចង្អុលទៅក្រោមដដែល នេះគឺជាហេតុដែលយើងត្រូវស្រាវជ្រាវរកប្រស្នាកំបាំងចង្អុលដៃនេះ។

៩/.ខ្លោងទ្វារឬក្បាំងដែលគ្របពីលើគាត់ ក៏បានបង្ហាញភាសាគំនិតបង្កប់ទុក ក្នុងពេលដែលគាត់ចាកចេញពីទោស ព្រោះថាក្បាំងគឺនៅលើក្បាល មានន័យថាក្បាំងបាំងក្បាល ឬបាំងរឿងក្នុងក្បាលកុំឲ្យគេដឹង ឬមើលឃើញ។

១/.ក្បាលគុជសីទាំងសង្ខាងកំពុងបួងកម្រងផ្កា តំណាងឲ្យការបង្រួមទីតាំងទាំងពីរ ឲ្យទៅជាទីតាំងមួយថ្មី (មើលការពន្យល់រូបមុន) ពេលនោះការអបអរសាទរ បានត្រូវពាក់កម្រងផ្កាបំពាក់លើកឡើង ដែលជានិមិត្តរូបបញ្ជាក់ប្រាប់ថា រឿងអាថ៌កំបាំងគាត់ចាប់ផ្ដើមមានគេឆ្ងល់ហើយគេដឹង រួចជ្រាវរកប្រភពសរសៃសូត្រ ដែលហូតចេញពីនាងដែលជាប់ក្នុងសំបុកសីមា ដោយគាត់បានបំពេញពលិកម្មដេកស្ងោរក្នុងទឹកក្ដៅ ហេតុតែសរសៃសូត្រដើម្បីត្បាញជាសំពត់ហូល....(និមិត្តរូបស្រកានាគ) និងមួយទៀតតំណាងគប់ភ្លើង។

២/.ទ្រនុងរាងប្រាសាទទីមួយ តំណាងឲ្យការរួចចាកទោសរបស់គាត់ ជាលើកដំបូង ឬលើកទីមួយ។

៣/.ទ្រនុងរាងប្រាសាទទីពីរ តំណាងឲ្យការរួចចាកទោសលើកទីពីរ

៤/.ទ្រនុងរាងប្រាសាទទីបី តំណាងឲ្យការរួចចាកទោសលើកទីបី ហើយគ្រប់ទ្រនុងនាគនិម្មិតរូបប្រាសាទ តែងមានក្បាច់បាំងពីក្រោមប្រាសាទ ក្បាច់តំណាងឲ្យការលាក់បាំងរឿងអាថ៌កំបាំងរបស់គាត់ ក្នុងពេលដែលគាត់កំពុងចាកចេញពីទោស ដែលកូននាគភាគច្រើនពុំបានដឹងពីរឿងនេះ (ពុំទាន់បានដឹងការផ្សព្វផ្សាយ)។

៥/.ទ្រនុងកណ្ដាលជាទ្រនុងចុងក្រោយ ឬច្រកទ្វារចុងក្រោយ គាត់បានឆ្លាក់ប្រាប់យើងឲ្យមើលរូបហើយពិចារណាថា ទ្វារចុងក្រោយនេះត្រូវបំបែកជាបីតំណាក់កាលទៀត

* ក្បាំងថ្នាក់ទីមួយ មានទំហំតូច
* ក្បាំងថ្នាក់ទីពីរ មានទំហំធំ
* ក្បាំងថ្នាក់ទីបី មានទំហំកណ្ដាល

ឆ្លងកាត់ទ្វារមួយបែកខ្នែងបី (មើលមង្គលទីបីក្នុងភាគពី២) នេះទៀត ទើបអច្ឆរមាតាអាចរួចផុតពីអំណាចឃុំរបស់យក្ស បើយើងមើលរួចពិចារណាតាមប្រស្នារូប អត្ថន័យរូបបានប្រាប់យើងថា សោទីមួយ ទីពីរ ទីបី គឺងាយនឹងបើក ព្រោះពុំមានថ្នាក់បិទបាំងសាំញ៉ាំច្រើន ពេលចូលទៅដល់ទ្វារទីបួន ឬសោទីបួន គឺមានទ្វារមួយតែបែកជាទ្វារបី។ ទ្វារមួយបំបែកជាបីនេះ យើងច្បាស់ជាយល់ថា គាត់លំបាកនឹងចេញឲ្យរួចទៅដល់កំពូលវិញណាស់ ព្រោះទ្វារខាងលើមួយ ស្មើទ្វារខាងក្រោមពីរ ដូច្នេះកូននាគដែលទៅជួយគាត់ ត្រូវប្រើពេលវេលាកាន់តែវែងឆ្ងាយ។ ហេតុនេះហើយទើបគេឆ្លាក់រូបព្រះវិស្ណុដេកលើកថ្មោល ហើយនៅលើខ្លួនត្រូវជាប់ផ្លែព្រួញដ៏ច្រើន (មើលរូបទី៧៦) ការឈឺចាប់ទុក្ខវេទនារបស់អ្នកទាំងពីរ កាន់តែអូសបន្លាយគួរឲ្យអាណិត និងសង្វេគ។

បង្រួមសេចក្ដីមក ការបកពន្យល់ភាសាគំនិតដោយសង្ខេបពីរូបនៅប្រាសាទរលស់នេះ (អស់ម្ដងបន្តិចៗ) បើយើងមើលនឹងភ្នែកគឺឃើញត្រឹមតែរូប បើយើងមើលហើយពិចារណាក្នុងថ្វាស គឺឃើញរឿងនៅក្នុងបេះដូងមួយ ដែលពោរពេញទៅដោយភាពស្មុកស្មាញ លំបាកវេទនាទុក្ខសោករបស់អ្នកជំនាន់មុន និងអ្នកជំនាន់ក្រោយ។ ទោះបីរូបតូចតែមានអត្ថន័យជ្រៅ ព្រោះបញ្ញារបស់បុគ្គលអច្ឆរិយមិនងាយនឹងចាក់ទម្លុះឲ្យយល់បានឡើយ ដូចជាគាថារបស់ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាសសម្ដែងថា "**បុគ្គលណាបានឃើញនូវសច្ចធម៌ ទើបឃើញតថាគត បើបុគ្គលនោះពុំបានឃើញនៅសច្ចធម៌ទេ ឥពុំបានឃើញតថាគតឡើយ**" គឺបានឃើញត្រឹមតែសំបករូបតថាគតតែប៉ុណ្ណោះ។

# ៨៨/.រូបភាពទី៨៨រូបផ្ដែរ(មិនដឹងប្រភព)



រូបផ្ដែរនេះគឺជារូបចុងក្រោយនៅក្នុងបណ្ដាំព្រះមាតាមហានគរភាគទីបី ហើយក៏ជារូបមួយដែលមានសារៈសំខាន់ណាស់ចំពោះខ្ញុំ ដែលធ្វើឲ្យខ្ញុំមានជំនឿលើគតិបណ្ឌិតរបស់អច្ឆរមាតា វាក៏ជាត្រីវិស័យមួយសម្រាប់ចង្អុលផ្លូវ ធ្វើឲ្យកើតមានកម្លាំងព្យាយាមឡើងវិញ ពេលដែលជួបឧបសគ្គមករារាំង ដើម្បីអាចឈានទៅបំបែកអាថិកំបាំងជាបន្ត ពេលដែលខ្ញុំមើលយល់ពីអត្ថន័យក្នុងប្រស្នាថ្មនេះ។ ព្រោះភាសាថ្មក្នុងផ្ដែរបានផ្ដាំឲ្យខំប្រឹងប្រែងនាំបណ្ដាំព្រះម៉ែ ឲ្យបានដល់ទីបញ្ចប់ ដោយរូបចម្លាក់ក្នុងផ្ដែរនេះ គឺជាប្លង់មួយសម្រាប់ឲ្យដឹងកាលពេលវេលា ក្នុងការបើកសោទ្វារម្ដងៗ ហើយនឹងសម្រាប់ទប់ស្កាត់ឧបសគ្គផ្សេងៗ ពេលកំពុងស្រាវជ្រាវរឿងនៅក្នុងបណ្ដាំព្រះមាតាមហានគរនេះ។ ក្នុងរូបភាពផ្ដែរនេះត្រូវបានចែកចេញជាបីថ្នាក់ គឺថ្នាក់ខាងលើ ថ្នាក់កណ្ដាល និងថ្នាក់ខាងក្រោម ហើយនៅក្នុងថ្នាក់នីមួយៗ បានបង្ហាញពីសកម្មភាពផ្សេងៗគ្នា ហើយក្នុងរូបផ្ដែរនេះទៀតសោត ត្រូវបានបំផ្លាញស្ទើរតែអស់ទៅហើយ តែយើងអាចផ្គុំផ្គុំមើលនូវយល់បាន។ ការមើលអត្ថន័យបង្កប់ក្នុងភាសាថ្មរូបផ្ដែរនេះ យើងត្រូវចាប់ផ្ដើមមើលពីចំណុចកណ្ដាលមុន ឯរូបនៅខាងឆ្វេង និងខាងស្ដាំ គឺអត្ថន័យប្រហាក់ប្រហែលនឹងគ្នា ទោះបីត្រូវបំផ្លាញមួយចំហៀង ក៏យើងនៅអាចស្វែងយល់មួយចំហៀងទៀតបាន ហើយក្នុងផ្ដែរនេះ រូបរឿងបានមូលមិនខ្វះដូចផ្ដែរប្រាសាទដ៏ទៃទៀតឡើយ។

១/.រូបចំកណ្ដាលផ្ដែរ

ក/.ខាងលើមានក្បាលយក្សដ៏ធំមួយ ដែលក្នុងមាត់យក្សគឺជាតួខ្លួននាគ ដែលយក្សបានលេបតាំងពីអតីតកាលមក (មើលការពន្យល់រូបមុនៗ)។ នៅខាងក្រោមខ្លួននាគដែលជាប់ទោស មានដៃយក្សកំពុងលើទ្រខ្លួននាគឡើងបញ្ចូលទៅក្នុងមាត់វិញ មានន័យថាយក្សព្រមលើករាជបញ្ជាខ្លួនឡើង ដែលរាជបញ្ជានេះបានដាក់ទោស អស់រយៈកាលជាងពីរពាន់ឆ្នាំកន្លងមកហើយ ចំពោះបុព្វដូនតា ដែលបានប្រព្រឹត្តខុសជាមួយនឹងយក្សនេះ។ និមិត្តរូបដៃទ្រខ្លួននាគបញ្ចូលទៅក្នុងមាត់វិញនេះ បានបង្ហាញពីការចុះចាញ់ ព្រមទទួលលើករាជបញ្ជាឡើង តើដោយសារហេតុអ្វី បានជាយក្សព្រមលើករាជបញ្ជាឡើង? បើខ្លួនមានឫទ្ធិអំណាចខ្លាំងៗ (មើលភាពសម្បើមរបស់យក្សក្នុងរូប) ហេតុអ្វីក៏យក្សត្រូវចុះចាញ់?

ខ/.រូបក្បាលព្រះវិស្ណុនៅចំចន្លោះកណ្ដាលក្បាលយក្ស និងនាគក្បាលបីនេះហើយ ដែលគាត់បានមកបញ្ចប់នូវពៀរវេរារបស់អ្នកទាំងពីរ តើព្រះវិស្ណុនេះគាត់បញ្ចប់ពៀររបស់យក្ស និងមាតានាគខាងក្រោម ដោយកម្លាំងឫទ្ធិអ្វី ទើបធ្វើឲ្យយក្សព្រមចុះចាញ់? នេះជាចម្លើយមួយដែលលំបាកនឹងឆ្លើយពន្យល់ ក៏ប៉ុន្តែបើយើងក្រឡេកមើលទៅក្នុងបារមី ពីអតីតកាលរបស់ព្រះពោធិសត្វគ្រប់ៗព្រះអង្គ ដែលអាចស្ដាបនាឲ្យព្រះពោធិសត្វត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធបាន គឺត្រូវបំពេញបារមីទាំង១០ ដែលបារមីទាំង១០នោះ ត្រូវបែកជាបីថែមទៀតត្រូវជា៣០ គឺមានបារមី១០ ឧបបារមី១០ បរមត្ថបារមី១០។ បារមីគឺគុណជាតិដែលត្រូវសន្សំឲ្យគ្រប់ទាំង៣០នេះ ទើបធ្វើឲ្យព្រះពោធិសត្វគ្រប់ៗព្រះអង្គ អាចត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធបាន ហើយក្នុងបារមីទាំង១០នេះ គឺមានបារមីមួយឈ្មោះថាអធិដ្ឋានបារមី។ ព្រះវិស្ណុដែលលោកអាចឲ្យយក្សព្រមចុះចាញ់ ព្រមលើករាជបញ្ជាឡើងបាន ព្រោះលោកបានបំពេញក្នុងអធិដ្ឋានបរមត្ថបារមី មានន័យថាគាត់អធិដ្ឋានឧទ្ទិស (ការតាំងចិត្ត) ជីវិតរបស់គាត់ ឲ្យទៅយក្ស ដើម្បីឲ្យយក្សឈប់ចងពៀរ ហើយព្រមដោះលែងអច្ឆរមាតាខាងក្រោម នេះជាហេតុដែលយក្សព្រមចុះចាញ់ រួចលើករាជបញ្ជាចូលទៅក្នុងមាត់វិញ។ ដូច្នេះគ្រប់ផ្ដែរ ឬរឿងលើជញ្ជាំងគ្រប់ប្រាសាទនានាទូទាំងមាតុភូមិនេះ តែងមានរូបព្រះវិស្ណុនៅត្រង់ចំណុចកណ្ដាលជានិច្ច ព្រោះព្រះវិស្ណុ ឬពោធិសត្វលោកេស្វរៈ... ត្រូវមកបញ្ចប់ពៀររបស់អ្នកទាំងពីរ។

គ/.រូបនាគក្បាលបីខាងក្រោម ដែលមានដៃព្រះវិស្ណុខាងលើចាប់ខ្សែសង្វាង ដែលចុងខ្សែម្ខាងនៅជាប់នឹងក្បាលនាគ និងចុងខ្សែម្ខាងទៀតនៅជាប់នឹងដៃយក្ស ខ្សែនេះតំណាងឲ្យចំណងពៀរវេរា

ដែលអ្នកទាំងពីរចងគ្នា ឥឡូវដល់ពេលព្រះវិស្ណុចុះមកស្រាយចំណងចងនេះ ដោយការបំពេញបរមត្ថបារមីខាងលើ។ ហើយនៅសង្ខាងរូបក្បាលនាគ មានផ្ការំយោលធ្លាក់ចេញពីចន្លោះដៃយក្សខាងលើ ដែលផ្កានេះក្លាយជានិមិត្តរូបសោខណ្ឌរូបមួយៗ ឲ្យដាច់ចេញពីគ្នា ងាយឲ្យយើងអ្នកសិក្សាស្រាវជ្រាវភាសារូប ឆាប់មើលយល់ពីសិល្បបំភាន់នេះ។

២/.រូបពីចំហៀងក្បាលគុជសីខាងស្តាំដៃយក្ស (បើកសោទ្វារទី១)

**ក**/.រូបថ្នាក់ជាន់កណ្តាលពីខាងស្តាំដៃយក្ស មាននិមិត្តរូបក្បាលគុជសី (ពន្យល់រួចហើយ) និងនិមិត្តរូបកន្ទុយនាគត្រូវយក្សលេប នៅជាប់នឹងមាត់សត្វគុជសី ដែលតួខ្លួននាគនៅជាប់ក្នុងអំណាចឃុំរបស់យក្សនៅឡើយ ព្រោះនេះជាលើកទីមួយដែលគាត់ត្រូវចាកចេញ ពីសោទ្វារជាន់ទីមួយ (មើលការពន្យល់រូបសោទាំងបួនជាន់រូបទី១)។ ហើយការបើកទ្វារលើកទីមួយនេះ បានរបើកឡើងនៅថ្ងៃ៥ ១៥១០ ឆ្នាំរោង ថ្ងៃទី២៨ ខែកញ្ញា ព.ស២៥៤៤ គ.ស២០០០ ដែលនៅក្នុងថ្ងៃនោះវេលាព្រឹក សេនាជននៅការពារសន្តិសុខ រមណីដ្ឋានភ្នំអរជ្ជរស្សកន្លែងសន្ធប់រូងនាគ(ទ្វារឃុំអច្ឆរមាតាចុះក្រោយ) គាត់បាននិយាយប្រាប់ថា កាលវេលាថ្ងៃខាងលើចិនហុងស៊ុយបានមកដុតធូប កន្លែងព្រះអង្គធំបាក់បែកនេះ ស្រាប់តែមានកើតរឿងចម្លែកមួយ គឺវិញ្ញាណនាគពីរឈ្មោលមួយ ញីមួយ (សំដីនិយាយរបស់សេនាជន) ចូលក្នុងខ្លួនចិនពីរនាក់ ហើយចិនទាំងពីរនាក់នោះ ដើរដូចដំណើរនាគហើយនិយាយថាគាត់បានរួចពីទុក្ខទោសហើយ (ហេតុភេទលើកទីមួយ កិច្ចធ្វើនៅខេត្តព្រះសីហនុរួចនៅអរជ្ជរស្ស) ។

**ខ**/.រូបក្បាលនាគខាងក្រោម ដែលចេញពីមាត់ទ្វារលើកទីមួយ បានបែរមុខចូលមកខាងក្នុង ហើយមានរូបព្រះវិស្ណុតូចមួយ នៅអង្គុយពីខាងក្រោយនាគក្បាលបីនោះ ដែលនៅសង្ខាងមានទងផ្កាខណ្ឌជាប់។ កាលគាត់ចេញពីទ្វារគឺរូមតូច ពេលចេញផុតមកដល់ក្រោមទើបរីកធំ ដែលគាត់ចេញពីទ្វារទីមួយមក រួចបែរក្បាលចូលមកខាងក្នុង គឺមានន័យថាគាត់ចេញមកក្នុងប្រទេសខ្មែរនេះ មើលគ្រោះធម្មជាតិក្នុងឆ្នាំនោះ ដែលគាត់បានសម្តែងពីមហិទ្ធិឫទ្ធិឲ្យកូននាគប្រុសស្រីដឹងថា បណ្តាសានេះគាត់ចង់ព្រមានកូននាគប្រុសស្រី ដែលពុំដឹងគុណគាត់ (ទំនួញប្រេត បណ្តាសាប្រេត)។ ចំណែកឯរូបព្រះវិស្ណុដែលរូមតូច បានបង្ហាញប្រាប់យើងឲ្យដឹងថា គាត់ពុំអាចយករឿងនេះទៅប្រាប់ឲ្យអ្នកណាឲ្យគេជឿ និងជួយគាត់បានឡើយ ព្រោះរឿងអច្ឆរមាតាវាធំហួសពីឋានៈរបស់គាត់ នេះម្យ៉ាងៗទៀតថ្នាក់ខាងក្រោម ដែលអច្ឆរមាតាចេញមកខាងក្រៅនេះ មានន័យថាអ្នកដឹងនឹងនាំអច្ឆរមាតាចេញ ឋានៈគាត់ស្មើនឹងប្រជារាស្ត្រសាមញ្ញ (មើលការពន្យល់ពាក្យបន្ទាយសំរិទ)។ ហើយក្នុងឆ្នាំដដែលនោះ មាន

ភូតហេតុនាគផុះច្រើនកន្លែង ធ្វើឲ្យកូននាគមានការងឿងឆ្ងល់រហូតមកដល់សព្វថ្ងៃពីរឿងនាគផុស ដោយពុំដឹងថាកើតចេញពីហេតុអ្វី? ពេលចេញពីទ្វារទីមួយរួចហើយ គាត់ត្រូវត្រឡប់ចូលទៅក្នុងឃុំ ដើម្បីបើកសោទ្វារទីពីរជាបន្តទៀត។

៣/.រូបក្បាលគុជសីខាងស្ដាំដៃយក្សបន្ទាប់ទី២(បើកទ្វារទី២)

ក/.រូបក្បាលគុជសីទីពីរនេះក៏ដូចរូបទីមួយដែរ រូបនេះតំណាងឲ្យទ្វារជាន់ទីពីរ ដែលព្រះវិស្ណុជាកូននាគត្រូវនាំមាតាចេញជាលើកទីពីរ (មើលប្លង់ប្រាសាទបន្ទាយសំរែផ្លូវចូលសព្វថ្ងៃ)។ សោទ្វារទីពីរនេះ ត្រូវបានរបើកឡើងនៅថ្ងៃ៤ ១២ ២ ឆ្នាំមមី ទី២៩ ខែមករា ព.ស២៥៤៦ គ.ស២០០៣ សូមកូននាគស្រាវជ្រាវមើលហេតុភេទក្នុងថ្ងៃនោះដែលកើតមានក្នុងនគរ ។

ខ/.និមិត្តរូបនាគដែលព្រះវិស្ណុជិះចេញមកខាងក្រៅ ក្នុងទ្វារទីពីរនេះ ក៏ដូចជានិមិត្តរូបក្នុងទ្វារទីមួយដែរ ព្រោះរូបព្រះវិស្ណុនៅតូច ហើយក្បាលនាគបែរចូលមកខាងក្នុងនគរដដែល ក្នុងចន្លោះទ្វារទីមួយ និងទ្វារទីពីរនេះ មានរយៈពេលជិត៧ឆ្នាំ។ រួចគាត់ត្រូវត្រឡប់ចូលទៅក្នុងឃុំវិញ ព្រោះគាត់ត្រូវសន្សំបុណ្យគឺបារមីព្យាយាមបើកសោទ្វារទីបីជាបន្តទៀត ដោយអំណាចរំយោលផ្កាខណ្ឌរបស់យក្សគឺត្រូវតែធ្វើដូច្នេះ។

៤/.រូបក្បាលគុជសីខាងស្ដាំដៃយក្សបន្ទាប់ទី៣(បើកទ្វារទី៣)

ក/.ក្នុងសោទ្វារមាត់គុជសីលើកទីបីនេះ ត្រូវបំបែកខ្នែងជាពីរទៀតបើតាមមើលរូប ព្រោះនិមិត្តរូបក្បាច់ដែលនៅក្នុងខណ្ឌរំយោលផ្កា មានរាងដូចជាក្បាលនាគបែរចេញទៅខាងក្រៅ មានន័យថាជាសោទ្វារមួយដែរ ព្រោះមានរំយោលខណ្ឌសង្ខាង។ សោទ្វារនេះបានបើកឡើងនៅថ្ងៃទី១១ ១ ឆ្នាំរកា ទី២៦ ខែធ្នូ ព.ស២៥៤៨ គ.ស២០០៤ គឺថ្ងៃដែលមានកើតគ្រោះធម្មជាតិរលកយក្សស៊ូណាមី ព្រោះនិមិត្តសញ្ញាក្បាច់បានប្រាប់យើងថា គាត់ឈប់បែរចូលមកខាងក្នុងទៀតហើយ គឺសញ្ញាក្បាច់បែរចេញទៅខាងក្រៅ (គាត់ចេញពីឃុំទៅខាងក្រៅនគរ ឬប្រទេស)។

ខ/.ក្បាលនាគនិមិត្តសោទីបីនេះ គឺគ្មានរូបព្រះវិស្ណុជិះទៀតទេ ដោយព្រះវិស្ណុបានដេកបាត់ទៅហើយ (មើលការពន្យល់រូបទី៧២) ក្បាលនាគនិមិត្តនេះ ដូចជាការសម្ដែងឫទ្ធិឲ្យពិភពលោកស្គាល់ពី



អំណាចគាត់ បើមើលរូបរលកយក្សស៊ូណាមិពីលើ យើងឃើញដូចជារូបនាគមួយកំពុងពត់ពែនខ្លួនបង្ហាញពីឫទ្ធានុភាព ហើយគាត់ត្រូវត្រឡប់ចូលទៅក្នុងទីឃុំវិញ ដើម្បីបើកទ្វារជាលើកចុងក្រោយ។

៥/.សោទ្វារជាន់ទីបីក្នុងទ្វារលើកទីពីរ ក្នុងទ្វារចុងក្រោយនេះ ក្បាច់រំយោលដែលធ្លាក់ចុះមកខណ្ឌ ឲ្យកើតជាវគ្គៗនោះ ឥឡូវនេះបើយើងមើលតាមរូបភាព គឺក្បាច់រំយោលនោះ ធ្លាក់ចេញពីមាត់គុជសីក្នុងទ្វារទីបីនេះបានតែបន្តិច រំលងចុះមកខណ្ឌបានទៀតហើយ។ ចុងក្រោយនេះ នាគដែលជានិមិត្តរូបអច្ឆរមាតា បានចេញតាមច្រកទ្វារនេះដោយរលូន តាមទំហំរូបរាងពិតប្រាកដ មិនដូចជាចេញទាំងបីលើកពីខាងដើមឡើយ គឺចេញមកដោយពេញលក្ខណៈ (មានសេរីភាពពេញលេញ)។ ឯរូបព្រះវិស្ណុដែលធ្លាប់តែតូចពីមុននោះ ក្នុងរូបចុងក្រោយនេះគាត់បានរីកធំទៅតាមគុណធម៌ ក្បាលនាគក៏ធំទៅតាមសភាពដើម ហើយបែរចេញទៅក្រៅ ប៉ុន្តែចេញចុះមកខាងក្រោមដដែល មានន័យថាកូននាគប្រុសស្រី ពុំទាន់មាននរណាព្រមទទួលស្គាល់គាត់ឡើយ។ នៅទ្វារចុងក្រោយនេះគាត់ចេញមកស្ថិតនៅលើបល្ល័ង្កមួយ ដែលនៅខាងក្រោមបល្ល័ង្កគឺមានកូនស្វាតូចមួយ កំពុងទ្រសែងបល្ល័ង្កនោះចេញ សកម្មភាពរបស់កូនស្វានេះ ខ្លួនតូចទេតែអាចលើកទ្របល្ល័ង្ក និងរូបដ៏ធំខាងលើរួច (មើលរូបខាងឆ្វេងដៃយក្ស)។ កូនស្វានេះក៏តំណាងឲ្យកូននាគម្នាក់ដែលបានដឹង និងយល់ពីរឿងពិតរបស់អច្ឆរមាតាមហានគរ ហើយខ្លួនជួយគាំទ្រហែហមគាត់ ចេញពីទីឃុំឃាំង ទោះបីជាខ្លួនស្ថិតក្នុងស្រទាប់ឋានៈខាងក្រោមក៏ដោយ ( **មើលការពន្យល់ពីស្វារូបទី ៧៥**) ។

៦/.រូបផ្ដែរជាន់ខាងលើ បង្ហាញពីមនុស្សបីនាក់ស្ថិតនៅទាំងសង្ខាងក្បាលយក្ស ហើយរូបមនុស្សទាំងបីសង្ខាងនោះ នៅពីលើក្បាលគុជសី ដែលពុំដឹងមានកាន់អ្វីក្នុងដៃឡើយ ព្រោះរូបបានបាក់បែកអស់ទៅហើយ លំបាកនឹងមើលឲ្យយល់បានណាស់ ដោយលក្ខណៈរូបបាត់បង់ស្ទើរតែទាំងអស់ទៅហើយ ដូច្នេះខ្ញុំមិនអាចបកពន្យល់បានឡើយ ព្រោះឯកសារពុំគ្រប់គ្រាន់។

សរុបសេចក្ដីមកអត្ថន័យភាសាគំនិតបង្កប់ក្នុងរូប ផ្ដែរដែលនៅសេសសល់នេះ ព្រឹទ្ធដូនតាយើងគាត់បានលួចឡើង មកចង្អុលបង្ហាញកូននាគក្នុងសម័យនោះ ឲ្យដាប់ឆ្លាក់រឿងទាំងនេះទុកដើម្បីជាប្រយោជន៍ដល់កូននាគសម័យក្រោយ អាចយកមកធ្វើជាត្រីវិស័យសម្រាប់ចង្អុលបង្ហាញផ្លូវកុំឲ្យវង្វេងភាន់ច្រឡំ អស់សេចក្ដីព្យាយាម ព្រោះតែការរារាំងពីអ្នកដទៃ ដែលពួកគេទាំងនោះពុំបានយល់រឿង។ អច្ឆរមាតាលោកបានដឹងជាមុនថា ក្នុងការបើកសោទ្វារទាំងបីជាន់នេះ បុគ្គលដែលជាកូននាគនោះ ត្រូវក្រាញនន្សៀលរងគ្រប់សម្ពាធទុក្ខ ដែលសង្កត់ប្រៀបបីដូចបុគ្គលទ្រភ្នំ ឬឱបភ្នំ ព្រោះការលើកស្ពាន និងរកស្ពានទៅភ្ជាប់រឿងពីអតីត និងបច្ចុប្បន្នឲ្យជាប់គ្នា គឺពុំងាយស្រួលឡើយ (មើលការពន្យល់រូបវិស្ណុដេកក្បាលស្ពាន)។

## III.អត្ថន័យសាសនមាតាបង្កប់ក្នុងថ្ម(ពាក្យប្រៀនប្រដៅរបស់អច្ឆរមាតាឲ្យមើលថ្ម)

ក/.យើងដឹងហើយថា ការចូលទៅទស្សនាគ្រប់ប្រាសាទថ្ម ដែលអច្ឆរមាតាបានបន្សល់បណ្ដាំទុក ជាដំបូងគឺនៅខ្លោងទ្វារចូល ដែលនៅលើខ្លោងទ្វារនោះមានផ្ដែរ (ពន្យល់រួចហើយ) ហើយផ្ដែរនោះមានខាងក្រៅ និងខាងក្នុង ដែលគ្រប់ផ្ដែរទាំងអស់ភាគច្រើន គឺមានសសរដែលទ្រនៅបណ្ដាំម៉ែនោះ ឈ្មោះថាសសរពេជ្រ។ ហើយពីផ្ដែរឡើងទៅក្បាំងក្លែង ឬបាំងក្លែង (ពន្យល់រួចហើយ) តែងមានល្បាក់ថ្មលយចេញ ដែលគាត់ចង់ឲ្យយើងដឹងថា ការឡើងតាមផ្ដែរទៅលើ ត្រូវឆ្លងកាត់ល្បាក់លយចេញមួយ ហើយល្បាក់នេះបើយើងពុំមានដៃស្អិតដូចជីងចក់ ឬតុកកែទេ ពុំអាចឆ្លងទៅតំណាក់ក្បាំងបានឡើយ (នេះជាប្រស្នារបស់គាត់)។ ដូច្នេះការដឹងរឿងក្នុងផ្ដែរគឺមិនទាន់ចប់នូវឡើយ ត្រូវឡើងទៅមើលរឿងជាបន្តនៅលើក្បាលគាត់ថែមទៀត ដែលក្បាលនោះមានក្បាំងពាក់បំភាន់ ដើម្បីការពារការរុករកស្រាវជ្រាវ របស់អ្នកមកពីខាងក្រៅ (បរទេស)។ បើយើងឡើងតាមសភាពធម្មតា គឺបានត្រឹមថ្នាក់ផ្ដែរតែប៉ុណ្ណោះ យើងលំបាកឆ្លងទៅល្បាក់ខាងលើទៀតបានណាស់ (មើលឯកសារឡើងជញ្ជាំងភ្នំដែលមានល្បាក់លយចេញ) ដូចនេះទើបរូបនៅសសរទ្វារទន្លេបាត់ទី (រូបទី៧២ និង៧៣) ចុង

ក្រោយត្រូវបាត់រូបព្រះវិស្ណុ ព្រោះតំណាក់កាលឆ្លងកាត់ល្បាក់លយចេញនេះ ជាតំណាក់កាលលំបាក។ អច្ឆរមាតាគាត់ចង់ប្រាប់យើងថា បណ្ដាំអាចិកំបាំងរបស់គាត់ គឺលំបាកនឹងយល់បានណាស់ ប្រៀបបីដូចជាបុគ្គលដែលសិក្សាបរមត្ថធម៌អភិធម្មយ៉ាងដូច្នោះ សិក្សាបានចេះចាំហើយធ្វើឲ្យការត្រាស់ដឹងនៅសច្ចធម៌ រឹតតែលំបាកជាងការសិក្សាទន្ទេញនោះទៅទៀត ព្រោះគោត្រភូញាណពីបុថុជ្ជនឆ្លងទៅកាន់លោកុត្តរបាន ត្រូវសន្សំបុណ្យយ៉ាងតិចក៏មួយសែនមហាកប្បដែរ កុំថាឡើយគោត្រភូលោកុត្តរ សូម្បីតែកាមាវចរចិត្តឆ្លងទៅរូបាវចរចិត្ត និងអរូបាវចរចិត្តនោះ មនុស្សយើងសព្វថ្ងៃនេះ គឺឆ្លងបានដោយលំបាកណាស់។

៦/.អច្ឆរមាតាគាត់ផ្ដាំជាបន្តទៀតថា បើកូនឆ្លងផុតតំណាក់ផ្ដែរនេះហើយ កូនត្រូវឆ្លងចូលតំណាក់ក្បាំង ហើយក្បាំងនេះបើយើងក្រឡេកមើលក្បាំងប្រាសាទអង្គរវត្ត យើងច្បាស់ជាអស់កម្លាំងនឹងឡើងជាពុំខាន ព្រោះក្បាំងមានច្រើនជាន់ថ្នាក់ ហើយគ្រប់ជាន់ថ្នាក់ក្នុងក្បាំងទាំងនោះ មានរឿងរបស់គាត់និងកូននាគ រួមទាំងអ្នកដែលមានពៀរវេរានឹងគាត់ផង តាមឈ្មោនីសដាក់ទោសគ្រប់ជាន់ថ្នាក់។ ដូចរូបទី៨៨ដែលបានពន្យល់រួចមកហើយនេះ បានបង្ហាញប្រាប់យើងថា និមិត្តរូបអច្ឆរមាតាទំរាំតែអាចចេញមកបង្ហាញស្រមោល ពីអតីតកាលរបស់គាត់បានម្ដងៗ ត្រូវប្រើរយៈពេលដ៏យូរ ទើបអាចចេញរួច បង្ហាញរួចហើយត្រូវចូលក្នុងបន្ទប់ឃុំមួយថ្មីផ្សេងទៀត ដើម្បីរកនៅគន្លិះបើកទ្វារឃុំឃាំងជាបន្តទៀត។

៧/.យើងមានគ្រឿងសក្ការមួយបែបហៅថា "**បាយសី**" ហើយយើងតែងតែយល់ថា បាយសីគឺជាឥទ្ធិពលរបស់ព្រហ្មញ្ញសាសនាទៀតផង តែតាមពិតគឺពុំមែនដូច្នោះឡើយ។ បាយសីពាក្យពិតពីមុនគឺមានឈ្មោះថា "**បាចសី**" តែពាក្យនិយាយបានយារក្លាយជាបាយសី ពាក្យថាបាចសី ⇨ បិសាច តើអ្នកណាជាបិសាច ដែលយើងនាំគ្នារៀបគ្រឿងសក្ការនេះថ្វាយបូជា? បិសាចគឺអច្ឆរមាតាមហានគរដែលអ្នកការទូតចិនជិវតាក្វាន់ បានស្គាល់តាមរយការហៅ របស់អ្នកស្រុកចេនឡាក្នុងសម័យនោះ ព្រោះបិសាចពស់ ឬនាគនេះ (មើលការពន្យល់រូបទី៧៩) គឺជាទេវតា ឬព្រះភូមិ ដែលជាអ្នកថែរក្សាព្រះនគរនេះទាំងមូល។ ដូច្នេះហើយទើបព្រឹទ្ធដូនតាបានបន្សល់ទុកនូវ វត្ថុជាគ្រឿងសក្ការបូជានេះ ជានិមិត្តរូបសម្រាប់បង្ហាញជាតំណាងជំនួសរូបគាត់ បើយើងមើលតាមលក្ខណៈរូបរបស់បាចសី គឺដូចជាក្រចកម្រាមដៃទាំងប្រាំ (កូនបាយសីដែលគេកាច់ទាំងប្រាំ) របស់ស្ត្រីដែលពុំធ្លាប់បានកាត់ ដូចនេះក្រចកត្រូវតែតូចវែង ហើយស្រួច (មើលក្រចកដៃមហាក្សត្រីចិន ក្នុងរឿងភាគ ឬក្រចកព្រាយបិសាច)

។ ក្រចកទាំងប្រាំតំណាងឲ្យកូនរបស់បាយសី បានឡើងបន្តគ្នាជាថ្នាក់ៗមានន័យថា អច្ឆរមាតាលោកប្រឹងប្រវាឡើង លួចចេញពីទីឃុំក្នុងសមុទ្រទឹកដោះ ដើម្បីឡើងមកជួបនឹងកូនសម័យនោះ ផ្តល់ឱវាទឲ្យកូន នឹងទុកនូវប្រស្នាបាចសីនេះ។ បើយើងមើលថ្នាក់ក្បាំងក្លែងរបស់ប្រាង្គប្រាសាទនីមួយៗ និងមើលទម្រង់ថ្នាក់របស់បាយសី អត្ថន័យខាងក្នុងបង្កប់គឺដូចគ្នា គ្រាន់តែមួយជាក្បាំងពាក់នៅលើក្បាល និងមួយទៀតនៅចុងក្រចក ហើយបាចសីនេះគឺមានតែនៅក្នុងស្រុកខ្មែរយើងតែប៉ុណ្ណោះ ព្រោះវាជារឿងប្រស្នារអាថិកំបាំងរបស់បិសាចពស់ ឬនាគ (អច្ឆរមាតាមហានគរ)។

ដូច្នេះទើបប្រាសាទបន្ទាយស្រី មានឈ្មោះហៅក្រៅមួយទៀត គឺ **"ប្រាសាទកាច់បាយសី ឬកាច់បាចសី"** ព្រោះអត្ថន័យសាច់រឿងក្នុងថ្មរបស់ប្រាសាទនេះ បាននិយាយរៀបរាប់ពីការកាច់បំបាក់ ភាពរុងរឿងរបស់ស្ត្រីជាអច្ឆរមាតា គឺព្រះមាតានាគ (បិសាចពស់) ហើយចាប់គាត់យកទៅឃុំ និងចុងក្រោយមានកូននាគមានឈ្មោះថា ព្រះវិស្ណុ ឥសូរ លោកេស្វរៈ....បានជិះគោដឹកព្រះម៉ែចេញ (មើលការពន្យល់ពីសត្វគោភាគ២)។ គ្រប់គ្រូមន្តអាគម (ជាអ្នកមានជំនឿលើព្រហ្មញ្ញសាសនា) តែងរៀបគ្រឿងសក្ការមានបាយសី ដូងស្លាធម៌ជាតំណាងឲ្យគ្រូតូចធំ ដែលជាគ្រូដើមទៅតាមថ្នាក់បាយសី តែពួកគាត់ទាំងនោះ ពុំដែលបានគិតរកប្រស្នារអាថិកំបាំង ក្នុងវត្ថុសម្រាប់បូជាទាំងនេះឡើយ គឺគ្រាន់តែដឹងថាបូជាឲ្យគ្រូដើមតៗគ្នាតែប៉ុណ្ណោះ មិនដឹងថាគ្រូដើមដំបូងរបស់ខ្លួនជាអ្នកណាឡើយ ហើយតែងទម្លាក់គ្រឿងសក្ការទាំងនេះ ថាជាកេរតំណែលបន្សល់ពីឥទ្ធិពលព្រហ្មញ្ញសាសនា។

២/.គ្រឿងសក្ការដែលអមជាមួយបាយសី គឺដូងស្លាធម៌ តើដូងស្លាធម៌មានអត្ថន័យដូចម្តេចទាក់ទងនឹងរឿងអច្ឆរមាតា? ដូងស្លាធម៌គេតែងតែយកដូងខ្ចី និងទុំមកធ្វើ ប្រស្នារបស់ឈ្មោះផ្លែដូងនេះខ្ញុំបានបកពន្យល់រួចហើយ ពីល្បែងចាក់ទឹកដូង ក្នុងអាថិកំបាំងបណ្តាំមាតាមហារនគរខ្មែរភាគ១។ ឥឡូវនេះខ្ញុំគ្រាន់តែលើកយកពីប្រស្នាម្លូស្លាកំបោរ មកបកពន្យល់ថា ហេតុអ្វីបានជាវត្ថុទាំងបីនេះយើងតែងនាំគ្នាហូបបន្តគ្នា ហើយជាពិសេសទៅទៀតនោះ គឺបូជាព្រះធម៌ (ដូងស្លាធម៌)។ ស្លឹកម្លូតំណាងឲ្យភេទរបស់ស្ត្រី ព្រោះរាងរបស់ស្លឹកនេះ ដូចភេទរបស់ស្ត្រី ស្លាតំណាងឲ្យសាច់របស់បេះដូង (បេះដូងព្រះមាតាពោរពេញដោយភាពចត់) ព្រោះបេះដូងសត្វ ឬមនុស្ស ពេលដែលយើងហាន់បេះដូងសត្វ មានសាច់ជាន់ៗ ដូចជាសាច់ផ្លែស្លា រីឯកំបោរវិញ គឺតំណាងឲ្យថ្ម អាចបំបែកថ្មឲ្យទៅជាកំបោរបានលុះត្រាតែដុត (ធ្វើតបៈធម៌) ទើបអាចដឹងរឿងក្នុងថ្ម។ វត្ថុទាំងបីនេះ ពេលដែលបានទំពារចូលគ្នាគឺក្លាយដូចជាឈាម ហេតុអ្វីបានជាភាគច្រើនស្ត្រីដែលចាស់ៗ គេឲ្យហូបម្លូស្លា? ព្រោះស្ត្រី

ដែលចាស់ គាត់ឈប់មានឈាមរដូវ ហេតុនេះគាត់ពុំអាចបង្កើតបុត្របានទៀតឡើយ ប្រស្នាហូបម្លូស្លានេះ គាត់ចង់ប្រាប់យើងជាកូនតាគថា កូនខ្មែរដែលកំពុងយកភេទ (យោនី) ម៉ែមកជេរ អ្នកត្រូវសម្លឹងមើលទឹកមាត់ស្លា ដែលស្តោះចេញពីមាត់ស្ត្រីហូបម្លូ ន័យរបស់គាត់ចង់ប្រាប់យើងថា អនាគតជាតិរបស់អ្នកនោះ នឹងកើតជាប្រេតស៊ីខ្ទុះឈាម លាមក....ព្រោះភេទរបស់ម៉ែសម្រាប់បង្ហូរចេញនូវឈាម ទឹកមូត្រ និងកាកសំណល់ផ្សេងៗពេលប្រសូតបុត្រ ហើយបើអ្នកនោះយកភេទម៉ែមកដាក់ក្នុងមាត់ (ជេរម៉ែ) តើឲ្យពួកគេមានកំណើតក្នុងសុគតិភពម្តេចបាន? ដូច្នេះហើយទើបស្ត្រីដែលចាស់ ត្រូវហូបម្លូស្លាបន្តគ្នា ដើម្បីទុកជាប្រស្នាឲ្យកូនតាគសម័យក្រោយពិចារណា ទើបនៅក្នុងច្បាប់ប្រុសស្រីដូនតាបានផ្តាំទុកថា "**ស្លាម្លូស៊ីឲ្យច្រៀក កុំបីបៀកទាំងមូលមិញ តូចធំឲ្យច្រៀកចេញ តាមពាក្យចាស់ថាអភ័ព្វ**" ក្នុងន័យនេះហើយ ដែលយើងពុំដឹងអត្ថន័យក្នុងប្រស្នានេះ ព្រោះយើងពុំបានច្រៀកគិតពិចារណា រកហេតុផលពិតពីវត្ថុទាំងបីនេះ។ ហើយម្លូស្លាកំប្រោរនេះ មានឋានៈនៅលើអាសនៈសម្រាប់គោរពបូជា ដែលខុសពីរុក្ខជាតិផ្សេងៗ នឹងនៅក្នុងពិធីមង្គលដទៃផ្សេងៗ ដូចជាក្នុងមង្គលការគេបានរៀបម្លូពាន់ស្លាពាន់ (ម្លូព័ន្ធស្លាព័ន្ធ) តើន័យរបស់**ពាន់** និង**ព័ន្ធ**នេះ ន័យមួយណាជាន័យពិតដែលបានបង្កប់ក្នុងពាក្យនិយាយនេះ?

**គ**/.ហេតុអ្វីបានជាអច្ឆរមាតាយកបណ្តាំទៅទុកក្នុងថ្ម?

គ្រប់ប្រាង្គប្រាសាទទាំងអស់របស់ខ្មែរ ពុំដែលបានសរសេររៀបរាប់សាវតារឿង ទុកនៅលើប្រាសាទឡើយ បើសរសេរគឺគ្រាន់តែកំណត់កាលបរិច្ឆេទ ក្នុងការកសាងរបស់ស្តេចអង្គមួយៗ និងឧទ្ទិសដល់បុគ្គល ដែលមានឧបការៈតែប៉ុណ្ណោះ ចំណែកឯរឿងពិតរបស់គាត់ គេពុំបានសរសេរអក្សរជាសាច់រឿងឡើយ គឺគេដាប់ឆ្លាក់ចារឹករូបជារឿងសុទ្ធតែម្តង ដូចជាយើងទស្សនាខ្សែភាពយន្ត។ ហេតុតែអច្ឆរមាតាយករឿងទៅទុកក្នុងថ្ម ព្រោះបណ្តាវត្ថុក្នុងលោក វត្ថុដែលអាចទុកឯកសារបានយូរជាងគេ គឺមានតែថ្ម ឯវត្ថុដទៃដូចជា ស្បែក ក្រដាស ឈើ ស្លឹក ស្ពាន់ ប្រាក់....ពុំអាចរក្សាទុកឯកសារបានយូរឡើយ ម្យ៉ាងទៀតបើចង់សរសេរភាសារូប ក៏លំបាកនឹងសរសេរទៀតផងព្រោះត្រូវការទីវែង។ ចំណែកឯថ្មវិញមានសភាពរឹងមាំ នឹងអាចទុកឯកសារសាវតាបានយូរ (ចំពោះគ្មានការបំផ្លាញ) ហើយលោកដឹងថា កសាងតិចតួចគឺពុំបានទៀត ដោយកម្លាំងនៃការបំផ្លាញទៅថ្ងៃក្រោយមានទំហំធំព្រោះពូជជ័យដែលទទួលមរតកគាត់ ក្លាយជាពូជចាញ់ (មើលរឿងអាជ័យមេរត ឬមេត្រត) ដូច្នេះបើពួកគេបំផ្លាញអស់មួយ គឺនៅសល់មួយ បំផ្លាញលើគោកអស់នៅសល់ក្នុងទឹក និងក្នុងដី...។ល។ ទម្រាំ

តែដល់គម្រប់ឆ្នាំដែលគាត់ត្រូវរួចពីទោស ឯកសារថ្មទាំងនេះក៏នៅសេសសល់ អាចឲ្យកូននាគដែលមានឧបនិស្ស័យ ជាមួយនឹងគាត់គេមើលយល់ គេអាចនឹងជួយគាត់បាន នេះជាហេតុដែលកូនជ័យសម័យអង្គរ កសាងប្រាសាទថ្មបន្តគ្នា រហូតដល់តំណាក់កាលចុងក្រោយ គឺស្ដេចជ័យវរ្ម័នទី៧ ដែលកូនគាត់នេះហើយ បានតែងនិទានរឿងជ័យទុកសម្រាប់ទៅថ្ងៃអនាគត នឹងកើតមានកូនជ័យពីរ ជ័យទីមួយគឺជ័យសួស្ដី ឬធនជ័យ ឯជ័យទីពីរគឺជ័យមេរត ឬមេត្រត គឺកូនជ័យក៏លូង់ហើយចាញ់ ឯមេដែលធ្លាប់តែនៅពីលើគេ (**មេដំបូល**) ឥឡូវមេមកធ្វើជាមេរត ឲ្យគេក្រាលរនាបរួចគេដើរ គេដេក គេអង្គុយ គេជាន់ពីលើ (ប្រស្នានៅក្នុងរឿង)។ សាច់រឿងទាំងពីរបានប្រាប់ពីឈ្មោះអ្នកនិពន្ធ ឬម្ចាស់រឿងរួចទៅហើយ នៅក្នុងតួឯកប្រុសស្រីនោះ ហើយគាត់បានដឹងទៀតថា តទៅថ្ងៃមុខធនធានជ័យពីអតីត ត្រូវធ្លាក់ទៅក្នុងទឹកអស់ហើយ មើលពាក្យបន្ទរក្នុងរឿងធនជ័យៗបានស្រែកប្រាប់ថា "**អាជ័យធ្លាក់ទឹកហែអើៗ**" ដែលធ្លាក់ទឹកពិតប្រាកដនោះ គឺសមិទ្ធិផលកេរមរតករបស់ដូនតា ជ័យជំនាន់មុនទេតើ ដែលត្រូវធ្លាក់ទឹកនោះ តើយើងជាពូជកូនជ័យ ពូជកូននាគគួរនាំគ្នាស្រង់កេរមរតកជ័យយ៉ាងដូចម្ដេចហ្ន៎? ដូចក្នុងប្រស្នានំមួយដែលយើងបានស្គាល់ នឹងធ្លាប់ហូបនោះ គឺនំបញ្ចុកបុន្ម៉ៃប៉ែនចុក តើឈ្មោះរបស់នំនេះ កើតចេញពីអ្នកណាជាអ្នកដាក់? ឈ្មោះរបស់នំនេះ កើតចេញពីធនជ័យជាអ្នកដាក់ ហើយឈ្មោះនំនេះកើតមានរឿងអ្វីខ្លះ ចំពោះធនជ័យ? បើយើងមើលតាមសាច់រឿងរបស់ធនជ័យ គាត់គឺជាព្រះពោធិសត្វលោកេស្វរៈ ដោយហេតុអ្វី? ត្រង់វគ្គដែលគាត់ស្វែងរកភរិយានោះ គាត់បានស្វែងរកស្ត្រីដែលមានប្រាជ្ញា គឺស្រីសួស្ដី ឯក្នុងទសជាតកព្រះមហោសថ ព្រះអង្គគឺព្រះពោធិសត្វដែលជាអតីតជាតិ របស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង អត្ថន័យរឿងក៏ដូចជារឿងរបស់ធនជ័យដែរ ពេលដែលព្រះមហោសថស្វែងរកភរិយា ព្រះអង្គបានស្វែងរកស្ត្រីដែលមានប្រាជ្ញាទីបំផុតបានជួបនឹងនាងអមរា ដែលជាស្ត្រីមានរូបសម្បត្តិនិងបញ្ញាសម្បត្តិ ចំណុចត្រង់នេះហើយដែលយើងអាចយល់បានថាធនជ័យគឺជាព្រះពោធិសត្វលោកេស្វរៈ ព្រោះព្រះបាទជ័យវរ្ម័នទី៧លោកបានដកយកអត្ថន័យ ចេញពីរឿងព្រះមហោសថ សម្រាប់ឲ្យយើងជា កូននាគពិចារណាពីតួអង្គធនជ័យ។ ហើយពាក្យជ័យនិងសួស្ដីនេះ គេតែនាំគ្នាស្រែកសួគ្នាក្នុងពិធីមង្គលការថា ជ័យហង សួហង គឺមានន័យថា ជ័យផងសួស្ដីផង ហើយមានអ្វីជាបន្ទាល់ (សម្គាល់) គេក៏នាំគ្នាគោះគង ដែលសម្លេងគងនេះ ជាសញ្ញាប្រាប់ថា ពេលទ័ពចូលសមរភូមិសម័យដើម តែងគោះសម្លេងគងស្គរ ដែលអ្នកសែងស្គរនិងគងដើមទន្ទឹមអ្នកកាន់ទង់ជ័យ (សម្លេងគង គឺជាសម្លេងឈ្នះក្នុងសមរភូមិ)។ សព្វថ្ងៃគេយល់ថាពាក្យជ័យនិងសួនេះ ដកចេញពីរឿងព្រះបាទត្រសក់ផ្អែមនិងសួសជាប្អូន នឹងដកចេញពីតួអង្គសួស

ក្នុងរឿង អនណើយស្រីអន ចំណុចត្រង់នេះសូមមិត្តអ្នកអានស្វែងរកចម្លើយពិតដោយខ្លួនឯងចុះ ព្រោះក្នុងមង្គលការគេត្រូវយកលំនាំបុគ្គលដែលឈ្មោះមានពីរនាក់ គឺស្ត្រីម្នាក់បុរសម្នាក់ ដើម្បីធ្វើជាតំណាងឲ្យសិរីមង្គល ដល់កូនប្រុសស្រីរបស់ពួកគេ។

រីឯឈ្មោះនំប៉ែនចុកវិញគឺកើតមានក្នុងពេល ដែលគាត់ត្រូវស្តេចបំបរបង់ទៅស្រុកចិន ព្រោះហេតុតែខ្លាចញញើតបញ្ញារបស់គាត់ ហើយនំនេះឈ្មោះរបស់វាបានកើតឡើង ក្នុងពេលដែលស្តេចចិនចង់បរិភោគ។ ធនជ័យគាត់បានបញ្ជាឲ្យស្តេចចិន តាមងើយមើលសរសៃនំ រួចគាត់បានពោលតិះដៀលថា "**មើលមុខស្តេចចិនដូចជាមុខឆ្កែ មើលមុខស្តេចខ្មែរដូចខែពេញបូណ៌មី**" មានន័យថាចិនបានតាមព្យាបាទដល់ពូជជ័យរបស់គាត់ ទីបំផុតអំពើបាបកម្មនេះធ្វើឲ្យបុគ្គលអ្នកប្រព្រឹត្ត នឹងធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិបួន មាននរក ប្រេត តិរិច្ឆាន អសុរកាយ ហើយតិរិច្ឆាននេះជានិមិត្តរូបតំណាងឲ្យសត្វឆ្កែ។ ចំណែកពាក្យថាមើលមុខស្តេចខ្មែរដូចខែពេញបូណ៌មី គាត់ចង់ឲ្យស្តេចចិនមើលមុខរបស់គាត់ពេលដែលងើយមុខឡើង ព្រោះគាត់មានកំណើតកើតចេញពីមហាសុបិន្តរបស់ម្តាយគាត់ "**យល់សប្តិយល់សូង យល់សប្តិឃើញដូង បេះបានទាំងផ្លែ យល់សប្តិឃើញខែៗពេញបូណ៌មី**" ព្រោះគាត់គឺជាស្តេចបញ្ញា ដែលមានពន្លឺភ្លឺស្រទន់មិនបៀតបៀនគេ សុខចិត្តស៊ូទ្រាំលំបាកគ្រប់បែបយ៉ាងដើម្បីខ្មែរ។ កំណើតខ្លែងឯក ក៏កើតមានពេលដែលគាត់ជាប់គុក (មើលរឿង) ព្រោះគាត់ចង់ប្រាប់ស្តេចចិនថា អ្នកមិនអាចយកនគរនេះបានឡើយ ឲ្យតែពូជជ័យនៅរស់ ឯកខ្មែរនៅតែស្រែកខ្ទរពេញផ្ទៃអាកាសដដែល គ្រាន់តែបច្ចុប្បន្នយើងយកក្បាលក្រពើ មកពាក់ពីមុខឯកឲ្យឈប់ស្រែកជាបណ្តោះអាសន្នតែប៉ុណ្ណោះ (មើលល្បែងចាក់ទឹកដូង) ពេលដែលយើងនាំគ្នា ដោះក្បាលក្រពើចេញវិញ ឯកនៅតែស្រែកបង្ហាញពីមោទនភាពអច្ឆរិយ (អច្ឆរា) ដដែល។ ឈ្មោះនំបញ្ចុកនេះ ធនជ័យគាត់ហៅពេលផ្ចាញ់ស្តេចចិន តាមឈ្មោះនឹងន័យពិតគឺនំប៉ែនចុក ដោយអ្នកធ្វើនំត្រូវយកអង្ករទៅត្រាំទឹកឲ្យរីករួចយកទៅកិនៗរួចត្រងចងពាតៗរួចយកទៅបុកៗរួច យកទៅផ្តុំស្ងោរៗរួចយកទៅបុកទៀត ទើបយកមកលុញផ្តុំឲ្យប៉ុននឹងរន្ធប៉ែន រួចច្រកដុំម្សៅចូលទៅក្នុងប៉ែន ទើបយកដុំឈើប៉ុនមាត់ប៉ែន មកចុកពីលើដើម្បីរោយម្សៅ ឲ្យធ្លាក់ទៅក្នុងខ្ទះទឹកក្តៅ ដែលកំពុងពុះឯក្រោម។ ពេលសរសៃនំឆ្អិនហើយ គេដួសយកមកត្រាំក្នុងថ្លាងទឹកត្រជាក់ ទើបគេចាប់ឆ្វាយជាចង្វាយ តម្រៀបក្នុងកញ្ច្រែងល្អី ឬកញ្ជើ....បើមិត្តអ្នកអានបានមើលអាថ៌កំបាំងបណ្តាំមាតាមហានគរភាគ១ ត្រង់វគ្គដែលខ្ញុំបានពន្យល់ពីបាយនោះ ទើបយើងដឹងពីទុក្ខវេទនា ជាប្រស្នានៃនំប៉ែនចុកនេះ។ គេត្រូវយកអង្ករទៅកិនជាម្សៅ រួចបុក

ស្មោរចុងក្រោយត្រូវយកម្សៅនេះទៅចុកបិទ រន្ធបង្ហើយរបស់គាត់ (មើលអត្ថន័យវត្ថុភាគ១) ព្រោះអង្ករ ម្សៅ ឬបាយ និមិត្តរូបតំណាងឲ្យព្រះមេ តែម្សៅតំណាងព្រះមេនេះ ត្រូវគេយកទៅញាត់ក្នុងរន្ធប៉ែន រួចយកឈើឆ្នុកទៅចុកបិទសង្កត់ កុំឲ្យម្សៅនេះចេញមកលើរួច តែម្សៅតំណាងឲ្យសរសៃរបស់មេនោះ ត្រូវរុះរោយធ្លាក់ទៅដេកត្រាំក្នុងទឹកក្តៅ (មើលការពន្យល់ពីសរសៃសូត្រ)។ រន្ធប៉ែនតំណាងឲ្យយោនីរបស់គាត់ ឆ្នុកដែលចុកពីលើរន្ធប៉ែន តំណាងឲ្យការបិទសន្ធប់ ព្រះមេកុំឲ្យចេញមកក្រៅរួច កិន បុក ស្មោរ....តំណាងឲ្យការព្យាបាទឈ្នានីស មិនចង់ឲ្យគាត់ចេញមកខាងក្រៅរួច នេះជាប្រស្នារបស់នំប៉ែនចុកនេះ ដែលព្រឹទ្ធដូនតាជ័យបានបន្សល់ទុកជាកេរមរតក។ ចង់ដឹងរឿងរបស់សរសៃនំប៉ែនចុកនេះ ត្រូវយកទឹកទៅលាចង្វាយ ដែលបានឆ្វាយទុកក្នុងកញ្ច្រែង...នោះ ទឹកដែលត្រូវយកមកលាចង្វាយទីមួយឈ្មោះថា ទឹកសម្លខ្ទាយ ឬសម្លប្រហើរ ទឹកទីពីរគឺសម្លការី (ពាក្យនិយាយគិរី = ភ្នំ)។ ឈ្មោះសម្លប្រហើរមានន័យថា យើងខ្វះខ្ទាយដោយសម្លនេះត្រូវបង់មើមខ្ទាយ ជាគ្រឿងផ្សំមួយ ហើយពាក្យខ្ទាយនេះ ក្លាយមកពីពាក្យខ្វះខ្ទាយ ហេតុតែយើងប្រហែសធ្វេសខ្វះខ្ទាយគំនិត ទើបយើងពុំអាចដឹងពីអាថ៌កំបាំងអច្ឆរមាតាយើង (មើលបន្ថែមក្នុងចាក់ទឹកដូងលើកទី១) ហើយពាក្យថាប្រហើរនេះ ពីដើមដែលម្តាយឪពុកធ្លាប់ស្តីឲ្យកូនចៅថា **"មើលវាធ្វើឲ្យប្រហើរ ឥតខ្វល់ខ្វាយជួយដោះទុក្ខធុរៈម៉ែឪសោះ"** ព្រោះពាក្យប្រហើរគឺមានតែក្លិន។ ចំណែកទឹកទីពីរគឺសម្លការី ដែលសម្លនេះប្រកពគ្រឿងផ្សំ ចេញមកពីជនជាតិក្លិង្គ (ឥណ្ឌា) សម្លនេះ អាចស្រាយប្រស្នាកំបាំងចង្វាយ ដែលគេឆ្វាយរឿងរបស់ព្រះមេទុកពីអតីតបាន អាចឲ្យរលាមើលឃើញរឿងពិតរបស់នំនេះ (មើលចាក់ទឹកដូងបែបទីពីរភាគ១)។ ធនជ័យគាត់បានប្រាប់យើងនៅក្នុងប្រស្នាចាក់ទឹកដូងទាំងពីរបែប ចាក់លើកទីមួយគឺពុំឃើញរឿងអ្វីឡើយ ព្រោះរវល់តែក្រពើតាមដេញខាំគាត់ ទាល់តែចាក់លើកទីពីរ ទើបឃើញរឿងម៉ែបង្កប់នៅក្នុងនោះ ដោយការចាក់លើកទីពីរ មានពាក្យ**មាតា**នាំមុខ មាតាគឺជាភាសាអ្នកដែនមគធ: (បាលី) សព្វថ្ងៃស្ថិតក្នុងប្រទេសឥណ្ឌា។ រឿងនិទានតន្ត្ររបស់ធនជ័យ គឺជារឿងដែលបង្កប់ទៅដោយប្រស្នាដ៏មានជម្រៅ សម្រាប់បំបែកការរំលោភបំពានមកលើពូជពង្សជ័យឬនាគ ព្រោះយើងជាកូនខ្មែរសព្វថ្ងៃ គឺជាអ្នកទទួលមរតកជ័យពីអតីត ហេតុដែលខ្ញុំលើកយករឿងនេះមកពន្យល់ គ្រាន់តែចង់ដកយកនូវចំណែកមួយ របស់អ្នកប្រាជ្ញាជំនាន់មុន មកធ្វើការពិចារណាតែប៉ុណ្ណោះ។ ដូចពាក្យដែលគាត់បានផ្តាំនឹងស្តេច មុនពេលស្លាប់ថា **"បើព្រះអង្គសោយត្រីព្រួលកុំចោលស្រកា សោយត្រីប្រាកុំចោលស្រកី ស្មោរក្បាលត្រីប្រាកុំចោលម្ជូរសណ្តាន់ ឬសន្តាន"** ហើយពាក្យនេះទៀតសោត គាត់ផ្តាំទុកសម្រាប់អ្នក

ដឹកនាំ ដែលទទួលមរតកជ័យគ្រប់ជំនាន់ ត្រូវមានគោលធម៌សម្រាប់ដឹកនាំប្រទេសឲ្យបានសុខសាន្ត និងរីកចម្រើន។

១/.ពាក្យថាសោយត្រីព្រួលកុំចោលស្រកា ន័យត្រង់ត្រីព្រួលអាចរស់បាន ដោយសារស្រកា ព្រោះស្រកាជាគ្រឿងបិទបាំងរាងកាយត្រី ន័យបង្កប់ស្រកាប្រៀបដូចជាប្រជារាស្ត្រ ដែលនៅជុំវិញអ្នកដឹកនាំដែលមានគុណធម៌ ន័យបង្កប់មួយទៀត បើសិនជាមិនចង់ឲ្យអំណាចដឹកនាំរបស់ខ្លួនប្រែប្រួល ឬប្រួលប្រែទេ (ព្រួលមាន សូរដូចប្រួល) គ្រប់អ្នកដឹកនាំត្រូវគិតប្រយោជន៍ស្រកាគឺប្រជារាស្ត្រ ព្រោះរាស្ត្រអាចលើកបុគ្គលម្នាក់ធ្វើជាអ្នកដឹកនាំបាន ហើយក៏អាចរុះរើទម្លាយនូវអំណាចដឹកនាំបុគ្គលនោះឲ្យប្រែប្រួលក្រឡាប់ចាក់បាន នេះជាន័យក្នុងប្រស្នាទីមួយ ដែលធនជ័យបានផ្ដាំអ្នកដឹកនាំ (ស្ដេច)។

២/.ប្រស្នាទីពីរព្រះអង្គសោយត្រីប្រាកុំចោលស្រកី (ពន្យល់រួចហើយភាគ១) ន័យត្រង់ស្រកីគឺនៅនឹងក្បាល ស្រកីជាច្រមុះដកដង្ហើមរបស់ត្រី ត្រីប្រាអាចរស់បាន គឺដោយសារច្រមុះសម្រាប់ដកដង្ហើមនេះ បើគ្មានស្រកីទុកដូចជាស្លាប់។ ន័យបង្កប់ទីមួយ នគរមួយអាចរស់បានដោយឯករាជ្យ ត្រូវពឹងផ្អែកលើសេដ្ឋកិច្ច ព្រោះសេដ្ឋកិច្ចជាភាពខ្លាំងរបស់នគរមួយៗ ឬដូចជាគ្រួសារមួយអាចមានភាពសុខដុមរមនាបាន គឺស្ត្រីជាអ្នក**ក**ផ្ដុំទ្រព្យសម្បត្តិគ្រប់យ៉ាងឲ្យគង់វង្ស ទើបអាចក្លាយជាអ្នកបរិបូរណ៍ដោយទ្រព្យ ពាក្យ**ស្រកី**ក្លាយមកពីពាក្យត្រឡប់ថា **ស្រីក**មានន័យថា បើស្រី**ក**ទុក្ខគឺបានទុក្ខ បើស្រី**ក**សុខគឺបានសុខ និងសុភមង្គល។ ន័យបង្កប់ទីពីរ គឺប្រាស្រ័យទាក់ទង សង្គមជាតិមួយអាចរីកចម្រើនបានអ្នកដឹកនាំត្រូវចេះប្រាស្រ័យទាក់ទង (ឲ្យដឹងសួរសុខទុក្ខ) ពីក្រោមទៅលើ ពីតូចទៅធំ ពីទាបទៅខ្ពស់ ពីក្នុងប្រទេសទៅក្រៅប្រទេស ដើម្បីចម្រាញ់នឹងនាំយកនូវអ្វីដែលថ្មី និងជឿនលឿន សម្រាប់យកមកកសាងមាតុភូមិរបស់ខ្លួនឲ្យបានរីកចម្រើន ដូចន័យប្រស្នាថា សោយត្រីប្រាកុំចោលស្រកី គឺក្បាលត្រូវចេះគិតពីដង្ហើមរស់ សម្រាប់ចិញ្ចឹមខ្លួនត្រីទាំងមូល (**ស្ដេចប្រាជ្ញនាម៉ឺនប្រាជ្ញ ដូចពស់នាគរាជពាំកែវមនោរា**)។

៣/.ប្រស្នាទីបីគឺ ស្ងោរក្បាលត្រីប្រាកុំចោលម្ទូរសណ្ដាន់ ន័យត្រង់បើយើងស្ងោរក្បាលត្រី ត្រូវប្រើម្ទូរសម្រាប់កាត់នូវចម្អាប ហេតុអ្វីបានជាគាត់មិនយកម្ទូរដទៃ បែរជាយកម្ទូរសណ្ដាន់មកដាក់ជាប្រស្នា? ព្រោះពាក្យសណ្ដាន់ និងសន្ដានដែលតំណាងឲ្យញាតិ មានសូរសព្ទស្រដៀងគ្នា សម្រាប់ចងជាប្រស្នាបំភាន់។ ន័យបង្កប់គាត់ចង់ប្រាប់អ្នកដឹកនាំគ្រប់ជំនាន់ថា បើយើងគ្រប់គ្រងនគរត្រូវសម្លឹង

មើលញាតិរបស់ខ្លួន ព្រោះភាគច្រើននៃញាតិ តែងយកអំណាចរបស់អ្នកដឹកនាំ ទៅប្រើគំរាមកំហែងអ្នកនៅខាងក្រោមផ្ដេសផ្ដាស ទៅតាមចិត្តលោភលន់របស់ខ្លួន ដែលធ្វើឲ្យអ្នកដឹកនាំមានញាតិដូចនេះ នឹងមានកេរ្តិ៍ឈ្មោះមិនល្អ។ គ្រប់អ្នកដឹកនាំទាំងឡាយ ត្រូវតែប្រើច្បាប់គឺម្ទូរសម្រាប់កាត់នូវចម្អាបគឺក្លិនឆ្អាបមិនល្អ ដែលញាតិរបស់ខ្លួនបានធ្វើឲ្យខូចសណ្ដាប់ធ្នាប់សង្គមព្រោះបានយកឈ្មោះអ្នកដឹកនាំទៅបាំង ជាពិសេសធ្វើឲ្យកើតនៅគំនុំគំគួន ចំពោះអ្នកដឹកនាំដែលមានញាតិមិនល្អ ធ្វើឲ្យកម្លាំងរាស្ត្រដែលរងគ្រោះត្រូវរកវិធីសាស្ត្រ រម្លាយអំណាចបុគ្គលនោះចោល នេះជាហេតុដែលធនជ័យយកឈ្មោះម្ទូរសណ្ដាន់ **មកបញ្ចប់ប្រស្នាចុងក្រោយ មុនពេលគាត់ស្លាប់**។ បើយើងគ្រាន់តែស្ដាប់រឿងពុំបានពិចារណា គឺបានត្រឹមតែស្ដាប់រួចសើចសប្បាយ បើយើងពិចារណារឿងធនជ័យ លោកគឺជាពោធិសត្វលោកេស្វរៈ ដែលខ្ញុំបានពន្យល់ប្រៀបធៀបខាងលើ ដែលឈ្មោះពោធិសត្វនេះ យើងធ្លាប់បានស្គាល់ឈ្មោះគាត់ក្នុងសម័យអង្គរធំនោះឯង (ស្ដេចជ័យវរ្ម័នទី៧) ។

ប្រស្នាកំបាំងរបស់ឈ្មោះនំប៉ែនចុកនេះ យើងអាចយល់ឃើញទៅដល់ឈ្មោះខេត្តស្វាយរៀងសព្វថ្ងៃ ព្រោះខេត្តនេះនៅជាប់នឹងខេត្តព្រៃវែង ហើយខេត្តព្រៃវែងនេះជារាជធានីបាភ្នំពីអតីតកាល ហើយក៏ជាទីក្រុងបាត់បង់នូវក្បាលពីអតីត ដោយអំណាចស្ដេចថ្វាបានមកកាត់ក្បាលស្ដេចខ្មែរក្នុងកាលនោះ (មើលប្រវត្តិសាស្ត្រខ្មែរ)។ ពាក្យហៅពីមុនគឺឆ្វាយរឿង ព្រោះរឿងត្រូវបាត់បង់ក្បាលនៅទីនោះ ទម្រាំអាចប្រមូលរឿងយកទៅកសាងឯភ្នំគូលែនបាន ត្រូវឆ្វាយយករឿងពីទីនោះ យកទៅលានៅភ្នំគូលែន ដែលក្រោយមកបានហៀរហូរ មកដល់ទីក្រុងយសោធបុរៈ គឺខេត្តសៀមរាបសព្វថ្ងៃ។ នេះគ្រាន់តែជាការឆ្កឹះឲ្យមិត្តអ្នកអាននាំគ្នាស្រាវជ្រាវតែប៉ុណ្ណោះ ព្រោះអ្នកប្រាជ្ញាដែលជាអ្នកដឹកនាំពីមុន លោកបានដឹងពីរឿងរ៉ាវអនាគត របស់នគរនេះរួចជាស្រេចទៅហើយ ដោយភាសាគំនិតបានបង្កប់ទុកនៅក្នុងថ្ម ដែលខ្ញុំបានពន្យល់ដោយសង្ខេបខាងលើ បានចង្អុលបង្ហាញប្រាប់យើងរួចទៅហើយ។ ផ្ដែរក្នុងរូបទី១គឺនៅប្រាសាទប៉ែនជុន ហើយខ្ញុំមិនដឹងថាប្រាសាទនេះ ស្ថិតនៅក្នុងខេត្តណាឡើយ ឈ្មោះប្រាសាទ និងអត្ថន័យរូបដែលខ្ញុំបានពន្យល់ហើយ គឺមានន័យស្រដៀងនឹងនំប៉ែនចុកនេះ ខ្ញុំពុំបាច់ពន្យល់ទៀតឡើយ ព្រោះការបកស្រាយភាសារូប និងការបកស្រាយនំប៉ែនចុកនេះ អាចធ្វើឲ្យយើងស្វែងយល់ពីឈ្មោះប្រាសាទនេះបាន ដោយពាក្យនេះបានបង្ហាញន័យគ្រប់ គ្រាន់តែប្រលិះគ្នាបន្តិចបន្តួចប៉ុណ្ណោះ គឺ **ប៉ែនជុន និងប៉ែនចុក**។

បង្រួមសេចក្តីមកការបកស្រាយពន្យល់ក្នុងភាគទីបីនេះ ដោយខ្ញុំបាទខំប្រមែលប្រមូលឯកសារថ្មមកបកពន្យល់ រួមទាំងគំនិតផ្សេងៗ ដែលបានបកស្រាយហើយនេះ ទុកដូចជាកូនប្រទីបមួយ ឬសោមួយ សម្រាប់បើកមើលអាថ៌កំបាំងរបស់ពូជពង្សនាគ ដែលបានរលុបបាត់ដានអស់ទៅហើយនោះ ឲ្យមកស្ថិតក្នុងសន្តានចិត្តកូននាគប្រុសស្រីឡើងវិញ។ ការខិតខំស្រាវជ្រាវរាវរកការពិតរបស់រូបចម្លាក់ ដែលធ្វើឲ្យខ្ញុំឆ្ងល់អស់ជាង២០ឆ្នាំនេះ ពីរូបក្បាលនាគខ្មែរដែលមានតែក្បាលនោះ ទីបំផុតចម្លើយគឺមាននៅក្នុងឯកសារស្រាវជ្រាវ អាថ៌កំបាំងបណ្ដាំមាតាមហានគរភាគ១ភាគ២ ហើយភាសារូបនេះបានបកពន្យល់ក្នុងភាគ៣ ដើម្បីឲ្យកូននាគព្រមទទួលស្គាល់ការពិត ដែលព្រះម៉ែបានយកសាវតាររបស់ខ្លួនទៅប្រតិស្ឋានទុកក្នុងថ្ម។ ហើយក្នុងរយៈពេលខ្ញុំបានជួបស្ត្រីម្នាក់ក្នុងសុបិន្ត ដែលកាលនោះគាត់មានអាយុ១៩៩៨ឆ្នាំ (មើលអារម្ភបទភាគ១) តែជាអ្នកទោស ពីពេលដែលបានជួបគាត់ មកទល់នឹងបច្ចុប្បន្ននេះ មានរយៈពេល១២ឆ្នាំកន្លងផុតទៅហើយ ក្នុងរយៈពេល១២ឆ្នាំនេះ ខ្ញុំបានស្វែងរកអាថ៌កំបាំងរបស់ស្ត្រីនេះ ថាតើគាត់ជានរណា? ពេលនេះឯកសារស្រាវជ្រាវទាំង៣ភាគ បានបើកបង្ហាញពីរូបរាងពិតរបស់គាត់ហើយ។ គ្រាន់តែថាកូនខ្មែរប្រុសស្រី ព្រមទទួលស្គាល់គាត់ដែរឬអត់ នោះគឺអាស្រ័យការពិចារណាឈ្វេងយល់ របស់កូននាគដែលជាអ្នកបានទទួលមរតកគាត់សព្វថ្ងៃនេះ ឯខ្ញុំបានត្រឹមតែនាំរឿងទុក្ខវេទនារបស់គាត់ មកបើកបង្ហាញតែប៉ុណ្ណោះ។ ឯកសារសាវតានេះប្រៀបបីដូចស្រះទឹក កូននាគប្រុសស្រីដូចជាអ្នកស្រេកទឹក ចំណែកឯខ្ញុំបាទជាអ្នកស្គាល់ និងចង្អុលបង្ហាញផ្លូវទៅស្រះទឹក ដូច្នេះកូននាគអ្នកអាចបាត់ស្រេកបាន លុះត្រាតែព្រមក្រេបផឹកទឹកក្នុងស្រះនោះ ឯភារធ្ងន់របស់ខ្ញុំត្រូវបានបញ្ចប់ ក្នុងការប្រមូលឯកសារសាវតាព្រះម៉ែមហានគរទាំងបីភាគនេះ។

ខ្ញុំនៅតែមានសង្ឃឹមក្នុងចិត្តថា បញ្ញារបស់កូននាគដែលជាបុត្របានទទួលមរតកព្រះម៉ែគឺព្រះពុទ្ធសាសនា ដែលព្រះអង្គជាមេនាគធំជាងគេក្នុងភពបីនេះ កូននាគប្រុសស្រីច្បាស់ជាយល់ នូវហេតុបច្ច័យគ្រប់យ៉ាង ដែលកម្មបានតាក់តែងនឹងវិចិត្ររួចហើយ ឲ្យវដ្តសង្សារនេះវិលគ្មានទីបញ្ចប់ សោយផលសុខ និងទុក្ខ នៅពេលណាដែលអមតធម៌ពុំទាន់កើតឡើង ដោយឯកសារសាវតាព្រះម៉ែទាំង៣ភាគនេះ គ្រាន់តែបើកបង្ហាញពីការសោយផលបាបពីអតីតកាលរបស់ពួកគាត់តែប៉ុណ្ណោះ។ អាទិទេពខ្មែរអាចរស់ឡើងវិញបាន គឺដោយសារកូនខ្មែរព្រមជ្រោងគាត់ឡើង ហើយភាពអច្ឆរិយអាចឋិតថេរបាន ទាល់តែយើងព្រមលើកព្រមទទួលស្គាល់ អ្នកបង្កើតភាពអច្ឆរិយគឺអច្ឆរមាតាមហានគរ

ខ្ញុំមិនចង់ឲ្យ គ្រោះមហន្តរាយមួយថ្មីទៀតកើតឡើងក្នុងនគរនេះ ព្រោះតែត្រូវបណ្ដាសារបស់ពួកគាត់ ដោយហេតុតែយើងជាកូននាគពុំដឹងគុណគាត់នោះទេ (**ទំនួញប្រេត បណ្ដាសាប្រេត**)។

ខ្ញុំព្រះករុណាខ្ញុំបាទ ក៏សូមអភ័យទោសគ្រប់សំណាក់មិត្តអាន ទាំងគ្រហស្ថនិងបព្វជិត នូវរាល់កំហុសឆ្គងទាំងឡាយ ដែលកើតឡើងដោយអចេតនា ព្រោះខ្ញុំបាទពុំមែនជាអ្នកនិពន្ធ ដូចនេះកង្វះខាតក្នុងអក្ខរាវិរុទ្ធនិងឃ្លាល្បះ ច្បាស់ជាកើតមាននូវកំហុសដោយអចេតនា ម្យ៉ាងទៀតសាវតារឿងបានលាក់បាំងទុកយូរឆ្នាំហើយ ដូច្នេះពេលលើកឡើងរមែងមានច្រែះស្និម អាចឲ្យការបកស្រាយមានការភាន់ច្រឡំខ្លះជាពុំខាន ហើយអ្នកដែលជួយវាយអត្ថបទនិងបញ្ចូលរូបភាព គឺកូនប្រុសរបស់ខ្ញុំឈ្មោះ គៀត វង្សចន្ទ័ភូមាន។

ជាទីបញ្ចប់ខ្ញុំព្រះករុណាខ្ញុំបាទសូមប្រគេនបុណ្យ ជូនបុណ្យ និងឧទ្ទិសបុណ្យ ដែលបានខិតខំស្រាវជ្រាវសាវតារអាថ៌កំបាំងមាតាមហានគរទាំង៣ភាគនេះ សូមផលនៃបុណ្យនេះជួយឧបត្ថម្ភគាំទ្រដល់លោកអ្នកដ៏មានគុណ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ និងញាតិធម៌របស់ខ្ញុំគ្រប់កាលទាំងបី ដែលពួកលោកសុទ្ធតែជាអ្នកមានឧបការគុណ សូមឲ្យជួបតែសេចក្ដីសុខក្នុងសម្បត្តិមនុស្ស សុខក្នុងសម្បត្តិទេវតា និងសុខក្នុងសម្បត្តិព្រះនិព្វាន ដែលជាសុខរួចផុតចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ។

ខេត្តព្រះសីហនុថ្ងៃ **៥១៥១០** ឆ្នាំខាលទោស័ក ថ្ងៃទី**២៣** ខែកញ្ញា ព.ស**២៥៥៤** / គ.ស**២០១០**

ឯកសារសាវតាព្រះម៉ែនេះ ខ្ញុំសូមរក្សាសិទ្ធិទាំងស្រុង

ពីខ្ញុំព្រះករុណាខ្ញុំបាទអ្នកទទួលមរតកព្រះម៉ែ

**គៀត ចាន់ធុន**

អតីតសិស្សសាលាវិចិត្រសិល្ប